ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# របាយការណ៍
# ស្ដីពី
# ស្ថានភាពកុមារឆ្នាំ២០២៤
# និងទិសដៅបន្ត



ខែឧសភា ឆ្នាំ២០២៥

# អារម្ភកថា

ការរក្សាបាននូវសន្តិភាព និងការពង្រឹងស្ថិរភាពសង្គម នយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា បានរួមចំណែកយ៉ាងធំធេងក្នុងការរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងធានាបាននូវកំណើនសេដ្ឋកិច្ចរបស់កម្ពុជាគួរឱ្យកត់សម្គាល់។ តាមរយៈការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០២៤-២០២៨ ប្រកបដោយចក្ខុវិស័យច្បាស់លាស់ កម្ពុជាបានឈានដល់ឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ និងមានគោលដៅសម្រេចឱ្យបានជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ គ្រប់ដំណាក់កាលទាំងអស់នៃការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល បានកំណត់យក "មនុស្ស" ជាវិស័យអាទិភាពចម្បងបំផុត ហេតុនេះការយកចិត្តទុកដាក់ចំពោះសុខុមាលភាព សុវត្ថិភាព និងការអភិវឌ្ឍកុមារ គឺជាគ្រឹះដ៏សំខាន់ក្នុងការកសាងមូលធនមនុស្ស ប្រកបដោយសក្តានុពលសម្រាប់ការអភិវឌ្ឍកម្ពុជានាពេលអនាគត។ រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តយ៉ាងពេញលេញ និងមានចក្ខុវិស័យច្បាស់លាស់ក្នុងការលើកកម្ពស់សិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ ដោយធ្វើយ៉ាងណាឱ្យកុមារ ក្រុមគ្រួសារ និងសហគមន៍ ទទួលបាននូវគុណភាព និងគុណតម្លៃនៃការរស់នៅក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាពស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍នីតិរដ្ឋ ដោយមានការចូលរួមយ៉ាងសកម្មពេញលេញស្មើភាពគ្នាក្នុងការអភិវឌ្ឍគ្រប់វិស័យ និងគ្រប់កម្រិត។

របាយការណ៍ស្តីពីស្ថានភាពកុមារ គឺជាឯកសារដ៏សំខាន់មួយដែលបង្ហាញពីសមិទ្ធផលសម្រេចបានលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា ដែលបញ្ជាក់ពីការយកចិត្តទុកដាក់លើការលើកកម្ពស់សុខុមាលភាព ការពង្រឹងកិច្ចការពារ ការផ្តល់អំណាច នឹងការរក្សាឧត្តមប្រយោជន៍កុមារ។ របាយការណ៍នេះ គឺជាការវាស់វែង និងបង្ហាញពីវឌ្ឍនភាពនៃការងារវិស័យកុមារ និងជាឯកសារសម្រាប់ចង្អុលបង្ហាញពីការទទួលខុសត្រូវ ការតស៊ូមតិ និងជាមូលដ្ឋានសម្រាប់រៀបចំគោលនយោបាយ និងផែនការផងដែរ។ របាយការណ៍នេះ មិនត្រឹមតែរំលេចពីការអនុវត្តរបស់រាជរដ្ឋាភិបាលនោះទេ តែក៏ជាកញ្ចក់ឆ្លុះបញ្ចាំង និងវាយតម្លៃលើការអនុវត្តរបស់អង្គការ សង្គមស៊ីវិល និងផ្នែកពាក់ព័ន្ធនានាផងដែរ ដោយបង្ហាញពីការធានានូវការអនុវត្ត ពេញលេញចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារ។ លទ្ធផលនៃរបាយការណ៍នេះនឹងក្លាយជាមូលដ្ឋាននៃការពិចារណា ក្នុងការសម្រេចចិត្តរៀបចំយុទ្ធសាស្ត្រ កម្មវិធី សកម្មភាព និងការបែងចែកធនធានសម្រាប់ធ្វើអន្តរាគមន៍ចំគោលដៅ ជាពិសេសគឺជាកាតាលីករសម្រាប់ការផ្លាស់ប្តូរវិជ្ជមាន តាមរយៈការផ្តល់តឹកតាងសម្រាប់ការពិនិត្យតាមដានលើការរីកចម្រើន ឬតម្រូវការបន្ទាន់ណាមួយរបស់កុមារ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមកោតសរសើរដោយស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គការសង្គមស៊ីវិល ឪពុកម្តាយ អាណាព្យាបាល និងក្មួយៗកុមារទាំងអស់ ដែលបានរួមសហការប្រកបដោយការទទួលខុសត្រូវ និងការប្តេជ្ញាខ្ពស់ ក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដើម្បីផ្តល់កិច្ចការពារកុមារពីអំពើហិង្សា ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទគ្រប់ទម្រង់។

ថ្ងៃទី ព្រហស្បតិ៍ ១១រោច ខែពិសាខ ឆ្នាំម្សាញ់ ព.ស ២៥៦៩

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២៥

**ជ. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**ប្រធាន**

**ជា សុមេធី**

# មាតិកា


១. សេចក្តីផ្តើម ..... 3
២. ទិដ្ឋភាពទូទៅ នៃស្ថានភាពកុមារកម្ពុជា ..... 4
២.១. ក្របខ័ណ្ឌច្បាប់ ..... 5
២.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការសកម្មភាព ..... 6
៣. ការរស់រានមានជីវិត ..... 9
៣.១. សុខភាព និងសុខុមាលភាពមូលដ្ឋាន ..... 9
ក. ដំណើរឆ្ពោះទៅរកការគ្រប់ដណ្តប់សុខភាពជាសាកល ..... 9
ខ. ភាពប្រសើរឡើងនៃស្ថានភាពសុខភាព ..... 10
គ. សុខភាពបន្តពូជ ..... 11
ឃ. សុខភាពមាតា និងទារក ..... 12
ង. សុខភាពកុមារ ..... 14
ច. ការកែលម្អកង្វះអាហារូបត្ថម្ភ ..... 15
៣.២. ការចុះអត្រានុកូលដ្ឋាន ..... 17
ក. ការចុះបញ្ជីកំណើត ..... 17
៣.៣. បរិយាកាសគ្រួសារ ..... 17
ក.ការថែទាំជំនួស ..... 17
ខ.ការសុំកូន ..... 18
គ.កូនតាមឪពុកម្តាយក្នុងពន្ធនាគារ ..... 18
៣.៤. បទដ្ឋាននៃការរស់នៅ ..... 18
ក. ទឹកស្អាត និងអនាម័យ ..... 18
ខ. បង្គន់អនាម័យ ..... 19
គ. វឌ្ឍនភាពការតភ្ជាប់បណ្តាញអគ្គិសនីតាមភូមិ និងការតភ្ជាប់ចរន្តអគ្គិសនីតាមខ្នងផ្ទះ ..... 20
៤. ការអភិវឌ្ឍកុមារ ..... 22
៤.១. ការអប់រំ ..... 22
ក. ធនធានមនុស្សផ្នែកអប់រំ ..... 22
ខ. ការអប់រំកុមារតូច ..... 23
គ. ការអប់រំបឋមសិក្សា ..... 24
ឃ. ការអប់រំមធ្យមសិក្សា ..... 25
៤.២. ការបណ្តុះបណ្តាលវិជ្ជាជីវៈ ..... 28
៥. ការការពារកុមារ ..... 30
៥.១.ការបង្ការ ទប់ស្កាត់ ..... 30
ក. ការលើកកម្ពស់កិច្ចការពារ ..... 30
ខ. ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ..... 37
គ. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ..... 37
ឃ. គ្រឿងញៀន ..... 38

ង. ការទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនិងការងារដោយបង្ខំ........................38
៥.២.ការអន្តរាគមន៍ និងឆ្លើយតប..........................................................................................39
ក. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ.........................................................39
ខ. គ្រឿងញៀន...........................................................................................................40
គ. បណ្តាញទូរសព្ទទាន់ហេតុការណ៍ និងការរាយការណ៍តាមអនឡាញ.......................................41
៥.៣. កិច្ចការយុត្តិធម៌..................................................................................................41
ក. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ.........................................................41
៥.៤. ការផ្តល់ជំនួយ និងសេវាគាំទ្រ...................................................................................42
ក. ការងារសង្គមកិច្ច....................................................................................................42
ខ.អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ..........................................................43
គ. គ្រឿងញៀន...........................................................................................................45
ឃ. កាកបាទក្រហមកម្ពុជា (កក្រក)..................................................................................46
ង. កម្មវិធីជំនួយសង្គម..................................................................................................49
៦. ការចូលរួមរបស់កុមារ....................................................................................................51
៦.១. ក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា និងកាយរឹទ្ធិជាតិកម្ពុជា ......................51
៦.២. បណ្តាញយុវជន បណ្តាញកុមារ និងក្លឹបកុមារ...............................................................51
៧. កិច្ចសហប្រតិបត្តិការលើវិស័យកុមារ..................................................................................52
៧.១. កិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ.............................52
ក. អង្គការក្លែនអន្តរជាតិកម្ពុជា........................................................................................52
ខ. អង្គការឆោលហ្វាន កម្ពុជា ........................................................................................54
គ. អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា .....................................................................55
ឃ. អង្គការសកម្មភាពដើម្បីកុមារ (APLE)............................................................................57
ង. អង្គការសេរីភាពកម្ពុជាអូស្ត្រាលី (AusCam Freedom Project).........................................61
ច. អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ (VCAO) ....................................................61
ឆ. អង្គការមូលនិធិហាការអន្តរជាតិ (Hagar International Foundation) ...................................61
ជ. អង្គការសម្ព័ន្ធចាប់ដៃ ..............................................................................................62
ឈ. អង្គការសង្គ្រោះកុមារ (Save the Children)..................................................................64
ញ. អង្គភាពការពារកុមារ (CPU) ....................................................................................67
ដ. អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា (១២៨០) ........................................................68
ឋ. អង្គការសម្ព័ន្ធដើម្បីសិទ្ធិកុមារកម្ពុជា - ស.ស.ក. (CRC Cambodia) ...................................73
ឌ. អង្គការម្លប់ឫស្សី .....................................................................................................76
ឍ. សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ (ច.ក.យ.ក.ស.ក./CCYMCR)............77
៨. បញ្ហាប្រឈម..................................................................................................................78
៩. ទិសដៅអនុវត្តបន្ត............................................................................................................83
១០. សេចក្តីសន្និដ្ឋាន.............................................................................................................87

## ១. សេចក្តីផ្តើម

១. ជារៀងរាល់ឆ្នាំ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ តែងតែសម្របសម្រួលចងក្រងនូវរបាយការណ៍លទ្ធផលនានាពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិកុមាររបស់ក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលជាដៃគូ។ របាយការណ៍នេះ ត្រូវបានរៀបចំឡើងដើម្បីបង្ហាញនូវការវាយតម្លៃដ៏ទូលំទូលាយមួយអំពីស្ថានភាពកុមារនៅកម្ពុជានាពេលបច្ចុប្បន្ន។ ការវាយតម្លៃនេះគ្របដណ្តប់លើទិដ្ឋភាពសំខាន់ៗជាច្រើននៃជីវិតរបស់កុមារ ដែលក្នុងនោះរួមមាន ការអប់រំ សុខភាព អាហារូបត្ថម្ភ ការការពារ លក្ខខណ្ឌរស់នៅ និងបរិយាបន្នសង្គម។ល។ តាមរយៈការវិភាគ នៃផ្នែកទាំងនេះ យើងនឹងអាចកំណត់បាននូវបញ្ហាប្រឈម និងឱកាសនានារបស់កុមារ ទន្ទឹមនេះ យើងក៏បានប្រមូលនូវអនុសាសន៍សម្រាប់ការអនុវត្ត ដើម្បីលើកកម្ពស់សុខុមាលភាព និងការអភិវឌ្ឍកុមារនៅក្នុងប្រទេសឱ្យកាន់តែប្រសើរផងដែរ។

២. របាយការណ៍នេះ គឺជាមូលដ្ឋានដ៏សំខាន់មួយសម្រាប់ការរៀបចំគោលនយោបាយ និងការសម្រេចចិត្តនានាពាក់ព័ន្ធនឹងកិច្ចការវិស័យកុមារ។ ការយល់ដឹង និងទិន្នន័យដែលបង្ហាញនៅក្នុងរបាយការណ៍នេះ នឹងជួយដល់អ្នករៀបចំគោលនយោបាយ ក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល ធ្វើការសម្រេចចិត្តបានគ្រប់ជ្រុងជ្រោយ តាមរយៈការយល់ដឹងពីបញ្ហាប្រឈម និងកាលានុវត្តភាព ដើម្បីអាចរៀបចំកម្មវិធីដែលជាតម្រូវការគោលដៅរបស់កុមារប្រកបដោយប្រសិទ្ធភាព។

៣. តាមរយៈរបាយការណ៍នេះ ក៏អាចជួយលើកកម្ពស់ការយល់ដឹងដល់ផ្នែកពាក់ព័ន្ធនានារួមទាំងសាធារណជនផងដែរ ចំពោះបញ្ហានានា ដែលប៉ះពាល់ដល់កុមារនៅកម្ពុជា។ ផ្អែកលើការគូសបញ្ជាក់ពីបញ្ហាប្រឈមទាំងនេះនឹងជួយលើកកម្ពស់ការយល់ដឹង និងការធ្វើសកម្មភាពបន្ទាន់នានា ដើម្បីឧត្តមប្រយោជន៍កុមារកាន់តែច្រើន។ របាយការណ៍នេះ នឹងផ្តល់នូវធនធានដ៏មានតម្លៃ ដើម្បីបង្ហាញពីអន្តរាគមន៍របស់ក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល។ អនុសាសន៍ចេញពីរបាយការណ៍នេះ គឺជាភស្តុតាងដែលអាចជួយបង្កើនប្រសិទ្ធភាពនៃកម្មវិធី និងគំនិតផ្តួចផ្តើមនានា ដោយធានាថាធនធានត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងទទួលផលវិជ្ជមានជាអតិបរមា។

៤. របាយការណ៍នេះ គឺជាមូលដ្ឋានសម្រាប់តាមដានវឌ្ឍនភាពនៃកិច្ចខិតខំប្រឹងប្រែងក្នុងគោលបំណងកែលម្អស្ថានភាពរបស់កុមារនៅកម្ពុជា។ លទ្ធផលនៃរបាយការណ៍នេះ នឹងជួយឱ្យផ្នែកពាក់ព័ន្ធនានាអាចតាមដានវឌ្ឍនភាព និងទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយ និងកម្មវិធី។ ភាពប្រទាក់គ្នា នៃទិដ្ឋភាពទូទៅរបស់របាយការណ៍នេះ នឹងរួមចំណែកលើកទឹកចិត្តឱ្យមានកិច្ចសហការក្នុងចំណោមផ្នែកពាក់ព័ន្ធនានា រួមទាំងក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងសង្គមស៊ីវិល។ កិច្ចសហការបែបពហុវិស័យនេះ គឺជាយន្តការដ៏សំខាន់ក្នុងការធ្វើអន្តរាគមន៍ និងសម្របសម្រួលដោះស្រាយបញ្ហានានាដែលកុមារជួបប្រទះនៅក្នុងប្រទេសកម្ពុជា។

## ២. ទិដ្ឋភាពទូទៅ នៃស្ថានភាពកុមារកម្ពុជា

៥. យោងតាមរបាយការណ៍សេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ២០២១ និងចំណោលប្រជាជន ២០២២-២០៣៣ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ បានបង្ហាញថា នៅឆ្នាំ២០២៤ កម្ពុជាមានប្រជាជនសរុបចំនួន ១៧ ៣៣៦ ៣០៧នាក់ ក្នុងនោះបុរសមានចំនួនប្រមាណ ៨ ៤៨៣ ៧៥៤នាក់ (៤៩%) ស្ត្រីមានចំនួនប្រមាណ ៨ ៨៥២ ៥៥៣នាក់ (៥១%)។ ចំនួនប្រជាជនដែលមានអាយុពី ០-១៨ឆ្នាំ សរុបមានចំនួន ៣៣៤ ១៤៩នាក់ (ស្រីចំនួន ១៦២ ៥៣៨នាក់ ប្រុសចំនួន ១៧១ ៦១២នាក់)។ បើផ្អែកលើទិន្នន័យរបស់នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ (ដកស្រង់នៅខែមេសា ឆ្នាំ២០២៥) បានបង្ហាញថា ក្នុងចំណោមគ្រួសារក្រីក្រចំនួន ៧២ ០១២គ្រួសារ មានកុមារនៅក្នុងបន្ទុកជាមធ្យមចំនួន ១.៥៩ នាក់។ ចំពោះកុមារនៃគ្រួសារក្រីក្រទាំងនោះ ត្រូវបានទទួលនូវការយកចិត្តទុកយ៉ាងខ្លាំងពីរាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សុខុមាលភាពសង្គមរបស់ពួកគាត់ តាមរយៈការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០២៤-២០៣៥។

៦. ដើម្បីធានានូវឧត្តមប្រយោជន៍របស់កុមារ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅក្នុងឆ្នាំ ១៩៩២ ពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារនៅឆ្នាំ២០០២ និងស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធនៅឆ្នាំ២០០៤ អនុសញ្ញាអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារនៅឆ្នាំ២០០៥ អនុសញ្ញាអន្តរជាតិខាងការងារលេខ១៣៨ ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការងារនៅឆ្នាំ១៩៩៩ អនុសញ្ញាអន្តរជាតិខាងការងារលេខ២៩ ស្តីពីការងារដោយបង្ខំឬជាកាតព្វកិច្ចនៅឆ្នាំ១៩៦៩ អនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសនៅឆ្នាំ២០០៧ ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំងស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារនៅឆ្នាំ២០០៦ និងអនុសញ្ញាស្តីពីសិទ្ធិជនពិការនៅឆ្នាំ២០១២។ល។

៧. រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ និងលើកកម្ពស់ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ច្បាប់ជាតិ និងច្បាប់អន្តរជាតិពាក់ព័ន្ធ ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ និងការប្តេជ្ញាចិត្តក្នុងការគោរព ការពារ បំពេញសិទ្ធិនានាចំពោះប្រជាពលរដ្ឋ ជាពិសេសចំពោះកុមារ ដើម្បីរស់នៅក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាព ស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍នីតិរដ្ឋ ដើម្បីធានាឲ្យបាននូវសុខុមាលភាព និងការគាំពារសង្គមចំពោះកុមារកម្ពុជា។ ជាមួយគ្នានេះដែរ ក្រសួង ស្ថាប័ន អាជ្ញាធរ ដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ ដៃគូអភិវឌ្ឍ អង្គការជាតិនិងអន្តរជាតិ ប្រជាជន សហគមន៍ ព្រះសង្ឃ ព្រឹទ្ធាចារ្យ មាតាបិតា និងកុមារខ្លួនឯងផ្ទាល់បានចូលរួមចំណែកក្នុងការអនុវត្តសិទ្ធិកុមារនៅកម្ពុជា សម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន។

៨. ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបាននឹងកំពុងរៀបចំ និងពង្រឹងក្របខ័ណ្ឌច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋាន និងយន្តការជាច្រើនពាក់ព័ន្ធកិច្ចការកុមារ។ ប្រព័ន្ធនៃការអប់រំត្រូវបានកែទម្រង់ និងបង្កើនប្រសិទ្ធភាពពីមួយថ្ងៃទៅមួយថ្ងៃ។ ការលើកកម្ពស់សុខភាព តាមរយៈការលុបបំបាត់ការកង្វះអាហារូបត្ថម្ភលើកុមារ ការកាត់បន្ថយមរណភាពមាតា ទារកនិងកុមារ ការទទួលបានទឹកស្អាត និងអនាម័យ

ព្រមទាំងការពង្រីកកម្មវិធីគាំពារសង្គមឱ្យកាន់តែទូលំទូលាយ។ បច្ចុប្បន្ននេះ ក្នុងគោលបំណងលើកកម្ពស់សុខុមាលភាព និងការពារឧត្តមប្រយោជន៍របស់កុមារ រាជរដ្ឋាភិបាលបានពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើបរិយាបន្ន នៃការការពារ ការដោះស្រាយអំពើហិង្សា និងការរំលោភបំពានគ្រប់ទម្រង់លើកុមារ។

## ២.១. ក្របខ័ណ្ឌច្បាប់

៩. ចាប់ពីឆ្នាំ២០២០ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ.) បាននឹងកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារនៃព្រះរាជាណាចក្រកម្ពុជា។ សេចក្តីព្រាងច្បាប់នេះ មានគោលបំណងដើម្បីការពារ លើកកម្ពស់សុខុមាលភាពកុមារ ផ្តល់អំណាចក្នុងការចូលរួម រក្សាឧត្តមប្រយោជន៍របស់កុមារ និងពង្រឹងការអនុវត្តសិទ្ធិកុមារនៅកម្ពុជា។

១០. ក្នុងគោលបំណងធានាសុចរិតភាព នៃការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ និងការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការការពារសិទ្ធិ សេរីភាពបុគ្គល ពិសេសដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន ក្រសួងមហាផ្ទៃបាននឹងងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន។

១១. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បាននឹងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីសន្តិសុខសាយប័រ។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំឡើងស្របតាមក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល និងគោលនយោបាយរដ្ឋាភិបាលឌីជីថល។ សេចក្តីព្រាងច្បាប់នេះ មានគោលបំណងកំណត់នូវគោលការណ៍ វិធាន យន្តការគ្រប់គ្រង និងការថែរក្សាសន្តិសុខសាយប័រ នៃហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសំខាន់ៗ ស្របតាមនិន្នាការតំបន់ និងសកលលោក។

១២. ក្រសួងព័ត៌មានបាននឹងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីសិទ្ធិទទួលព័ត៌មាន ក្នុងគោលបំណងធានាដល់សាធារណជនគ្រប់រូបនូវសិទ្ធិ សេរីភាពក្នុងការទទួលបានព័ត៌មានពីស្ថាប័នសាធារណៈ ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

១៣. ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ បាននឹងកំពុងបន្តពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងអំពើរត់ពន្ធមនុស្ស និងសេចក្តីព្រាងច្បាប់ស្តីពីអំពើពពោះជំនួស។

១៤. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ក.ប.) បាននឹងកំពុងសិក្សារៀបចំ (១).សេចក្តីព្រាងច្បាប់ស្តីពីទេសន្តរប្រវេសន៍ការងារក្នុងគោលបំណងលើកកម្ពស់សិទ្ធិ និងអត្ថប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍ និងចូលរួមទប់ស្កាត់ការជួញដូរមនុស្សខុសច្បាប់ (២).សេចក្តីព្រាងច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីពង្រឹងយន្តការក្នុងការគ្រប់គ្រងការដឹកនាំ និងសម្របសម្រួលកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល និង(៣).សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាព និងសុខភាពការងារ ក្នុងគោលបំណងធានាលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងាររបស់បុគ្គលបំពេញការងារ តាមរយៈការបង្កើតប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ សំដៅបង្កើតឱ្យមានបរិយាកាសការងារល្អ លើកកម្ពស់ផលិតភាពការងារ និងចូលរួមជំរុញកំណើនសេដ្ឋកិច្ច។

## ២.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការសកម្មភាព

១៥. ដើម្បីបន្តជំរុញការអភិវឌ្ឍកម្ពុជាប្រកបដោយចីរភាព និងបរិយាបន្ន រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា បានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច សំដៅការពារ ថែរក្សា និងពូនជ្រំុសមិទ្ធផលជាតិ លើកកម្ពស់កិត្យានុភាពជាតិ ជំរុញសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ លើមូលដ្ឋាននេះ ជាមួយបាវចនាទាំង ៥ គឺ កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព។ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ គឺជាក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០២៤-២០២៨ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា កម្មវិធីកែទម្រង់យុទ្ធសាស្ត្រតាមវិស័យ និងផែនការយុទ្ធសាស្ត្រថវិកា។

១៦. បញ្ចកោណទី១ : ការអភិវឌ្ឍធនធានមនុស្ស - ការអភិវឌ្ឍមូលធនមនុស្ស គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញពិពិធកម្ម និងកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងភាពធន់។ មូលធនមនុស្សមានគុណភាពខ្ពស់ និងសុខភាពល្អ គឺជាទ្រព្យសកម្មជាតិដ៏រឹងមាំសម្រាប់បង្កើនតម្លៃសេដ្ឋកិច្ច លើកកម្ពស់តម្លៃវប្បធម៌ និងបង្កើតគំនិតថ្មីៗ សំដៅធានាចីរភាពកំណើនរយៈពេលវែង និងជីវភាពការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ក្នុងន័យនេះ រាជរដ្ឋាភិបាលផ្តោតលើអាទិភាព ៥ ៖ (១).ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (២).ការបណ្តុះបណ្តាលជំនាញបច្ចេកទេស (៣).ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន (៤).ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង និង (៥).ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន។

១៧. ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០២៤-២០៣៥ មានគោលដៅចម្បង ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងសង្គតិភាព ក្នុងប្រព័ន្ធគាំពារសង្គមទាំងមូល ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនគ្រប់ស្រទាប់ ស្របតាមការរីកចម្រើនសេដ្ឋកិច្ចជាតិ។ រាជរដ្ឋាភិបាលនឹងបន្តលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស និងសុខុមាលភាពពលរដ្ឋ តាមរយៈការបន្តជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំ និងមានភាពធន់ដែលជាអាទិភាពមួយកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ គឺការផ្តោតលើការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គម តាមអភិក្រមហានិភ័យ នៃវដ្តជីវិត ដោយឈរលើស្មារតី "មិនបោះបង់ពលរដ្ឋណាម្នាក់" ជាមួយនឹងទស្សនវិស័យ និងគោលដៅដ៏ច្បាស់លាស់គឺ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយសមធម៌ និងបរិយាបន្ន។

១៨. ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥ គឺជាត្រីវិស័យតម្រង់ទិសដើម្បីលើកកម្ពស់ការយល់ដឹងឱ្យកាន់តែប្រសើរចំពោះបញ្ហាពលកម្មកុមារនៅប្រទេសកម្ពុជា និងផ្តល់ជាកម្លាំងចលករជំរុញដល់កិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីសម្រេចឱ្យបានគោលដៅអភិវឌ្ឍសកលប្រកបដោយចីរភាព ២០១៥-២០៣០ ដែលកំណត់បញ្ចប់គ្រប់ទម្រង់នៃពលកម្មកុមារនៅឆ្នាំ២០២៥។ បន្ថែមពីនេះ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ ក្នុងគោលដៅ ៣.៦ ស្តីពីការគ្រប់គ្រង និងការពារពលករទេសន្តប្រវេសន៍ ក្នុងការទទួលបានការងារសមរម្យ និងការទទួលស្គាល់ជំនាញ។ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ដែលលើកកម្ពស់ការបណ្តុះបណ្តាលយុវជន ស្របគ្នានឹង

កម្មវិធីមុខរបរ និងការងារសមរម្យសម្រាប់យុវជនដំណាក់កាលទី៣ ក្រោមជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសពីភ្នាក់ងារអភិវឌ្ឍប្រទេសស្វីស។ ក្នុងកម្មវិធីនេះ ការផ្សព្វផ្សាយស្ដីពីពលកម្មកុមារដែលប្រកបដោយបរិយាបន្ន នៅកន្លែងការងារសម្រាប់សហគ្រាសធុនតូច និងមធ្យម គឺជាវិធានការចាំបាច់ក្នុងការពង្រឹងការយល់ដឹងរបស់កម្មករនិយោជិត និយោជក និងសហគមន៍ ដើម្បីទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ។ ផែនការមេលើកទី៣ ស្ដីពីសុវត្ថិភាពនិងសុខភាពការងារឆ្នាំ២០២៣-២០២៧ ដែលមានបញ្ចូលយុទ្ធសាស្ត្រការលុបបំបាត់ពលកម្មកុមារ និងការងារដោយបង្ខំ សហប្រតិបត្តិការក្នុងការបង្ការមេរោគអេដស៍ ជំងឺអេសដ៍ ការប្រើប្រាស់គ្រឿងញៀន ជំងឺឆ្លង និងជំងឺមិនឆ្លងនៅកន្លែងធ្វើការ។ លើសពីនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននិងកំពុងរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីទេសន្តរប្រវេសន៍ការងារឆ្នាំ២០២៥-២០៣៤ សេចក្តីព្រាងកែសម្រួលប្រកាសលេខ ២៥១ ស្តីពីការលើកសរសើរ និងការដាក់វិន័យ និងសេចក្តីព្រាងកែសម្រួលប្រកាសលេខ ០៤៦ ស្តីពីដំណើរការជ្រើសរើស និងការណែនាំតម្រង់ទិសពលករមុនចេញដំណើរ។

១៩. ចក្ខុវិស័យសម្រាប់អនាគតរបស់កម្ពុជា គឺធានាឱ្យកុមារគ្រប់រូបទទួលបាននូវសិទ្ធិស្មើៗគ្នា ដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ រួមមាន៖ សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបាននូវការការពារ សិទ្ធិក្នុងការអភិវឌ្ឍ និងសិទ្ធិចូលរួម។ នៅខែឧសភា ឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩។ គោលនយោបាយជាតិនេះ បានកំណត់នូវសសរស្តម្ភជាយុទ្ធសាស្រ្តចំនួន៣ ដោយផ្តោតលើការបង្ការទប់ស្កាត់ ការអន្តរាគមន៍ និងការផ្តល់សេវាឆ្លើយតប។ ដើម្បីឆ្លើយតបចំពោះការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារឱ្យទទួលបានជោគជ័យ ក.ជ.ក. បានរៀបចំផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ដោយបានកំណត់នូវសកម្មភាពជាក់លាក់សម្រាប់ក្រសួង ស្ថាប័ន ដែលត្រូវបំពេញការងារក្នុងការលើកកម្ពស់សិទ្ធិកុមារ។ ផែនការនេះត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១។

២០. ទន្ទឹមនេះ ដើម្បីរៀបចំប្រព័ន្ធកិច្ចការពារកុមារមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីបង្ការទប់ស្កាត់ អន្តរាគមន៍ និងការផ្តល់សេវាឆ្លើយតបនៅគ្រប់កម្រិត ប្រកបដោយប្រសិទ្ធភាព ក្នុងការការពារកុមារគ្រប់ទម្រង់នៃការរំលោភបំពាន និងការអនុវត្តប្រកបដោយគ្រោះថ្នាក់ នៅខែវិច្ឆិកា ឆ្នាំ២០២២ ក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ចេញនូវផែនការយុទ្ធសាស្រ្តវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦។

២១. ដើម្បីលើកកម្ពស់វិស័យអប់រំ ជាពិសេសការកសាងគ្រឹះ នៃមូលធនមនុស្ស ក្រសួងអប់រំ យុវជន និងកីឡា (អ.យ.ក.) បានអនុម័ត និងផ្សព្វផ្សាយឱ្យអនុវត្តផែនការយុទ្ធសាស្រ្តវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ និងរៀបចំផែនការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំ ឆ្នាំ២០២៤-២០២៨។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡាក៏បានដាក់ឱ្យអនុវត្តផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយ ស្តីពីកិច្ចការពារកុមារនៅសាលារៀន ឆ្នាំ២០២៤-២០២៨ ផងដែរ។

២២. ក្រសួងសុខាភិបាលបានដាក់ចេញផែនការយុទ្ធសាស្រ្តសុខាភិបាល ឆ្នាំ២០២៤-២០៣៣ ដែលជាបំណងប្រាថ្នាធម្មានុរូបរបស់ប្រជាជនកម្ពុជាគ្រប់រូប និងជាប្លង់គោលសម្រាប់ធ្វើអាទិភាវូបនីយកម្មគោលដៅយុទ្ធសាស្រ្តក្នុងការធ្វើឱ្យប្រជាជនគ្រប់រូបរស់នៅប្រកបដោយសុខភាព និងសុខុមាលភាពល្អប្រសើរ រួមចំណែក

ក្នុងការអភិវឌ្ឍមូលធនមនុស្ស និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព តាមរយៈការបន្តពង្រឹងវឌ្ឍនភាព និងអន្តរាគមន៍ជាអាទិភាពផ្សេងៗ ដែលក្នុងនោះរួមមាន ការកែលម្អសុខភាពបន្តពូជ កង្វះអាហារូបត្ថម្ភលើកុមារ ព្រមទាំងការកាត់បន្ថយមរណភាពមាតា ទារក និងកុមារ។

២៣. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយផែនការសកម្មភាពស្តីពីការធ្វើឱ្យប្រសើរឡើងនូវការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០២៣-២០២៧ ព្រមទាំងបានដាក់ឱ្យអនុវត្តប្រកាសលេខ២៣៣ ស.អ.យ. ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីក្រមសីលធម៌សម្រាប់កិច្ចការពារកុមារ និងបានបញ្ចប់ការពិនិត្យ និងកែសម្រួលសេចក្តីព្រាងបទដ្ឋានស្តីពីអង្គការសុវត្ថិភាពកុមារ និងសៀវភៅបណ្តុះបណ្តាល ព្រមទាំងសេចក្តីព្រាងប្រកាសស្តីពីការបង្កើតគណៈកម្មការដឹកនាំ និងគ្រប់គ្រងគុណវុឌ្ឍិនៃអង្គការសុវត្ថិភាព។

២៤. អនុវត្តតាមផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (២០២១-២០២៥) ក.ជ.ក. បានបញ្ជ្រាបគោលការណ៍ណែនាំ ជាតិស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញទៅដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ ទន្ទឹមនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក៏បានធ្វើការផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំ ស្តីពីកិច្ចការពារកុមារនៅកម្ពុជាតាមប្រព័ន្ធអនឡាញសម្រាប់ក្រុមហ៊ុនឧស្សាហកម្មបច្ចេកវិទ្យាឌីជីថលផងដែរ។

២៥. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានផ្សព្វផ្សាយជំរុញការអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ ដល់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលក្នុងស្រុកចំនួន ៨៨ក្រុមហ៊ុន បានទំនាក់ទំនងក្រុមហ៊ុនអន្តរជាតិចំនួន ៥ ដើម្បីស្វែងរកលទ្ធភាពបច្ចេកទេសក្នុងការទប់ស្កាត់ និងដកហូតរូបភាពមិនសមរម្យពីប្រព័ន្ធអនឡាញ។ ក្រសួងបានបង្កើតកម្មវិធីគាំទ្រដល់ក្រុមហ៊ុនឌីជីថលតូចៗនៅក្នុងស្រុក ក្នុងការរៀបចំនីតិវិធីផ្ទៃក្នុងរបស់ក្រុមហ៊ុន ដើម្បីអនុវត្តតាមគោលការណ៍ណែនាំ។ ក្រៅពីនេះ ក្រសួងបានសហការជាមួយអង្គការដែនដីមនុស្សហូឡង់ប្រចាំកម្ពុជា ក្នុងការរៀបចំបន្ថែមនូវយុទ្ធនាការលើកកម្ពស់ការយល់ដឹងស្តីពីគ្រោះថ្នាក់និងហានិភ័យលើប្រព័ន្ធអនឡាញរយៈពេល ៦ខែ ដែលមានអ្នកចូលមើលសារអប់រំនេះជាមធ្យមប្រមាណ ៨០០ ០០០នាក់ក្នុង១ខែ។ ក្រសួងបានលើកទឹកចិត្តឱ្យដាក់តំណភ្ជាប់ប្រព័ន្ធរាយការណ៍ និងលេខទូរស័ព្ទជំនួយបន្ទាន់ក្នុងគេហទំព័រ និងថ្នាលឌីជីថលរបស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ព្រមទាំងបានធ្វើការផ្សព្វផ្សាយសារនានាតាមទូរស័ព្ទដៃជាប្រចាំ។ ការរាយការណ៍ពីករណីរំលោភបំពានផ្លូវភេទលើប្រព័ន្ធអនឡាញ ឆ្លងតាមតំណភ្ជាប់ដែលផ្សព្វផ្សាយដោយក្រុមហ៊ុន មានចំនួន ១៥ករណី។

២៦. ផ្អែកលើផែនការយុទ្ធសាស្ត្រ ដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមឆ្នាំ២០២១-២០២៥ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កំពុងរៀបចំយន្តការកសាងសមត្ថភាពកម្លាំងសេវាសង្គម ឱ្យមានកម្រិតចំណេះដឹង និងកម្រិតជំនាញពិតប្រាកដ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីផ្តល់សេវាសង្គមកិច្ចជូនអតិថិជន ដែលជាជនរងគ្រោះ និងងាយរងគ្រោះធានាបានប្រសិទ្ធភាពខ្ពស់។

# ៣. ការរស់រានមានជីវិត[1]

## ៣.១. សុខភាព និងសុខុមាលភាពមូលដ្ឋាន[2]

### ក. ដំណើរឆ្ពោះទៅរកការគ្រប់ដណ្តប់សុខភាពជាសាកល

២៧. ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្នុងនោះអាទិភាពគន្លឹះមួយនៃការអភិវឌ្ឍមូលធនមនុស្សគឺការកែលម្អសុខភាព និងសុខុមាលភាពប្រជាជនតាមរយៈការបន្តកាត់បន្ថយការឈឺ និងស្លាប់បណ្តាលមកពីជំងឺឆ្លងចម្បងៗ និងការលើកកម្ពស់សុខភាពបន្តពូជ មាតា ទារក និងកុមារ។ ខណៈដែលកម្មវិធីគោលនយោបាយអាទិភាពទី១ ក្នុងចំណោមកម្មវិធីគោលនយោបាយអាទិភាពចំនួន ៦ របស់រាជរដ្ឋាភិបាល គឺ "ការពង្រីកសេវាថែទាំសុខភាពឆ្ពោះទៅកាន់ការគ្របដណ្តប់សុខភាពជាសកល" ដែលបានកំណត់គោលដៅច្បាស់លាស់ឆ្នាំ២០៣៥៖ គ្របដណ្តប់ប្រជាជនយ៉ាងតិច ៨០% ដោយប្រព័ន្ធគាំពារសុខភាពសង្គមគ្របដណ្តប់សេវាសុខភាពសារវន្តយ៉ាងតិច ៨០% និងកាត់បន្ថយចំណាយប្រាក់ពីហោប៉ៅលើការថែទាំសុខភាពក្រោម ៣៥% នៃការចំណាយសរុបលើសុខភាព។

២៨. ប្រជាជនគ្របដណ្តប់ដោយមូលនិធិសមធម៌សុខាភិបាល និងបេឡាជាតិសន្តិសុខសង្គមផ្នែកថែទាំសុខភាព (ប.ស.ស-ថ) មានចំនួន ៧ ៥៧៧ ៥៧៨នាក់ ឬស្មើ ៤៣.៧១% នៃប្រជាជនសរុប។ ក្នុងនោះប្រជាជនដែលគ្រប់ដណ្តប់ដោយមូលនិធិសមធម៌សុខាភិបាលចំនួន ៤ ៧៥៧ ៩១៥នាក់ និងសមាជិក ប.ស.ស-ថ ដែលបានចុះបញ្ជី និងបង់ភាគទានចំនួន ២ ៨១៩ ៦៦៣នាក់។

ស្ថិតិប្រជាជនគ្របដណ្តប់ដោយប្រព័ន្ធគាំពារសង្គម ឆ្នាំ២០២៤

| បរិយាយ | ២០២៤ | |
|---|---|---|
| | ចំនួន | ភាគរយ |
| **១. មូលនិធិសមធម៌** | **៤,៧៥៧,៩១៥** | **២៧.៤៤%** |
| - គ្រួសារក្រីក្រ (កំណត់អត្តសញ្ញាណគ្រួសារក្រីក្រទុកជាមុន) | ២,៩០២,៤៨៣ | ១៦.៧៤% |
| - កម្មករក្រៅប្រព័ន្ធ/ក្រុមផ្សេងទៀត (មានបណ្ណសមធម៌ចេញដោយក្រសួងផែនការ និង ប.ស.ស.) | ១០៥,២៣១ | 0.៦០% |
| - គ្រួសារងាយរងហានិភ័យ (មានបណ្ណសមធម៌ចេញដោយក្រសួងផែនការ) | ១,៧៥០,២០១ | ១០.០៩% |
| **២. ប.ស.ស.** | **២,៨១៩,៦៦៣** | **១៦.២៦%** |
| - កម្មករ និយោជិតនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ | ១,៧៥៦,៣២៨ | ១០.១៣% |
| - មន្ត្រីរាជការ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន | ៤៩៤,៣១៥ | ២.៨៥% |
| - ប្រជាជន នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ | ៤១៨,២០៦ | ២.៤១% |
| - បុគ្គលក្នុងបន្ទុកសមាជិក ប.ស.ស. | ១៥០,៨១៤ | 0.៨៧% |
| **សរុប (១+២)** | **៧,៥៧៧,៥៧៨** | **៤៣.៧១%** |

ប្រភពទិន្នន័យ៖ ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយសុខាភិបាល ប.ស.ស. និងវិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ

[1] កុមារត្រូវមានជីវិតរស់នៅ មានសុវត្ថិភាព និងមានអ្វីៗចាំបាច់សម្រាប់រស់នៅ ដូចជាចំណីអាហារមានជីវជាតិ មានឈ្មោះ មានសញ្ជាតិ ការព្យាបាលសុខភាព សម្លៀកបំពាក់ ជម្រកស្នាក់នៅ និងជីវភាពសមរម្យ ព្រមទាំងទទួលបានការថ្នាក់ថ្នមពីឪពុកម្តាយ អាណាព្យាបាល និងសង្គម

[2] របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០២៤ ទិសដៅការងារឆ្នាំ២០២៥ និងឆ្នាំបន្ត របស់ក្រសួងសុខាភិបាល

២៩. សន្ទស្សន៍នៃការគ្រប់ដណ្តប់សុខភាពកម្ពុជាបានកើនឡើងពី ៥៨ នៅឆ្នាំ២០២១ ដល់ ៦០.១ នៅឆ្នាំ២០២៤។ និន្នាការនេះ បញ្ជាក់ពីវឌ្ឍនភាពក្នុងដំណើរឆ្ពោះទៅកាន់ការគ្រប់ដណ្តប់សុខភាពជាសកលនៅកម្ពុជា។ គួរសម្គាល់ថា ក្នុងសន្ទស្សន៍នេះ មានសូចនាករចំនួន ១៧ ចែកចេញជា ៤ក្រុម ដែលក្រុមនីមួយៗមានអត្រាដូចតទៅ៖ (១).សុខភាពបន្តពូជ មាតា ទារក និងកុមារ មានអត្រា ៦៦.៦% (២).សេវាជំងឺឆ្លង ៨៧.១% (៣).សេវាជំងឺមិនឆ្លង ៥១.៤% (៤).សមត្ថភាពផ្តល់សេវា និងការទទួលបានសេវា ៤៣.៨%។ យោងតាមទិន្នន័យនេះ សូចនាករសមត្ថភាពផ្តល់សេវា នៅមានកម្រិតទាបនៅឡើយ។

៣០. រវាងឆ្នាំ២០២៣ និងឆ្នាំ២០២៤ ការប្រើប្រាស់សេវាសុខភាពក្រោមប្រព័ន្ធគាំពារសុខភាពសង្គមបានកើនឡើង ៥១.៥០%។ ករណីប្រើប្រាស់សេវាក្រោមកម្មវិធីមូលនិធិសមធម៌កើនឡើង ៤៥.២៤% ឬពី ៣ ៣៤៧ ៣៤៤ករណី ដល់ ៤ ៨៦១ ៨២៩ករណី និងក្រោមគម្រោង ប.ស.ស-ថ បានកើនឡើង ៥៥.៦៥% ឬពី ៥ ០៥៤ ៦៣៩ករណី ទៅ ៧ ៨៦៧ ៤៧៩ករណី។

៣១. ការចំណាយដោយមូលនិធិសមធម៌ក្នុងឆ្នាំ២០២៤ បានកើនឡើង ១០.៥២% ធៀបនឹងការចំណាយក្នុងឆ្នាំ២០២៣ និងការចំណាយដោយ ប.ស.ស-ថ បានកើនឡើង ៦៤.៨៣%។ ជារួម កំណើននៃការចំណាយខាងលើនេះ គឺមានសង្គតិភាពជាមួយការកើនឡើងនៃការប្រើប្រាស់សេវាសុខាភិបាល និងការពង្រីកវិសាលភាពគ្របដណ្តប់ប្រជាជននៃកម្មវិធីទាំងពីរ។

៣២. បន្ទុកហានិភ័យនៃការចំណាយលើសុខភាពបានបង្ហាញថា អាំងស៊ីដង់នៃចំណាយលើសពី ១០% នៃចំណូល ឬចំណាយសរុបរបស់គ្រួសារបានធ្លាក់ចុះពី ១៧.៨៥% នៅឆ្នាំ២០១៩ មកនៅ១២.៨៦% ឆ្នាំ២០២១ និងងើបឡើងវិញ ១៥.៤៥% នៅឆ្នាំ២០២៣ និងអាំងស៊ីដង់ចំណាយលើសពី ២៥% នៃចំណូល ឬចំណាយសរុបរបស់គ្រួសារបានធ្លាក់ចុះពី ៥.០៥% នៅឆ្នាំ២០១៩ មកនៅ ៤.១៦% នៅឆ្នាំ២០២៣។ រីឯអាំងស៊ីដង់នៃប្រជាពលរដ្ឋដែលធ្លាក់ខ្លួនក្រីក្រដោយសារការចំណាយលើសុខភាពក៏បានធ្លាក់ ចុះពី ៣.៩៣% នៅឆ្នាំ២០១៩ ទៅ ៣.៥៤% នៅឆ្នាំ២០២១ និងងើបឡើងដល់ ៤.៥៧% នៅឆ្នាំ២០២៣។ ការធ្លាក់ចុះត្រូវបានកត់សម្គាល់ថា ជាបច្ច័យនៃការពង្រីកការគ្របដណ្តប់នៃកម្មវិធីមូលនិធិសមធម៌ និង ប.ស.ស-ថ។ ទោះជាបែបនេះក្តី ទិន្នន័យនេះហាក់នៅខ្ពស់ ហើយក៏សបញ្ជាក់ផងដែរថាការចំណាយប្រាក់ពីហោប៉ៅរបស់ប្រជាពលរដ្ឋកម្ពុជាការថែទាំសុខភាពនៅមានកម្រិតខ្ពស់លើសពី ៦០% នៃចំណាយសរុបលើការថែទាំសុខភាព។

### ខ. ភាពប្រសើរឡើងនៃស្ថានភាពសុខភាព

៣៣. កម្ពុជាសម្រេចបានសមិទ្ធផលធំធេងក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងសុខភាព នៅក្នុងបណ្តាទសវត្សចុងក្រោយនេះ។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងសារពើពន្ធប្រកបដោយការប្រុងប្រយ័ត្ន បានដើរតួចម្បងក្នុងការរក្សាកំណើនសេដ្ឋកិច្ចរឹងមាំ និងមានសង្គតិភាព ការធ្លាក់ចុះយ៉ាងលឿន នៃភាពក្រីក្រ ភាពរឹងមាំនៃប្រព័ន្ធសុខាភិបាល ការពង្រីកប្រព័ន្ធគាំពារសង្គម ភាពប្រសើរឡើងនៃកត្តាសង្គមដែលមានបច្ច័យលើសុខភាព។ល។ វឌ្ឍនភាពទាំងអស់នេះបានធ្វើឱ្យអត្រារស់រានមានជីវិតរបស់កុមារកើនឡើង។



ប្រភព៖ ជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០០៨ និង២០១៩

## គ. សុខភាពបន្តពូជ

៣៤. ផែនការគ្រួសារ និងការពន្យារកំណើត៖ រវាងឆ្នាំ២០២០-២០២៤ អត្រាប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបណាមួយមាននិន្នាការធ្លាក់ចុះ។ ដោយឡែករវាងឆ្នាំ២០២៣ និងឆ្នាំ២០២៤ អត្រានេះបានធ្លាក់ចុះ ០.៨៩%ពិន្ទុ។ ចំនួនស្ត្រីក្នុងវ័យបន្តពូជអាយុពី ១៥-៤៩ឆ្នាំ ដែលបានរៀបការ ហើយកំពុងប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបណាមួយ បានធ្លាក់ចុះពី ៥៧៥ ៨៩៣នាក់ នៅឆ្នាំ២០២៣ មកនៅ ៥៥៦ ៤៥៧នាក់ (ប្រើប្រាស់នៅសេវាសាធារណៈចំនួន ៥៣៨ ៩៨៥នាក់ និងនៅសេវាឯកជនដែលបានរាយការណ៍ចំនួន ១៧ ៤៧២នាក់) នៅឆ្នាំ២០២៤។ អត្រានេះប្រែប្រួលពីខេត្តដែលមានអត្រាទាបជាងគេ ១.២៥% ទៅខេត្តដែលអត្រាខ្ពស់ជាងគេ ២៤.៣៤%។ មធ្យោបាយពន្យារកំណើតទំនើបដែលស្ត្រីកំពុងប្រើប្រាស់នៅមូលដ្ឋានសុខាភិបាលសាធារណៈភាគច្រើនគឺថ្នាំគ្រាប់ ៤៩.៩៦% ថ្នាំចាក់ ៣០.៥៦% បន្ទាប់មកដាក់កងក្រោមស្បែក ៩.១៨% កងដាក់ក្នុងស្បូន ៦.៩៣% និងស្រោមអនាម័យត្រឹមតែ ៣.៣៧% ប៉ុណ្ណោះ។ នៅឆ្នាំ២០២៤ មានមូលដ្ឋានសុខាភិបាលសាធារណៈកំពុងផ្តល់សេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទសម្រាប់យុវវ័យ តាមពិធីសារដែលបានធ្វើបច្ចុប្បន្នភាព បានកើនឡើង ៦០កន្លែង ពី ៩៥កន្លែងនៅឆ្នាំ២០២៣ ដល់ ១៥៥កន្លែងនៅឆ្នាំ២០២៤។

៣៥. ការរំលូត/រលូត រវាងឆ្នាំ២០២៣ និងឆ្នាំ២០២៤ បានកើនឡើង ៨.៩៦% ឬពី ១៥ ៧៣៧ករណី នៅឆ្នាំ ២០២៣ ទៅ ១៧ ១៤៧ករណី នៅឆ្នាំ២០២៤ ក្នុងនោះករណីរលូតចំនួន ១១ ៤០៧ករណី ឬកើនឡើងប្រមាណ ១៧.៩% (ឆ្នាំ២០២៣ មានចំនួន ៩ ៦៧៥ករណី) និងករណីរំលូតចំនួន ៥ ៧៤០ករណី ឬធ្លាក់ចុះ ៥.៣១% (ឆ្នាំ២០២៣ មានចំនួន ៦ ០៦២ករណី)។ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលផ្តល់សេវារំលូត/រលូតប្រកបដោយសុវត្ថិភាព និងសេវាថែទាំក្រោយរំលូត/រលូតមានចំនួន ៩៣០កន្លែង ដោយកើនឡើង ១១០កន្លែង ធៀបនឹងឆ្នាំ២០២៣ ដែលមាន ៨២០កន្លែង។ ចំនួនករណីរំលូត និងរលូតមានកម្រិតផ្សេងៗគ្នាពីខេត្តមួយទៅខេត្តមួយទៀត។

## ឃ. សុខភាពមាតា និងទារក

៣៦. អត្រាមរណភាពមាតា មរណភាពទារក និងកុមារអាយុក្រោម ៥ឆ្នាំ បានបន្តធ្លាក់ចុះថែមទៀតរវាងឆ្នាំ២០១៤ និងឆ្នាំ២០២១/២២។ គួរកត់សម្គាល់ថា មរណភាពទារក និងកុមារអាយុក្រោម៥ឆ្នាំសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ មុនកាលកំណត់ ៨ឆ្នាំ។ ដោយឡែកការធ្លាក់ចុះនៃមរណភាពមាតាមានល្បឿនយឺតក្នុងអំឡុងពេលពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២១ ធៀបនឹងល្បឿន នៃការធ្លាក់ចុះក្នុងសម័យកាលគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ឆ្នាំ២០០០-២០១៥។




៣៧. ការថែទាំគភ៌មុនសម្រាលៈ នៅឆ្នាំ២០២៤ អត្រាពិនិត្យថែទាំគភ៌មុនសម្រាលលើកទី២ បានធ្លាក់ចុះ ៧.៩៣ ភាគរយពិន្ទុ ធៀបនឹងឆ្នាំ២០២៣។ បើគិតជាករណីស្ត្រីពិនិត្យថែទាំគភ៌មុនសម្រាលលើកទី២បានកើនឡើង ៣ ៤០៥ករណី ឬស្មើនឹង ១.០៣%។ ស្ត្រីមានគភ៌ ៣៣៤ ៣៦៤នាក់ បានមកពិនិត្យថែទាំគភ៌លើកទី២ ឬស្មើនឹង ៩១.៤១% នៃស្ត្រីមានគភ៌រំពឹងទុក។ ពិនិត្យនៅសេវាសាធារណៈមានចំនួន ៣០១ ៨៨៣ករណី និងនៅសេវាឯកជនមានចំនួន ៣២ ៤៨១ករណី។

៣៨. នៅឆ្នាំ២០២៤ ការពិនិត្យថែទាំគភ៌មុនសម្រាលលើកទី៤ បានកើនឡើង ៥.៥៧% ធៀបនឹងឆ្នាំ២០២៣ ឬកើនឡើងពី ២៤៩ ៥២៣នាក់ នៅឆ្នាំ២០២៣ ដល់ ២៦៣ ៤៣៥នាក់ នៅឆ្នាំ២០២៤។ អត្រាពិនិត្យ ថែទាំគភ៌មុនសម្រាលលើកទី២ និងលើកទី៤ ប្រែប្រួលពីខេត្តមួយទៅខេត្តមួយ។ អត្រាពិនិត្យលើកទី២ ទាបបំផុត ៥៥.១៧% និងអត្រាខ្ពស់បំផុត ១០០.៨៤%។ ការពិនិត្យថែទាំគភ៌មុនសម្រាលបានស្រាវជ្រាវរកឃើញស្ត្រីមានគភ៌បម្រុងមានគ្រោះថ្នាក់ ៣៧ ៣៧៣នាក់ ក្នុងនោះមានបញ្ហាធ្លាក់ឈាម ៧៩០នាក់ ស្លេកស្លាំង ១៧ ៣៦០នាក់ និងបញ្ហាផ្សេងៗទៀត ១៩ ២២៣នាក់។ ស្ត្រីទាំងនោះ បានទទួលការប្រឹក្សាយោបល់ និងការណែនាំព្រមទាំងការពិនិត្យតាមដាន និងការថែទាំយ៉ាងយកចិត្តទុកដាក់នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ។

៣៩. នៅឆ្នាំ២០២៤ ស្ត្រីសម្រាលដោយបុគ្គលិកសុខាភិបាលមានចំនួន ២៨៣ ៩៥១នាក់ ទាបជាងឆ្នាំ២០២៣ ដែលមានចំនួន ៣០១ ៩០៩នាក់ និងបើគិតភាគរយជាមួយស្ត្រីមានគភ៌រំពឹងទុក អត្រាសម្រាលដោយបុគ្គលិកសុខាភិបាលបានធ្លាក់ចុះពី ៩០.៦២% នៅឆ្នាំ២០២៣ មកនៅ ៧៧.៦៣%។ រីឯស្ត្រីសម្រាលនៅមូលដ្ឋានសុខាភិបាលចំនួនសរុប ២៧៧ ៣៤៩នាក់។ បើគិតជាអត្រាសម្រាលនៅមូលដ្ឋានសុខាភិបាលបានធ្លាក់ចុះពី ៨៨.២៣% នៅឆ្នាំ២០២៣ មកនៅ ៧៥.៨២% នៃស្ត្រីមានគភ៌រំពឹងទុក។

៤០. មរណភាពមាតា និងទារក៖ យោងតាមរបាយការណ៍ប្រចាំឆ្នាំស្តីពីការស្រាវជ្រាវមរណភាពមាតា និងការសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបកើត ក្នុងឆ្នាំ២០២៤ ករណីសង្ស័យមរណភាពមាតា ដែលបានរាយការណ៍ពីមូលដ្ឋានសុខាភិបាលសាធារណៈមានចំនួនសរុប ៧៩នាក់ ទាបជាងឆ្នាំ២០២៣ ដែលមាន ៩៥នាក់។ រីឯទារកកើតរស់មានចំនួន ២៦៧ ៥០០នាក់ និងទារកកើតស្លាប់ ១ ០៥៥នាក់ ក្នុងនោះទារកកើតស្លាប់មុន ២៤ម៉ោង ១៩៨នាក់ និងទារកស្លាប់កើត(ស្លាប់កើតភ្លាមៗ និងស្លាប់កើតយូរ) ១ ៧១៦នាក់។ ក្រៅពីស្ថានភាពខាងលើ ទារកកើតទម្ងន់តិចជាង ២.៥ គ.ក្រ ចំនួន ១៧ ៤១៥នាក់ ទារកទម្ងន់លើសពី ២.៥ គ.ក្រ ចំនួន ២៤៩ ៦៨៧នាក់ ទារកកើតមិនបានថ្លឹងទម្ងន់ចំនួន ៣៩៨នាក់ និងម្តាយផ្តល់កំណើតកូនភ្លោះពីរចំនួន ១ ៥៩៧នាក់ ឬភ្លោះបីចំនួន ១៨នាក់។

ស្ថានភាពទារកកើត ដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ ឆ្នាំ២០២០-២០២៤

| ស្ថានភាពទារកកើត | 2020 | 2021 | 2022 | 2023 | 2024 |
|---|---|---|---|---|---|
| ទារកកើតរស់ | 309 637 | 285 173 | 259 954 | 280 972 | 267 500 |
| ទារកកើតស្លាប់ | 2 416 | 2 540 | 2 042 | 2 087 | 1 055 |
| - ទារកកើតស្លាប់មុន២៤ម៉ោង | 304 | 280 | 240 | 492 | 198 |
| ទារកស្លាប់កើត (កើតភ្លាមៗ/កើតយូរ) | 2 054 | 1 157 | 1 100 | 2 025 | 1 716 |
| ទារកកើតមានទម្ងន់តិចជាង ២.៥ គ.ក្រ | 19 654 | 17 942 | 17 902 | 17 472 | 17 415 |
| ទារកកើតមានទម្ងន់លើសពី ២.៥ គ.ក្រ | 289 506 | 266 949 | 241 747 | 263 353 | 249 687 |
| ទារកកើតមិនបានថ្លឹងទម្ងន់ | 477 | 282 | 8 234 | 147 | 398 |
| ចំនួនម្តាយផ្តល់កំណើតកូនភ្លោះពីរ/បី | 1 982/24 | 1 673/22 | 1 442/15 | 1 769/18 | 1 597/18 |

ប្រភព៖ ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលរបស់ក្រសួងសុខាភិបាល

៤១. ការបង្ការការចម្លងមេរោគអេដស៍/មេរោគស្វាយពីម្តាយទៅកូន៖ ស្ត្រីមានគភ៌ដែលមកទទួលការពិនិត្យថែទាំមុនសម្រាលមានចំនួន ៣២២ ៨៥០នាក់ ឬស្មើនឹង ៩៨.៦% បានធ្វើតេស្តមេរោគអេដស៍ ក្នុងនោះស្ត្រី ៥៣០នាក់ រកឃើញវិជ្ជមានមេរោគអេដស៍ ហើយ ៥២៨នាក់ ឬស្មើនឹង ៩៩.៦% បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍។ រីឯស្ត្រីមានគភ៌ចំនួន ៣២១ ៥៦៩នាក់ ឬស្មើនឹង ៩៨.២% បានធ្វើតេស្តរកមេរោគស្វាយ ក្នុងនោះស្ត្រីចំនួន ៣ ៥១៤នាក់ រកឃើញវិជ្ជមានមេរោគស្វាយ ហើយស្ត្រីចំនួន ៣ ៤៣០នាក់ ស្មើនឹង ៩៧.៦% បានទទួលការព្យាបាលជំងឺស្វាយដោយចាក់ Benzathine Penicillin G។ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមានចំនួនសរុប ១ ៤១៦កន្លែង ដោយនៅឆ្នាំ២០២៤ បានកើនឡើងចំនួន ២៩កន្លែង។

## ង. សុខភាពកុមារ

| សូចនាករ | លទ្ធផល | | | | | ចំណុចដៅ |
|---|---|---|---|---|---|---|
| | 2020 | 2021 | 2022 | 2023 | 2024 | 2024 |
| ១.អត្រាគ្របដណ្តប់នៃបង្ការជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស រលាកថ្លើមប្រភេទបេ រលាកសួត រលាកស្រោមខួរ (DPT-Hept Bib) ៣ដូស(%) | 106.6 | 98.31 | 96.33 | 107.77 | 95.35 | >95 |
| ២.អត្រាគ្របដណ្តប់នៃវ៉ាក់សាំងបង្ការកញ្ជ្រិល ស្អូចនៅខែទី៩ (%) | 107.0 | 102.0 | 102.1 | 108.63 | 109.1 | >95 |
| ៣.ចំនួនលើកនៃការពិគ្រោះជំងឺក្រៅករណីថ្មី លើកុមារអាយុក្រោម៥ឆ្នាំ ម្នាក់ក្នុងមួយឆ្នាំ | 1.29 | 1.26 | 1.28 | 1.64 | 1.63 | 1.67 |

ប្រភព៖ ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលរបស់ក្រសួងសុខាភិបាល

៤២. ការផ្តល់ថ្នាំបង្ការជំងឺ៖ បច្ចុប្បន្នកម្មវិធីជាតិផ្តល់ថ្នាំបង្ការបានផ្តល់វ៉ាក់សាំងចំនួន ១២មុខ ក្នុងនោះវ៉ាក់សាំង ១១មុខ សម្រាប់កុមារអាយុក្រោម ១ឆ្នាំ រួមមាន៖ វ៉ាក់សាំងបង្ការជំងឺរបេង ខាន់ស្លាក់ ក្អកមាន់ តេតាណូស គ្រុនស្វិតដៃជើង កញ្ជ្រិល រលាកថ្លើមប្រភេទបេ (បញ្ចូលនៅឆ្នាំ២០០១) រលាកស្រោមខួរក្បាល (បញ្ចូលនៅឆ្នាំ២០១០) និងរលាកខួរក្បាល JE និងកញ្ជ្រឹល-ស្អូច (បញ្ចូលនៅឆ្នាំ២០១០ និង២០១៣) និងវ៉ាកសាំង ១ មុខទៀតសម្រាប់បង្ការជំងឺមហារីកមាត់ស្បូនលើកុមារីអាយុ ៩ឆ្នាំ (បញ្ចូលនៅឆ្នាំ២០១៧)។ នៅក្នុងឆ្នាំ ២០២៤ អត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងបង្ការជំងឺលើកុមារអាយុក្រោម ១ឆ្នាំ ដែលមានចំនួនប៉ាន ប្រមាណ ៣៤១ ៥២៥នាក់ ដែលសម្រេចចន្លោះពី ៧៨.៨៨% ដល់១០៩.១០% ទៅតាមប្រភេទថ្នាំបង្ការ។

៤៣. ចំពោះកុមារ ដែលមានអាយុលើសពី ១ឆ្នាំ រួមមាន៖ កុមារ ៣៥៤ ៥៦៤នាក់ បានទទួលថ្នាំបង្ការជំងឺកញ្ជ្រឹល-ស្អូច (MR18) ស្មើនឹង ១០៣.៨២%។ កុមារីអាយុ ៩ឆ្នាំចំនួន ១៤៨ ៥៩៨នាក់ទទួលបានថ្នាំបង្ការជំងឺមហារីកមាត់ស្បូន ស្មើនឹង ៩៥.៧៧% នៃចំនួនកុមារីអាយុ ៩ឆ្នាំ ស្រង់ជាក់ស្តែងក្នុងទូទាំងប្រទេស។

៤៤. ការពិនិត្យជំងឺក្រៅករណីថ្មី នៃកុមារអាយុក្រោម ៥ឆ្នាំបានកើនឡើងពី ២ ៤៩៨ ៨៤៣ករណី នៅឆ្នាំ២០២៣ ទៅ ២ ៥៩៤ ៣៨៩ករណី នៅឆ្នាំ២០២៤ ក្នុងនោះ ពិនិត្យនៅមូលដ្ឋានសុខាភិបាលសាធារណៈមានចមនួន ២ ៣៦០ ៨៥៨ករណី និងនៅសេវាឯកជនបានរាយការណ៍ចំនួន ២៣៣ ៥៣១ករណី។ រីឯចំនួនលើកនៃការពិនិត្យពិគ្រោះជំងឺក្រៅករណីថ្មី នៃកុមារអាយុក្រោម ៥ឆ្នាំ ម្នាក់ក្នុងមួយឆ្នាំ មាននិន្នាការកើនពី ១.២៩ នៅឆ្នាំ២០២០ មកដល់ ១.៦៣ នៅឆ្នាំ២០២៤។ កម្រិតប្រើប្រាស់សេវាពិនិត្យជំងឺក្រៅករណីថ្មី និងចំនួនលើកមកពិនិត្យពិគ្រោះជំងឺករណីថ្មី ដោយកុមារអាយុក្រោម៥ឆ្នាំម្នាក់ក្នុងមួយឆ្នាំ ប្រែប្រួលតាមរាជធានី ខេត្ត ពីអត្រាទាបបំផុត ០.៤៦លើក ទៅអត្រាខ្ពស់បំផុត ២.៣៩លើក។

៤៥. ជំងឺនាំមុខឬបញ្ហាសុខភាព ១០ ដែលជាមូលហេតុចម្បងនៃការពិនិត្យជំងឺក្រៅករណីថ្មី ៩៨៥ ០១៦ករណី ក្នុងនោះរួមមាន៖ ជំងឺរលាកផ្លូវដង្ហើមលើស្រួចស្រាល់ចំនួន ៦៧៥ ៤៤៦ករណី ឬស្មើនឹង ៦៨.៥៧% ជំងឺរាកគ្មានខ្សោះជាតិទឹក ចំនួន ៧៩ ២៧៧ករណី ឬស្មើនឹង ៨.០៥% ជំងឺរលាកសួត ចំនួន ៥២ ៤៥៩ករណី ឬស្មើនឹង ៥.៣៣% ជំងឺរលាកផ្លូវដង្ហើមផ្នែកខាងក្រោមផ្សេងៗទៀត ចំនួន ៣៥ ១៣៨ករណី ៣.៥៧% ជំងឺរលាកទងសួតស្រួចស្រាល់ចំនួន ៣៥ ០៤០ករណី ឬស្មើនឹង ៣.៥៦% ជំងឺរាកមូលចំនួន ៣០ ១២៨ករណី ឬស្មើនឹង ៣.០៦% ជំងឺរលាកបំពង់កស្រួចស្រាល់ចំនួន ២៣ ៧៣៣ករណី ឬស្មើនឹង ២.៤១% ជំងឺរាកខ្សោះ

ជាតិទឹកមធ្យមចំនួន ២២ ២៦៥ករណី ឬស្មើនឹង ២.២៦% ជំងឺរមាស់ស្បែកចំនួន ១៨ ៩៣២ករណី ឬស្មើនឹង ១.៩២% និងជំងឺហឺតចំនួន ១២ ៥៩៨ករណី ឬស្មើនឹង១.២៨%។ គួរកត់សម្គាល់ជំងឺភ្នែកក្រហមបានលេចឡើងក្នុងឆ្នាំ២០២៣ ស្ថិតក្នុងលេខរៀងទី៨ នៃបញ្ហាសុខភាពចម្បងទាំង១០ បានធ្លាក់ចេញពីជំងឺចម្បងទាំង១០ នៅឆ្នាំ២០២៤ និងជំនួសមកវិញដោយជំងឺហឺតនៅលេខរៀងទី១០ ឆ្នាំ២០២៤។

៤៦. ការពិនិត្យជំងឺក្រៅតាមពិធីសារសមាហរណកម្មគ្រប់គ្រងជំងឺកុមារលើកុមារអាយុក្រោម ៥ឆ្នាំ មានចំនួនសរុប ១ ១១១ ៨៩០ករណី ក្នុងនោះករណីថ្មីចំនួន ១ ០៧៥ ២៩៣ករណី។ គួរកត់សម្គាល់ថា ចំនួនពិនិត្យករណីថ្មីតាមបែបសមាហរណកម្មនៅឆ្នាំ២០២៤ បានថយចុះប្រមាណ ១.១% ទាបជាងឆ្នាំ២០២៣។

៤៧. ការសម្រាកព្យាបាលៈ កុមារអាយុក្រោមប្រាំឆ្នាំសម្រាកព្យាបាលបានកើនពី ២០៥ ៦៨២នាក់ (ស្រី ៨៩ ៤០៦នាក់) នៅឆ្នាំ២០២៣ ទៅ ២៥៩ ១២៥នាក់(ស្រី ១១៤ ៩៤៥នាក់) ឬកើនឡើងក្នុងអត្រា ២៥.៩៨% នៅឆ្នាំ២០២៤។ ក្នុងនោះ កុមារសម្រាកពេទ្យនៅមូលដ្ឋានសុខាភិបាលសាធារណៈ ដែលស្លាប់ក្នុងឆ្នាំ២០២៤ មានចំនួនថយចុះពី ១ ៦៧៥នាក់នៅឆ្នាំ២០២៣ មកត្រឹម ១ ៣០១នាក់នៅឆ្នាំ២០២៤ ឬថយចុះក្នុងអត្រា ២២.៣៣% ។ ជំងឺនាំមុខ ឬរោគវិនិច្ឆ័យចម្បង ៥ ដែលជាមូលហេតុនៃការសម្រាកព្យាបាលរបស់កុមារចំនួនសរុប ៧៨ ៣១០ករណី ក្នុងនោះរួមមាន៖ ជំងឺរលាកបំពង់កស្រួចស្រាវ ២៥.០០% ជំងឺរលាកទងសួតស្រួចស្រាវ ២១.៧២% ជំងឺរាកគ្មានខ្សោះជាតិទឹក ១៨.២៩% ជំងឺរលាកផ្លូវដង្ហើមលើស្រួចស្រាវ ១៧.៦៣% និងជំងឺរលាកសួត ១៦.៧២%។

## ច. ការកែលម្អកង្វះអាហារូបត្ថម្ភ

| សូចនាករ | លទ្ធផល | | | | | គោលដៅ |
|---|---|---|---|---|---|---|
| | 2020 | 2021 | 2022 | 2023 | 2024 | 2024 |
| %នៃទារកបានទទួលការបំបៅដោយ ទឹកដោះម្ដាយក្នុងអំឡុងមួយម៉ោងដំបូងនៃកំណើត | 71.14 | 72.22 | 71.95 | 71.02 | 72.73 | 72 |
| %នៃកុមារអាយុពី ៦-៥៩ខែ បានទទួលគ្រាប់ថ្នាំជីវជាតិ-អា ក្នុងអំឡុងពេល៦ខែចុងក្រោយនៃឆ្នាំ | 74.0 | 62.59 | 70.70 | 84.02 | 92.73 | 80 |
| %នៃកុមារអាយុពី១២ខែ ដល់៥៩ខែបាន ទទួលថ្នាំម៉េបង់ដាហ្សូលក្នុងអំឡុងពេល ៦ខែចុងក្រោយនៃឆ្នាំ | 76.0 | 61.86 | 64.42 | 73.73 | 92.73 | 95 |
| %ស្ត្រីមានគភ៌ទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក៩០គ្រាប់ | 89.47 | 76.16 | 79.84 | 87.29 | 79.55 | 90 |
| %ស្ត្រីក្រោយសម្រាលបានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក ៤២គ្រាប់ | 80.96 | 77.16 | 72.25 | 76.22 | 68.39 | 90 |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរបានទទួលការថែទាំព្យាបាលនៅមណ្ឌលសុខភាព | | | | | 3,991 | |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរបានទទួលការថែទាំព្យាបាលនៅមន្ទីរពេទ្យ | | | | | 880 | |
| ចំនួនមណ្ឌលសុខភាពបានធ្វើការស្រាវជ្រាវ និងព្យាបាលកុមារកង្វះអាហារូបត្ថម្ភមធ្យម និងធ្ងន់ធ្ងរ | | | | | 776 | |
| ចំនួនមន្ទីរពេទ្យទទួលការព្យាបាលកុមារកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ | | | | | 41 | |

៤៨. អន្តរាគមន៍ក្នុងការកែលម្អស្ថានភាពអាហារូបត្ថម្ភកុមារ រួមមាន៖ ផ្តល់ការអប់រំម្តាយពីអត្ថប្រយោជន៍នៃការបំបៅទារកដោយទឹកដោះម្តាយ ការផ្តល់អាហារបំប៉នស្របតាមដំណាក់កាលលូតលាស់របស់កុមារ និងការថែទាំ និងការបង្ការទារក/កុមារពីជំងឺផ្សេងៗ ការផ្តល់វ៉ាក់សាំងបង្ការជំងឺតាមកាលវិភាគ ការផ្តល់មីក្រូសារជាតិ និងថ្នាំទម្លាក់ព្រូន ការតាមដានការលូតលាស់របស់កុមារ និងការពិនិត្យព្យាបាលថែទាំកុមារកង្វះអាហារូបត្ថម្ភតាមលំនាំគ្លីនិក។

៤៩. ការបំបៅទារកដោយទឹកដោះម្តាយ៖ អត្រាទារកកើតរស់បានទទួលការបំបៅដោយទឹកដោះម្តាយ នៅក្នុងមួយម៉ោងដំបូងក្រោយកំណើតនៅឆ្នាំ២០២៤ បានកើនឡើង ១.៧១ភាគរយពិន្ទុ។ អត្រានេះប្រែប្រួលពីខេត្តមួយទៅខេត្តមួយទៀតពីអត្រាទាបបំផុត ៤២.០២% ទៅអត្រាខ្ពស់បំផុត ៩៩.៣៣%។

៥០. ការផ្តល់គ្រាប់ថ្នាំជីវជាតិ-អា៖ តាមការប៉ាន់ស្មានដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ កុមារអាយុពី ៦-៥៩ខែ នៅឆ្នាំ២០២៤ មានចំនួន ១ ៤១៩ ៨៤៤នាក់ ក្នុងនោះ កុមារបានទទួលគ្រាប់ថ្នាំជីវជាតិ-អា ក្នុងអំឡុងពេល ៦ខែដើមឆ្នាំ (ជុំទីមួយ) មានចំនួន ១ ១៨២ ០៦៧នាក់ ស្មើនឹង ៨៣.២៥% និងក្នុងអំឡុងពេល ៦ខែចុងឆ្នាំ (ជុំទីពីរ) មានចំនួន ១ ៣១៦ ៦៧៥នាក់ ឬស្មើនឹង ៩២.៧៣% ដោយកើនឡើង ៨.៧% ធៀបនឹងឆ្នាំ២០២៣។ អត្រានេះមានការប្រែប្រួលពីខេត្តមួយទៅខេត្តមួយទៀត ពីកម្រិតទាបបំផុត ៤៤.៧% ទៅកម្រិតខ្ពស់បំផុត ១៣៨.៤៤%។ ដោយឡែកការផ្តល់គ្រាប់ថ្នាំជីវជាតិ-អា ក្នុងការព្យាបាលកុមារមានជំងឺស្ងួតភ្នែក និងជំងឺខ្វាក់មាន់បានចំនួន ១៣ ៣៩៧នាក់ កុមារមានជំងឺកញ្ជ្រិល ១ ៧៤៥នាក់ និងកុមារកង្វះអាហាររូបត្ថម្ភ ឬរាគជាប់ ឬរាគរុំរ៉ៃ ៥៦៦នាក់។

៥១. ការផ្តល់ថ្នាំទំលាក់ព្រូន៖ នៅ២០២៤ កុមារអាយុពី ១២-៥៩ខែ ដែលបានទទួលថ្នាំមេបង់ដាហ្សុល ជុំទី២ (៦ខែចុងឆ្នាំ) មានចំនួន ១ ១៦២ ២៨៤នាក់ បានកើនឡើងប្រមាណ ១៥.០៥% ធៀបនឹងឆ្នាំ២០២៣។ ស្ត្រីក្នុងវ័យបន្តពូជអាយុពី១៥-៤៩ឆ្នាំ ចំនួន ២៦៣ ០៦១នាក់ និងស្ត្រីបំបៅដោះកូនចំនួន ១៥៣ ៨០៩នាក់ បានទទួលថ្នាំមេបង់ដាហ្សុល ដោយមានការកើនឡើងលើសឆ្នាំ២០២៣ ចំនួន ១៣៤ ៨៥២នាក់ (ជាងទ្វេដង) និង ៦៨ ៧៤៨នាក់ (ជាង ៨០%) តាមលំដាប់រៀង។

៥២. ការផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិក៖ នៅឆ្នាំ២០២៤ ស្ត្រីមានគភ៌បានទទួលគ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិក ៩០គ្រាប់ មានចំនួន ២៩០ ០០១នាក់ ឬស្មើនឹង ៧៩.៥៥% នៃស្ត្រីមានគភ៌រំពឹងទុក ដោយថយចុះប្រមាណ ៧.៧៤% ធៀបនឹងឆ្នាំ២០២៣ (៨៧.២៩%)។ រីឯស្ត្រីក្រោយសម្រាលបានទទួលអាស៊ីតហ្វូលិក/គ្រាប់ថ្នាំជាតិដែក ៤២គ្រាប់ មានចំនួន ២៥០ ១៧៣នាក់ ឬស្មើនឹង ៦៨.៣៩% ដោយថយចុះប្រមាណ ៧.៨៣% ធៀបនឹងឆ្នាំ២០២៣។

៥៣. ការពិនិត្យពិគ្រោះ និងព្យាបាលជំងឺកង្វះអាហារូបត្ថម្ភនៅឆ្នាំ២០២៤ កុមារអាយុក្រោម ៥ឆ្នាំ ដែលបានមកពិនិត្យពិគ្រោះជំងឺក្រៅ និងបានរកឃើញមានបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវមានចំនួនសរុប ១១ ៣១០ករណី ដោយកើនឡើង ២៦% បើធៀបនឹងឆ្នាំ២០២៣ (៨ ៩៧៧ករណី)។

## ៣.២. ការចុះអត្រានុកូលដ្ឋាន

### ក. ការចុះបញ្ជីកំណើត

៥៤. នៅកម្ពុជា កុមារប្រមាណ ៩៤% នៃកុមារទាំងអស់ ដែលមានអាយុ ០-៤ឆ្នាំ មានសំបុត្រកំណើត។ ភាគរយនេះ គឺមានកម្រិតខ្ពស់បំផុតនៅរាជធានីភ្នំពេញ ប្រមាណជិត ៩៤% នៅទីប្រជុំជនផ្សេងៗ មានជិត ៩៧% និងនៅតំបន់ជនបទ មានជិត៩៣%។[3]

៥៥. ក្នុងឆ្នាំ២០២៤ ចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទបានចំនួន ៨១៤ ៤០៤បញ្ជី (មនុស្ស ១ ០៨៩ ៣៧២ នាក់ ស្រី ៥៤២ ៤៥៤នាក់)។ គិតចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០២៤ ការចុះបញ្ជីអត្រានុកូលដ្ឋានសម្រេចបាន ២១ ៣៩២ ៧៦៧បញ្ជី មនុស្ស ២២ ៨២១ ៩៨៥នាក់ ស្រី ១០ ៩២៧ ៧២៧នាក់។

## ៣.៣. បរិយាកាសគ្រួសារ[4]

### ក.ការថែទាំជំនួស

៥៦. កន្លែងថែទាំកុមារមានចំនួន ២៥១ ដែលមានកុមារសរុបចំនួន ៨ ៦៨៥នាក់ (ស្រី ៤ ៣៣៦នាក់) ក្នុងនោះ កុមារអាយុពី ០-១៧ឆ្នាំ មានចំនួន ៧ ០០១នាក់ (ស្រី ៣ ៤៥៥នាក់) និងយុវជនមានអាយុចាប់ពី ១៨ឡើង មានចំនួន ១ ៦៨៤នាក់ (ស្រី ៨៨១នាក់)។ កុមារថែទាំដោយសាច់ញាតិផ្លូវការចំនួន ៣៤៥នាក់ (ស្រី ១៩៣ នាក់) និងយុវជនអាយុលើស ១៨ឆ្នាំចំនួន ៣៩នាក់ (ស្រី ២៥នាក់)។ កុមារថែទាំដោយគ្រួសារធម៌ចំនួន ២២៤នាក់ (ស្រី ៩០នាក់) និងយុវជនអាយុលើស ១៨ឆ្នាំចំនួន ៥នាក់ (ស្រី ៣នាក់)។ កុមារដែលត្រូវបានធ្វើសមាហរណកម្ម ឬបង្រួបបង្រួមគ្រួសារ ឬកុមារចាកចេញពីមណ្ឌលថែទាំសរុបចំនួន ៣១៨នាក់ (ស្រី ២០១នាក់) និងយុវជនអាយុលើស ១៨ឆ្នាំចំនួន ២៧ (ស្រី ៨នាក់)។

**តារាង ៖ ចំនួនកន្លែងថែទាំ និងចំនួនកុមារ និងយុវជន ទិន្នន័យឆ្នាំ២០២៤**

| ប្រភេទកន្លែងថែទាំ | ចំនួន | ចំនួនកុមារអាយុ ០-១៧ឆ្នាំ | | ចំនួនយុវជន ១៨ឆ្នាំឡើង | |
|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី |
| មណ្ឌលថែទាំរបស់រដ្ឋ | ២១ | ១,២៨៧ | ៥៨៧ | ២៤៧ | ១២៥ |
| មណ្ឌលថែទាំរបស់អង្គការដៃគូ | ១៥៥ | ៤,៦១៤ | ២,៣៧៧ | ៨៥៨ | ៤២៨ |
| កន្លែងថែទាំបែបសហគមន៍ | ៧៥ | ១,១០០ | ៤៩១ | ៥៨០ | ៣២៨ |
| **សរុបរួម** | **២៥១** | **៧,០០១** | **៣,៤៥៥** | **១,៦៨៤** | **៨៨១** |

ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤ និងទិសដៅអនុវត្តបន្ត របស់ក្រសួង ស.អ.យ.

៥៧. ក្នុងឆ្នាំ២០២៤ មណ្ឌលថែទាំកុមាររបស់សមាគម អង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ៥៦ ទទួលបានវិញ្ញាបនបត្រទទួលស្គាល់នៅមានសុពលភាព លើមណ្ឌលថែទាំសរុបចំនួន ១៥៥។ បច្ចុប្បន្ន មជ្ឈមណ្ឌល

[3] របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០២១ ទំព័រ៣៣

[4] របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួង ស.អ.យ.

ទារក និងកុមារជាតិមានកុមារ និងយុវជនស្នាក់នៅសរុបចំនួន ១៩១នាក់ ស្រី៨៦នាក់ ក្នុងនោះកុមារ និងយុវជនពិការចំនួន ១៧០នាក់ កុមារ និងយុវជនផ្ទុកមេរោគអេដស៍ចំនួន ៧នាក់ និងកុមារធម្មតា ១៤នាក់។

៥៨. ដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ បទដ្ឋានស្តីពីអង្គការសុវត្ថិភាពកុមារ សៀវភៅបណ្តុះបណ្តាលបទដ្ឋានស្តីពីអង្គការសុវត្ថិភាពកុមារសម្រាប់គ្រូបង្គោល សៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

៥៩. កំពុងរៀបចំសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិកាកិច្ចការពារកុមារដែលរងផលប៉ះពាល់ដោយការធ្វើទេសន្តរប្រវេសន៍រវាងព្រះរាជាណាចក្រថៃ និងព្រះរាជាណាចក្រកម្ពុជា។

### ខ.ការសុំកូន

៦០. ក្រសួង ស.អ.យ. បានសហការជាមួយអង្គការដៃគូ ដើម្បីជំរុញការអនុវត្តការងារសុំកូនក្នុងប្រទេស ដោយបានបណ្តុះបណ្តាលអំពីច្បាប់ នីតិវិធីអនុវត្តដល់មន្ត្រីមន្ទីរ ស.អ.យ. រាជធានី ខេត្ត បុគ្គលិកសង្គមនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធសរុបចំនួន ៤៤៧នាក់។ ទទួលបានដីកាសម្រេចសុំកូនពេញលេញក្នុងប្រទេសសរុបចំនួន ៤។

៦១. បានបញ្ចូនក្នុងទិន្នន័យនូវសំណុំឯកសារចាស់ៗ នៃការសុំកូនអន្តរប្រទេសចំនួន ៣៣០ករណី។ ទន្ទឹមនឹងនេះ រដ្ឋបាលសុំកូនអន្តរប្រទេសក៏ទទួលបាននូវរបាយការណ៍ស្តីពីស្ថានភាពកុមារ ដែលជាកូនសុំសរុបចំនួន ២២០ ករណី ក្នុងនោះនៅប្រទេសអូទ្រីសចំនួន ២ករណី ប្រទេសអ៊ីតាលីចំនួន ២១៨ករណី។

### គ.កូនតាមឪពុកម្តាយក្នុងពន្ធនាគារ

៦២. ក្នុងឆ្នាំ២០២៣ ផ្អែកលើទិន្នន័យការគ្រប់គ្រងករណី មានស្ត្រីមានផ្ទៃពោះ និងកុមារតាមម្តាយក្នុងពន្ធនាគារសរុបចំនួន ១៥២នាក់ ដែលក្នុងចំណោមនោះ ស្ត្រីមានផ្ទៃពោះចំនួន ៣៨នាក់ និងកុមារតាមម្តាយក្នុងពន្ធនាគារសរុបចំនួន ១១៤នាក់ (ស្រី ៦៣នាក់) ។

## ៣.៤. បទដ្ឋាននៃការរស់នៅ

### ក. ទឹកស្អាត និងអនាម័យ

៦៣. ទឹកស្អាត និងអនាម័យត្រូវបានចាត់ទុកថា មានចំណងទាក់ទងយ៉ាងរឹងមាំជាមួយអាហារូបត្ថម្ភ។ បញ្ហាកង្វះអាហារូបត្ថម្ភ និងភាពក្រិនក្រេះ បានបង្កឡើងដោយសារបញ្ហាអនាម័យនៅមានកម្រិតទាប និងការប្រើប្រាស់ទឹកមិនស្អាត។ នៅទូទាំងប្រទេសកម្ពុជា ក្នុងឆ្នាំ២០២១ មានគ្រួសារប្រមាណ ៨៧% (ទីប្រជុំជន ៩១.៦% ទីជនបទ ៨២.៧%) មានលទ្ធភាពប្រើប្រាស់ប្រភពទឹកដែលបានកែលម្អ។[5] សេចក្តីប្រកាសថ្នាក់ជាតិ ស្តីពីស្តង់ដាគុណភាពទឹកទទួលទាន និងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត ត្រូវបានរៀបចំឡើងដាក់ឱ្យប្រើប្រាស់ ហើយស្ថានីយប្រព្រឹត្តិកម្មទឹកស្អាតមួយចំនួនត្រូវបានកែលម្អ និងបើកឱ្យដំណើរការដើម្បីលើក

[5] របាយការណ៍អង្កេតសេដ្ឋកិច្ចកម្ពុជា ២០២១ ទំព័រ៤៣

កម្ពស់គុណភាពទឹកស្អាត និងពង្រីកវិសាលភាពឱ្យបានកាន់តែទូលំទូលាយ ដល់អ្នកប្រើប្រាស់នៅទូទាំងប្រទេស។

៦៤. រាជរដ្ឋាភិបាលអាណត្តិទី៧ បានគិតគូរដល់ការពង្រឹងសមត្ថភាពផលិត និងការផ្តល់ សេវាផ្គត់ផ្គង់ទឹកស្អាតនៅគ្រប់តំបន់ទីប្រជុំជន រហូតដល់ទីជនបទដទៃទៀត សម្រាប់ការប្រើប្រាស់ទូទៅដល់សាធារណជន ដោយពង្រឹង និងធានាប្រសិទ្ធភាពនៃការផលិត ការចែកចាយ និងការធ្វើអាជីវកម្មប្រកបដោយគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជនទូទាំងប្រទេសមានប្រតិបត្តិករផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ដែលទទួលបានប្រកាសអនុញ្ញាតសរុបចំនួន ៤៥៤ ប្រកាស ដែលក្នុងនោះមានរដ្ឋាករទឹកសាធារណៈចំនួន ១១ (ស្មើនឹង ១៤ប្រកាស) និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនមាន ចំនួនសរុប ៤៤០ប្រកាស។[6]

៦៥. ក្នុងឆ្នាំ២០២៤ កន្លងមក ការផលិត និងផ្គត់ផ្គង់ទឹកស្អាតសរុបចំនួនប្រមាណ ៥៣០ លានម៉ែត្រគូប មានកំណើនប្រមាណ ៦៨ លានម៉ែត្រគូប ស្មើនឹង ១៤.៩% ធៀបនឹង ឆ្នាំ២០២៣ មានចំនួនប្រមាណ ៤៦១ លានម៉ែត្រគូប។ រដ្ឋាករទឹកសាធារណៈ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនបានភ្ជាប់តំណជូនអតិថិជនសរុបចំនួន ១ ៤៤០ ៩១៣តំណ មានកំណើនឡើង ១៣៣ ១០៣តំណ ស្មើនឹង ១០.២% ប្រៀបធៀបនឹងឆ្នាំ២០២៣ មានចំនួន ១ ៣០៧ ៨១០តំណ។

៦៦. ក្នុងឆ្នាំ២០២៤ កន្លងមក ភូមិដាក់បណ្តាញទឹកស្អាតសរុបមានចំនួន ៧ ៤២៤ភូមិ នៃចំនួនភូមិសរុបដែលមានក្នុងតំបន់សេវាកម្មចំនួន ១០ ៦៧៩ភូមិ ក្នុងនោះរដ្ឋាករទឹកសាធារណៈបានដាក់បណ្តាញក្នុងភូមិសរុបចំនួន ១ ៤៧១ ភូមិ នៃចំនួនភូមិសរុបក្នុងតំបន់សេវាកម្មចំនួន ១ ៩៦០ភូមិ។ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនបានដាក់បណ្តាញក្នុងភូមិចំនួន ៥ ៩៥៣ភូមិ នៃចំនួនភូមិសរុបក្នុងតំបន់សេវាកម្មចំនួន ៨ ៧១៩ភូមិ។[7]

៦៧. គិតត្រឹមឆ្នាំ២០២៤នេះ លទ្ធផលសម្រេចបានលើសេវាផ្គត់ផ្គង់ទឹកស្អាតកម្រិតមូលដ្ឋាននៅតំបន់ជនបទប្រមាណ៨៧% និងការផ្គត់ផ្គង់ទឹកប្រកបដោយសុវត្ថិភាពនៅតំបន់ជនបទប្រមាណ ២១% និងការផ្តល់សេវាអនាម័យជនបទកម្រិតមូលដ្ឋានប្រមាណ៩២% និងការគ្រប់គ្រងអនាម័យជនបទប្រកបដោយសុវត្ថិភាពប្រមាណ ៥១%។ ក្រសួងអភិវឌ្ឍន៍ជនបទបានប្តេជ្ញាអនុវត្តផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកឱ្យសម្រេចបានគោលដៅអត្រាគ្របដណ្តប់ចំនួន ១០០% ត្រឹមឆ្នាំ ២០៣០ លើការទទួលបានសេវាទឹកស្អាត និងអនាម័យជនបទ។[8]

## ខ. បង្គន់អនាម័យ

៦៨. ភាគរយនៃគ្រួសារក្នុងប្រទេសកម្ពុជា ដែលមានលទ្ធភាពប្រើប្រាស់បង្គន់អនាម័យកែលម្អពីឆ្នាំ២០០៤ ដល់ឆ្នាំ២០២១ បានកើនឡើងពី ២៥% នៅឆ្នាំ២០០៤ ដល់ ៥៦% នៅឆ្នាំ២០១៤ ហើយបន្តកើនឡើងដល់ ៨៨% នៅឆ្នាំ២០២១។[9]

---

[6] របាយការណ៍លទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងរាឆ្នាំ២០២៥ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

[7] របាយការណ៍លទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងរាឆ្នាំ២០២៥ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

[8] របាយការណ៍ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

[9] របាយការណ៍អង្កេតសេដ្ឋកិច្ចកម្ពុជា ២០២១ ទំព័រ៤៧

៦៩. ចំពោះការលើកកម្ពស់ការរស់នៅស្អាត និងអនាម័យ ក្រសួងបានបង្កើតយន្តការថ្នាក់ជាតិសហការជាមួយថ្នាក់ក្រោមជាតិ អនុវត្តកម្មវិធី "បញ្ចប់ការបន្ទោបង់ពាសវាលពាសកាល" (Open Defecation Free-ODF) ដោយគិតត្រឹមឆ្នាំ២០២៤នេះ ប្រជាជនជនបទទទួលបានសេវាអនាម័យកម្រិតមូលដ្ឋានប្រមាណ ៩២% ក្នុងនោះស្ថានភាពបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល (ODF) មានភូមិចំនួន ១១ ៨៨១ ឃុំចំនួន ១ ២៥៥ ស្រុកចំនួន ១៣៤ បានបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល(ODF) និងរាជធានី-ខេត្ត បញ្ចប់ការបន្ទោបង់ពាសវាលពាសកាល (ODF) ចំនួន ១៤ រួមមានខេត្តស្វាយរៀង ព្រៃវែង កណ្ដាល កំពង់ស្ពឺ កំពង់ឆ្នាំង កែប ព្រះសីហនុ កំពង់ចាម រតនគិរី សៀមរាប ត្បូងឃ្មុំ តាកែវ ស្ទឹងត្រែង និងរាជធានីភ្នំពេញ ដែលបានបញ្ចប់ការបន្ទោបង់កម្រិតខ្ពស់ ODF Plus។ បើធៀបនឹងផែនការឆ្នាំ២០២៣ គឺមានការកើនឡើងលើសការរំពឹងទុក ហើយបានគ្របដណ្ដប់នៅតាមរាជធានី-ខេត្ត ដោយមានការចូលរួមសហការគ្នាយ៉ាងល្អពីសំណាក់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តជាតិ និងប្រជាពលរដ្ឋក្នុងមូលដ្ឋានប្រកបដោយការទទួលខុសត្រូវខ្ពស់។[10]

## គ. វឌ្ឍនភាពការតភ្ជាប់បណ្ដាញអគ្គិសនីតាមភូមិ និងការតភ្ជាប់ចរន្តអគ្គិសនីតាមខ្នងផ្ទះ

៧០. ការអភិវឌ្ឍបណ្ដាញចែកចាយថាមពលអគ្គិសនីទាំងរដ្ឋ និងឯកជន នៅក្នុងប្រទេសកម្ពុជា តាមរយៈខ្សែបណ្ដាញជាតិបញ្ជូនអគ្គិសនីដល់រាជធានី-ខេត្ត ទាំង២៥ ភូមិដែលមានអគ្គិសនីប្រើប្រាស់ មានការកើនឡើងពី ២៤.១៦% នៅឆ្នាំ២០០៩ ដល់ ៩៩.១៥% នៅឆ្នាំ២០២៤។ ចំពោះការតភ្ជាប់ថាមពលអគ្គិសនីតាមខ្នងផ្ទះក៏មានការកើនឡើងពី ១៨.៧៩% នៅឆ្នាំ២០០៩ ដល់ ៩៥.២៤% នៅឆ្នាំ២០២៤ ។




[10] របាយការណ៍ស្ដីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ


វឌ្ឍនភាពនៃការតភ្ជាប់ចរន្តអគ្គិសនីតាមខ្នងផ្ទះ
%នៃចំនួនខ្នងផ្ទះសរុបដែលបានតភ្ជាប់ចរន្តអគ្គិសនី
120
100
80
60
40
20
0
18.79
22.88
24.17
29.25
38.14
42.72
49.37
58.23
68.64
72.16
77.87
81.06
86.43
89.86
94.02
95.24
2009
2010
2011
2012
2013
2014
2015
2016
2017
2018
2019
2020
2021
2022
2023
2024
ឆ្នាំ

## ៤. ការអភិវឌ្ឍកុមារ[11]

### ៤.១. ការអប់រំ[12]

#### ក. ធនធានមនុស្សផ្នែកអប់រំ

៧១. បុគ្គលិកអប់រំគ្រប់កម្រិតមានចំនួន ១២៦ ៧៦៦នាក់ ស្រី ៦០ ៤៤១នាក់ ត្រូវជា ៤៨% (ថ្នាក់ជាតិ ៥ ២៤២ នាក់ ស្រី ១ ៨៣៨នាក់ និងថ្នាក់ក្រោមជាតិ ១២១ ៥២៤នាក់ ស្រី ៥៨ ៦០៣នាក់) ក្នុងនោះគ្រូមត្តេយ្យសិក្សាមាន ៣ ៧៩៨នាក់ ស្រី ៣ ៦៨៦នាក់ គ្រូបឋមសិក្សា ៥៤ ៣៩១នាក់ ស្រី ២៩ ៣៣៩នាក់ គ្រូបង្រៀនកម្រិតមូលដ្ឋាន ៤៣ ៣៧៥នាក់ ស្រី ១៩ ៤២៦នាក់ គ្រូបង្រៀនកម្រិតមូលដ្ឋានកីឡា ២ ៦៥៥នាក់ ស្រី ៥៤១នាក់ គ្រូបង្រៀនកម្រិតឧត្តម (បង្រៀននៅវិទ្យាល័យ) ២០ ៧២២នាក់ ស្រី ៦ ៩៨៨នាក់ គ្រូបង្រៀនកម្រិតឧត្តមបម្រើការងារនៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ១ ៦៥៤នាក់ ស្រី ៤៣៣នាក់ អធិការបឋម ២២នាក់ ស្រី ៤នាក់ អធិការមធ្យម ១៤៩នាក់ ស្រី ២៤នាក់។

៧២. ក្រសួងបានសិក្សាលើស្ថានភាពពង្រាយគ្រូបង្រៀន និងដាក់ចេញវិធានការដោះស្រាយជាក់លាក់ ដើម្បីធានាបានការផ្តល់ និងការប្រើប្រាស់បុគ្គលិកអប់រំនៅកម្រិតសាលារៀនប្រកបដោយប្រសិទ្ធភាព ជាពិសេសដាក់ចេញនូវវិធានការកាត់បន្ថយជាបណ្តើរៗចំនួនសិស្សក្នុងបន្ទប់រៀន ដើម្បីធានាគុណភាពអប់រំ។ ការរៀបចំផែនការអភិវឌ្ឍធនធានមនុស្ស ដើម្បីពង្រឹងការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ ដោយផ្តោតលើការបណ្តុះបណ្តាលវិជ្ជាជីវៈគ្រូបង្រៀន អ្នកដឹកនាំ និងគ្រប់គ្រង អ្នកស្រាវជ្រាវ និងអ្នកវាយតម្លៃអប់រំ ព្រមទាំងបង្កើតយន្តការសម្រាប់តម្រង់ទិសការងារ ការចុះជួយបង្វឹកការងារ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំផងដែរ។

៧៣. ការជំរុញការអនុវត្តគន្លងអាជីព ដែលក្រសួងបានអនុម័តរួចហើយនូវក្របខ័ណ្ឌគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន និងប្រព័ន្ធសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមទាំង ក្របខ័ណ្ឌនិងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀននិងនាយកសាលារៀន។ មកទល់ពេលនេះ អង្គភាពចំនួន ៥ (១. វិទ្យាស្ថានជាតិអប់រំ ២. វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ៣. វិទ្យាស្ថានគរុកោសល្យបាត់ដំបង ៤. វិទ្យាល័យព្រះស៊ីសុវត្ថិ (សាលារៀនជំនាន់ថ្មី) ៥. មហាវិទ្យាល័យអប់រំ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ) ត្រូវបានទទួលស្គាល់ជាអង្គភាព ផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងបានបើកវគ្គចំនួន ៤៨ ប្រធានបទរួចមកហើយ។

៧៤. ដើម្បីឧត្តមនៅគ្រឹះស្ថានសិក្សា ក្រសួងបានលើកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ឮជំរុញលើការអប់រំឌីជីថល ការធ្វើទំនើបកម្មកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃ។ ការលើកម្ពស់សមត្ថភាពការស្រាវជ្រាវ និងនវានុវត្តន៍ ជាពិសេសការកែលម្អការចូលរៀន ប្រកបដោយសមធម៌ និងគុណភាព។

---

[11] កុមារត្រូវទទួលបាននូវការសិក្សារៀនសូត្រគ្រប់ប្រភេទ គឺការសិក្សានៅសាលារៀន និងនៅតាមផ្ទះ ឬសហគមន៍ ដូចជាទទួលការអប់រំ និងផ្តល់ដំបូន្មានល្អៗស្តីពីការរស់នៅ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការថែទាំប៉នសុខភាព។ល។

[12] សន្និបាតបូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២៣-២០២៤ និងទិសដៅឆ្នាំសិក្សា២០២៤-២០២៥

### ខ. ការអប់រំកុមារតូច

៧៥. សាលាមត្តេយ្យសិក្សាគ្រប់រូបភាពចំនួន ៩ ០៣៦សាលា/កន្លែង កើនចំនួន ១៤៥សាលា/កន្លែង ដែលមានទីតាំង ១ ១១៩ឃុំ សង្កាត់ ក្នុងចំណោម ១ ៦៥២ឃុំ សង្កាត់។ ក្នុងនោះសាលាមត្តេយ្យសិក្សាសាធារណៈចំនួន ៤ ៧២៥ កើនចំនួន ៣១សាលា ក្នុងនោះមត្តេយ្យសាលាដាច់ដោយឡែក ៣៨០ កើន ២០។ សាលាឯកជនមានកម្រិតមត្តេយសិក្សាចំនួន ៩៦៣។ សាលាមត្តេយ្យសិក្សាសហគមន៍ចំនួន ៣ ៣៤៨កន្លែង កើនចំនួន ៥៨កន្លែង និងទារកដ្ឋាននៅតាមសហគមន៍រោងចក្រ សហគ្រាស ១៧កន្លែង កើន ៤កន្លែង។

៧៦. ថ្នាក់មត្តេយ្យសិក្សាគ្រប់រូបភាពចំនួន ១៥ ៩៣០។ ថ្នាក់មត្តេយ្យសិក្សារដ្ឋចំនួន ៨ ៤៥៧ ក្នុងនោះថ្នាក់មត្តេយ្យដាច់ដោយឡែក ១ ៧៦០ និងថ្នាក់មត្តេយ្យសាលាក្នុងបឋមសិក្សា ៦ ៦៩៧។ ថ្នាក់មត្តេយ្យសិក្សាឯកជន ៣ ៩១៦។ ថ្នាក់មត្តេយ្យសិក្សាសហគមន៍ចំនួន ៣ ៥៥៧កន្លែង (មត្តេយ្យសិក្សាសហគមន៍មានលក្ខណៈស្តង់ដា ១ ៤៣៨ថ្នាក់)។

៧៧. កុមារតូចទទួលបានសេវាអប់រំគ្រប់រូបភាពចំនួន ៤២៥ ៥៣៩នាក់ (កើន ២៤ ៥៨០នាក់) ស្រីចំនួន ២១១ ៩១៣ នាក់ (កើន ១០ ៦២៣នាក់)។ កុមារអាយុ ៣ឆ្នាំមានចំនួន ៥៦ ៤៨៧នាក់ (កើន ២ ០៦៤នាក់) ស្រីចំនួន ២៩ ០១២នាក់ (កើន ៧១១នាក់)។ កុមារអាយុ ៤ឆ្នាំមានចំនួន ១៣៨ ៨៦៨នាក់ (កើន ១១ ២៨២នាក់) ស្រីចំនួន ៦៩ ៧១០នាក់ (កើន ៤ ៩៥៨នាក់)។ កុមារអាយុ ៥ឆ្នាំមានចំនួន ២៣០ ១៨៤នាក់ (កើន ១១ ២៣៤ នាក់) ស្រីចំនួន ១១៣ ១៩១នាក់ (កើន ៥ ៣០៧នាក់)។

៧៨. ការពង្រឹងអភិបាលកិច្ចសាលាមត្តេយ្យសិក្សាបាននាំមកនូវការកែលម្អ និងការពង្រឹងគុណភាពការផ្តល់សេវាអប់រំកុមារតូច ដែលចូលរួមចំណែកដល់ការលើកកម្ពស់ការគាំពារ និងអភិវឌ្ឍកុមារតូចគ្រប់រូបភាព ប្រកបដោយសមធម៌ បរិយាបន្ន និងបណ្តុះកុមារតូចនូវបំណិនសង្គម និងបំណិនចំណេះដឹង ដើម្បីត្រៀមខ្លួនសម្រាប់ការចូលរៀននៅបឋមសិក្សា។ ម៉្យាងវិញទៀត ប្រជាជនកម្ពុជា និងអាជ្ញាធរថ្នាក់ក្រោមជាតិមានការយល់ដឹងពីសារសំខាន់សេវាអប់រំកុមារតូច ជាពិសេស បានចូលរួមនៅក្នុងការបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍។

៧៩. អត្រាចុះឈ្មោះចូលរៀនរបស់កុមារទទួលបានសេវាអប់រំគ្រប់រូបភាពមាន៖ កុមារអាយុ ៥ឆ្នាំ ៧១.៤% កើន ៦% ស្រី ៧១.៩% កើន ៥.១%។ កុមារអាយុ ៤ឆ្នាំ ៤៣.១% កើន ៦.៤% ស្រី ៤៤.៣% កើន ៥.៦%។ កុមារអាយុ ៣ឆ្នាំ ១៦.៧% កើន ១.៥% ស្រី ១៧.៦% កើន ១.៤%។

៨០. ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកម្មវិធីការអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច (ទំពួន គ្រឹង ព្នង កួយ ក្រោល កាវ៉ែត ព្រៅ ចារ៉ាយ និងកាចក់) នៅ ២១ក្រុង ស្រុក ក្នុងខេត្តរតនគិរី ស្ទឹងត្រែង មណ្ឌលគិរី ក្រចេះ និងព្រះវិហារ ដែលមានសាលាមត្តេយ្យសិក្សារដ្ឋ ៤កន្លែង និងមត្តេយ្យសិក្សាសហគមន៍ ១៥៤កន្លែង។

៨១. ក្រសួងបានអនុវត្តកម្មវិធីការអប់រំបរិយាបន្នសម្រាប់សាលាមត្តេយ្យសិក្សាសាធារណៈចំនួន ៩២១ កុមារមានពិការភាពចំនួន ៣២១នាក់ ស្រីចំនួន ១៣៦នាក់ ថយចំនួន ៤៣៧នាក់ ស្រីចំនួន ១២៤នាក់ និងមត្តេយ្យសិក្សាសហគមន៍ចំនួន ៣៨១កន្លែង កុមារមានពិការភាពចំនួន ២៣២នាក់ ស្រីចំនួន ៩១នាក់ កើនចំនួន ៤៧នាក់ នៅខេត្តសៀមរាប កំពង់ធំ រតនគិរី ក្រចេះ បាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ឧត្តរមានជ័យ

ព្រៃវែង ព្រះសីហនុ និងរាជធានីភ្នំពេញ។ ក្រសួងក៏បានបំប៉នសមត្ថភាពគ្រូមត្តេយ្យសិក្សាស្តីពីការអប់រំបរិយាបន្ន និងផែនការជួយជាបុគ្គលសម្រាប់កុមារ ដែលមានតម្រូវការពិសេស ព្រមទាំងបានបំប៉នសមត្ថភាពប្រធានក្រុមបច្ចេកទេស ឬប្រធានកម្រងសាលាមត្តេយ្យសិក្សាគោលដៅស្តីពីគំរូល្បែងសិក្សាបរិយាបន្ន និងបានចុះពិនិត្យតាមដានការអនុវត្តគំរូល្បែងបរិយាបន្ន និងសិក្សាស្រាវជ្រាវពីប្រសិទ្ធភាពនៃការប្រើប្រាស់ល្បែងបរិយាបន្ននៅតាមកម្រងសាលាមត្តេយ្យសិក្សាគោលដៅដោយសហការជាមួយដៃគូអភិវឌ្ឍ។

៨២. ក្រសួងបានផ្តល់ប្រពន្ធផ្គត់ផ្គង់ទឹកស្អាត និងបង្គន់អនាម័យ ដល់សាលាមត្តេយ្យសិក្សាសហគមន៍ ផ្តល់ថ្នាំទម្លាក់ដង្កូវព្រូនដល់កុមារ រៀបចំកន្លែងលាងសម្អាតដៃដោយមានទឹក និងសាប៊ូជាប្រចាំសាលា។ ផ្តល់កម្មវិធីអាហារតាមសាលារៀនដល់កុមារមត្តេយ្យសិក្សានៅក្នុងបឋមសិក្សា ៤៤២សាលា ក្នុងចំណោម ៥៥៣សាលា នៃកម្មវិធីអាហារតាមសាលារៀន។

៨៣. ការអនុវត្តកម្មវិធី និងសកម្មភាពនានាទទួលបានការគាំទ្រ និងការចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធ។ ប្រការនេះបានបង្ហាញនូវវឌ្ឍនភាព នៃការវិនិយោគលើការអប់រំកុមារតូចបែបពហុវិស័យ ប្រកបដោយភាពប្រទាក់ក្រឡាគ្រប់ទិដ្ឋភាព។

### គ. ការអប់រំបឋមសិក្សា

៨៤. សាលាបឋមសិក្សាសរុបចំនួន ៨ ២៨៨ កើនចំនួន ៣៦។ សាលាបឋមសិក្សារដ្ឋមានចំនួន ៧ ៣៩៨ ក្នុងនោះសាលាបឋមសិក្សាឧបសម្ពន្ធ ៥៩។ សាលារៀនឯកជនកម្រិតបឋមសិក្សាមានចំនួន ៨៩០។

៨៥. សិស្សបឋមសិក្សាមានចំនួន ២ ២៦១ ២១៦នាក់ ថយ ៤ ៥៦៧នាក់ ស្រីចំនួន ១ ០៨៥ ៨៨០នាក់ ថយ ១ ០១២នាក់ ធៀបទៅនឹងឆ្នាំសិក្សា២០២៤-២០២៥។ សិស្សបឋមសិក្សាសាធារណៈចំនួន ២ ០៧៨ ៤០១នាក់ ថយ ១៣ ៩១៦នាក់ ស្រីចំនួន ៩៩៧ ០០៣នាក់ ថយ ៥ ៧៦៤នាក់។ សិស្សបឋមសិក្សាឯកជនចំនួន ១៨២ ៨១៥នាក់ កើន ៩ ៣៤៩នាក់ ស្រីចំនួន ៨៨ ៨៧៧នាក់ កើន ៤ ៧៥២នាក់។

៨៦. អត្រាពិតចូលរៀនថ្មី ៩៧.២% កើន ៣.១% ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ មាតាបិតាចាប់ផ្តើមយល់ដឹងអំពីអត្ថប្រយោជន៍ពីការបញ្ជូនកូនទៅសាលារៀនតាំងពីកម្រិតមត្តេយ្យសិក្សា។ ការបញ្ជូនកូនទៅរៀនមត្តេយ្យសិក្សាអាចជួយសម្រាលបន្ទុកមាតាបិតា ដែលជាប់រវល់ក្នុងការបំពេញការងារ និងប្រកបរបរចិញ្ចឹមជីវិត។ ទន្ទឹមនឹងនេះ ក្រសួងផ្តល់សេវាអប់រំកុមារតូច និងមត្តេយ្យសិក្សាកាន់តែប្រសើរ ធ្វើឱ្យអ្នកទទួលសេវាមានទំនុកចិត្ត និងបញ្ជូនកូនទៅរៀន។ លទ្ធផលដែលបានមកពីការអនុវត្តជាក់ស្តែងរំពឹងថានឹងជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស និងអាចរួមចំណែកកាត់បន្ថយអត្រាត្រួតថ្នាក់ ជាពិសេស នៅថ្នាក់ដំបូងនៃការអប់រំបឋមសិក្សា ដោយកុមារមានមូលដ្ឋានគ្រឹះលើការអាន ការសរសេរ ការគិតលេខ ទំនាក់ទំនង ការលេងល្បែងសិក្សា ការងារក្រុម ការបណ្តុះភាពក្លាហាន ការអភិវឌ្ឍរាងកាយ និងបញ្ញា។ល។ និន្នាការនេះស្របនឹងកំណើន នៃការទទួលបានសេវាអប់រំកុមារតូចនៅមុនពេល និងនៅពេលចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំនេះ ប៉ុន្តែការចូលរៀននៅមត្តេយ្យសិក្សាមានកំណើននៅឆ្នាំសិក្សាជាបន្តបន្ទាប់។

៨៧. អត្រាពិតចូលរៀនថ្មីនៅបឋមសិក្សា ៩៧.២% កើន ៣.១% ប្រុស ៩៧.៩% កើន ៤.២% និងស្រី ៩៦.៥% កើន ១.៩%។ អត្រាពិតចូលរៀនថ្មីកើនឡើង ព្រោះការចូលរៀនត្រឹមត្រូវតាមអាយុរបស់សិស្សថ្នាក់ទី១ បានត្រឡប់ទៅរកស្ថានភាពដូចមុនពេលរីករាលដាលនៃជំងឺកូវីដ-១៩។

៨៨. អត្រាពិតនៃការសិក្សាបឋមសិក្សា ១០២.៣% (កើន ២.៧%) ប្រុស ១០៣.១% (កើន ៣.៤%) ស្រី ១០១.៥% (កើន ១.៩%)។ អត្រារួមនៃការសិក្សា ១២៤.៦% កើន ១១.៩% ប្រុស ១២៦.៨% កើន ១២.៩% ស្រី ១២២.៤% កើន ១១.១%។

៨៩. អត្រាបញ្ចប់ការសិក្សា ១០១.៥% កើន ១២.៣% ប្រុស ៩៩% កើន ១២.៧% ស្រី ១០៤.១% កើន ១១.៨%។ អត្រាគង់វង្សនៅបឋមសិក្សា ៨៤.៥% កើន ៧% ប្រុស ៧៩.៦% កើន ០.៩% ស្រី ៨៩.៨% កើន ១៣.៥%។

៩០. ក្រសួងបានផ្ដល់មូលនិធិគាំទ្រដំណើរការសាលារៀនសាធារណៈ ដោយផ្អែកលើទីតាំងតំបន់ និងចំនួនសិស្ស។ កម្មវិធីផ្ដល់អាហារតាមសាលារៀន ដោយប្រើកសិផលសហគមន៍បានអនុវត្តចំនួន ៥៥៣សាលា ក្នុងខេត្ត ១០ មានសិស្សទទួលផល ១៤៨ ៥៦៥នាក់ ធៀបនឹងឆ្នាំសិក្សា ២០២២- ២០២៣ សាលារៀនគោលដៅ កើន ១២៦។ កម្មវិធីផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក ដែលបានអនុវត្តដល់សិស្សចំនួន ១៤៨ ៩៧៩នាក់។

៩១. រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានយកចិត្តទុកដាក់ក្នុងការវិនិយោគផ្នែកហេដ្ឋារចនាសម្ពន្ធសាលារៀន ដើម្បីបង្កើនការចូលរៀន និងការលើកកម្ពស់អាហារូបត្ថម្ភឈានទៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ទន្ទឹមនេះ ក្រសួងក៏បានបង្កើនចំនួនសាលារៀនជំនាន់ថ្មី តាមរយៈការផ្តល់នូវវិញ្ញាបនបត្រសាលារៀនជំនាន់ថ្មី ដើម្បីជាសក្ខីភាពបញ្ជាក់ពីឧត្តមភាព នៃការអនុវត្តកន្លងមក។ ក្នុងនោះក្រសួងក៏បានបង្កើនម៉ោងសិក្សាមុខវិជ្ជាសិក្សា និងជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សឱ្យប្រកបដោយគុណភាព ដោយប្រើប្រាស់មូលនិធិសមធម៌។ ពង្រឹងការចូលរួមរបស់សហគមន៍ លើកកម្ពស់សមត្ថភាព គណនេយ្យភាព ស្វ័យភាព តម្លាភាព និងភាពជាម្ចាស់ ពោលគឺបណ្ដុះវប្បធម៌ថ្មីនៅតាមសាលារៀន ឈានទៅសម្រេចស្តង់ដាសាលាបឋមសិក្សាគំរូ។ ពង្រឹងវិធីសាស្ត្របង្រៀននិងរៀន និងសម្ភារឧបទេសតាមរយៈការសិក្សាភាសាខ្មែរ(អាន-សរសេរ) និងគណិតវិទ្យាថ្នាក់ដំបូង ដែលមានវិធីសាស្ត្រថ្មីៗ ទំនើបទាន់សម័យ ធ្វើឱ្យកុមារសប្បាយនឹងសកម្មភាពក្នុងការរៀនសូត្រ ក្រោមការជួយគាំទ្រពីសំណាក់ទីប្រឹក្សាគរុកោសល្យ។

៩២. ក្រសួងអប់រំ យុវជន និងកីឡា បានពង្រឹងកម្មវិធីអប់រំបរិយាបន្នសម្រាប់កុមារជនជាតិដើមភាគតិច និងកុមារមានពិការភាព។ កម្មវិធីអប់រំពហុភាសា ៩៦សាលា ១៨ស្រុក មានគ្រូ ២៣៥នាក់ ស្រី ៩៨នាក់ សិស្ស ៤ ២៦១នាក់ ស្រី ២ ០១១នាក់ នៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង។ កម្មវិធីអប់រំកុមារមានពិការភាព និងការពន្លឿនការសិក្សា ដែលបានផ្តល់ឱកាសកាន់តែប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ កុមារមានពិការភាព និងកុមារលើសអាយុឱ្យទទួលបានការអប់រំប្រកបដោយគុណភាព និងបរិយាបន្ន។

### ឃ. ការអប់រំមធ្យមសិក្សា

៩៣. គ្រឹះស្ថានមធ្យមសិក្សាសាធារណៈមាន ១ ៨២៥ កើន ២ ក្នុងនោះអនុវិទ្យាល័យ ១ ២៤៤ ថយ ២ និងវិទ្យាល័យ ៥៨១ (វិទ្យាល័យធនធាន ៦៧ និងវិទ្យាល័យអប់រំពិសេស ៦)។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ថ្នាក់ទី១២ មាន ៥៤៦ និងកម្រិតថ្នាក់ទី១០ ដល់ថ្នាក់ទី១២ មាន ៣៥។

៩៤. គ្រឹះស្ថានមធ្យមសិក្សាឯកជនមាន ៤៤២ (កើន ២៧) ក្នុងនោះអនុវិទ្យាល័យ ១១៤ (កើន ១៥) និងវិទ្យាល័យ ៣២៨ (កើន១២)។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ថ្នាក់ទី១២ មាន ៣២២ (កើន ១១) និងកម្រិតថ្នាក់ទី១០ ដល់ថ្នាក់ទី១២ មាន៦ (កើន ១)។

៩៥. សិស្សមធ្យមសិក្សាបឋមភូមិមាន ៧១២ ២៩៨នាក់ (កើន ១ ១៨៥នាក់) ស្រី ៣៧១ ១៨៨នាក់ (កើន ៩៤១នាក់)។ សិស្សមធ្យមសិក្សាបឋមភូមិរដ្ឋ ៦៦១ ៥០៨នាក់ (ថយ ៧៧៥នាក់) ស្រី ៣៤៤ ៩០៦នាក់ (ថយ ៤៩១នាក់)។ សិស្សមធ្យមសិក្សាបឋមភូមិឯកជន ៥០ ៧៩០នាក់ (កើន ១ ៩៦០នាក់) ស្រី ២៦ ២៨២ នាក់ (កើន ១ ៤៣២នាក់)។

៩៦. សិស្សមធ្យមសិក្សាទុតិយភូមិសរុប ៤៥៦ ៨០៤នាក់ (កើន ២៦ ០១២នាក់) ស្រី ២៥៣ ៨៦៤នាក់ (កើន ១៦ ៥៦៦នាក់)។ សិស្សមធ្យមសិក្សាទុតិយភូមិរដ្ឋ ៤១៣ ៣៥២នាក់ (កើន ១៧ ៥២៣នាក់) ស្រី ២៣១ ៤៩៧ នាក់ (កើន ១២ ៤៥២នាក់)។ សិស្សមធ្យមសិក្សាទុតិយភូមិឯកជន ៤៣ ៤៥២នាក់ (កើន ៨ ៤៨៩នាក់) ស្រី ២២ ៣៦៧នាក់ (កើន ៤ ១១៤នាក់)។

### ស្ថិតិមធ្យមសិក្សាចំណេះទូទៅសាធារណៈ: ឆ្នាំសិក្សា ២០២២-២០២៣ និង២០២៣-២០២៤

| បរិយាយ | ឆ្នាំសិក្សា | | កើន/ថយ (+/-) |
|---|---|---|---|
| | ២០២៣-២០២៤ | ២០២៤-២០២៥ | |
| សាលារៀន | ១,៨២៣ | ១,៨២៥ | +២ |
| បន្ទប់រៀន | ២១,៥៦៤ | ២១,៦២០ | +៥៦ |
| ថ្នាក់រៀន | ២៣,៨៤២ | ២៣,០៦៩ | -៧៧៣ |
| បុគ្គលិកសរុប | ៥២,៩១៤ | ៥២,៣០០ | -៦១៤ |
| បុគ្គលិកស្រី | ២១,៥៥៩ | ២១,៣៧០ | -១៨៩ |
| បុគ្គលិកមិនបង្រៀនសរុប | ៨,០០៧ | ៨,០០៧ | ថេរ |
| បុគ្គលិកមិនបង្រៀនស្រី | ២,២៣៧ | ២,២២២ | -១៥ |
| បុគ្គលិកបង្រៀនសរុប | ៤៤,៩០៧ | ៤៤,២៩៣ | -៦១៤ |
| បុគ្គលិកបង្រៀនស្រី | ១៩,៣២២ | ១៩,១៤៨ | -១៧៤ |
| សិស្សមធ្យមសិក្សាសរុប | ១,០៥៨,១១២ | ១,០៧៤,៨៦០ | +១៦,៧៤៨ |
| សិស្សមធ្យមសិក្សាស្រី | ៥៦៤,៤៤២ | ៥៧៦,៤០៣ | +១១,៩៦១ |
| សិស្សមធ្យមសិក្សាបឋមភូមិសរុប | ៧១១,១១៣ | ៧១២,២៩៨ | ១,១៨៥ |
| សិស្សមធ្យមសិក្សាបឋមភូមិស្រី | ៣៧០,៧៤៦ | ៣៧១,១៨៨ | ៩៤១ |
| សិស្សមធ្យមសិក្សាទុតិយភូមិសរុប | ៤៣០,៧៩២ | ៤៥៦,៨០៤ | ២៦,០១២ |
| សិស្សមធ្យមសិក្សាទុតិយភូមិស្រី | ២៣៧,២៩៨ | ២៥៣,៨៦៤ | ១៦,៥៦៦ |

ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

៩៧. មធ្យមសិក្សាបឋមភូមិ៖ អត្រាឡើងថ្នាក់ថយ ០.៤% (ស្រីកើន ០.២%) អត្រាត្រួតថ្នាក់កើន ០.៣% (ស្រីកើន ០.២%) និងអត្រាបោះបង់ការសិក្សា ១៥.៥% (ស្រីថយ ០.១%)។

៩៨. មធ្យមសិក្សាទុតិយភូមិ៖ អត្រាឡើងថ្នាក់កើន ០.២% (ស្រីកើន ០.១%) អត្រាត្រួតថ្នាក់ថយ ០.២% (ស្រីថយ ០.១%) និងអត្រាបោះបង់ការសិក្សា ១៣.៧% (ស្រីកើន ០.១%)។

### អត្រាលំហូរសិស្សនៅមធ្យមសិក្សារវាងឆ្នាំសិក្សា ២០២១-២០២២ និង ២០២២-២០២៣

| បរិយាយ | ឆ្នាំសិក្សា | | កើន-ថយ | ឆ្នាំសិក្សា | | កើន-ថយ |
|---|---|---|---|---|---|---|
| | ២០២២-២៣ | ២០២៣-២៤ | (+/-) | ២០២២-២៣ | ២០២៣-២៤ | (+/-) |
| | មធ្យមសិក្សាបឋមភូមិ | | | | | |
| | សរុប | | | ស្រី | | |
| អត្រាឡើងថ្នាក់ | ៨២.១ | ៨១.៧ | -០.៤ | ៨៤.៦ | ៨៤.៨ | +០.២ |
| អត្រាត្រួតថ្នាក់ | ២.៥ | ២.៨ | +០.៣ | ១.៥ | ១.៧ | +០.២ |
| អត្រាបោះបង់ការសិក្សា | ១៥.៤ | ១៥.៥ | +០.១ | ១៣.៨ | ១៣.៥ | -០.៣ |
| បរិយាយ | មធ្យមសិក្សាទុតិយភូមិ | | | | | |
| | សរុប | | | ស្រី | | |
| អត្រាឡើងថ្នាក់ | ៨៤.៦ | ៨៤.៨ | +០.២ | ៨៧.២ | ៨៧.៣ | +០.១ |
| អត្រាត្រួតថ្នាក់ | ១.៧ | ១.៥ | -០.២ | ១.២ | ១.១ | -០.១ |
| អត្រាបោះបង់ការសិក្សា | ១៣.៧ | ១៣.៧ | ០ | ១១.៥ | ១១.៦ | +០.១ |

ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

៩៩. លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ៖ បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ១៧៥ ៣៩៦នាក់ ស្មើ ៩៤,៦៩% ស្រី ៩៧ ៤៥៦នាក់ ស្មើ ៩៦,២១% ដោយមានកំណត់និទ្ទេសល្អ ល្អបង្គួរ និងមធ្យម។ បើធៀបទៅនឹងឆ្នាំ២០២២-២០២៣ បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ១៧៣ ២១៦នាក់ ស្មើ ៩៤.៧៨% ស្រី ៩៥ ៣៩៦នាក់ ស្រី ៩៧.០៣%។

១០០. លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ៖ បេក្ខជនមកប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ១៣៤ ៦២៩នាក់ (ស្រី ៧៣ ៩២៩នាក់) បេក្ខជនប្រឡងជាប់ ១០៦ ៣៥១នាក់ ស្មើ ៧៩% (ស្រី ៦១ ៥៣០នាក់ ស្មើ ៨៣.២៣%) ក្នុងនោះបេក្ខជននិទ្ទេស A ២ ២១៦នាក់ (ស្រី ១ ២៨១នាក់) និទ្ទេសB ៩ ៧០១នាក់ (ស្រី ៥ ៩៨៥នាក់) និទ្ទេស C ២២ ៦៧៥នាក់ (ស្រី ១៤ ២២០នាក់) និទ្ទេស D ៣៦ ៦៨៣នាក់ (ស្រី ២១ ៦៩៨នាក់) និងនិទ្ទេស E ៣៥ ០៧៦នាក់ (ស្រី ១៨ ៣៤៦នាក់)។

### ការប្រៀបធៀបលទ្ធផលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និង សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅនិងបំពេញវិជ្ជា រវាងឆ្នាំសិក្សា២០២១-២០២២ និង២០២២-២០២៣

| ភូមិសិក្សា | ឆ្នាំសិក្សា | | ឆ្នាំសិក្សា | | កើន-ថយ,(+/-) | | | |
|---|---|---|---|---|---|---|---|---|
| | ២០២២-២៣ | | ២០២៣-២៤ | | | | | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ភាគរយ | ស្រី | ភាគរយ |
| ម.បឋមភូមិ | ១៧៣,២១៦ | ៩៥,៣៩៦ | ១៧៥,៣៩៦ | ៩៧,៤៥៦ | +២,១៨០ | +១.២៦ | +២០,៦០ | +២.១៦ |
| ម.ទុតិយភូមិ | ៩៨,៤៦០ | ៥៦,៤៩២ | ១០៦,៣៥១ | ៦១,៥៣០ | +៧,៨៩១ | +៨.០១ | +៥,០៣៨ | +៨.៩២ |

១០១. លទ្ធផលសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ២០២៣-២០២៤ ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣ ថយ 0.0៩% ស្រីថយ 0.៨២% រីឯលទ្ធផលសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ២០២៣-២០២៤ ធៀបនឹងឆ្នាំសិក្សា២០២២- ២០២៣ កើន ៦.១១% ស្រីកើន ៥.១៤%។

១០២. លទ្ធផលសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ២០២៣-២០២៤ ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣ កើន ៦.១១% ស្រីកើន ៥.១៤% ក្នុងនោះថ្នាក់វិទ្យាសាស្ត្រកើន ៥.៧៣% ស្រីកើន ៥.១៤% និង ថ្នាក់វិទ្យាសាស្ត្រសង្គមកើន ៦.១០% ស្រីកើន ៤.៦៧%។

១០៣. សាលាមធ្យមវិចិត្រសិល្បៈ មានការិយាល័យចំនួន៤ និងមានសាលាជំនាញចំនួន៥ គឺ (ទី១)-សាលាតូរ្យតន្ត្រី មាន ២៤ឯកទេស (ទី២)-សាលារបាំ មាន ៣ឯកទេស (ទី៣)-សាលាល្ខោន មាន ៣ឯកទេស (ទី៤)-សាលាសៀក មាន ៧ឯកទេស និង(ទី៥)-សាលាសិល្បៈសូនរូប មាន ១០ឯកទេស។ សាលាមធ្យមវិចិត្រសិល្បៈ មានគ្រូបង្រៀនពេញម៉ោងចំនួន ២១០នាក់ (ស្រីចំនួន៦៥នាក់) គ្រូបង្រៀនក្រៅម៉ោង ចំនួន១២៣នាក់ (ស្រីចំនួន៥៣នាក់) បុគ្គលិកសិក្សាចំនួន៣២នាក់ (ស្រី១០នាក់) និងមានសិស្សានុសិស្សសរុបចំនួន៩២៨នាក់ (សិស្សស្រីចំនួន៥២៦នាក់)។

១០៤. សាលាមធ្យមវិចិត្រសិល្បៈ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ គឺជាគ្រឹះស្ថានសិក្សាចាប់ពីកម្រិតបឋមភូមិ (ថ្នាក់ថ្នាលទី១ ឬថ្នាក់ទី៤នៃសាលាចំណេះដឹងទូទៅ) រហូតដល់កម្រិតទុតិយភូមិ (ថ្នាក់ឆ្នាំទី៦ ឬថ្នាក់ទី១២ នៃសាលាចំណេះដឹងទូទៅ) របស់រដ្ឋតែមួយគត់ ដែលមានកម្មវិធីសិក្សាផ្តោតសំខាន់លើវិស័យសិល្បៈវប្បធម៌ ក្នុងគោលបំណងអភិរក្ស ថែរក្សា បណ្តុះបណ្តាល និងផ្ទេរចំណេះជំនាញ ក៏ដូចជាបទពិសោធន៍លើវិស័យសិល្បៈ ទស្សនីយភាព និងសិល្បៈសូនរូបទាំងទម្រង់បុរាណនិងសម័យ ប្រកបដោយគុណភាពដល់ក្មេងជំនាន់ក្រោយ។ សិស្សានុសិស្ស ដែលបានឆ្លងកាត់ប្រព័ន្ធសិក្សានៅសាលាមធ្យមវិចិត្រសិល្បៈនឹងក្លាយជាធនធានសិល្បករប្រកបដោយវិជ្ជាជីវៈពេញលេញ និងមានគរុកោសល្យសិល្បៈ ដែលអាចផ្ទេរចំណេះដឹង បម្រើ គាំពារ និងលើកស្ទួយសិល្បៈវប្បធម៌ខ្មែរឲ្យចុំច្រើនទៅអនាគត។ បន្ថែមពីលើជំនាញសិល្បៈ សាលាបានបញ្ចូលកម្មវិធីសិក្សាចំណេះដឹងទូទៅស្របតាមក្រឹតក្រមរបស់ក្រសួងអប់រំ យុវជន និងកីឡា។

១០៥. ការសិក្សានៅសាលាមធ្យមវិចិត្រសិល្បៈ បែងចែកជា ៣ កម្រិតធំៗ គឺភូមិសិក្សាថ្នាល ភូមិសិក្សាទី១ និងភូមិសិក្សាទី២។ សញ្ញាបត្ររបស់សាលាមធ្យមវិចិត្រសិល្បៈមាន ២ កម្រិត គឺសិស្សដែលបញ្ចប់ភូមិសិក្សាទី១ ឬថ្នាក់ឆ្នាំទី៣ (មធ្យមសិក្សាបឋមភូមិឬឌីប្លូម) ទទួលបានសញ្ញាបត្រសិល្បៈ និងសិស្សដែលបញ្ចប់ភូមិសិក្សាទី២ ឬថ្នាក់ឆ្នាំទី៦ (មធ្យមសិក្សាទុតិយភូមិឬបាក់ឌុប) ទទួលបានស្នាតកបត្រសិល្បៈ។

## ៤.២. ការបណ្តុះបណ្តាលវិជ្ជាជីវៈ

១០៦. នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសជាផ្លូវការអំពីការអនុវត្តកម្មវិធីសន្តិសុខសង្គមស្តីពីការថែទាំសុខភាពដោយស្ម័គ្រចិត្ត ក្នុងគោលបំណងពង្រីកសេវាថែទាំសុខភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល ដែលបុគ្គលស្វ័យនិយោជន៍ និងសមាជិកគ្រួសាររបស់បេឡាជាតិសន្តិសុខសង្គម (ប្តីប្រពន្ធ និងកូន) អាចទទួលបានសេវាថែទាំសុខភាពដោយបង់ប្រាក់វិភាគទានត្រឹមតែ ១៥ ៦០០រៀលក្នុងមួយខែ។ ប័ណ្ណមូលនិធិសមធម៌សុខភាពដែលបានធ្វើបច្ចុប្បន្នភាពនៅត្រឹមថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤ មានសមាជិកសរុប ១៣៥ ០០២នាក់ (ស្រី ៧៤ ៥០៩នាក់) បានចុះបញ្ជីអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. សរុប

ចំនួន ១៥១ ៤២៤នាក់ ការចុះបញ្ជីមន្ត្រីសាធារណៈចំនួន ១២៦ ៦២៣ នាក់ អ្នកក្នុងបន្ទុកកម្មករនិយោជិតសរុបចំនួន ៨ ៦៣៧នាក់ និងអ្នកក្នុងបន្ទុកបុគ្គលស្វ័យនិយោជន៍សរុបចំនួន ១៦ ១៦៤នាក់។

១០៧. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់អនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ។ នៅឆ្នាំ ២០២៤ បានផ្តល់ការបណ្តុះបណ្តាលដល់យុវជនសរុបចំនួន ១៧ ១៨០នាក់ (ស្រី ៦ ០៩៩នាក់) ក្រុមគោលដៅចំនួន ៧ ៨៦៦នាក់ (ស្រី ៣ ៦៦៦នាក់) ក្នុងនោះមានយុវជនអាយុចាប់ពី ១៥-១៧ឆ្នាំ ចំនួន ៣ ៧៦០នាក់ (ស្រី ១ ៧២៤នាក់) ក្រុមគោលដៅចំនួន ២ ១១៧នាក់ (ស្រី ១ ០៥៨នាក់) និងមានការងារធ្វើសរុបចំនួន ១០ ១០៨នាក់ (ស្រី ៣ ៦៩៦នាក់) ក្រុមគោលដៅចំនួន ៤ ៦៧៣នាក់ (ស្រី ២ ០៤៨នាក់) ក្នុងនោះមានយុវជនអាយុចាប់ពី ១៥-១៧ឆ្នាំ ចំនួន ១ ៣៧៧នាក់ (ស្រី ៥៦៥នាក់) ក្រុមគោលដៅចំនួន ៧៩៣នាក់ (ស្រី ៣៤៩នាក់)។

# ៥. ការការពារកុមារ[13]

## ៥.១.ការបង្ការ ទប់ស្កាត់

### ក. ការលើកកម្ពស់កិច្ចការពារ

១០៨. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានរៀបចំរបាយការណ៍ ស្តីពីស្ថានភាពកុមារឆ្នាំ២០២៣ ដែលជាឯកសារមូលដ្ឋាន ដើម្បីឆ្លុះបញ្ចាំងអំពីយន្តការបរិយាបន្នរបស់រាជរដ្ឋាភិបាលក្នុងការធានាការពារ និងលើកកម្ពស់ឧត្តមប្រយោជន៍របស់កុមារកម្ពុជា ជាពិសេសការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ។

១០៩. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល រៀបចំទិវាកុមារអន្តរជាតិ និងទិវាកុមារកម្ពុជា ១មិថុនា ក្រោមប្រធានបទ "វិនិយោគលើកុមារថ្ងៃនេះ សំដៅបង្កើនមូលធនមនុស្សក្នុងយុគសម័យបរិវត្តកម្មឌីជីថល" ដែលមានអ្នកចូលរួមប្រមាណជាង ៣០០០នាក់។

១១០. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការរៀបចំពិធីអបអរសាទរខួបលើកទី៧៥ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៣ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៤ ក្រោមប្រធានបទ "រួមគ្នាអនុវត្តការប្តេជ្ញាចិត្ត ដើម្បីបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ ដែលជាអនុប្រធាន សមាជិក សមាជិកា ថ្នាក់ដឹកនាំ នៃ គ.ជ.ព. អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត លោក លោកស្រី ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលរាជធានី-ខេត្ត លោក លោកស្រី តំណាងអង្គការទស្សនៈពិភពលោក តំណាងអង្គការILO តំណាងអង្គការនិយោជក និយោជិត អង្គការដៃគូពាក់ព័ន្ធ លោកគ្រូ អ្នកគ្រូ ភ្ញៀវកិត្តិយស កុមារា និងកុមារី សរុបចំនួន ៣៥០នាក់ (ស្រី ៨៨នាក់)។

១១១. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បាននឹងកំពុងរៀបចំសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០។

១១២. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងគ្រោងរៀបចំសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឆ្នាំ២០២៦-២០៣៥ (ដំណាក់កាលទី៣) ដែលជាគំនិតផ្តួចផ្តើមដ៏សំខាន់មួយក្នុងគោលបំណងដោះស្រាយបញ្ហាពលកម្មកុមារឱ្យបានទូលំទូលាយ។

១១៣. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំកិច្ចប្រជុំពិនិត្យតាមដានការអនុវត្តសារាចររាជរដ្ឋាភិបាលកម្ពុជា លេខ ០៦ សរ. ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិចំនួន ៤៨ចំណុច អគ្គលេខាធិការដ្ឋាន ក.ជ.ក. បែងចែកអនុសាសន៍ទៅតាមក្រសួង ស្ថាប័នចំនួន ២៧។ ជាការឆ្លើយតប ក្រសួង ស្ថាប័នចំនួន ១៧ បានបញ្ចូលទៅក្នុងផែនការរបស់ខ្លួន។

---

[13] ឪពុកម្តាយត្រូវមើលថែ និងប្រៀនប្រដៅកុមារ ហើយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវចាត់វិធានការជួយកុមារឱ្យរួចផុតពីគ្រោះមហន្តរាយនានា ដូចជា គ្រឿងញៀន ល្បែងអបាយមុខ អំពើអនាចារ ការរើសអើង ការសេពកាមគុណលើកុមារ ការធ្វើអាជីវកម្មលើកុមារ ការលក់កុមារ និងអំពើផ្សេងៗទៀត ដែលប៉ះពាល់ដល់ឧត្តមប្រយោជន៍កុមារ។ ឪពុកម្តាយ ត្រូវការពារកូនរបស់ខ្លួន និងចូលរួមចំណែកការពារកុមារផ្សេងៗទៀត ពីការរំលោភបំពានទាំងឡាយដែលបង្កឡើងដោយជនខិលខូច។ អាជ្ញាធរមានសមត្ថកិច្ច ក៏មានភារកិច្ចការពារកុមារពីការរំលោភបំពាននានា ដែលប្រព្រឹត្តដោយឪពុកម្តាយ អាណាព្យាបាល ឬអ្នកមានអំណាចផ្សេងៗទៀតមកលើកុមារ

១១៤. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ.) បានសហការជាមួយក្រសួងមហាផ្ទៃ ផ្សព្វផ្សាយសៀវភៅណែនាំ ស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ ដែលមានអ្នកចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ ស.អ.យ. រាជធានី ខេត្ត រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធសរុបចំនួន ១១០ នាក់ និងបានរៀបចំផែនការអនុវត្ត (Roadmap) សម្រាប់អនុវត្តនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ សៀវភៅកិច្ចតែងការមេរៀនសម្រាប់បណ្តុះបណ្តាលគ្រូបង្គោល បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិបានចំនួន២៩នាក់ ស្រី០៦នាក់ និងបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្តចំនួន៦ គឺខេត្តរតនគិរី ព្រះវិហារ សៀមរាប កំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង បានចំនួន ៦០នាក់។

១១៥. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំបណ្តុះបណ្តាលស្តីពី ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ចំនួន ២៣វគ្គ ៖

- ពង្រឹងសមត្ថភាពដល់មន្ត្រីនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ចំនួន១៥ខេត្ត ស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្ម ដែលមានអ្នកចូលរួមសរុបចំនួន ២៩៥នាក់ (ស្រី៩៨នាក់)
- បានចូលរួមជាគ្រូបង្គោលក្នុងវគ្គបណ្តុះបណ្តាល ស្តីពីលក្ខខណ្ឌការងារ និងការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងនៅតាមបណ្តា សហគ្រាស គ្រឹះស្ថាន នៅប្រទេសកម្ពុជា លើប្រធានបទស្តីពីវិធានការក្នុងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ តាមសហគ្រាស គ្រឹះស្ថាន ដោយសហការជាមួយសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC) វិទ្យាស្ថានជាតិការងារ និងអង្គការអន្តរជាតិ ខាងការងារ ចំនួន៦វគ្គ ដែលមានសិក្ខាកាមដែលជាសមាជិករបស់សមាគម(TAFTAC) សរុបចំនួន ២០៥នាក់ (ស្រី១០៧នាក់) (ខេត្តកំពង់ចាម ខេត្តសៀមរាប ខេត្តកំពង់ស្ពឺ នៅស្នាក់ការសមាគម TAFTAC តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងតាមប្រព័ន្ធ ZOOM)
- ចូលរួមបណ្តុះបណ្តាលដល់មន្ត្រីទទួលបន្ទុកឆ្លើយតបសំណួរតាមប្រព័ន្ធទូរស័ព្ទ (Hotline) ស្តីពីលំហូរស្នើសុំប្រើប្រាស់កម្មករនិយោជិតវ័យក្មេង នៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម LACMS ដែលមានអ្នកចូលរួមសរុប១១នាក់ (ស្រី៦នាក់)
- ចូលរួមជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាល ស្តីពីលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យការងារ ដល់ម្ចាស់សហគ្រាសធុនតូច និងមធ្យម នៅខេត្តបាត់ដំបង ដែលមានអ្នកចូលរួមសរុប ៤៧នាក់ (ស្រី៥នាក់)។

១១៦. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីការអនុវត្តនីតិវិធីធ្វើអធិការកិច្ចកន្លែងថែទាំកុមារ ដល់មន្ត្រីបង្គោល នៃមន្ទីរ ស.អ.យ. រាជធានី ខេត្ត និងមន្ត្រី នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃរាជធានីភ្នំពេញ ខេត្តកណ្តាល ព្រះសីហនុ សៀមរាប និងខេត្តបាត់ដំបង តាមប្រព័ន្ធអនឡាញ និងបានចុះផ្តល់បច្ចេកទេសដល់មន្ត្រីបង្គោលនៃមន្ទីរ ស.អ.យ. និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្ត អំពីការធ្វើអធិការកិច្ចកន្លែងថែទាំកុមារចំនួន ០៦រាជធានី ខេត្ត គឺរាជធានីភ្នំពេញ ខេត្តព្រះវិហារ រតនគិរី បន្ទាយមានជ័យ សៀមរាប និងខេត្តបាត់ដំបង។

១១៧. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះត្រួតពិនិត្យ និងផ្តល់បច្ចេកទេសផ្ទាល់ស្តីពីការគ្រប់គ្រងករណីកុមារតាមប្រព័ន្ធបច្ចេកវិទ្យា Primero ដល់មន្ត្រីបង្គោលនិងបុគ្គលិកសង្គមនៃមន្ទីរ ស.អ.យ. ចំនួន ២៨នាក់ និងមន្ត្រីបង្គោលនៃការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមនៃរដ្ឋបាលក្រុង ស្រុក ចំនួន ៦១ នៃខេត្តតាកែវ កែប កំពង់ឆ្នាំង ពោធិ៍សាត់ ស្វាយរៀង ព្រៃវែង បន្ទាយមានជ័យ បាត់ដំបង សៀមរាប កណ្តាល ព្រះវិហារ រតនគិរី និងមន្ត្រីនៃមជ្ឈមណ្ឌលសំចតប៉ោយប៉ែតសរុបចំនួន ៨៩នាក់ ស្រី ចំនួន ៣៨នាក់។

១១៨. បានអនុវត្តយុទ្ធនាការ "គ្រួសាររឹងមាំ" ដើម្បីទប់ស្កាត់អំពើហិង្សាលើកុមារ និងការបំបែកកុមារចេញពីគ្រួសារ ដោយមិនចាំបាច់លើវិធីសាស្ត្រ៖ (១)បច្ចេកវិទ្យាគមនាគមន៍ដែលមានការប្រាស្រ័យទាក់ទងគ្នា (ICTs)៖ គេហទំព័រយុទ្ធនាការគ្រួសាររឹងមាំ (២)បណ្តាញផេកហ្វេសប៊ុកនៃយុទ្ធនាការ "គ្រួសាររឹងមាំ" (Strong Family Facebook Page) ចំនួន ៧០ដង ដែលបានផ្សព្វផ្សាយទៅដល់អ្នកប្រើប្រាស់ គណនេយ្យហ្វេសប៊ុកនៅទូទាំងប្រទេសចំនួន ១៥ ៨០៧ ៩៥៥ មានអ្នកចូលទស្សនាចំនួន ២៨ ៦៣១ ៦៤២ដង មានប្រតិកម្ម ត្រឡប់ចំនួន ១ ១០២ ៤៤៤ដង អ្នកចែករំលែកបន្តបានចំនួន ៥ ៦១៤ និងមានអ្នកតាមដានផេកថ្មីចំនួន ៣ ២៥៦នាក់ (៣)ការបង្កលក្ខណៈឱ្យមានការចូលពីសហគមន៍ (បណ្តុះបណ្តាល និងចុះផ្សព្វផ្សាយតាមសហគមន៍)៖ បានបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ក្រោមជាតិចំនួន ២៩៨នាក់ (ស្រី ១៦៧នាក់) នៅរាជធានីខេត្តទាំង៧ និងចុះផ្សព្វផ្សាយនៅសហគមន៍ដល់កុមារវ័យជំទង់ ឪពុកម្តាយ អ្នកថែរក្សាកុមារ និងសមាជិកសហគន៍ចំនួន ៣៨ ៦២៧នាក់ (ស្រី ២៣ ២១៦នាក់) និង(៤)ការស្វែងរកការគាំទ្រ៖ បង្កើតមាតិកាផ្សព្វផ្សាយខ្លីៗកិច្ចសហការជាមួយអ្នកមានឥទ្ធិពល។

១១៩. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីផ្សព្វផ្សាយសារអំពាវនាវក្នុងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ តាមរយៈការដាក់បញ្ចូលក្នុងប្រព័ន្ធនិយ័តករទូរគមនាគមន៍កម្ពុជា (TRC) សម្រាប់ដាក់បញ្ចូលទៅក្នុងសារទូរស័ព្ទទូទាំងប្រទេស លើខ្លឹមសារ៖ (១) រួមគ្នាអនុវត្តការប្តេជ្ញាចិត្តដើម្បីបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ (២) ការប្រើប្រាស់ពលកម្មកុមារ ជាអំពើខុសច្បាប់ (៣) ការប្រើប្រាស់ពលកម្មកុមារអាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ។ ករណីមានការសង្ស័យការប្រើប្រាស់ពលកម្មកុមារ សូមទាក់ទង ១២៩៧ ឬ១២៨៦។

១២០. ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ព្រមទាំងកម្មវិធីការអប់រំវិន័យបែបវិជ្ជមាន តាមរយៈការផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន ក្នុងគោលបំណង ដើម្បីទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាគ្រប់ទម្រង់លើកុមារ ទាំងក្នុងនិងជុំវិញសាលារៀន។

១២១. រាជរដ្ឋាភិបាលបានកំណត់នូវគោលនយោបាយដើម្បីអភិវឌ្ឍទេសចរណ៍ជា "ទេសចរណ៍វប្បធម៌ និងធម្មជាតិ" គ្មានគោលនយោបាយលើកទឹកចិត្តដល់ទេសចរណ៍ផ្លូវភេទ ប្រឆាំងដាច់ខាតការកេងប្រវញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ ។

១២២. ក្នុងឆ្នាំ២០២៤កន្លងទៅនេះ ក្រសួងទេសចរណ៍ បានបើកសិក្ខាសាលាស្តីពី "សុវត្ថិភាពកុមារ និងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ក្នុងវិស័យទេសចរណ៍" ជូនដល់មន្ទីរពាក់ពន្ធ័ជុំវិញខេត្ត អាជ្ញាធរដែនដី យុវជន ស.ស.យ.ក. សមាគម ម្ចាស់ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍

នៅតាមបណ្តាខេត្តមួយចំនួន រួមមាន៖ ខេត្ត តាកែវ ខេត្តកំពង់ស្ពឺ ខេត្តបាត់ដំបង និងខេត្តព្រះសីហនុ ដែលមានសិក្ខាកាមចូលរួមសុប ២៥៥នាក់ (ស្រី៩៥នាក់) ។

១២៣. ក្រសួងព័ត៌មានបានផលិត និងផ្សព្វផ្សាយមាតិកាវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី និងព័ត៌មានបោះពុម្ពពាក់ព័ន្ធទៅនឹងការបង្ការ និងការទប់ស្កាត់អំពើហិង្សាលើកុមារ រួមមាន៖ មាតិកាទម្រង់ជាព័ត៌មាន មាតិកាទម្រង់ជាបទយកការណ៍ និងបទអត្ថាធិប្បាយ។ មាតិកាគ្រប់ទម្រង់ត្រូវបានផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយជាតិរួមមានទូរទស្សន៍ វិទ្យុAM វិទ្យុFM ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ទូរទស្សន៍ថ្នាលឌីជីថល MoInfoTV និងបណ្តាញសង្គមថ្នាក់ជាតិ និងរាជធានី ខេត្ត រួមមាន Facebook, Telegram គេហទំព័រ និងTik Tok Instagram ព្រមទាំងមធ្យោបាយផ្សព្វផ្សាយបោះពុម្ព រួមមាន៖ ព្រឹត្តិប័ត្រប្រចាំថ្ងៃ ទស្សនាវដ្តីកម្ពុជាប្រចាំខែ និងកាសែតអេឡិចត្រូនិចប្រចាំថ្ងៃ។

១២៤. ក្រសួងព័ត៌មានបានរៀបចំកម្មវិធីមហោស្រពតន្ត្រី និងចម្រៀងកុមារពានរង្វាន់ក្រសួងព័ត៌មាន ឆ្នាំ២០២៥ ក្រោមប្រធានបទ "កុមារ៖ អនាគតយើង ការទទួលខុសត្រូវរបស់យើង"។ ទន្ទឹមនេះ ក្រសួងក៏បានចេញសេចក្តីណែនាំ ដល់អ្នកផលិតមាតិកាផ្សព្វផ្សាយតាមបណ្តាញសង្គម និងអ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមត្រូវបញ្ឈប់ជាបន្ទាន់ ដូចការប្រើប្រាស់វិធីសាស្ត្រលេងសើច (Prank) មកផលិតមាតិការបស់ខ្លួន ដើម្បីលក់ផលិតផលឲ្យដាច់ ឬទាញការចាប់អារម្មណ៍មកលើខ្លួន ដែលបង្ករផលប៉ះពាល់ដល់កិត្តយសសេចក្តីថ្លៃថ្នូរសិទ្ធិរបស់អ្នកដទៃ និងប្រពៃណី ទំនៀមទម្លាប់ វប្បធម៌ជាតិ។

១២៥. ក្រសួងកិច្ចការនារី បានប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវឯកសារគោលការណ៍ណែនាំ ស្តីពីដំណើរការទារកដ្ឋាន ជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងមានក្រសួងចំនួន៣ ដែលបាននឹងកំពុងអនុវត្ត៖ ក្រសួងកិច្ចការនារី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីជួយសម្រួលបន្ទុកមាតាបិតាដែលជាមន្ត្រីរាជការ និងមានក្រសួងចំនួន ៤ទៀត កំពុងពិនិត្យលទ្ធភាពក្នុងការបង្កើត (ក្រសួងមុខងារសាធារណៈ ក្រសួង អធិការកិច្ច ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)។

១២៦. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំនូវស្តង់ដាអប្បបរមាស្តីពីការរៀបចំបង្កើតទារកដ្ឋាននៅតាមសហគ្រាស គ្រឹះស្ថាន ក្នុងគោលបំណង បង្កើតទារកដ្ឋាននៅតាមសហគ្រាស គ្រឹះស្ថាន មានស្តង់ដារួមតែមួយ ជួយបងប្អូនកម្មការិនីក្នុងការថែទាំកុមារ និងកាត់បន្ថយចំណាយរបស់កម្មការិនី។

១២៧. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតប្រព័ន្ធតាមដានពលករទេសន្តរប្រវេសន៍ (Tracking System for Migrant Workers) ដែលមានមុខងារដូចជា៖ តាមដានដំណើរការឯកសារពលករទេសន្តរប្រវេសន៍ ស្វែងរកទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ និងស្វែងរកភ្នាក់ងារនៃទីភ្នាក់ងារជ្រើសរើសឯកជន។ ក្រសួងបានរៀបចំ និងផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីនីតិវិធីបញ្ជូន និងខិតប័ណ្ណអំពីនីតិវិធីបញ្ជូន និងដំណើរការឯកសារពលករទៅធ្វើការនៅបរទេសដោយស្របច្បាប់នៅបរទេស តាមរយៈគេហទំព័រផ្លូវការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួង បានផលិត និងផ្សព្វផ្សាយវីដេអូឃ្លីបអំពីការចុះឈ្មោះទៅធ្វើការនៅបរទេសតាមរយៈបញ្ជរសេវាសាធារណៈចល័ត និងកម្មវិធីទូរសព្ទដៃឈ្មោះ "MLVT Services" បានផ្ញើបញ្ចីសារអេឡិចត្រូនិកខ្លីៗក្នុងទូរសព្ទដៃ (Pushing Message) ស្តីពីការទៅធ្វើការនៅបរទេសដោយ

ស្របច្បាប់ សុវត្ថិភាព និងជៀសវាងការធ្វើទេសន្តរប្រវេសន៍ការងារដោយប្រថុយប្រថាន និងបានចាត់តាំងអនុព័ន្ធការងារអមស្ថានទូតកម្ពុជានៅប្រទេសថៃ៤រូប ប្រទេសកូរ៉េ២រូប ប្រទេសម៉ាឡេស៊ី២រូប និងប្រទេសជប៉ុន១រូប ដើម្បីផ្តល់នូវសេវាគាំពារដល់ពលករទេសន្តរប្រវេសន៍កម្ពុជា នៅតាមបណ្តាប្រទេសទទួល។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយអង្គការ IOM រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ក្រោមជាតិនៅខេត្តបន្ទាយមានជ័យចំនួន ២វគ្គ អំពីក្របខណ្ឌច្បាប់ គោលនយោបាយ បទប្បញ្ញត្តិពាក់ព័ន្ធ នីតិវិធីទទួលនិងដោះស្រាយបណ្តឹង និងការធ្វើទេសន្តរប្រវេសន៍ការងារដោយសុវត្ថិភាពដល់តំណាងរដ្ឋបាលខេត្ត មន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីនិងសិស្សនៃវិទ្យាស្ថានពហុបច្ចេកទេសខេត្ត លោក លោកស្រី អភិបាល-អភិបាលរង (ចំនួន ៩ក្រុង-ស្រុក) មេឃុំ-ចៅសង្កាត់ ក្រុមប្រឹក្សាឃុំ-សង្កាត់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ (ចំនួន ៦៨ឃុំ-សង្កាត់) អង្គការសង្គមស៊ីវិល និងអតីតពលករចំនួន ២២៧នាក់ (ស្រី ៨៦នាក់) និងសហការជាមួយអង្គការ ILO រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ក្រោមជាតិចំនួន ៣ខេត្ត នៅខេត្តកំពង់ចាម ព្រៃវែង និងខេត្តកំពត អំពីក្របខណ្ឌច្បាប់ គោលនយោបាយ បទប្បញ្ញត្តិពាក់ព័ន្ធ នីតិវិធីទទួលនិងដោះស្រាយបណ្តឹង និងការធ្វើទេសន្តរប្រវេសន៍ការងារដោយសុវត្ថិភាពដល់តំណាងរដ្ឋបាលខេត្ត មន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក លោកស្រីតំណាងក្រុង-ស្រុក មេឃុំ-ចៅសង្កាត់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី ដែលមានអ្នកចូលរួមចំនួន ១៦៦នាក់ (ស្រី ៣៥នាក់) ក្នុងនោះមានអ្នកចូលរួមនៅខេត្តកំពង់ចាម មានចំនួន ៥៧នាក់ (ស្រី ៩នាក់) នៅខេត្តព្រៃវែងមានចំនួន ៥៦នាក់ (ស្រី ១៦នាក់)និងនៅខេត្តកំពតមានចំនួន ៥៣នាក់ (ស្រី ១០នាក់)។

១២៨. មន្ត្រីក្រសួង មន្ទីរកិច្ចការនារី ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម មេឃុំ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) មេភូមិ សមាជិកភូមិ និងអ្នកស្ម័គ្រចិត្តភូមិក្នុងរាជធានី ខេត្តទាំង២៥ សរុបចំនួន ៣០៣នាក់ (ស្ត្រី ២៥៣នាក់) បានទទួលចំណេះដឹងពីវគ្គបណ្តុះបណ្តាលចំនួន ៧លើក ស្តីពី "សុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ" និងឧបករណ៍ផ្សព្វផ្សាយសកល (កម្រិតទី១) ស្តីពី "ការចិញ្ចឹមកូនបែបវិជ្ជមាន" នៅខេត្តបន្ទាយមានជ័យ កោះកុង សៀមរាប បាត់ដំបង ស្វាយរៀង ប៉ៃលិន និងខេត្តកណ្តាល ដើម្បីបង្កើនការយល់ដឹង និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគាំទ្រ និងផ្សព្វផ្សាយបន្តនៅតាមសហគមន៍។

១២៩. ប្រជាពលរដ្ឋក្នុងសហគមន៍នៃរាជធានីភ្នំពេញ ខេត្តរតនគិរី បាត់ដំបង កណ្តាល សៀមរាប ព្រះសីហនុ បន្ទាយមានជ័យ និង ខេត្តព្រះវិហារ សរុបចំនួន ២៧៨៤នាក់ (ស្ត្រី ២២៨០នាក់) បានទទួលចំណេះដឹងពីការផ្សព្វផ្សាយចំនួន ១១លើក លើឧបករណ៍ផ្សព្វផ្សាយសកល (កម្រិតទី១) ស្តីពី "ការចិញ្ចឹមកូនបែបវិជ្ជមានក្រោមកិច្ចសហការពីមន្ទីរកិច្ចការនារី មន្ត្រីការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមក្រុង ស្រុក និងអាជ្ញាធរមូលដ្ឋាន ដែលគាំទ្រដោយអង្គការយូនីសេហ្វ។

១៣០. សិស្សានុសិស្សចំនួន ១៦៧៣នាក់ (ស្ត្រី ៩៤៩នាក់) នៃវិទ្យាល័យសម្តេចឪ វិទ្យាល័យហ៊ុនសែនវត្តស្វាយ និងវិទ្យាល័យហ៊ុនសែនប្រាសាទបាគងនៃខេត្តសៀមរាប,វិទ្យាល័យបូជនីយកិច្ច វិទ្យាល័យព្រះគោ វិទ្យាល័យសេសានសុវត្ថិភាព នៃខេត្តស្ទឹងត្រែង និងវិទ្យាល័យហ៊ុនសែនឧត្តរមានជ័យ វិទ្យាល័យបន្ទាយអំពិល និងវិទ្យាល័យហ៊ុនសែនចុងកាល់នៃខេត្តឧត្តរមានជ័យ អភិបាលរងក្រុង ស្រុក មន្ត្រីការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ការិយាល័យអប់រំ យុវជន និងកីឡា នាយក នាយករង លោកគ្រូ អ្នកគ្រូ បានទទួលចំណេះដឹងពីវេទិកាពិគ្រោះយោបល់ស្តីពី ការលើកកម្ពស់សមភាពយេនឌ័រ ក្នុងវិស័យអប់រំក្រោមប្រធានបទ

"ការចិញ្ចឹមកូនបែបវិជ្ជមាន" "សុវត្ថិភាពកុមារនៅលើប្រព័ន្ធអនឡាញ" និង "ខ្ញុំមិនភ័យខ្លាច" ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងនិងបង្កើនភាពអង់អាចដល់សិស្សានុសិស្ស ជាពិសេសសិស្សស្រីឱ្យមានភាពក្លាហានក្នុងការបន្តការសិក្សារហូតចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ និងការចាប់យកជំនាញថ្មីៗសម្រាប់សិក្សាបន្តនៅថ្នាក់ឧត្តមសិក្សាឱ្យស្របតាមតម្រូវការទីផ្សារ និងបង្កើនចំណេះដឹងពីការចិញ្ចឹមកូនបែបវិជ្ជមាន។

១៣១. រៀបចំវេទិកាអប់រំផ្សព្វផ្សាយ ស្តីពីការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យសុខភាព ក្រោមប្រធានបទ "សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ" ដល់សិស្សានុសិស្សវិទ្យាល័យហ៊ុនសែនស្ទឹងត្រែង និងវិទ្យាល័យហ៊ុនសែនអូរពងមាន់ នៃខេត្តស្ទឹងត្រែងសរុបចំនួន ៤៣៩នាក់ (ស្ត្រី ២៨៤នាក់) គាំទ្រដោយអង្គការផ្លែនអន្តរជាតិ (PLAIN International) ក្នុងគោលបំណងបង្កើនការយល់ដឹងដល់យុវវ័យស្តីពីយេនឌ័រនិងសុខភាពបន្តពូជ សុខភាពផ្លូវភេទ ការថែទាំអនាម័យខ្លួនប្រាណពេលពេញវ័យ និងសេវាសុខភាពបន្តពូជសម្រាប់យុវវ័យនៅមូលដ្ឋានសុខាភិបាល ព្រមទាំងហានិភ័យនៃការមានផ្ទៃពោះនៅវ័យក្មេង។

១៣២. បានសម្របសម្រួលក្នុងការអភិវឌ្ឍ និងជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីជាមួយដៃគូជាតិ អន្តរជាតិ និងអង្គការសង្គមស៊ីវិល ដែលធ្វើឱ្យអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាពីដៃគូស្និទ្ធស្នាលមានការថយចុះគួរឱ្យកត់សម្គាល់គឺពី ២៩% ក្នុងឆ្នាំ២០១៤ មកនៅត្រឹម ២១% ក្នុងឆ្នាំ២០២១-២០២២ ដែលបានជះផលជាវិជ្ជមាន តាមរយៈការទទួលខុសត្រូវរួមគ្នារបស់ក្រសួង ស្ថាប័ន ការផ្តល់សេវាជំនួយផ្លូវច្បាប់ ទំនុកចិត្តរបស់អ្នកទទួលសេវា ការយល់ដឹងកាន់តែច្រើនជាងមុនថា អំពើហិង្សាលើស្ត្រី និងក្មេងស្រី គឺជាការបំពានសិទ្ធិមនុស្ស។ ដោយសារ លទ្ធផលដ៏គ្រចះគ្រចង់នេះ អ្នកជំនាញអន្តរជាតិបានវាយតម្លៃនិងទទួលស្គាល់ថា កម្ពុជាជាប្រទេសឈានមុខមួយក្នុងតំបន់អាស៊ាន ដែលមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី ហើយប្រទេសកម្ពុជាក៏ត្រូវបានរំលេចជាឧទាហរណ៍គំរូ នៅក្នុងរបាយការណ៍វាយតម្លៃក្នុងការអនុវត្តផែនការសកម្មភាពថ្នាក់តំបន់អាស៊ានលើការលុបបំបាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីផងដែរ។

១៣៣. ផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ និងផ្លូវចិត្តដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រសរុបចំនួន ១១៨ករណី។ បានបញ្ចប់ឯកសារផែនទីតម្រង់ទិសឆ្ពោះទៅការធ្វើវិសោធនកម្មច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ ដើម្បីធ្វើវិសោធនកម្មមាត្រាមួយចំនួន ឱ្យឆ្លើយតបនឹងបរិបទនៃសង្គមបច្ចុប្បន្ន ព្រមទាំងបាននឹងកំពុងដឹកនាំសម្របសម្រួលក្រុមការងារបច្ចេកទេសឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីរៀបចំផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៤ ឆ្នាំ២០២៤-២០៣០ (NAPVAW IV) ដើម្បីរួមគ្នាបន្តអនុវត្តការងារបង្ការទប់ស្កាត់ ផ្តល់កិច្ចអន្តរាគមន៍ និងផ្តល់កិច្ចការពារដល់ស្ត្រី និងក្មេងស្រីរងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ និងក្រុមជនងាយរងគ្រោះឱ្យកាន់តែមានប្រសិទ្ធភាព។

១៣៤. ក្រសួងកិច្ចការនារីក៏កំពុងរៀបចំផែនការសកម្មភាពជាតិ ស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់ ដើម្បីរួមគ្នាផ្តល់កិច្ចការពារកុមារនិងការលើកកម្ពស់សិទ្ធិកុមារ ជាពិសេសការចូលរួមបង្ការទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង កាត់បន្ថយហានិភ័យនៃការបោះបង់ការសិក្សា ដើម្បីធានាឱ្យមានភាពល្អប្រសើរឡើងនូវបរិយាកាសរៀនសូត្រ ល្អក្នុងសាលារៀន និងបង្កើតឱ្យមានជា

ឱកាស ជម្រើស ឯករាជ្យភាព ការពង្រឹងសិទ្ធិអំណាច ជាពិសេសក្មេងស្រីវ័យជំទង់អាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការការពារពីការរំលោភបំពានផ្លូវភេទ និងអំពើហិង្សាគ្រប់ទម្រង់។

១៣៥. គណៈកម្មការគ្រប់គ្រងមូលដ្ឋានសុខាភិបាលឯកជន និងស្រាវជ្រាវបាតុភាពមិនប្រក្រតីនៅមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន បានចុះត្រួតពិនិត្យ និងណែនាំមូលដ្ឋានសុខាភិបាលឯកជន ដើម្បីពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិទាក់ទងនឹងការបម្រើសេវាសុខាភិបាល និងការមិនអនុញ្ញាតឱ្យធ្វើការផ្សាំ ឬការជួញដូរកោសិកា ជាលិកា សរីរាង្គមនុស្ស កោសិកាមេជីវិតញី ឬឈ្មោល ដោយមិនមានការអនុញ្ញាតពីក្រសួងសុខាភិបាល រួមមាន៖ ភ្នំពេញ-១.មន្ទីរពេទ្យជប៉ុន សាន់រ៉ាយ ២.មន្ទីរពេទ្យអ័រឃើត កោះពេជ្រ និងបាត់ដំបង-៣.មន្ទីរពេទ្យ យី គួក និងមន្ទីរពេទ្យ កៃ ស៊ីនួន។

១៣៦. ក្នុងឆ្នាំ២០២៤ ការត្រួតពិនិត្យផលិតផលថ្នាំជក់សម្រេចលទ្ធផលចម្បងៗ រួមមាន៖ ការដាក់សារព្រមានសុខភាពជារូបភាព និងជាភាសាខ្មែរ លើកញ្ចប់ផលិតផលថ្នាំជក់ បាន ៨៩.២១% នៃគោលដៅផែនការ។ ការអនុវត្តអនុក្រឹត្យស្តីពីវិធានការហាមជក់ ឬបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ ឬទីសាធារណៈសម្រេចបាន៖ (១)បិទស្លាកហាមជក់បារីបាន ៨៧.៧២% នៃគោលដៅផែនការ (២)អនុវត្តបានពេញលេញតាមការកំណត់របស់អនុក្រឹត្យនៅកន្លែងធ្វើការ និងទីកន្លែងសាធារណៈបាន ៥១% និង (៣)គាំទ្រវិធានការហាមឃាត់ការជក់បារីនៅកន្លែងធ្វើការ ឬ កន្លែងសាធារណៈបាន ៩៧%។

១៣៧. ការហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីដោយឧស្សាហកម្មថ្នាំជក់។ ការប្តឹងក្រុមហ៊ុនចំនួន ៤ គឺ ក្រុមហ៊ុន Japan Tobacco International Co., Ltd (JTI), ក្រុមហ៊ុន Viniton Group Co., Ltd., ក្រុមហ៊ុន British American Tobacco Ltd., និងក្រុមហ៊ុន Korea Tobacco International Co., Ltd. ទៅតុលាការ ក្នុងនោះក្រុមហ៊ុន Viniton ត្រូវបានពិន័យជាប្រាក់ និងក្រុមហ៊ុន British American Tobacco Ltd., កំពុងរង់ចាំនីតិវិធីតុលាការបន្ត។

១៣៨. ការត្រួតពិនិត្យគ្រឿងស្រវឹង៖ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចបង្កើតក្រុមការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ដើម្បីកំណត់អំពីបែបបទ នីតិវិធី និងវិធានក្នុងការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ដើម្បីធានាសណ្តាប់ធ្នាប់សង្គម សុខុមាលភាពសាធារណៈ កាត់បន្ថយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច វប្បធម៌ និងប្រពៃណីជាតិ។ ក្រុមការងារបានដាក់ចេញនូវប្រកាសស្តីពីការកំណត់អំពីបែបបទ នីតិវិធី និងវិធានក្នុងការគ្រប់គ្រងការផ្សាយពាណិជ្ជកម្ម ផលិតផលគ្រឿងស្រវឹង ដែលមានគោលការណ៍ចំនួន ១៧ចំណុច ក្នុងនោះ មានកំណត់ទីតាំងដែលមិនអនុញ្ញាត ឱ្យផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹងនៅជុំវិញបរិវេណគ្រឹះស្ថានសិក្សា គ្រឹះស្ថានសុខាភិបាល គ្រឹះស្ថានសាសនា រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ អាកាសយានដ្ឋានអន្តរជាតិ ជាដើម និងការដាក់សារអប់រំលើរាល់ការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង និងគ្រប់គ្រងលើខ្លឹមសារ សកម្មភាព និងមធ្យោបាយនៃការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង។

១៣៩. ក្រសួងសុខាភិបាលបានឱ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីការផ្តល់ប្រឹក្សាលះបង់ការប្រើប្រាស់ផលិតផលគ្រឿងស្រវឹង និងបានផ្តល់ដល់មណ្ឌលសុខភាព ស្ថាប័នពាក់ព័ន្ធសម្រាប់អប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរបស់ប្រជាជន អំពីឥរិយាបថរស់នៅប្រកបដោយសុខុមាលភាពក្នុងការបង្ការជំងឺមិនឆ្លង ដែលបណ្តាលមកពីការប្រើប្រាស់ផលិតផលគ្រឿងស្រវឹង។

## ខ. ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ

១៤០. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) បានសហការជាអង្គការដែនដីមនុស្ស-ហូឡង់ដ៍ (TdH) ធ្វើការវាយតម្លៃពាក់កណ្តាលអាណត្តិនៃផែនការសកម្មភាព ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវតាមកុមារប្រព័ន្ធអនឡាញនៅកម្ពុជា ឆ្នាំ២០២១-២០២៥។

១៤១. បានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលជាដៃគូ ធ្វើការបណ្តុះបណ្តាលគ្រូបង្គោល កម្លាំងសេវាសង្គម និងក្រុមគោលដៅដែលជាឪពុកម្តាយ អាណាព្យាបាល អ្នកថែទាំ កុមារវ័យជំទង់ និង យុវជន ស្តីពីសិទ្ធិកុមារ ប្រព័ន្ធកិច្ចការពារកុមារ ការចូលរួមរបស់កុមារ និងសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញចំនួន២៥លើក ដែលមានអ្នកចូលរួមប្រមាណ ៩០០នាក់ នៅខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប ព្រៃវែង ក្រចេះ និងរាជធានីភ្នំពេញ។

១៤២. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងអង្គការឆាលហ្សានបានសហការរៀបចំសៀវភៅ និងសម្ភារៈឧបទេសសម្រាប់បណ្តុះបណ្តាលស្តីពី "សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ" សម្រាប់គ្រូបង្គោល និងអ្នកសម្របសម្រួល កម្លាំងសេវាសង្គម ឪពុកម្តាយ អាណាព្យាបាល អ្នកថែទាំ និងកុមារវ័យជំទង់ ដោយបានប្រកាសជាផ្លូវការឱ្យប្រើប្រាស់នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ ក្រោមអធិបតីភាពឯកឧត្តម **ឌា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

១៤៣. អគ្គលេខាធិការដ្ឋាន ក.ជ.ក. និងអង្គការឆាលហ្សាន កម្ពុជា បានសហការបង្កើតកម្មវិធីស្វ័យសិក្សាតាមទូរសព្ទស្តីពី "សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ (Swipe Safe app)" និងបានដាក់ឱ្យប្រើប្រាស់សាកល្បងទៅដល់កុមារវ័យជំទង់នៅស្រុកសង្កែ ខេត្តបាត់ដំបង និងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដើម្បីប្រមូលធាតុចូល និងធ្វើបច្ចុប្បន្នលើពាក្យពេចន៍ និងខ្លឹមសាររបស់កម្មវិធី (app) ។

១៤៤. ក្រសួងកិច្ចការនារីបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសេវាជំនួយតាមទូរស័ព្ទ HelpLine និង Chatbot ដែលមានឈ្មោះថា "កម្មវិធីសុវត្ថិភាពយើង (GBV Safe App)"។ កម្មវិធីនេះ គឺជាការអន្តរាគមន៍ថ្មីមួយក្នុងការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅក្នុងបរិបទឌីជីថល សម្រាប់ការផ្តល់ព័ត៌មាន និងលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ការស្វែងរកសេវាគាំទ្រ ការរាយការណ៍ ព័ត៌មានបញ្ជូនបន្ត និងការផ្តល់កិច្ចអន្តរាគមន៍ឱ្យបានទាន់ពេលវេលា។

## គ. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ

១៤៥. គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសហការជាមួយអង្គការដៃគូបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ តាមរយៈវេទិកាសាធារណៈការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ទិវាជាតិអន្តរសាសនាយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងតាមកម្មវិធីផ្សេងៗ សរុបចំនួន ១៩៥ ៦៣៧ លើក មានអ្នកចូលរួមសរុបចំនួន ៩ ៣៣៣ ៩៦៩នាក់ (ស្រីចំនួន ៤ ៨២៦ ២៧០នាក់) ធៀបនឹងឆ្នាំ២០២៣ មានចំនួន ៨ ៩២៧ ២៨៩នាក់ គឺមានការកើនឡើងចំនួន ៤០៦ ៦៨០នាក់ ស្មើនឹង ៤.៥៥%។ (សម្គាល់ចំនួននេះគិតត្រឹមអ្នកចូលរួមផ្ទាល់ ដោយមិនគិតអ្នកដែលបានទទួលព័ត៌មានតាមបណ្តាញសង្គម ការអប់រំបែបសាសនា ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀតទេ)។

១៤៦. អគ្គស្នងការដ្ឋាននគរបាលជាតិ៖ កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្តនៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរដែលបម្រុងឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ចំនួន៤៦លើក មនុស្សចំនួន ៨២៣នាក់ (ស្រី ២៣២នាក់ កុមារ១នាក់) ដោយបានធ្វើកិច្ចសន្យាការអប់រំណែនាំ និងឱ្យត្រឡប់ទៅភូមិកំណើតវិញ។ ក្នុងនោះមាន៖ ខេត្តបន្ទាយមានជ័យចំនួន ៣៩លើក មនុស្សចំនួន ៨០៣នាក់ (ស្រី ២២៣នាក់) ខេត្តបាត់ដំបងចំនួន៦លើក មនុស្សចំនួន ១៥នាក់ (ស្រី ៧នាក់ កុមារ ១នាក់) និងខេត្តព្រះវិហារចំនួន ១លើក មនុស្សចំនួន៥នាក់ (ស្រី ២នាក់)។

១៤៧. នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានធ្វើសម្ភាសន៍ជនបរទេសដែលបានដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចំនួន ២ ០៥៩នាក់ មានបុរសបរទេស ១ ៩១៨នាក់ និងស្ត្រីបរទេស ១៤១នាក់ មាន ៤០សញ្ជាតិ (ចិន ១ ០៧៣នាក់ (ស្រី២នាក់) កូរ៉េខាងត្បូង ៤២៥នាក់ (ស្រី ៥១នាក់) អាមេរិក ៣០១នាក់ (ស្រី ៥១នាក់) អូស្ត្រាលី ៤៩នាក់ (ស្រី១៥នាក់) កាណាដា ២៤នាក់ (ស្រី៤នាក់) បារាំង ៥៦នាក់ (ស្រី ២នាក់) ម៉ុងហ្គោលី១នាក់ ជប៉ុន ៩នាក់ (ស្រី១នាក់) អាឡឺម៉ង់៧នាក់ ថៃ៤នាក់ (ស្រី១នាក់) ម៉ាឡេស៊ី ២៤នាក់ (ស្រី ៤នាក់) ក្រិច ២នាក់ វៀតណាម ១៧នាក់ (ស្រី៤នាក់) អង់គ្លេស ៨នាក់ បែលហ្សិក ៦នាក់ ទួកគី ៧នាក់ ឥណ្ឌូនេស៊ី ១០នាក់ (ស្រី ២នាក់) មីយ៉ាន់ម៉ា ១នាក់ អ៊ីស្រាអែល ៣នាក់ កូឌីវ័រ ១នាក់ ម៉ិចស៊ិចកូ ១នាក់ ហ្វីលីពីន ២នាក់ ម៉ារ៉ុក ១នាក់ អាហ្វ្រិកខាងត្បូង ១នាក់ ដាណាម៉ាក ២នាក់ ហូឡង់១នាក់ អេស្តូនី១នាក់ ហ្វាំងឡង់១នាក់ អូទ្រីស ១នាក់ ស្វីស១នាក់ នីហ្សេរីយ៉ា៣នាក់ ប៉ូឡូញ២នាក់ បង់ក្លាដេស១នាក់ ញូហ្សេលែន៣នាក់ នេប៉ាល់២នាក់ រុស្ស៊ី២នាក់ (ស្រី១នាក់) ឆេក១នាក់ ឡាវ៣នាក់ សឹង្ហបុរី១នាក់ លីប៊ី១នាក់)។ ក្នុងនោះបានវាយតម្លៃបញ្ជូនឱ្យក្រុមការងារច្រកចេញ-ចូលតែមួយបានចំនួន ១ ៧៦៥នាក់ ស្ត្រីបរទេស ១៣៧នាក់។

## ឃ. គ្រឿងញៀន

១៤៨. ផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ទាំង៩លើកកន្លងមក (២០១៧-២០២៤) អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់បានអនុវត្ត និងបំពេញតួនាទីយ៉ាងសកម្មលើកិច្ចការសំខាន់ៗមួយចំនួនដូចជា ជំរុញការផ្សព្វផ្សាយអប់រំយ៉ាងផុលផុស តាមគ្រប់មធ្យោបាយ គ្រប់រូបភាព និងដល់ទីកន្លែងសរុបចំនួន ៧៥៦ ៩៣៤ លើក ដែលមានអ្នកចូលរួមនិងទទួលសារអប់រំក្នុងម្នាក់អាចទទួលសារអប់រំលើសពីម្តង (តួលេខបូកយោងសរុបចំនួន ៣២ ៨៥៥ ២២៤ អង្គ/នាក់)។ ជាពិសេសក្នុងឆ្នាំ២០២៤កន្លងមកនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានសហការរៀបចំការប្រកួតកីឡាបាល់ទាត់មិត្តភាពក្រោមមូលបទ "រួមគ្នាដើម្បីសប្បុរសធម៌ និងប្រយុទ្ធប្រឆាំងគ្រឿងញៀន" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងវេទិកាផ្សព្វផ្សាយអប់រំបញ្ហាគ្រឿងញៀនដ៏ធំមួយគឺ "ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦មិថុនា២០២៤" ដែលត្រូវបានការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងបទឧក្រិដ្ឋ(UNODC) ទទួលស្គាល់និងកោតសរសើរចំពោះកម្ពុជាជាប្រទេសគំរូ ក្នុងការរៀបចំទិវាអន្តរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការបង្កើតកម្មវិធីទូរស័ព្ទដៃ NoDrug ជាដើម។

## ង. ការទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនិងការងារដោយបង្ខំ

១៤៩. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះអធិការកិច្ចការងារចំនួន ១០ ៤៨៤លើក ដែលក្នុងនោះការចុះនៅកន្លែងធ្វើការចំនួន ៥៤៧លើក (រួមមាន៖ ការចុះអធិការកិច្ចការងារសាមញ្ញចំនួន ១១៨លើក ការ

ចុះធ្វើអធិការកិច្ចពិសេសដោយមិនជូនដំណឹងចំនួន ៣១៩លើក និងការចុះអធិការកិច្ចតាមដាន ការដាក់ពិន័យចំនួន ១១០លើក) និងការធ្វើស្វ័យអធិការកិច្ចការងារចំនួន ៩ ៩៣៧លើក។

១៥០. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ ដោយបានធ្វើអធិការកិច្ចការងារចំនួន ១០ ៤៨៤ លើក និងបានចុះត្រួតពិនិត្យលក្ខខណ្ឌការងារ និងកំណត់អត្តសញ្ញាណកម្មករនិយោជិតវ័យក្មេង មុនចេញលិខិតអនុញ្ញាតឱ្យប្រើប្រាស់កម្មករនិយោជិតវ័យក្មេងតាមការស្នើសុំរបស់ក្រុមហ៊ុនចំនួន ២លើក ព្រមទាំងបានដកហូតទប់ស្កាត់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិ-ឧស្សាហកម្មចំនួន ៤០០នាក់ (ស្រី២០០នាក់) ក្នុងខេត្តគោលដៅចំនួន ៧ គឺ ខេត្តកណ្តាល សៀមរាប ត្បូងឃ្មុំ ព្រៃវែង បាត់ដំបង បន្ទាយមានជ័យ និងខេត្តពោធិ៍សាត់។ ក្រសួងក៏បានចុះផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារចំនួន ៣១២លើក មានអ្នកចូលរួមចំនួន ៨ ៤៤៥នាក់ (ស្រី ៣ ៥៩០នាក់) និងបានផលិតវីដេអូ ចំនួន២ (១)ស្តីពីការចូលរួមបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅកម្ពុជា និង(២)ចម្រៀងស្តីពីការអបអរសាទរទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា ព្រមទាំងបានផ្សព្វផ្សាយតាមបណ្តាញទំនាក់ទំនងសង្គម ផេកផ្លូវការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផេកសម្តេចមហាបវរធិបតី ដោយមានអ្នកចូលទស្សនាសរុបចំនួន ៨៦ ៧១៦នាក់ និងការចែករំលែកបន្តចំនួន ១៤ ៨៤១នាក់។

**ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារដែលចូលរួមសកម្មភាពសេដ្ឋកិច្ច**

| ល.រ | សកម្មភាពការងារ | ឯកតា | ២០២២ | ២០២៣ | បម្រែបម្រួល (%) |
|---|---|---|---|---|---|
| ១ | កិច្ចអន្តរាគមន៍ស្ទួល | សរុប (នាក់) | ៤០០ | ៤០០ | 0.00% |
| | | ស្រី (នាក់) | ២០៤ | ២០០ | -១.៩៦% |
| ២ | ផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ | លើក/ទីតាំង | ៤២ | ៣១២ | ៦៤៣% |
| | | សរុប (នាក់) | ២,៦៦៨ | ៨,៤៤៥ | ២១៧% |
| | | ស្រី (នាក់) | ១,២២៦ | ៣,៥៩០ | ១៩៣% |
| ៣ | បណ្តុះបណ្តាលស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ | វគ្គ | ១ | ២៣ | ២២០០% |
| | | សរុប (នាក់) | ៦៤ | ៥៥៨ | ៧៧១.៨៨% |
| | | ស្រី (នាក់) | ៤០ | ២១៦ | ៤៤០% |

ប្រភព៖ នាយកដ្ឋានការងារកុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ៥.២.ការអន្តរាគមន៍ និងឆ្លើយតប

### ក. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ

១៥១. នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្ស និងអំពោះធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៩៨ករណី ធៀបនឹងឆ្នាំ២០២៣ មានចំនួន ១៦៤ករណី កើនឡើងចំនួន៣៤ករណី ស្មើនឹង ២០.៧៣% និងបានឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ២៧៣នាក់/១៩៤នាក់ (ស្រី ៣៩នាក់ អនីតិជន ៣១នាក់) និងជនបរទេសចំនួន ៣០នាក់ (ស្រី១នាក់)

(ចិន២៣នាក់ អាមេរិក១នាក់ ឥណ្ឌា៣នាក់ វៀតណាម២នាក់ ហ្វីលីពីន១នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ៥២៣នាក់/៤៧៦នាក់ (ស្រី ៤០០នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ ១៤៥នាក់ អាយុ១៥-១៧ឆ្នាំ ៨៥នាក់ និងអាយុពី១៨ឆ្នាំឡើង ២៩៣នាក់ និងបានប្រគល់ឱ្យមន្ទីរសង្គមកិច្ច ២៧១នាក់ អន្តោប្រវេសន៍ ៨២នាក់ និងប្រគល់ឱ្យគ្រួសារ ១៧០នាក់ ក្នុងនោះចែកជា៖

១៥២. **ករណីអំពើជួញដូរមនុស្ស៖** បង្ក្រាបបាន ៥៣ករណី/២៤ករណី (កើន ២៩ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៩៦នាក់ (ស្រី ១២នាក់ អនីតិជន ២នាក់ (ស្រី១នាក់)) និងជនបរទេស ១១នាក់ (អាមេរិក១នាក់ ឥណ្ឌា៣នាក់ ចិន៥នាក់ វៀតណាម២នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ១៥៨នាក់ (ស្រី ៣៩នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ ១១នាក់ (ស្រី៣នាក់), អាយុ១៥-១៧ឆ្នាំ ៩នាក់ (ស្រី៧នាក់) និងអាយុ១៨ឆ្នាំឡើង១៣៨នាក់ (ស្រី៣០នាក់) និងបានប្រគល់ឱ្យមន្ទីរសង្គមកិច្ចចំនួន ៣៦នាក់ អន្តោប្រវេសន៍ ៨២នាក់ និងប្រគល់ឱ្យគ្រួសារ ៤០នាក់។

១៥៣. **ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ៖** បង្ក្រាបបាន ១៤៥ករណី/១៤០ករណី (កើន៥ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៧៧នាក់ (ស្រី២៧នាក់ អនីតិជន២៩នាក់ (ស្រី១នាក់)) និងជនបរទេស៧នាក់ (ចិន៦នាក់ វៀតណាម១នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ៣៦៥នាក់ (ស្រី ៣៦០នាក់) មាន៖ អាយុក្រោម១៥ឆ្នាំ ១៣៤នាក់ (ស្រី ១២៩នាក់) អាយុ ១៥-១៧ឆ្នាំ ៧៦នាក់ (ស្រី៧៦នាក់) និងអាយុ១៨ឆ្នាំឡើង ១៥៥នាក់ (ស្រី) និងបានប្រគល់ឱ្យមន្ទីរសង្គមកិច្ច ២៣៥នាក់ និងប្រគល់ឱ្យគ្រួសារ ១៣០នាក់)។

១៥៤. **ករណីស៊ីឈ្នួលពពោះជំនួសដើម្បីជួញដូរមនុស្ស (ទារក)៖** បង្ក្រាបបាន ១ករណី ឃាត់ខ្លួនមនុស្សសរុប ចំនួន ២៥នាក់ (ស្រី) មានជនជាតិហ្វីលីពីន ២០នាក់ វៀតណាម៤នាក់ ជនជាតិខ្មែរ១នាក់ និងបានកំណត់អត្តសញ្ញាណរកឃើញ ជនសង្ស័យ ចំនួន ១៣នាក់ ជាជនជាតិហ្វីលីពីន ដែលបានដាក់មេជីវិតឱ្យពពោះជំនួសដើម្បីជួញដូរទារក ដោយបានកសាងសំណុំរឿង បញ្ជូនទៅសាលាដំបូងខេត្តកណ្តាល។ ចំណែកស្ត្រីជនជាតិហ្វីលីពីន៧នាក់ វៀតណាម៤នាក់ ត្រូវបានបណ្តេញចេញ និងស្ត្រីជនជាតិខ្មែរមួយរូបត្រូវតុលាការចោទពីបទសមគំនិតក្នុងអំពើលក់-ដូរមនុស្ស។

## ខ. គ្រឿងញៀន

១៥៥. ជំរុញការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ ដោយបានបិទទីតាំងអាជីវកម្មសរុបចំនួន ៤៨ កន្លែង និងបានបើកប្រតិបត្តិការបង្ក្រាបបទល្មើស គ្រឿងញៀនដោយឃាត់ខ្លួនជនសង្ស័យជាច្រើនម៉ឺននាក់ និងចាប់យកគ្រឿងញៀនគ្រប់ប្រភេទមានទម្ងន់ប្រមាណ ៤២ ៨៤៨ គីឡូក្រាម និងសារធាតុគីមីផ្សំប្រមាណ ៥៩៦ ៣៩៩ គីឡូក្រាម រួមទាំងរឹបអូសមធ្យោបាយ សម្ភារៈ និងវត្ថុតាង ទ្រព្យសម្បត្តិ និងបង្កកអចលនទ្រព្យជាច្រើនកន្លែង។ ក្នុងនោះសមត្ថកិច្ចបានស្រាវជ្រាវរកឃើញ និងបង្ក្រាបបទល្មើសគ្រឿងញៀនដែលមានអង្គការចាត់តាំងចំនួន ៦២៧ ករណី ឃាត់ខ្លួនឧក្រិដ្ឋជនមេខ្លោង ១៩៥ នាក់ និងបណ្តាញខ្សែរយៈ ១ ៥៥៣ នាក់ កសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់។

១៥៦. ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តជំរុញការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ បប ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបានជាប់ជាប្រចាំក្នុងគោលបំណងលើក

កម្ពស់ជំនឿទុកចិត្ត ប្រសិទ្ធភាពការងារ និងអភិបាលកិច្ចល្អ ព្រមទាំងពង្រឹងគុណភាពធនធានមនុស្ស ប្រកបដោយភាពស្អាតស្អំនិងភាពជាគំរូក្នុងស្ថាប័នរដ្ឋទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

### គ. បណ្តាញទូរសព្ទទាន់ហេតុការណ៍ និងការរាយការណ៍តាមអនឡាញ

១៥៧. បច្ចុប្បន្ននេះ កម្ពុជាមានបណ្តាញទូរស័ព្ទចំនួន ២ខ្សែសំខាន់ៗដែលផ្តល់សេវាជួយកុមារ ក្នុងនោះមានបណ្តាញទូរសព្ទទាន់ហេតុការណ៍ ១២៨៨ របស់នគរបាលជាតិ និងបណ្តាញទូរជំនួយកុមារ ១២៨០ របស់អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា។ ក្រៅពីបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ទាំងពីរនេះ ក៏មានបណ្តាញទូរស័ព្ទទាន់ហេតុការណ៍មួយចំនួនផ្សេងទៀត ផ្តល់ដោយអង្គការដៃគូដែលធ្វើការពាក់ព័ន្ធនឹងកុមារផងដែរ។

១៥៨. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានដាក់ចេញឆានែលតេលេក្រាម ដើម្បីឆ្លើយតបរាល់សំណួរពាក់ព័ន្ធនឹងវិស័យការងារ ដូចជា https://t.me/KhmerWorkerChat (សម្រាប់កម្មករនិយោជិត) និង https://t.me/EmployerChat (សម្រាប់និយោជក)។ រាល់ករណីសង្ស័យប្រើប្រាស់ពលកម្មកុមារ សាធារណជនអាចទំនាក់ទំនង ឬរាយការណ៍តាមរយៈខ្សែទូរស័ព្ទទាន់ហេតុការណ៍លេខ១២៨៦ ឬ១២៩៧ និងប្រអប់បណ្តឹងអនាមិករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់អន្តរាគមន៍ក្នុងរយៈពេល ២៤ ម៉ោង។

## ៥.៣. កិច្ចការយុត្តិធម៌

### ក. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ

១៥៩. លទ្ធផលចំណាត់ការផ្តន្ទាទោសៈ ក្រុមការងារកិច្ចការយុត្តិធម៌ នៃ គ.ជ.ប.ជ. ដឹកនាំដោយក្រសួងយុត្តិធម៌ តាមរយៈទិន្នន័យទទួលបានពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជាលទ្ធផលតាមដំណាក់កាលទាំង៣ នៃនីតិវិធីតុលាការ មានដូចខាងក្រោមៈ

១៦០. **ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្តៈ** សំណុំរឿងសរុបមានចំនួន ៤០០ ក្នុងនោះ (សំណុំរឿងចាស់មានចំនួន ២០សំណុំរឿង និងសំណុំរឿងថ្មី ចំនួន ៣៨០សំណុំរឿង)ៈ ជនរងគ្រោះសរុបមានចំនួន ៤៣៥នាក់ (ស្រី ២៧៣នាក់) ក្នុងនោះ នីតិជនសរុបចំនួន ១០០នាក់ (ស្រី ៤៨នាក់) អនីតិជន ២៤៦នាក់ (ស្រី ១៩០នាក់) និងជនបរទេស ៨៩នាក់ (ស្រី ៣៥នាក់)។ ជនល្មើសសរុបចំនួន ៦៨៦នាក់ (ស្រី ៥៨នាក់) ក្នុងនោះៈ នីតិជនសរុបចំនួន ៤៤៥នាក់ (ស្រី៣៥នាក់) អនីតិជន ៨២នាក់ (ស្រី៣នាក់) អញ្ញាតជន ១២នាក់ និងជនបរទេស ១៥៩នាក់ (ស្រី២០នាក់)។

១៦១. **ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្តៈ** សរុបមានចំនួន ៤៦៣សំណុំរឿង ក្នុងនោះ (សំណុំរឿងចាស់មានចំនួន ១៥៤សំណុំរឿង និង សំណុំរឿងថ្មី ៣០៩សំណុំរឿង)ៈ ជនរងគ្រោះសរុបចំនួន ៥២៦នាក់ (ស្រី ៣៦១នាក់) ក្នុងនោះ នីតិជនសរុបចំនួន ១៥៣នាក់ (ស្រី ៨៤នាក់) អនីតិជន ២៧៥នាក់ (ស្រី២៤០នាក់) និងជនបរទេស ៩៨នាក់ (ស្រី ៣៧នាក់)។ ជនត្រូវចោទសរុបចំនួន ៨៩៩នាក់ (ស្រី ៧៤នាក់) ក្នុងនោះ នីតិជនសរុបចំនួន ៦៩៦នាក់ (ស្រី ៥១នាក់) អនីតិជន ៧៥នាក់ (ស្រី ២០នាក់) និងជនបរទេស ១២០នាក់ (ស្រី ៣នាក់)។

១៦២. **ដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត៖** សរុបមានចំនួន ៣២២សំណុំរឿង ក្នុងនោះ (សំណុំរឿងចាស់មានចំនួន ៦៩សំណុំរឿង និងសំណុំ រឿងថ្មី ២៥៣សំណុំរឿង)៖ ជនរងគ្រោះសរុបមានចំនួន ៣៣៧នាក់ (ស្រី២៩៥នាក់) ក្នុងនោះ នីតិជនសរុបចំនួន ៨២នាក់ ស្រី ៣៣នាក់ អនីតិជន ២២១នាក់ (ស្រី២១២នាក់) និងជនបរទេស ៣៤នាក់ (ស្រី១៨នាក់)។ ជនជាប់ចោទសរុបមានចំនួន ៤២៤នាក់ (ស្រី ៨៥នាក់) ក្នុងនោះ នីតិជនសរុបចំនួន ៣០៩នាក់ ស្រី ៦៩ នាក់ អនីតិជន ៦៦នាក់ (ស្រី៣នាក់) និងជនបរទេស ៤៩នាក់ (ស្រី១៣នាក់)។

១៦៣. **សាលាដំបូងខេត្តកណ្ដាលបានជំនុំជម្រះករណីស៊ីឈ្នួលពពោះជំនួសដើម្បីលក់-ដូរមនុស្ស (ទារក)** ស្ត្រីជនជាតិហ្វីលីពីន ចំនួន ១៣នាក់ ដោយបានប្រកាសសាលក្រមអនុវត្តទោសដាក់ពន្ធនាគារកំណត់រយៈពេល ៤ឆ្នាំ តែអនុវត្តទោសក្នុងពន្ធនាគាររយៈពេល ២ឆ្នាំ ទោសដែលនៅសល់ត្រូវព្យួរធម្មតា (តាមបញ្ញត្តិមាត្រា២៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា១៦ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ)។

## ៥.៤. ការផ្តល់ជំនួយ និងសេវាគាំទ្រ

### ក. ការងារសង្គមកិច្ច

១៦៤. ការងារសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ៖ បានផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់គ្រួសាររងគ្រោះដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយ ដោយយថាហេតុនៅតាមសហគមន៍ សរុបចំនួន ៣៤ ៨៩៤គ្រួសារ។

១៦៥. ការងារជនអនាថា និងជនផ្ទុកមេរោគអេដស៍៖ បានផ្តល់សេវាពិគ្រោះយោបល់ ដោះស្រាយ ទប់ស្កាត់ និងការពារដល់ជនអនាថាសរុបចំនួន ១ ៣២១នាក់ និងបានធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ ២ ២៨០នាក់។ បានប្រឹក្សាយោបល់ ថែទាំ គាំទ្រជនរងគ្រោះ ដែលរងផលប៉ះពាល់ដោយសារផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍ចំនួន ២៥០នាក់។

១៦៦. មជ្ឈមណ្ឌលជនវិបល្លាសស្មារតីបានទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅសរុបចំនួន ១៥៤នាក់ និងបានសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញចំនួន ៥នាក់។ បើគិតពីឆ្នាំ២០២១មក មានជនវិបល្លាសស្មារតីសរុបចំនួន ៣៧៣នាក់ កំពុងស្នាក់នៅព្យាបាល។

១៦៧. លើកកម្ពស់សេវាស្តារនីតិសម្បទាអនីតិជន ដោយបានធ្វើបច្ចុប្បន្នភាពទិន្នន័យអនីតិជនទំនាស់នឹងច្បាប់នៅតាមពន្ធនាគារ មណ្ឌលអប់រំកែប្រែរាជធានី ខេត្ត និងមណ្ឌលយុវនីតិសម្បទា មានអនីតិជនសរុបចំនួន ៤ ០៨៧នាក់ ស្រី ១៣៦នាក់ (ទណ្ឌិត ៦៩៣នាក់ ស្រី ១០នាក់ ពិរុទ្ធជន ៣ ៣៩៤នាក់ ស្រី ១២៦នាក់)។ បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពការងារយុត្តិធម៌អនីតិជន ដល់ភ្នាក់ងារសង្គមកិច្ចរាជធានី ខេត្ត។ ទន្ទឹមនេះ ក៏បានអនុវត្តកម្មវិធីបង្វែរអនីតិជនទំនាស់នឹងច្បាប់ ដោយក្នុងនោះរួមមាន៖ (១)ដំណាក់កាលរៀបចំរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់នឹងច្បាប់ ចំនួន ១៩២ករណី។ (២)ដំណាក់កាលចូលរួមស្តាប់ចម្លើយក្នុងសវនាការចំនួន ៥៧៥ករណី។ (៣)ដំណាក់កាលបង្វែរចំនួន ៣៧ករណី និងវិធានការផ្សេងទៀតក្រៅពីឃុំខ្លួនអនីតិជនទំនាស់នឹងច្បាប់ចំនួន ៤០ករណី។ (៤) សមាហរណកម្មអនីតិជនចំនួន ១៧ករណី។ (៥)បិទករណីអនីតិជនចំនួន ៥៥ករណី (បង្វែរ ១១ករណី)។

(៦)អនីតិជនទទួលបានការបន្ធូរបន្ថយទោស និងលើកលែងទោសចំនួន ១១នាក់ ក្នុងឱកាសពិធីបុណ្យឯករាជ្យជាតិ និងព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីត និងសំពះព្រះខែ អកអំបុក។

១៦៨. កិច្ចការពារ និងលើកកម្ពស់សុខុមាលភាពជនពិការៈ អត្រាជនមានពិការភាពបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារកំណើនជនចាស់ជរា ជំណពូជ គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដោយសារមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ អំពើហិង្សា គ្រោះមហន្តរាយ ជំងឺខ្វះអាហារូបត្ថម្ភ និងមូលហេតុផ្សេងៗទៀតដែលប្រែប្រួលតាមសម័យកាល។ យោងតាមការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ២០២១ របស់វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការបានបញ្ជាក់ថា អត្រាជនមានពិការភាពមានប្រមាណ ៥.៣% ស្មើនឹង ៨៧២ ៥២៧នាក់ នៃចំនួនប្រជាជនសរុប។ អត្រានេះមានការកើនឡើង បើប្រៀបធៀបនឹងការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ២០១៩ ដែលមានអត្រាជនមានពិការភាពត្រឹមតែចំនួន ៦៨៩ ៤៥៧ នាក់ ស្មើ ៤.៩% ប៉ុណ្ណោះ។

១៦៩. ពីឆ្នាំ២០២០-២០២៤ ក្រសួង ស.អ.យ. បានផលិត និងបោះពុម្ពប័ណ្ណសមធម៌សម្រាប់ជនមានពិការភាពចំនួន ២៨៧ ៥៩៩នាក់ ស្រី ១៧៣ ១៥៨នាក់។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ២០២អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីអត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន។ ជនមានពិការភាពចំនួន ៣៥៣ ៥៧៣នាក់ ស្រី ១៧៣ ១៥៨នាក់ ត្រូវបានកំណត់អត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន តាមការស្នើសុំដើម្បីទទួលបានបណ្ណសម្គាល់ពិការភាព។

១៧០. ជនមានពិការភាពចំនួន ៤៩ ០២១នាក់ បានចុះឈ្មោះចូលក្នុងកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនមានពិការភាពចំនួន ៣០ ១៣៥នាក់ បានចុះឈ្មោះដើម្បីទទួលផលពីកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ហើយជនមានពិការភាពចំនួន ៥៦៥នាក់ (ជនមានពិការភាពនៃគ្រួសារក្រីក្រចំនួន ៤៤៥នាក់ និងជនមានពិការភាព នៃគ្រួសាររងហានិភ័យចំនួន ១២០នាក់) បានចុះឈ្មោះចូលរៀនវគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈដោយឥតគិតថ្លៃ និងទទួលប្រាក់ឧបត្ថម្ភពីរដ្ឋ គិតត្រឹមថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤។

### ខ.អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ

១៧១. តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ទាំងក្នុងប្រទេស និងពីក្រៅប្រទេស សរុបចំនួន ៤៤៣នាក់ (ប្រុស១៣៤នាក់ ស្រី២៧៦នាក់) អនីតិជន ៣៣នាក់ (ប្រុស៣នាក់ ស្រី៣០នាក់)។ ក្រោយពីបានកំណត់អត្តសញ្ញាណដោយមន្ត្រីនគរបាលយុត្តិធម៌ បានរកឃើញជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ៤០៥នាក់ (ប្រុស១២១នាក់ ស្រី២៥៦នាក់) អនីតិជន ២៨នាក់(ប្រុស ២នាក់ ស្រី២៦នាក់) ។

១៧២. ការស្ដារនីតិសម្បទា បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងបុគ្គលសង្ស័យថារង គ្រោះដោយអំពើជួញដូរមនុស្ស ទទួលសេវាស្នាក់នៅ និងការស្ដារនីតិសម្បទា នៅមណ្ឌលរបស់អង្គការដៃគូ សរុប ៣៥១នាក់ (ស្រី ១៩៩នាក់) អនីតិជន ២១នាក់ (ស្រី១៨នាក់) ដែលមានអង្គការការីតាសកម្ពុជា ១៨២នាក់(ស្រី ៥៣នាក់ អនីតិជន៥នាក់) អង្គការអាដហុក ៧នាក់ (ស្រី) អង្គការរតនៈអ៊ីនធើណេសណល ៣៣នាក់ (ស្រី ៣១នាក់ អនីតិជន១នាក់) អង្គការមូលនិធិហាការអន្តរជាតិ ២៩នាក់ (ស្រី ២៨នាក់ អនីតិជន ១នាក់) អង្គការសម្ពន្ធចាប់ដៃ ២៧នាក់ (ស្រី ១៨នាក់ អនីតិជន ៩នាក់) អង្គការមូលនិធិ

A21 ១២នាក់ (ស្រី៥នាក់ អនីតិជន១នាក់) អង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ (CWCC) ៤២នាក់ (ស្រី៤១នាក់ អនីតិជន១នាក់) អង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជា ១១នាក់ (ស្រី១០នាក់ អនីតិជន១នាក់) អង្គការម៉ារីស៊ុ១នាក់(ស្រី) អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ១នាក់ (ប្រុស) អង្គការមេត្រីអន្តរជាតិ ១នាក់ អង្គការសង់ត្រាល ១នាក់ (ស្រី) មជ្ឈមណ្ឌលថែទាំនិងស្តារនីតិសម្បទាជនវិបល្លាសស្មារតី ២នាក់(ស្រី) និងមណ្ឌលស្តារគ្រឿងញៀន ២នាក់(ស្រី)។

១៧៣. ក្រសួងកិច្ចការនារីៈ ក្រុមការងារជំនាញនាយកដ្ឋានការពារផ្លូវច្បាប់ បានផ្តល់សេវាប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្លូវចិត្ត និងអន្តរាគមន៍ដល់ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ការគំរាមចែកចាយរូបអាសអាភាសបានចំនួន ៨ករណី មានជនល្មើស ៩នាក់ ត្រូវតុលាការសាលាដំបូងសម្រេចផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលពី ៥-៧ឆ្នាំ និងសងសំណងទៅដល់ជនរងគ្រោះសរុបចំនួន ១០៦ 000 000រៀល។

១៧៤. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ បានសហការជាមួយអង្គភាពពាក់ព័ន្ធ និងអង្គការដៃគូផ្តល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយរៀបចំបណ្តឹងទាមទារសំណងដល់ជនរងគ្រោះចំនួន ៧នាក់ សរុបជាទឹកប្រាក់ទទួលចន្លោះ ៨ លានរៀល និង ២០០ លានរៀល។

១៧៥. បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូសមាហរណកម្មជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុប ២៦នាក់ (ស្រី ២៥នាក់) ជាករណីធ្វើអាជីវកម្មផ្លូវភេទ ២៥នាក់ (ស្រី) និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ១នាក់។

១៧៦. បានធ្វើមាតុភូមិនិវត្តន៍ជនបរទេសទៅប្រទេសដើមវិញមានចំនួន ១៣៨នាក់ (ស្រី ២៤នាក់) អនីតិជន ១នាក់ (ស្រី១នាក់) ជាករណីជួញដូរកម្លាំងពលកម្មៈ ក្នុងនោះមានជនជាតិ ហ្វីលីពីន ២៨នាក់ (ស្រី១៣នាក់) ថៃ ៤នាក់ (ស្រី១នាក់) ចិន ១៩នាក់ (ស្រី១នាក់) វៀតណាម ២០នាក់ (ស្រី១០នាក់) ឥណ្ឌា ២៣នាក់ (ស្រី១នាក់) បង់ក្លាដេស៤១នាក់ (ប្រុស) ស្រីលង្កា១នាក់ ម៉ាឡេស៊ី១នាក់(ប្រុស) និងឥណ្ឌូនេស៊ី១នាក់ (ប្រុស)។

១៧៧. បានតាមដានករណីជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រោយពីធ្វើសមាហរណកម្មទៅសហគមន៍វិញចំនួន ១២១នាក់ (ប្រុស១៨នាក់ ស្រី៩៩នាក់ អនីតិជន៥នាក់) ជាករណីអាជីវកម្មផ្លូវភេទ ៧៨នាក់ (ស្រី) និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ៤៣នាក់ (ប្រុស ១៨នាក់ ស្រី ២១នាក់ អនីតិជន ៤នាក់)។

១៧៨. បានបិទករណី នៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ២៧នាក់ (ស្រី ២១នាក់) មានករណីធ្វើអាជីវកម្មផ្លូវភេទ ១៦នាក់ (ស្រី) និងរកេងប្រវ័ញ្ចកម្លាំងពលកម្ម ១១នាក់ (ស្រី ៥នាក់)។

១៧៩. បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាចំនួន ២០៨នាក់។

១៨០. បានទទួលជនរងគ្រោះដែលនិរទេសពីប្រទេសថៃចំនួន ៧ ៣៥០នាក់ និងបានសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះ និងបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ និងបានធ្វើសមាហរណកម្មចំនួន ៨៥នាក់។

១៨១. បានទទួលជនរងគ្រោះ និងងាយរងគ្រោះស្នាក់នៅក្នុងមណ្ឌលសំចតសង្គមកិច្ចសរុបចំនួន ១ ១៤៩នាក់ ស្រី ៣៧៧នាក់ រួមមាន មណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញចំនួន ៤៧៦នាក់ មណ្ឌលសំចតសង្គមកិច្ចខេត្តបាត់ដំបងចំនួន ២៩៥នាក់ មណ្ឌលសំចតសង្គមកិច្ចខេត្តសៀមរាបចំនួន ២៩៣នាក់ និងមណ្ឌលសំចតប៉ោយប៉ែតចំនួន ៨៥នាក់។

## គ. គ្រឿងញៀន

១៨២. អ្នកញៀនគ្រឿងញៀនសល់ក្នុងឆ្នាំ២០២៣ នៅតាមមជ្ឈមណ្ឌល មណ្ឌល មានចំនួន ៥ ៧០១នាក់ និងចូលថ្មីក្នុងឆ្នាំ២០២៤ មានចំនួន ១៨ ១០២នាក់ សរុបមានចំនួន ២៣ ៨០៣នាក់ ក្នុងនោះ កំពុងបន្តព្យាបាល និងស្តារនីតិសម្បទានៅក្នុងមជ្ឈមណ្ឌល មណ្ឌលមានចំនួន ៨ ៦២៣នាក់ និងបានធ្វើសមាហរណកម្មចូលក្នុងគ្រួសារ និងសហគមន៍វិញសរុបចំនួន ១៥ ១៨០នាក់។

១៨៣. ដោយឡែក អគ្គនាយកដ្ឋានពន្ធនាគារត្រូវបន្តយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងពន្ធនាគារនិងមណ្ឌល អប់រំកែប្រែឱ្យបានម៉ឺងម៉ាត់ ហ្មត់ចត់ ប្រកបដោយស្មារតីប្រុងប្រយ័ត្ននិងទទួលខុសត្រូវខ្ពស់ ដោយមិនត្រូវឱ្យមានការលួចនាំចូលគ្រឿងញៀនផ្តល់ឱ្យពិរុទ្ធជនឬទណ្ឌិត និង/ឬមានទំនាក់ទំនងពីក្នុងពន្ធនាគារចេញមកខាងក្រៅពាក់ពន្ធ័នឹងបទល្មើសគ្រឿងញៀន។ ជាមួយគ្នានោះ ត្រូវពិចារណាលើវិធានការក្នុងការគ្រប់គ្រងជនល្មើស ដែលពាក់ព័ន្ធនឹងគ្រឿងញៀនឬសេពគ្រឿងញៀន ដាច់ដោយឡែកពីទណ្ឌិតឬពិរុទ្ធជនដទៃទៀត។

១៨៤. អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកទឹកចិត្តនិងគាំទ្រ ដើម្បីធានានិរន្តរភាពនៃកិច្ចដំណើរការរបស់មជ្ឈមណ្ឌលរដ្ឋ ឯកជន និង អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងគិតគូរបង្កើតប្រព័ន្ធទិន្នន័យបែបឌីជីថលដើម្បីតាមដាននិងគ្រប់គ្រងអ្នកញៀន គ្រឿងញៀនឱ្យមានភាពច្បាស់លាស់ នៅតាមមជ្ឈមណ្ឌលជាតិនិងមណ្ឌលព្យាបាលនិងស្តារនីតិសម្បទារបស់រដ្ឋ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល និងនៅពេលធ្វើសមាហរណកម្មចូលក្នុងសហគមន៍វិញ។

១៨៥. ក្រសួងសុខាភិបាល ត្រូវខិតខំលើកកម្ពស់សមត្ថភាព វិជ្ជាជីវៈក្នុងការបន្សាបនិងព្យាបាល ព្រមទាំងពង្រីកសេវាបន្សាប ព្យាបាលដោយផ្អែកលើសហគមន៍ នៅតាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក ដើម្បីចូលរួមចំណែកកាត់បន្ថយការរីករាលដាលនៃការប្រើប្រាស់គ្រឿងញៀននៅតាមមូលដ្ឋាន

១៨៦. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវពង្រឹងនិងពង្រីកសមត្ថភាពមជ្ឈមណ្ឌលជាតិ ព្រមទាំងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទារបស់រដ្ឋបន្ថែមទៀត ដើម្បីត្រៀមទទួលជនរងគ្រោះ ដែលប្រមូលបានឬរកឃើញតាមរយៈការអនុវត្តវិធានការរដ្ឋបាលនិងវិធានការច្បាប់ក្នុងយុទ្ធនាការនេះ និង/ឬតាមការស្នើសុំដោយស្ម័គ្រចិត្តពីសំណាក់ក្រុមគ្រួសារនិងជនរងគ្រោះ។

១៨៧. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីជួយជនដែលញៀនគ្រឿងញៀន ក្នុងការស្វែងរកការងារធ្វើក្រោយចាកចេញពីមជ្ឈមណ្ឌលស្តារនីតិសម្បទា។ ក្រៅពីនេះ ក្រសួងបានធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នកទោសក្នុងពន្ធនាគារផងដែរ ។

១៨៨. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវយកចិត្ត ទុកដាក់រៀបចំឱ្យមានយន្តការគ្រប់គ្រងអ្នកប្រើប្រាស់គ្រឿងញៀន ដោយត្រូវប្រមូលទិន្នន័យឱ្យបានច្បាស់លាស់អំពីមុខសញ្ញាប្រើប្រាស់ និងងាយរងផលប៉ះពាល់ដោយសារគ្រឿងញៀន។ ទន្ទឹមគ្នានោះ ត្រូវជំរុញនិងលើកទឹកចិត្ត អ្នកដែលមិនទាន់ទទួលបានការព្យាបាល ឱ្យទៅទទួលយកការព្យាបាល និងត្រូវចាត់វិធានការតាមដានគ្រប់គ្រង ចំពោះបុគ្គលដែលបានធ្វើសមាហរណកម្មចូលក្នុងសហគមន៍ បន្ទាប់ពីចាកចេញពីមណ្ឌលព្យាបាល និងស្តារនីតិសម្បទា ដើម្បីបង្ការ ទប់ស្កាត់កុំឱ្យវិលត្រឡប់ទៅសេពគ្រឿងញៀនវិញ។

១៨៩. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវពិនិត្យលទ្ធភាព និងលើកសំណើដើម្បីបង្កើតនូវមណ្ឌលបណ្ដោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅមូលដ្ឋានរបស់ខ្លួន។

១៩០. លើកកម្ពស់សេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន មជ្ឈមណ្ឌលរដ្ឋ មណ្ឌលឯកជននិងអង្គការចំនួន ២០កន្លែង (ចំនួន១៧កន្លែងកំពុងដំណើរការ ចំនួន១កន្លែងកំពុងសាងសង់ និងចំនួន២កន្លែងមានច្បាប់អនុញ្ញាតិតែមិនទាន់សាងសង់) បានទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនចំនួន ១៨ ១០២នាក់ ស្រី ១ ០៨៦នាក់ ឱ្យស្នាក់នៅបន្សាប ព្យាបាល និងស្តារនីតិសម្បទា និងបញ្ចេញជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនចំនួន ១៥ ១៨០នាក់ ស្រី ៨៥១នាក់ ដូចនេះនៅសល់ ជាក់ស្តែងចំនួន ៨ ៦២៣នាក់ ស្រី ៥៣២នាក់។

### ឃ. កាកបាទក្រហមកម្ពុជា (កក្រក)

១៩១. កាកបាទក្រហមកម្ពុជា (កក្រក) ក្នុងឆ្នាំ២០២៤នេះ បានឆ្លើយតបភ្លាមៗទៅនឹងតម្រូវការជាក់ស្តែងនៅតាមសហគមន៍រងគ្រោះ និងប្រជាពលរដ្ឋងាយរងគ្រោះបំផុតបានចំនួន ៥០ ០៤៨គ្រួសារ (ថ្នាក់កណ្ដាលឆ្លើយតបបាន ២១ ៩១២គ្រួសារ និងសាខា ២៨ ១៣៦គ្រួសារ)។

១៩២. ការឆ្លើយតបគ្រោះមហន្តរាយ៖ កាកបាទក្រហមកម្ពុជា បានចែកអំណោយមនុស្សធម៌ ជូនប្រជាពលរដ្ឋរងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ នៅទូទាំង២៥ រាជធានី ខេត្តសរុប ៧ ៥០៩គ្រួសារ ក្នុងនោះ ១ ៦៨៦គ្រួសារ ទទួលអំណោយពីថ្នាក់កណ្ដាល និង ៥ ៨២៣គ្រួសារ ទទួលអំណោយពីថ្នាក់សាខា មានដូចជាករណីរងគ្រោះដោយទឹកជំនន់ ខ្យល់កន្ត្រាក់ រន្ទះបាញ់ស្លាប់ បាក់ច្រាំង ទន្លេ-ស្ទឹង ផ្ទុះឃ្លាំងគ្រាប់នៅខេត្តកំពង់ស្ពឺ និងរងគ្រោះដោយសារមីន។

១៩៣. ការត្រៀមឆ្លើយតបគ្រោះមហន្តរាយ៖ កាកបាទក្រហមកម្ពុជាបានត្រៀមបម្រុងជានិច្ច ដើម្បីឆ្លើយតបគ្រោះមហន្តរាយ ដោយថ្នាក់កណ្ដាលបានត្រៀមសន្និធិក្នុងឃ្លាំង ៥ ០០០សម្រាប់ ជារៀងរាល់ខែ ចំណែកសាខាបានត្រៀមស្បៀង ២០០សម្រាប់ ជារៀងរាល់ខែ ត្រៀមឆ្លើយតបក្នុងករណីចាំបាច់ភ្លាមៗ បានទាន់ពេលវេលា។ សាខាកាកបាទក្រហមកម្ពុជាទាំង២៥ រាជធានី ខេត្ត មានទំនាក់ទំនង និងរាយការណ៍ ជាប្រចាំមកទីស្នាក់ការកណ្ដាល អំពីការប្រកាសព័ត៌មានជាមុន (អាកាសធាតុ ខ្យល់កន្ត្រាក់ ទឹកជំនន់) ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ អាជ្ញាធរមូលដ្ឋានក្នុងការរៀបចំទួលសុវត្ថិភាព រួមទាំងការផ្សព្វផ្សាយជូនប្រជាជនបានត្រៀមស្បៀង ការថែទាំសុខភាព និងអនាម័យទឹកស្អាតក្នុង រដូវទឹកជំនន់។ ដើម្បីត្រៀមលក្ខណៈខ្វះទឹកនារដូវប្រាំងឆ្នាំនេះ សាខាកាកបាទក្រហមកម្ពុជាខេត្ត

ស្ទឹងត្រែងបានជួសជុលអណ្តូងស្នប់ ចំនួន១១ ជូនប្រជាពលរដ្ឋប្រើប្រាស់។ ជាមួយគ្នានេះ សាខាកាកបាទក្រហមកម្ពុជា មួយចំនួនបានត្រៀមមធ្យោបាយ ដើម្បីជួយសង្គ្រោះទាន់ពេលវេលាមានដូចជា អូប័រ ទូកស្ពាន់ អាវពោងការពារលិចទឹក។ល។ សិក្ខាសាលាស្តីពី "ការតម្រង់ទិស ការត្រៀមរៀបចំឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងការប៉ាន់ប្រមាណ" មានអ្នកចូលរួម ៤១នាក់ (ស្រី១០នាក់) ជាមន្ត្រីមកពីទីស្នាក់ការកណ្តាល សាខា កក្រក ២៣ រាជធានី ខេត្ត និង បុគ្គលិកអង្គការ Action Aid។ សិក្ខាសាលា មានគោលបំណងផ្សព្វផ្សាយការយល់ដឹងអំពីបែបផែន PER និង សារសំខាន់ក្នុងការពង្រឹងសមត្ថភាពសមាគមជាតិ លើការត្រៀមបង្ការ ការឆ្លើយតប និងការប្រកាសឱ្យដឹងមុន ចាត់សកម្មភាពទាន់ពេល (EWEA)។

១៩៤. ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ៖ ថ្នាក់កណ្តាល និងសាខាទាំង២៥ បានផ្តល់វគ្គតម្រង់ទិស អំពីការអប់រំផ្សព្វផ្សាយ និងយុទ្ធនាការនានាពាក់ព័ន្ធ ការងារគ្រប់គ្រងគ្រោះមហន្តរាយ ភាពធន់នឹងអាកាសធាតុ និងកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក ជូនប្រជាពលរដ្ឋ ក្នុងសហគមន៍ មន្ត្រីសាខា អនុសាខា យុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា សរុប ៤៩ ១២០នាក់។ ថ្នាក់កណ្តាល និងសាខា កាកបាទក្រហមកម្ពុជា ចំនួន១៦ បានដាំដើមឈើ ២២ ៦៥៦ដើម នៅតាមទីសាធារណៈ សាលារៀន មណ្ឌលសុខភាព និងរមណីយដ្ឋាននានា។ ដោយឡែកសាខា កក្រក ខេត្តសៀមរាប នៅបន្តថែរក្សា និងលើក សោភ័ណ្ឌភាពឧទ្យានសហស្សវត្ស កក្រក មានដើមឈើ ២ ៤៦០ដើម ដែលមានអាយុកាល២៥ឆ្នាំមកហើយ និង ដាំដើមឈើនៅឧទ្យានប្រាសាទអង្គរ ១ ០០០ដើម ដើម្បីចូលរួមយុទ្ធនាការ "ពន្លកបៃតង" ជាមួយក្រសួងបរិស្ថាន។

១៩៥. ដើម្បីពង្រឹងភាពធន់សហគមន៍ សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន បានអនុញ្ញាតឱ្យប្រើកញ្ចប់ថវិកា កក្រក អនុវត្តគម្រោងនៅភូមិ៣ ក្នុងឃុំខ្ពបអាទាវ ស្រុកលើកដែក ខេត្តកណ្តាល មានអ្នកទទួលផល ១ ៦២៧គ្រួសារ ស្មើ ៦ ០៥៤នាក់។ ជាលទ្ធផល ៖

- បានបណ្តុះបណ្តាលអំពីការគ្រប់គ្រងគ្រោះមហន្តរាយ និងសហគមន៍មានសុខភាពល្អ ជូនអ្នកស្ម័គ្រចិត្ត តាមភូមិ ៣០នាក់។
- បានអនុវត្តការផ្សព្វផ្សាយអំពីសុខភាពសហគមន៍ វិជ្ជាសង្គ្រោះបឋម គ្រោះមហន្តរាយ អនាម័យបរិស្ថាន និងបានសាងសង់របងសាលារៀនមួយ។

១៩៦. ដោយមានការគាំទ្រពីកាកបាទក្រហមចិន និងជំនួយបច្ចេកទេសពីថ្នាក់កណ្តាល សាខា កក្រក ខេត្តកំពង់ឆ្នាំង បាននិងកំពុងអនុវត្តគម្រោងកសាងភាពធន់សហគមន៍ នៅឃុំទឹកហូត ស្រុករលាប្អៀរ អនុវត្តនៅភូមិគោលដៅ ចំនួន៩ មានអ្នកទទួលផល ២ ៤៦៩គ្រួសារ ស្មើនឹង ១០ ០២២នាក់។ ជាលទ្ធផល ៖

- បានបណ្តុះបណ្តាលពីគោលការណ៍គ្រឹះរបស់ចលនា វិជ្ជាសង្គ្រោះបឋម ការគ្រប់គ្រងគ្រោះមហន្តរាយ ២លើក
- សិក្ខាសាលាផ្សព្វផ្សាយ អំពីការអនុវត្តកម្មវិធី១លើក និងការប៉ាន់ប្រមាណនិងសមត្ថភាពជូនអ្នកស្ម័គ្រចិត្ត កក្រក ២៨នាក់។

១៩៧. ការងារសុខភាពមាតា ទារក និងកុមារ៖ បានបោះពុម្ពសារលិខិតរបស់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិតប្រធាន ក្នុងទិវាសុខភាពមាតា ទារក និងកុមារ ២១កុម្ភៈ ទិវាធ្មបជាតិ ៥ឧសភា និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ជាភាសាខ្មែរនិងអង់គ្លេស និង ព្រឹត្តិបត្រព័ត៌មាន ការងារឥស្សរជនឆ្នើមថ្នាក់ជាតិ ៣ ៥៧០ច្បាប់ និងចែកផ្សាយតាមក្រសួង ស្ថាប័នរដ្ឋ ឯកជន អង្គការស៊ីវិល និងសប្បុរសជននានា។ ក្រុមការងារឥស្សរជនឆ្នើមថ្នាក់

ជាតិនៅទីស្នាក់ការកណ្តាល និងសាខា កក្រក ចំនួន២៤ បានចុះសួរសុខទុក្ខ និងផ្តល់ស្បៀងអាហារ សម្ភារប្រើប្រាស់ និងថវិកា ជូនស្ត្រីមានផ្ទៃពោះ ស្ត្រីទើបសម្រាលកូន ៣ ២០៦នាក់ (ថ្នាក់កណ្តាល ៨៣៨នាក់ និងសាខា ២ ៣៦៨នាក់)។

១៩៨. ដើម្បីឈានឆ្ពោះទៅទិវាសុខភាព មាតា ទារក និងកុមារ និងទិវាឆ្មបជាតិ ក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិនៅទីស្នាក់ការកណ្តាលបាន ៖

ទី១. សហការជាមួយទូរទស្សន៍ជាតិកម្ពុជា រៀបចំកិច្ចពិភាក្សា១២លើក ផ្តោតលើប្រធានបទ សុខភាព មាតា ទារក និងកុមារ សុខភាពបន្តពូជ និងការថែទាំសុខភាពបឋម ដើម្បីឈានឆ្ពោះទៅសម្រេចគោលដៅ អភិវឌ្ឍន៍ប្រកបដោយចីរភាពនៅឆ្នាំ២០៣០ រួមទាំងបន្តចែកផ្សាយតាមគ្រប់ស្ថានីយ៍ទូរទស្សន៍នានា និង តាមបណ្តាញសង្គម បានទូលំទូលាយ។

ទី២. បានផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោល ជូនបុគ្គលិក រោងចក្រ ៣៥នាក់ និង

ទី៣. បន្តរៀបចំទិវា និងការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពីសុខភាពមាតា ទារក និងកុមារ រួមគ្នាដើម្បីសហគមន៍ មានសុខភាពល្អ ភាពធន់នឹងអាកាសធាតុ ជូនមន្ត្រីសាខា អនុសាខា មន្ត្រី សិស្សនិស្សិត រួមទាំងស្ត្រី មានកូនតូច ២ ១៥៣នាក់ (ស្រី១២០០នាក់)។

ក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិនៅថ្នាក់សាខា កក្រក ចំនួន២៤ បានបន្តរៀបចំទិវា និងការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងអំពីសុខភាពមាតា ទារក និងកុមារ ដែលផ្តោតសំខាន់លើស្ត្រីក្នុងវ័យបន្តពូជ ស្ត្រី មានផ្ទៃពោះ និងស្ត្រីមានកូនតូច ៩ ៨៣១នាក់ (ស្រី៦ ៧៧៩នាក់)។

១៩៩. ការងារមេរោគអេដស៍ និងជំងឺអេដស៍៖ បានរៀបចំវេទិកាបញ្ចេញទស្សនៈរបស់យុវជន លើប្រធានបទ "យុវជនប្តេជ្ញារួមគ្នាបញ្ចប់ បញ្ហាអេដស៍នៅកម្ពុជា" នៅខេត្តព្រះសីហនុ ដែលមានយុវជនមកពីខេត្តសៀមរាប និងព្រះសីហនុជាវាគ្មិន ដែលមានការចូលរួមពី ថ្នាក់ដឹកនាំថ្នាក់កណ្តាល និងសាខា កក្រក ខេត្តព្រះសីហនុ-សៀមរាប រួមទាំងតំណាង មន្ទីរជុំវិញខេត្ត អ្នកផ្ទុកមេរោគអេដស៍ សិស្ស-និស្សិត ក្រុមយុវជន និងអ្នកស្ម័គ្រចិត្ត កក្រក ១ ០០០នាក់។ ទីស្នាក់ការកណ្តាល និងសាខា កក្រក ចំនួន២៤ (ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ចាម កណ្តាល កែប កោះកុង កំពត កំពង់ស្ពឺ ក្រចេះ កំពង់ធំ មណ្ឌលគិរី ឧត្តរមានជ័យ ប៉ៃលិន ពោធិ៍សាត់ ព្រៃវែង ព្រះវិហារ ព្រះសីហនុ ស្វាយរៀង សៀមរាប ស្ទឹងត្រែង តាកែវ ត្បូងឃ្មុំ និងរាជធានីភ្នំពេញ) បានបន្តរៀបចំទិវា និងការផ្សព្វផ្សាយលើកកម្ពស់ទប់ស្កាត់ការរីករាលដាលមេរោគអេដស៍-ជំងឺអេដស៍ ដោយផ្តោតសំខាន់លើ យុវវ័យជានិស្សិត ក្រុមសិល្បករ តារាសម្តែង និងក្រុមប្រឈមខ្ពស់ រួមមានបុរសស្រឡាញ់បុរស ក្រុមបំប្លែងភេទ ក្រុមស្ត្រីបម្រើសេវាកម្សាន្ត និងក្រុមប្រើប្រាស់គ្រឿងញៀន ១៧ ១៩៨នាក់ (ស្រី៥ ៣៨៣នាក់)។ សាខា កក្រក ចំនួន២៣ បានចុះសួរសុខទុក្ខ និងផ្តល់ស្បៀងអាហារ សម្ភារប្រើប្រាស់ និងថវិកា ជូនអ្នករស់នៅ ជាមួយមេរោគអេស៍-ជំងឺអេដស៍ ២ ១៧៥នាក់។

២០០. ការងារគ្រប់គ្រង និងអភិវឌ្ឍយុវជន កក្រក ៖ បច្ចុប្បន្ន កក្រក មានបណ្តាញយុវជន កក្រក ៣២ ១៤៣នាក់ (ស្រី២០ ១៧២នាក់) នៅតាមគ្រឹះស្ថានសិក្សា ចំនួន ៥៣៧ លើគ្រឹះស្ថានសិក្សាសរុប ១ ៤១៣ នៅទូទាំងប្រទេស។

២០១. ការងារគ្រប់គ្រង និងអភិវឌ្ឍអ្នកស្ម័គ្រចិត្ត កក្រក ៖ បច្ចុប្បន្ន កក្រក បានពង្រឹង ពង្រីកបណ្តាញអ្នកស្ម័គ្រចិត្ត កក្រក នៅទូទាំងប្រទេស ២៧ ២៨៨នាក់ (ស្រី ១០ ១៧៧នាក់) ឱ្យក្លាយជាប្រតិបត្តិករសកម្មបម្រើការងារ

មនុស្សធម៌នៅមូលដ្ឋាន ក្នុងនោះសាខា កក្រក ចំនួន១៧ មានអ្នកស្ម័គ្រចិត្ត ពី១០០-២៥៨ភាគរយ សាខា កក្រក ចំនួន៤ មានអ្នកស្ម័គ្រចិត្តពី ៨០-៩៩ភាគរយ និងសាខា កក្រក ចំនួន៤ មានអ្នកស្ម័គ្រចិត្តពី២៣-៦៣ ភាគរយ។

### ង. កម្មវិធីជំនួយសង្គម

២០២. ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់៖ គិតពីថ្ងៃចាប់ផ្តើមអនុវត្តកម្មវិធី មកដល់ថ្ងៃ២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ កម្មវិធីជាតិជំនួយសង្គម ផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ មានយុវជនបានចុះឈ្មោះក្នុងកម្មវិធីមានចំនួន ២៦ ៤៩៩ នាក់ យុវជនដែលបានបញ្ចប់ការសិក្សាចំនួន ៨ ៨៥៩នាក់ និងយុវជនដែលបានទទួលសាច់ប្រាក់ឧបត្ថម្ភសរុបចំនួន ១៤ ៦៣០ នាក់ ចំណាយថវិកាសរុបចំនួន ១០ ៤៣៨ ០៤៥ ០០០រៀល។

២០៣. គិតចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដល់គ្រួសារសរុបចំនួន ៧០៥ ៣៧១៦ និងថវិកាសរុបចំនួន ៥ ៤៣៨ ៤៤២ ៩៥៣ ០០០ រៀល ដែលបិទបញ្ចប់ត្រឹមខែមីនា ឆ្នាំ២០២៤ ហើយឈានទៅអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារចាប់ពីខែមេសា ឆ្នាំ២០២៤ តទៅ។ គិតចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ចំនួនគ្រួសារគោលដែលបានចុះឈ្មោះក្នុងកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារចំនួន ៦២៦ ៨៥៩គ្រួសារ។ ស្ត្រីមានផ្ទៃពោះសរុបចំនួន ៣៨ ៣២៧នាក់ និងកុមារអាយុក្រោម ២ឆ្នាំចំនួន ១៩ ២៧២នាក់ ជនចាស់ជរាចំនួន ៣០៩ ៦៣៤នាក់ ជនមានពិការភាពចំនួន ២៧ ៥៧៤នាក់ និងអ្នកផ្ទុកមេរោគ/កើតជំងឺអេដស៍ចំនួន ២ ៦៨១នាក់ ដែលចំណាយថវិកាសរុបចំនួន ២៩៨ ៦៧២ ៨៥៨ ០០០រៀល ស្មើនឹង ៧៤ ៦៦៨ ២១៥ដុល្លារអាមេរិក។ ដើម្បីអនុវត្តកម្មវិធីឱ្យទទួលបានជោគជ័យ ម.ជ.ជ បាន៖ បានបោះពុម្ពផ្ទាំងផ្សព្វផ្សាយ ចំនួន ៦ ០០០សន្លឹក និងខិត្តបណ្ណចំនួន ៥៤ ៤០០សន្លឹក ផ្សព្វផ្សាយកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដើម្បីចែកចាយជូនរាជធានី ខេត្ត។

២០៤. បានចុះពិនិត្យការចុះឈ្មោះចូលកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ នៅខេត្តសៀមរាប។ ពិនិត្យលើយន្តការ និងនីតិវិធីសម្រាប់ការឧបត្ថម្ភសាច់ប្រាក់ជូនសិស្សានុសិស្សក្នុងគ្រួសារមានបណ្ណសមធម៌ នៃកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដើម្បីត្រៀមធ្វើសមាហរកម្មអាហារូបករណ៍សិស្សចូលក្នុងកម្មវិធីជាតិកញ្ចប់គ្រួសារ យន្តការចុះឈ្មោះ និងនីតិវិធីសម្រាប់ការឧបត្ថម្ភសាច់ប្រាក់ជូនសិស្សានុសិស្ស ក្នុងគ្រួសារមានបណ្ណសមធម៌ នៃកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែលត្រូវអនុវត្តនាឆ្នាំ២០២៥ ខាងមុខ។

២០៥. អនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤នេះ ប្រតិភូក្រសួង ស.អ.យ. និងប្រតិភូក្រសួងមហាផ្ទៃបានជួបប្រជុំដើម្បីស្វែងយល់ពីស្ថានភាពស្ត្រីមានផ្ទៃពោះ ដែលកំពុងជាប់ពន្ធនាគារ និងកុមារតាមម្តាយ និងពិភាក្សាអំពីការផ្តល់ជំនួយសង្គមជាសាច់ប្រាក់ដូចនឹងស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ដែលស្ថិតក្នុងគ្រួសារមានបណ្ណសមធម៌មានសុពលភាព ក៏ដូចជាកម្មវិធីស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ជាមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីកម្មសិក្សា កម្មករនិយោជិតជាស្ត្រី ដែលជាសមាជិក ប.ស.ស ដែលមានចំនួន ២ ៧១៥ ០៨៤នាក់។

២០៦. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តការគាំពារកុមារ ចំនួន ២០០នាក់(ស្រី៨៨នាក់) ក្នុងខេត្ត គោលដៅ ចំនួន៤ គឺខេត្តត្បូងឃ្មុំ ខេត្តសៀមរាប ខេត្តកណ្តាល និងខេត្តបាត់ដំបង។

២០៧. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្សព្វផ្សាយស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីអាហារូបករណ៍សិស្ស ក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សា ចំណេះដឹងទូទៅ នៃកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ដែល កម្មវិធីនេះគ្រោងនឹងចាប់ផ្តើមអនុវត្តពីខែមករា ឆ្នាំ ២០២៥។

## ៦. ការចូលរួមរបស់កុមារ[14]

### ៦.១. ក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា និងកាយរឹទ្ធិជាតិកម្ពុជា[15]

២០៨. ក្រុមប្រឹក្សាកុមារកម្ពុជានៅតាមគ្រឹះស្ថានសិក្សាចំនួន ៩ ០៣៥ មានសមាជិក ១ ៥៩៧ ១០៤នាក់ (កើនឡើង ៣៣ ៨២០នាក់) ស្រី ៨០៣ ២០២នាក់ និងក្រុមប្រឹក្សាយុវជនកម្ពុជានៅតាមគ្រឹះស្ថានសិក្សា ៦០៩ មានសមាជិក ៣៨៤ ៥៥៩នាក់ (កើន ៩ ៩៦៧នាក់) ស្រី ២០៧ ៧១៦នាក់ ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។

២០៩. សមាជិកកាយរឹទ្ធិជាតិកម្ពុជា ១៨៥ ៣៥៦នាក់ ស្រី ៩១ ០៣៧នាក់ ស្មើ ៤៩.១១% ដែលចំនួននេះ សម្រេចបានតាមចំណុចដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ សមាជិកភាពនៃកាយរឹទ្ធិជាតិកម្ពុជា បានកើនឡើងដោយសារការយល់ច្បាស់អំពីគុណតម្លៃនៃគោលការណ៍គ្រឹះកាយរឹទ្ធិ ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការពង្រឹងប្រព័ន្ធកងល្បាតនៅតាមគឹះស្ថានសិក្សាសាធារណៈ ឯកជន និងសហគមន៍។

២១០. ក្រសួង អ.យ.ក. បានផ្តល់ឱកាសដល់យុវជន និងកុមារក្នុងការអនុវត្តគម្រោងស្ម័គ្រចិត្ត និងធ្វើការប្រកួតប្រជែង បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលស្តីពីការងារស្ម័គ្រចិត្ត ដែលបង្ហាញពីការចូលរួមរបស់យុវជន និងកុមារ ដើម្បីបង្ហាញពីសមត្ថភាព ការរួមចំណែក និងទស្សនៈរបស់ពួកគេ។ កម្មវិធីនេះ ឆ្លើយតបនឹងអាទិភាពទី៥ នៃផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។ ក្រសួងបានរៀបចំទិវាអន្តរជាតិអ្នកស្ម័គ្រចិត្ត អបអរសាទរ និងលើកទឹកចិត្តដល់យុវជនស្ម័គ្រចិត្ត ដើម្បីបង្ហាញអំពីស្នាដៃការងារស្ម័គ្រចិត្តរបស់ខ្លួន។ កម្មវិធីយុវជន និងកុមារ បានជះឥទ្ធិពលដល់ការអភិវឌ្ឍយុវជន និងកុមារគួរឱ្យកត់សម្គាល់ដោយផ្ទាល់ និងប្រយោល។ យុវជន និងកុមារដែលបានចូលរួមផ្ទាល់ក្នុងកម្មវិធីនេះ ទទួលបានការបំប៉នចំណេះដឹង និងសមត្ថភាពបន្ថែមពីលើការសិក្សាក្នុងថ្នាក់រៀន តាមរយៈការអនុវត្តជាក់ស្តែងស្របតាមបរិបទកម្មវិធីបំណិនសតវត្សរ៍ទី២១។

### ៦.២. បណ្តាញយុវជន បណ្តាញកុមារ និងក្លឹបកុមារ

២១១. ក្រៅពីក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា កាយរឹទ្ធិជាតិកម្ពុជា និងយុវជនកាកបាទក្រហមក៏មានអង្គការសង្គមស៊ីវិលជាច្រើនបានបង្កើតនូវបណ្តាញយុវជន បណ្តាញកុមារ និងក្លឹបកុមារ ដែលមានគោលដៅលើកកម្ពស់ការចូលរួម សាមគ្គីភាព ការចែករំលែកបទពិសោធន៍ និងទស្សនៈ ជាពិសេសសំឡេងរបស់ពួកគេទាក់ទងនឹងបញ្ហាកុមារនៅកម្ពុជា ដែលក្នុងនោះមានដូចជា អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា និងសមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ។ល។

---

14 កុមារមានសិទ្ធិចូលរួមក្នុងការបញ្ចេញមតិយោបល់លើបញ្ហា ឬសកម្មភាពដែលមានឥទ្ធិពលដល់ដំណើរជីវិតរបស់ពួកគេ ចូលរួមសកម្មភាពក្នុងសហគមន៍ ការប្រជុំនានា ចូលរួមការទទួលនិងផ្សព្វផ្សាយព័ត៌មាន ការអានសៀវភៅ កាសែត ទស្សនាវដ្តី មើលទូរទស្សន៍ ដើម្បីពង្រីកការយល់ដឹង និងចេះប្រើវិចារណញ្ញាណ រិះគិតចំពោះព្រឹត្តិការណ៍ផ្សេងៗ។

15 សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២៣-២០២៤ និងទិសដៅឆ្នាំសិក្សា២០២៤-២០២៥។

## ៧. កិច្ចសហប្រតិបត្តិការលើវិស័យកុមារ

### ៧.១. កិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ

២១២. ទន្ទឹមនឹងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ជាពិសេសក្រសួង ស្ថាប័ន ដែលបំពេញការងារផ្តោតលើកុមារ បានប្រឹងប្រែងក្នុងការលើកកម្ពស់សិទ្ធិកុមារពីថ្នាក់ក្រោមជាតិ និងថ្នាក់ក្រោមជាតិ យើងក៏មាន អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សង្គមស៊ីវិល ជាច្រើនបានចូលរួមសហការយ៉ាងសកម្មលើការការពារ និងលើកកម្ពស់ឧត្តមប្រយោជន៍កុមារ និងបានសហការយ៉ាងជិតស្និទជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលក្នុងនោះមានដូចជា អង្គការយូនីសេហ្វ អង្គការភ្លែនអន្តរជាតិកម្ពុជា អង្គការឆាលហ្វាន កម្ពុជា អង្គការដែនដីមនុស្ស-ហូឡង់ដ៍ អង្គការសង្គ្រោះកុមារ អង្គការទស្សនៈពិភពលោកអន្តរជាតិកម្ពុជា អង្គការភូមិកុមារ SOS អង្គភាពការពារកុមារ (CPU) អង្គការ Eriks អង្គការមូលនិធិហាការអន្តរជាតិ អង្គការសម្ព័ន្ធចាប់ដៃ អង្គការសម្ពន្ធដើម្បីសិទ្ធិកុមារកម្ពុជា អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា អង្គការសកម្មភាពដើម្បីកុមារ និងសមាគមចលនាកុមារនិងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ។ល។ ខាងក្រោមនេះ គឺជាលទ្ធផលការងាររបស់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សង្គមស៊ីវិលមួយចំនួន ដែលបានផ្តល់ជូនមក ក.ជ.ក.។

#### ក. អង្គការភ្លែនអន្តរជាតិកម្ពុជា

២១៣. នៅក្នុងឆ្នាំ២០២៤ អង្គការភ្លែនអន្តរជាតិកម្ពុជា បានបន្តជំរុញការអនុវត្តនូវយុទ្ធសាស្រ្តប្រទេសរបស់ខ្លួន ២០២១-២០២៧ ដោយផ្តោតសំខាន់លើការអនុវត្តកម្មវិធីស្នូលចំនួន ៤ ដូចជា៖ កម្មវិធីការចាប់ផ្តើមនូវសុខភាពល្អ កម្មវិធីកិច្ចការពារជំនាន់ថ្មី កម្មវិធីរៀនសូត្រពេញមួយជីវិត និងកម្មវិធីក្មេងស្រីជាអ្នកដឹកនាំ នៅក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាប រតនគីរី ស្ទឹងត្រែង ក្រចេះ មណ្ឌលគិរី។

២១៤. កម្មវិធីចាប់ផ្តើមជាមួយសុខភាពល្អ៖ បានសាងសង់/ជួសជុលសាលាមត្តេយ្យចំនួន១៨ ការផ្តល់សម្ភារៈសិក្សា និងគាំទ្រដល់ក្រុមមាតាបិតាចំនួន ៨៣ (ប្រជុំចំនួន ៧៧០ សមាជិក ៥ ៧៨១ នាក់) ដែលផ្តល់អត្ថប្រយោជន៍ដល់កុមារចំនួន ២ ០៣៤នាក់ (អាយុ ៣-៥ ឆ្នាំ)។ ការអប់រំមាតាបិតាលើអាហារូបត្ថម្ភ និងការលូតលាស់របស់កុមារដល់អ្នកចូលរួមចំនួន ៤១ ២២៥នាក់។ លើកកម្ពស់ការយល់ដឹងអំពីទឹកស្អាតនិងអនាម័យដល់គ្រួសារចំនួន ១០០ខ្នងផ្ទះ និងបានផ្តល់សម្ភារៈបរិក្ខារ និងការសាងសង់ប្រព័ន្ធទឹកភ្លៀងចំនួន ៣១៣កន្លែង និងបានបង្កើតប្រព័ន្ធទឹកស្អាតចំនួន៤កន្លែងនិងបានផ្តល់បង្គន់អនាម័យជូនគ្រួសារចំនួន ៨៥៩ខ្នងផ្ទះ។ បានអប់រំផ្សព្វផ្សាយនិងបានចូលរួមបញ្ឈប់ការបន្ទោរបង់ពាស់វាលសរុចំនួន ៧៧ភូមិ ២០ឃុំ ៥ស្រុក ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋសហគមន៍ចំនួន ៥៥ ០៣២នាក់ (ស្រី ២៧ ៥១២នាក់)។ បានផ្តល់សេវាពិនិត្យកុមារចំនួន ១៤ ៥៥៣នាក់ និងបានព្យាបាលកុមារដែលមានកង្វះអាហារូបត្ថម្ភតាមរយៈការផ្តល់អាហារបន្ថែម។

២១៥. កម្មវិធីកិច្ចការពារជំនាន់ថ្មី៖ បានបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់កុមារចំនួន ១៥ ២៤០នាក់ (ស្រី ៨ ៣៨២នាក់) ស្តីពីកិច្ចការពារកុមារពីការរំលោភបំពាននានា និងបានធ្វើឱ្យពួកគេទទួលបានចំណេះដឹង ជំនាញ ទំនុកចិត្ត និងការចូលរួមរបស់យ៉ាងសកម្មក្នុងការបន្តលើកម្ពស់ការយល់ដឹងដល់មិត្តៗរបស់ខ្លួននៅក្នុងសហគមន៍។ បានបណ្តុះបណ្តាលឪពុក-ម្តាយនិងអ្នកថែទាំ ១ ១៩៨នាក់ ឱ្យមានការយល់ដឹងអំពីសិទ្ធិកុមារ ការការពារកុមារ ការទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំកុមារ និងជំរុញឱ្យមានការលើកម្ពស់

សមភាពយេនឌ័រ។ បានបង្កើតក្រុមបណ្តាញកិច្ចការពារកុមារតាមភូមិចំនួន ៧៨បណ្តាញ និងកសាងសមត្ថភាពរបស់ពួកគេក្នុងការទប់ស្កាត់គ្រប់ទម្រង់នៃអំពើហិង្សា និងបានជំរុញឱ្យមានកិច្ចសហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់លើការទប់ស្កាត់និងការរាយការណ៍ទៅយន្តការណ៍គាំទ្រ និងអន្តរគមន៍តាមនីតិវិធីប្រតិបត្តកិច្ចការពារកុមារថ្នាក់ស្រុក និងខេត្ត។ បានបណ្តុះបណ្តាលសមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ស្តីពីកិច្ចការពារកុមារចំនួន ១៨៣នាក់ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៃរដ្ឋបាលស្រុកចំនួន ១៦៤នាក់។ បានសម្របសម្រួលការចូលរួមរបស់កុមារក្នុងកិច្ចប្រជុំគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ប្រចាំខែ។

២១៦. កម្មវិធីរៀនពេញមួយជីវិត៖ បានបន្តអនុវត្តកម្មវិធីផ្តល់អាហារពេលព្រឹកក្នុងសាលាចំនួន ២០២សាលាដែលផ្តល់ឧត្តមប្រយោជន៍ដល់កុមារចំនួសិស្សចំនួន ៣៥ ១១២នាក់ (ស្រី ១៧ ៤០២នាក់) រួមទាំងបន្តអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីអនាម័យការលាងដៃ និងការលាងសម្អាតចានក្រោយអាហារ។បានជួសជុលកន្លែងលាងដៃ៥១កន្លែងក្នុង២៦សាលារៀន និងសាងសង់បង្គន់អនាម័យចំនួន ១១១ បង្គន់ក្នុងសាលារៀនចំនួន ៣៦ និងកែលម្អប្រព័ន្ធទឹកក្នុងសាលារៀនចំនួន ៧សាលារៀនដោយបានផ្តល់ប្រយោជន៍ដល់កុមារចំនួន ១៣ ២០៥នាក់ (ស្រី ៦ ៥៩៩នាក់)។ បានធ្វើការលើកកម្ពស់និងធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំនៅក្នុងសាលារៀនគោលដៅចំនួន២៦៣ ដោយបង្កើនអត្រាចុះឈ្មោះចូលរៀន និងការផ្លាស់ប្តូរ និងកាត់បន្ថយការត្រួតថ្នាក់ ឬបោះបង់ការសិក្សា និងបានបង្កើតថ្នាក់ពន្លឿនដល់សិស្សចំនួន ៤០៣នាក់(ស្រី១៧៩នាក់) និងបណ្តុះបណ្តាលផ្នែកគរុកោសល្យពាក់ព័ន្ធ និងការគ្រប់គ្រងតាមសាលារៀនដល់គ្រូចំនួន ២១៣នាក់។ បានបណ្តុះបណ្តាលគ្រូបង្គោលចំនួន ៨៦នាក់ (ស្រី ៣១នាក់) លើការប្រើប្រាស់សៀវភៅណែនាំ និងសមភាពយេនឌ័រនិងបានជំរុញការចូលរួមរបស់មាតាបិតាក្នុងការចែករំលែកការអនុវត្តល្អៗ។ សិស្សចំនួន ៩ ៥០៥នាក់ (ស្រី ៤ ៧៩៣នាក់) រួមទាំងកុមារពិការចំនួន ៣៩៦នាក់ (ស្រី ១៦២នាក់) បានទទួលផល។ បានបន្តអនុវត្តគម្រោងសាលាសុវត្ថិភាពរបស់បានបង្កើនសុវត្ថិភាព និងភាពធន់យ៉ាងសំខាន់នៅក្នុងសាលារៀនកម្ពុជាចំនួន ៩៦ និងបានផ្តល់ឧត្តមប្រយោជន៍ដល់សិស្សចំនួន ៣០ ៨៧២នាក់ (ស្រី ១៥ ៣៩៤នាក់) និងឪពុកម្តាយចំនួន ១១ ៦៧៩នាក់។ បានផ្តល់សម្ភារៈសិក្សាមូលដ្ឋានត្រូវបានផ្តល់ជូនកុមារចំនួន ៦១៤នាក់ (ស្រី ៣១៧នាក់)ក្នុងសាលាគោលដៅ ១៦សាលា។ បានបើកវគ្គបណ្តុះបណ្តាលរយៈពេលពីរថ្ងៃស្តីពីការរៀបចំបន្ទប់សុខភាពក្នុងសាលា ដែលធ្វើឡើងជាមួយ MoEYS -SHD បានបណ្តុះបណ្តាលនាយកសាលា និងគ្រូចំនួន ២៨នាក់ (ស្រី ១៦នាក់) និង មន្ត្រី PoEYS ចំនួន ៤នាក់។ បានផ្តល់សម្ភារៈ និងបរិក្ខារសម្រាប់បង្កើតបន្ទប់សុខភាពនៅតាមសាលាគោលដៅ និងមានអ្នកទទួលផលជាលោកគ្រូ អ្នកគ្រូចំនួន ៤៨នាក់ (ស្រី ២៦នាក់) និងសិស្សចំនួន ១ ៤៦០នាក់ (ស្រី ៧២៣នាក់)។ បានផ្តល់វគ្គតម្រង់ទិសវិជ្ជាជីវៈក្នុងអនុវិទ្យាល័យចំនួន២៤នៅទូទាំង ខេត្តរតនគិរី ស្ទឹងត្រែង និងខេត្តសៀមរាប ដល់សិស្សានុសិស្សប្រមាណ ១២ ៥១៦នាក់ (ស្រី ៦ ៩១៩នាក់) ។

២១៧. កម្មវិធីក្មេងស្រីជាអ្នកដឹកនាំ៖ បានបណ្តុះបណ្តាលកុមារី និងក្មេងស្រី និងក្មេងប្រុសចំនួន ១ ០០៩នាក់ (ក្មេងប្រុស ៦០៨នាក់) ស្តីពីភាពអង្គអាចសមភាពយេនឌ័រជាច្រើននិងការកសាងទំនុកចិត្តលើខ្លួនឯង។ យោងតាមការវាយតម្លៃបានរកឃើញថា ៥០% ក្មេងស្រីបានរាយការណ៍ថាខ្លួនបានកើនឡើងនូវចំណេះដឹងអំពីការការពារខ្លួន និងមានទំនុកចិត្ត។ បានគាំទ្រនូវកិច្ចសន្ទនាអន្តរជំនាន់រវាងកុមារនិងឪពុកម្តាយ អ្នកសហគមន៍ អាជ្ញាធរមូលដ្ឋានចំនួន ២៦០នាក់ ស្តីពីវិសមភាពយេនឌ័រ តាមរយៈកិច្ចសន្ទនានេះបានផ្លាស់ប្តូរជាវិជ្ជមាន

ក្នុងចំណោមយុវជន ឪពុកម្តាយ និងអាជ្ញាធរមូលដ្ឋាន។ តាមការវាយតម្លៃបានរកឃើញថា ៧០% នៃឪពុកម្តាយយល់ដឹងអំពីយេនឌ័រ និងមានទំនាក់ទំនងដែលប្រសើរឡើង ហើយមានការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់សមភាពយេនឌ័រ ជាពិសេសបានដោះស្រាយកង្វល់អំពីការរំលោភបំពានលើកុមារតាមអ៊ីនធឺណិត។ បានកសាងសមត្ថភាពដល់កុមារីចំនួន ២៥នាក់ ស្តីពីជំនាញអ្នកបង្កើតមាតិកាលើប្រព័ន្ធផ្សព្វផ្សាយ ក្នុងការជំរុញការយល់ដឹងរបស់សាធារណៈជនអំពីសមភាពយេនឌ័រ និងការទប់ស្កាត់ការយាយីតាមអ៊ីនធឺណិត អំពើហិង្សាទាក់ទងនិងយេនឌ័រ ការចូលរួមទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅវ័យកុមារ និងសារៈសំខាន់នៃការចូលរួមរបស់ក្នុងវេទីការនៃការធ្វើសេចក្តីសម្រេចចិត្ត។ល។ បានបន្តលើកម្ពស់នៃការយល់ដឹងនិងការផ្លាស់ប្តូរនូវផ្នត់គំនិតយេនឌ័រ តាមរយៈការផ្តួចផ្តើមឱ្យមានក្មេងស្រីកាន់តួនាទីជំនួសដោយបានផ្តល់ឱកាសដល់កុមារីចំនួន ១៣នាក់ នូវបទពិសោធន៍ភាពជាអ្នកដឹកនាំ នៅក្នុងវិស័យចម្រុះ ការប្រឈមមុខនឹងភាពមិនច្បាស់លាស់ខាងយេនឌ័រ និងការបំផុសគំនិតនូវ មហិច្ឆតានាពេលអនាគត។ បានសម្របសម្រួលឱកុមារីនិងស្ត្រីវ័យក្មេងចំនួន ១៩៤នាក់ ចូលរួមនូវវេទិកានានានៃការធ្វើសេចក្តីសម្រេចចិត្តនិងចែករំលែកនូវក្តីកង្វល់របស់ខ្លួនជាមួយអ្នកធ្វើសេចក្តីសម្រេចចិត្តថ្នាក់ក្រោមជាតិ។ បានផ្តល់ឱកាសសម្រាប់កុមារីស្ត្រីវ័យក្មេងចំនួន ៣១នាក់ចូលវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងជំនាញការនិយាយជាសាធារណៈ។

### ខ. អង្គការឆាលហ្វាន កម្ពុជា

២១៨. អង្គការឆាលហ្វាន កម្ពុជា គឺជាការិយាល័យតំណាងរបស់អង្គការឆាលហ្វានអូស្រ្តាលី ដែលជាអង្គការអភិវឌ្ឍន៍អន្តរជាតិឯករាជ្យ បំពេញការងារដើម្បីកាត់បន្ថយភាពក្រីក្រសម្រាប់កុមារនៅក្នុងសហគមន៍ កំពុងអភិវឌ្ឍ។ អង្គការឆាលហ្វានអូស្ត្រាលី គឺជាសមាជិកសម្ព័ន្ធអង្គការឆាលហ្វាន ដែលជាបណ្តាញសកលនៃអង្គការចំនួន-១២ ជួយដល់កុមារ និងគ្រួសាររបស់ពួកគេជិត ២៣លាននាក់ នៅក្នុងប្រទេសចំនួន៧០។

២១៩. អង្គការឆាលហ្វាន បានចាប់ផ្តើមការងារនៅកម្ពុជា ក្នុងឆ្នាំ២០០៧ និងបានធ្វើការក្នុងភាពជាដៃគូ ដើម្បីបង្កើតឱ្យបាននូវសហគមន៍ ឬប្រព័ន្ធដែលជួយដល់កុមារងាយរងគ្រោះ និងយុវជនទាំងអស់បានយល់ និងជឿជាក់លើសិទ្ធិរបស់ពួកគេ។ គម្រោងជាច្រើនត្រូវបានអនុវត្តនៅតាមតំបន់ជនបទ នៃខេត្តស្វាយរៀង ក្រចេះ ព្រៃវែង និងបាត់ដំបង ដោយផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅរបស់សហគមន៍ក្រីក្រ និងងាយរងគ្រោះ។

២២០. អង្គការឆាលហ្វាន បានគាំទ្រកុមារ និងក្រុមគ្រួសាររបស់គេ ក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីអភិវឌ្ឍដែលមានរយៈពេលវែង ហើយផ្តោតសំខាន់លើវិស័យសំខាន់ ដូចជា៖ កិច្ចការពារកុមារ ការអប់រំ និងការសិក្សារៀនសូត្រពីសង្គម និងផ្លូវចិត្ត។ វិស័យកិច្ចការពារកុមារនៃអង្គការឆាលហ្វាន កម្ពុជា មានគោលបំណងពង្រឹងបរិយាកាសប្រកប ដោយសុវត្ថិភាពសម្រាប់កុមារា-កុមារី រួមទាំងកុមារដែលមានពិការភាពតាមរយៈយន្តការផ្លូវការ និងនៅសហគមន៍។ យុទ្ធសាស្ត្រនៃវិស័យកិច្ចការពារកុមារមាន៖

- **ប្រព័ន្ធផ្លូវការ** : ប្រព័ន្ធការពារកុមារដែលមានស្រាប់ មានដំណើរការ ក្នុងនោះអ្នកពាក់ព័ន្ធនិងអ្នកផ្តល់សេវាមានចំណេះដឹង ជំនាញ និងធនធានដើម្បីការពារ និងឆ្លើយតបទៅនឹងហានិភ័យនៃការការពារកុមារ។
- **គាំទ្រគ្រួសារ និងសហគមន៍** : ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំមានចំណេះដឹង និងជំនាញក្នុងការផ្តល់នូវសុវត្ថិភាពដល់កុមារដើម្បីអភិវឌ្ឍខ្លួនប្រកបដោយសក្តានុពល។

- **ចំណេះដឹង និងជំនាញការពារខ្លួនសម្រាប់កុមារ** : កុមារអាចកំណត់អត្តសញ្ញាណ ការពារ និងឆ្លើយតបទៅនឹងហានិភ័យនៅក្នុងកម្រិត និងវិសាលភាពនៃការគ្រប់គ្រងរបស់ពួកគេ និងអាចស្វែងរកជំនួយសមស្របនៅពេលដែលពួកគេត្រូវការ។

២២១. អង្គការឆាលហ្វាន កម្ពុជា បាននិងកំពុងសហការ និងគាំទ្រដល់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រៀបចំឯកសារសម្រាប់ការបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ។ ឯកសារសម្រាប់បណ្តុះបណ្តាលមាន ៤ ឯកសារផ្សេងៗគ្នាគឺៈ (១).ឯកសារសម្រាប់បណ្តុះបណ្តាលគ្រូបង្គោល (២). ឯកសារសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម (៣). ឯកសារសម្រាប់បណ្តុះបណ្តាលឪពុកម្តាយនិងអ្នកថែទាំ និង(៤). ឯកសារសម្រាប់បណ្តុះបណ្តាលកុមារ និងយុវជន។ ឯកសារទាំងនេះ ត្រូវបានពិនិត្យ និងប្រមូលធាតុចូលពីក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ ចំនួន ៣លើក ក្នុងឆ្នាំ២០២៣ និងបានដាក់ឱ្យប្រើប្រាស់សាកល្បងក្នុងស្រុកគោលដៅ នៃខេត្តចំនួន ៣ គឺ ស្រុកសង្កែ ខេត្តបាត់ដំបង ស្រុកសំបូរ ខេត្តក្រចេះ និងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ខាងក្រោមនេះ ជាអ្នកទទួលផលគម្រោងក្នុងដំណាក់កាលទី១។

| **អ្នកទទួលផល ក្រចេះ បាត់ដំបង និងព្រៃវែង** | **សរុប** |
|---|---|
| គ្រូបង្គោល (យុវជន និងCV) | ៤២ នាក់ |
| កម្លាំងសេវាសង្គម | ៣១៨ នាក់ |
| កុមារវ័យជំទង់ | ៥,៧៩០ នាក់ |
| ឪពុកម្តាយ | ៤,៣៧៨ នាក់ |

២២២. អង្គការឆាលហ្វាន កម្ពុជា សហការគាំទ្របច្ចេកទេសដល់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិបានចំនួន ១៥នាក់ ដែលជាគ្រូឧទេស នៃវិទ្យាស្ថានជាតិសង្គមកិច្ច លើការប្រើប្រាស់ឯកសារបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ។ គ្រូបង្គោលថ្នាក់ជាតិបានបន្តបណ្តុះបណ្តាលទៅដល់និស្សិត នៃវិទ្យាស្ថានជាតិសង្គមកិច្ច។

២២៣. អង្គការឆាលហ្វាន កម្ពុជា និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានផ្សព្វផ្សាយជាផ្លូវការលើការប្រើប្រាស់ឯកសារសម្រាប់ការបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពឯកឧត្តម **ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ទន្ទឹមនេះ ក្រុមការងារក៏បានកសាងកម្មវិធី App ស្វ័យសិក្សា ស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ ដោយបានដាក់ឱ្យសាកល្បង នៅខេត្តបាត់ដំបង ព្រៃវែង និងក្រចេះ។ លើសពីនេះទៀត គម្រោងសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញនេះ ក៏បានផ្តល់ឱ្យក្រុមការងារ បានប្រជុំជារៀងរាល់ត្រីមាសជាមួយដៃគូក្នុងតំបន់តាមអនឡាញ និងទស្សនកិច្ចសិក្សានៅក្នុងប្រទេស ព្រមទាំងមានរៀបចំកិច្ចសន្ទនាសហគមន៍ ដែលរៀបចំឡើងដោយក្រុមកុមារ ដើម្បីលើកឡើងនូវកង្វល់ បញ្ហាប្រឈមរបស់ពួកគេ ជូនអាជ្ញាធរមូលដ្ឋាន មន្ត្រីថ្នាក់ជាតិ ដើម្បីគិតគូពិចារណា ដោះស្រាយឱ្យបានទាន់ពេលវេលា។

## គ. អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា

២២៤. នៅឆ្នាំ២០២៤ អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា (TdH NL) បានអនុវត្តគម្រោងចំនួន១ ឈ្មោះថា គម្រោងសុវត្ថិភាព និងសិទ្ធិកុមារតាមប្រព័ន្ធអនឡាញ ហៅកាត់ថា "ស្រ្តូល" ដែលមានដៃគូរអនុវត្តគម្រោង

ចំនួន២គឺៈ អង្គកាសកម្មភាពដើម្បីកុមារ និងអង្គការសេរីភាពកម្ពុជាអូស្រ្តាលី និងមានកិច្ចសហការអនុវត្តគម្រោងជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងនាយកដ្ឋានគោលនយោបាយ ICT នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

២២៥. អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា បានគាំទ្រអង្គការសេរីភាពកម្ពុជាអូស្រ្តាលីធ្វើការផ្សព្វផ្សាយអប់រំស្តីពីចំណេះដឹងសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ និងការរាយការណ៍នៅតាមសាលារៀន និងសហគមន៍ដល់កុមារ យុវជន លោកគ្រូ អ្នកគ្រូ និងសមាជិកសហគមន៍។ ការប្រារព្ធទិវាពិភពលោកប្រឆាំងអំពើជួញដូរមនុស្សតាមរយៈសិល្បៈគំនូរ ដើម្បីលើកកម្ពស់ការយល់ដឹង និងទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ ការចែករំលែកការគ្រប់គ្រងពីករណីការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញដល់អង្គការចំនួន២គឺអង្គការ WOMEN និងអង្គការប្រតិបត្តការកុមារកម្ពុជា តាមរយៈកិច្ចសហការជាមួយ អង្គការឆាលហ្វាន កម្ពុជា។ ពង្រឹងការកិច្ចសហការនិងចែករំលែកពីយុទ្ធនាការផ្សព្វផ្សាយពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ ដែលរៀបចំក្រុមយុវតី និងបទបង្ហាញពី AusCam Chatbot សម្រាប់ការរាយការណ៍។ វគ្គបណ្តុះបណ្តាលដល់កុមារ និងយុវជន ស្តីពីការរៀបចំយុទ្ធនាការផ្សព្វផ្សាយ ពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញដល់សហគមន៍របស់ពួកគាត់។ វគ្គបណ្តុះបណ្តាលដល់អង្គការដៃគូ ស្តីពីកិច្ចការការពារ និងការឆ្លើយតបចំពោះការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ។ វគ្គបណ្តុះបណ្តាលដល់កុមារ និងក្រុមយុវតីពីការបង្កើត Slow Motion វីដេអូដើម្បីលើកកម្ពស់ការយល់ដឹងពីការរំលោភបំពាន កុមារតាមប្រព័ន្ធអនឡាញ និងការស្វែងរកជំនួយ។ គាំទ្រក្រុមកុមារនិងយុវជន រៀបចំយុទ្ធនាការ ១៦ថ្ងៃបញ្ឈប់អំពើហិង្សាស្ត្រី និងក្មេងស្រី ក្រោមប្រធានបទ "អំពើរហិង្សាផ្អែកលើយេនឌ័រតាមប្រព័ន្ធអនឡាញ និងសុវត្ថិភាពតាមប្រព័ន្ធអនឡាញសម្រាប់អ្នកទាំងអស់គ្នា" ដែលមានកុមារចូលរួមដោយផ្ទាល់ និងមានតាមប្រព័ន្ធអនឡាញ។

២២៦. គាំទ្រក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (នាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន) ជ្រើសរើសទីប្រឹក្សាសម្រាប់ការបង្កើតគោលការណ៍ការពារកុមារលើប្រព័ន្ធអនឡាញដល់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល។ គាំទ្ររៀបចំយុទ្ធនាការផ្សព្វផ្សាយស្តីពី "សុវត្ថិភាពអនឡាញសម្រាប់កុមារី និងយុវតី" ដោយសហការជាមួយអ្នកផលិតមាតិកា A Dose of Cath (Catherine Harry) ដែលបានទទួលបានការចាប់អារម្មណ៍ពីកុមារ និងយុវជនចំនួន ៨៤៨៨ (Like, Comment and Share)។

២២៧. គាំទ្រអង្គការសកម្មភាពដើម្បីកុមារបោះផ្សាយជាកញ្ចប់ព័ត៌មាន ៣សំខាន់ៗ (១).មេរៀនសម្រាប់អ្នកអនុវត្តច្បាប់ (២).មេរៀនសម្រាប់គ្រួសារជនរងគ្រោះ និង (៣).មេរៀនអនុវត្តល្អៗក្នុងការឆ្លើយតប និងការផ្តល់សំណងដល់ជនរងគ្រោះដើម្បីចែករំលែកចំនួន៥០០ក្បាល។ គាំទ្ររៀបចំកិច្ចប្រជុំពិភាក្សារវាងក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល និងមន្ត្រីអនុវត្តច្បាប់ ដើម្បីលើកកម្ពស់កិច្ចសហការរវាងក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល និងមន្ត្រីអនុវត្តច្បាប់ក្នុងការការពារ និងឆ្លើយតបចំពោះការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ។ គាំទ្រធ្វើការដោះស្រាយករណីជាមួយអាជ្ញាធរចំនួន១៦ករណី ដើម្បីលើកកម្ពស់បន្ថែមអោយការដោះស្រាយ ករណីកាន់តែមានលក្ខណៈកុមារមេត្រី និងរៀបចំជាកិច្ចប្រជុំពិភាក្សាចំនួន៦លើក ជាមួយមន្ត្រីអនុវត្តច្បាប់ មន្ត្រីសង្គមកិច្ច និងអង្គការដៃគូរ។ គាំទ្ររៀបចំកិច្ចប្រជុំពិភាក្សា និងធ្វើបទបង្ហាញពីបញ្ជីត្រួតពិនិត្យ ស្តីពីកុមារមេត្រី (Child Friendly Checklist) ក្នុងដំណើរការស៊ើបអង្កេតករណីទៅដល់មន្ត្រីប៉ូលីស ប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្សសរុបចំនួន១៥នាក់ (ស្ត្រី៣នាក់) នៅក្នុងខេត្តកណ្តាល និងសៀមរាប។ គាំទ្រការផ្សព្វផ្សាយអប់រំស្តីពីកិច្ចការពារ និងការឆ្លើយតបចំពោះការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ ផ្តល់វគ្គបណ្តុះបណ្តាល

ស្តីពីកិច្ចការពារ និងឆ្លើយតបចំពោះ ការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញដល់មន្ត្រី និងបុគ្គលិកអង្គការសង្គមស៊ីវិលនៅ ខេត្តបាត់ដំបង និងរាជធានីភ្នំពេញ ។

២២៨. គាំទ្រក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ធ្វើការវាយតម្លៃពាក់កណ្តាលអណ្តត្តិផែនការ សកម្មភាពដើម្បី បង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ២០២១-២០២៥។ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយគណៈកម្មការការពារកុមារថ្នាក់ជាតិ ដើម្បីពិភាក្សាវាយតម្លៃផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ២០២១-២០២៥ ពាក់កណ្តាលអណ្តត្តិ។ គាំទ្រការរៀបចំសិក្ខាសាលាពិគ្រោះយបល់ថ្នាក់តំបន់ និងសិក្ខាសាលាពិគ្រោះយោបល់ជាមួយកុមារ និងយុវជនដើម្បីពិនិត្យលើការរៀប ចំផែនការជាតិស្តីពីការបង្ការទប់ស្កាត់ និងឆ្លើយចំពោះហិង្សាលើកុមារឆ្នាំ២០២៥-២០៣០។

### ឃ. អង្គការសកម្មភាពដើម្បីកុមារ (APLE)

២២៩. អង្គការសកម្មភាពដើម្បីកុមារ សហការជាមួយនាយកដ្ឋាននីតិកម្ម និងនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នៃក្រសួង អ.យ.ក. បានរៀបចំបង្កើត និងដាក់បញ្ចូលសម្ភារៈអប់រំបណ្តុះបណ្តាលស្តីពីសុវត្ថិភាពកុមារតាមអនឡាញក្នុងកម្មវិធីសិក្សាកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ ក្រៅពីនោះ អង្គការ APLE ក៏បានចូលរួមជាមួយនាយកដ្ឋានទាំងពីរក្នុងការបង្កើតសៀវភៅណែនាំស្តីពីរបៀបបញ្ជ្រាប និងវិធីសាស្ត្របង្រៀនលើប្រធានបទការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

២៣០. ក្រោមកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការសកម្មភាពដើម្បីកុមារ (APLE) បានរៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹង និងវគ្គបណ្តុះបណ្តាលដោយមានអ្នកចូលរួមសរុបចំនួន ៣ ៨៨៣នាក់ (ស្រី២ ២០៧នាក់) ដោយមានកុមារសរុបចំនួន ២ ៣៩២នាក់ (ស្រី១ ៣៩៤នាក់) និងមនុស្សពេញវ័យចំនួន ១ ៤៩១នាក់ (ស្រី៨១៣នាក់)។ ជាងនេះទៅទៀត តំណាងអង្គការសកម្មភាពដើម្បីកុមារ (APLE) ក៏បានចូលរួមជាមួយយុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ដែលបានរៀបចំឡើងដោយអង្គការម្លប់តាប៉ាងនៅខេត្តព្រះសីហនុកាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤។ តំណាងអង្គការ APLE ក៏បានថ្លែងចំណាប់អារម្មណ៍ស្តីពីសុខុមាលភាពឌីជីថល និងសុវត្ថិភាពតាមប្រព័ន្ធអនឡាញទៅកាន់អ្នកចូលរួមសរុប៥៦៨នាក់ (ស្រី២៩០នាក់)។

២៣១. ដោយទទួលបានកិច្ចសហការពីបណ្ឌិត្យសភានគរបាលកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលជាតិ អង្គការ APLE បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការស្វែងយល់ និងការឆ្លើយតបបែបកុមារមេត្រីចំពោះបទល្មើសកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញបានចំនួន៧វគ្គ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តរតនគិរីដោយមានមន្ត្រីអនុវត្តច្បាប់ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងមន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា និងការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា និងមន្ត្រីជួរមុខនៅតាមមូលដ្ឋាននៃស្នងការដ្ឋាននគរបាលរាជធានីខេត្ត រួមមាន ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ព្រះវិហារ កំពង់ចាម កំពង់ឆ្នាំង ព្រៃវែង ពោធិ៍សាត់ រតនគិរី និងរាជធានីភ្នំពេញ សរុប ៣៤៩នាក់ (ស្រី១០៧នាក់)។

២៣២. ដើម្បីចូលរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងករណីរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទផ្លូវភេទកុមារឱ្យបានកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាព ហើយមានការគិតគូរខ្ពស់ស្របតាមគោលការណ៍អនុសញ្ញាសិទ្ធិកុមារ

អន្តរជាតិ អង្គការសកម្មភាពដើម្បីកុមារ ទទួលបានកិច្ចសហការពីអគ្គស្នងការដ្ឋាន នគរបាលជាតិ និងស្នងការដ្ឋានរាជធានីខេត្ត បានរៀបចំសាងសង់បន្ទប់សម្ភាសន៍បែបកុមារមេត្រីចំនួន ៦ទីតាំងផ្សេងគ្នា ក្នុងនោះមាននៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង សៀមរាប កណ្តាល និងកំពត និងមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ។ ទិន្នន័យដែលប្រមូលបានពីបន្ទប់សម្ភាសន៍បែបកុមារមេត្រីខាងលើបង្ហាញថា កុមាររងគ្រោះចំនួន ២២០នាក់ (ស្រី១១៥នាក់) ដែលមានអាយុចន្លោះពី ៦ដល់១៧ឆ្នាំ បានទទួលអត្ថប្រយោជន៍ពីការប្រើប្រាស់បន្ទប់សម្ភាសន៍បែបកុមារមេត្រីខាងលើ នៅពេលដែលពួកគេចូលរួមក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌក្នុងដំណាក់កាលមន្ត្រីនគរបាលជំនាញ។

២៣៣. អង្គការ APLE បានដំណើរការបណ្តាញរាយការណ៍បន្ទាន់តាមទូរសព្ទ និងអ៊ីនធឺណិតសម្រាប់សាធារណជនរាយការណ៍អំពីករណីសង្ស័យនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ និងទទួលបានការរាយការណ៍ករណីសរុបចំនួន ២៤៧ តាមរយៈលេខទូរសព្ទ ០៩២ ៣១១ ៥១១ និង Internet Hotline (www.aplecambodia.org/reporting-page) ក្នុងនោះមានករណីចំនួន ១៧៦ ពាក់ព័ន្ធនឹងអំពើកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ រួមមាន៖ (១).រូបភាពសម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) ១១១ករណី (២).ករណីសង្ស័យនៃការគំរាមកំហែងខាងផ្លូវភេទ(Sextortion) ៣១ករណី (៣).ករណីសង្ស័យនៃការលួងលោមតាមអនឡាញ (Online grooming) ០៧ករណី (៤).ករណីផ្សេងទៀតពាក់ព័ន្ធនឹងខ្លឹមសារដែលអាចបង្កគ្រោះថ្នាក់ ការបោកប្រាស់តាមអ៊ីនធឺណិត ការគំរាមកំហែងតាមអ៊ីនធឺណិត និងការបាត់ក្មេងជាដើម ២៧ករណី។

២៣៤. លើសពីនោះ អង្គការ APLE ក៏ទទួលបានការរាយការណ៍ ៧១ករណីពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារក្រៅប្រព័ន្ធអ៊ីនធឺណិត ក្នុងនោះមាន (១).១៣ករណីសង្ស័យពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារ (២).៣ករណីពាក់ព័ន្ធនឹងទេសចរណ៍ ឬអ្នកធ្វើដំណើរដែលមានគោលបំណងកេងប្រវ័ញ្ចផ្លូវភេទកុមារ (៣).១៥ករណីពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ (៤).៦ករណីពាក់ព័ន្ធនឹងសញ្ញារកម្ម និង(៥).៣១ករណីផ្សេងទៀតពាក់ព័ន្ធនឹងការស្វែងរកព័ត៌មានផ្លូវច្បាប់ ជំនួយសង្គម និងការប្រឹក្សាយោបល់។

២៣៥. ការឆ្លើយតបរបស់បណ្តាញរាយការណ៍បន្ទាន់តាមអ៊ីនធឺណិត៖ តំណភ្ជាប់ចំនួន ១ ៦៣០ ដែលមានរូបភាពនិងវីដេអូចំនួន ៨៩ ៥៦២ ត្រូវបានវិភាគដោយអ្នកជំនាញវិភាគមាតិការបស់អង្គការ APLE។ ក្នុងនោះ តំណភ្ជាប់ចំនួន ១ ៤៤២URLs ដែលមានរូបភាព និងសម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) និងមានខ្លឹមសារគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងកុមារដែលមានមាតិកា ៨៩ ១៣១ ត្រូវបានបញ្ជូន និងវិភាគតាមរយៈបណ្តាញ INHOPE ទៅកាន់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ESP/ISPs និង/ឬសេវាកម្មការពារ ឬជំនួយកុមារ។ ជាលទ្ធផលមានតំណភ្ជាប់ ៩៨៥URLs ដែលមាន ២២៤២៧ ជាមាតិកាខុសច្បាប់ ឬបង្កគ្រោះថ្នាក់ ស្មើនឹង ៦៨.៣០% នៃតំណភ្ជាប់ URL ដែលបានរាយការណ៍ត្រូវបានដកចេញដោយជោគជ័យ ហើយមានចំនួន ៤៤ករណីបានរាយការណ៍ទៅកាន់សមត្ថកិច្ចដើម្បីធ្វើការស៊ើបអង្កេតតាមនីតិវិធីច្បាប់។ អង្គការ APLE ដែលជាផ្នែកមួយនៃគម្រោង Arachnid បានធ្វើការវិភាគ និងដកហូតសម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) ចេញពីប្រព័ន្ធអ៊ីនធឺណិត។ ក្រុមអ្នកវិភាគបានដាក់ចំណាត់ថ្នាក់រូបភាពចំនួន ៨៧៤ ៤៤៤ ដោយមាន៦៥% បញ្ជាក់ថាជា CSAM ២០% ជាសម្ភារៈដែលបង្កគ្រោះថ្នាក់ និង១៥% ជាមនុស្សពេញវ័យ ឬមាតិកាដែលបង្កើតដោយ AI។ ការងារដ៏សំខាន់នេះបានជះឥទ្ធិពលដោយផ្ទាល់ដល់ជីវិតរបស់កុមាររងគ្រោះ

និងបានជួយទប់ស្កាត់មិនឱ្យក្លាយជាជនរងគ្រោះបន្ថែមទៀត និងការបំបែកវដ្តនៃការរំលោភបំពាន។ ទន្ទឹមនឹងនោះដែរ នៅពេលដែលអ្នកវិភាគរបស់យើងបានឃើញនឹងរូបភាពដែលគួរឱ្យរំខានជារៀងរាល់ថ្ងៃ ពួកគេបានប្រឈមមុខនឹងភាពតានតឹង ការថប់បារម្ភ និងអារម្មណ៍នៃភាពឯកោកាន់តែខ្លាំង ដោយមានការគាំទ្រតិចតួចដើម្បីទប់ទល់នឹងការងារដ៏លំបាកនេះ។

២៣៦. អង្គការ APLE បានផ្តល់របាយការណ៍ករណីសង្ស័យពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ ចំនួន ៤៤ករណី (ក្នុងនោះមាន២៦ករណីសង្ស័យពាក់ព័ន្ធអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ) ទៅកាន់នគរបាលជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងនគរបាលជំនាញប្រឆាំងបទល្មើសបច្ចេកវិទ្យាដើម្បីធ្វើការស៊ើបអង្កេតតាមនីតិវិធីច្បាប់។ ជាលទ្ធផលនៃការស៊ើបអង្កេត

២៣៧. នគរបាលបានឃាត់ខ្លួនជនសង្ស័យចំនួន៧នាក់ (ជនជាតិខ្មែរ៦នាក់) និងករណីជនជាតិអាមេរិក១នាក់ ត្រូវបានឃាត់ខ្លួនបញ្ជូនទៅតុលាការ។ ជនរងគ្រោះជាកុមារសរុបចំនួន២៨នាក់ (ស្រី២១នាក់) ដែលមានអាយុចន្លោះពី៦ទៅ១៧ឆ្នាំ ត្រូវបានកំណត់អត្តសញ្ញាណ ជួយសង្គ្រោះ និងបញ្ជូនទៅទទួលសេវាសមស្របផ្នែកច្បាប់ និងសង្គម។

២៣៨. អង្គការ APLE បានផ្តល់ជំនួយគាំទ្រផ្នែកសង្គម រួមមានការគាំទ្រផ្នែកសម្ភារៈ និងការប្រឹក្សាយោបល់ក្នុងដំណាក់កាលអន្តរាគមន៍វិបត្តិដល់ក្រុមគោលដៅដូចខាងក្រោមក្នុងខេត្តសៀមរាប បាត់ដំបង កំពង់ចាម កំពង់ធំ កំពង់ស្ពឺ ក្រចេះ កណ្តាល និងរាជធានីភ្នំពេញ ដែលមានកុមាររងគ្រោះថ្មីចំនួន២៨នាក់ (ស្រី២១នាក់)កុមារងាយរងគ្រោះថ្មីចំនួន២នាក់ (ស្រី២នាក់) និងគ្រួសាររបស់កុមាររងគ្រោះថ្មីចំនួន២៣នាក់ (ស្រី១៥នាក់)។ យើងក៏បានសម្របសម្រួលកុមាររងគ្រោះចំនួន២៨នាក់ (ស្រី២១នាក់) ទៅទទួលសេវាគាំទ្រផ្នែកសង្គមនៅក្នុងសហគមន៍សម្រាប់រយៈពេលវែងដែលផ្តល់ដោយអង្គការជំហ៊ានដំបូងកម្ពុជា អង្គការហាកា អង្គការ A21 អង្គការភាពញញឹមនៃកុមារ អង្គការពន្លកថ្មី អង្គការលីកាដូ និងអង្គការស៊ីធីផុញ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តសៀមរាប។ យើងបានរៀបចំកិច្ចប្រជុំពិភាក្សាលើការគ្រប់គ្រងករណីចំនួន១៩ដង ដែលក្នុងនោះមានអ្នកចូលរួមចំនួន៩២នាក់ (ស្រី៦៣នាក់) មកពីស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ ដូចជា ក្រសួងកិច្ចការនារី មន្ទីរកិច្ចការនារីខេត្តសៀមរាប មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តក្រចេះ និងខេត្តកំពង់ចាម ក្រុមប្រឹក្សាឃុំ សង្គមកិច្ចខណ្ឌ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារថ្នាក់ឃុំសង្កាត់ (គ.ក.ន.ក) និងអង្គការមិនមែនរដ្ឋាភិបាល រួមមានអង្គការ APLE អង្គការហាកា អង្គការសេរីភាពកម្ពុជាអូស្ត្រាលី អង្គការA21 អង្គការម្លប់តាប៉ាង អង្គការជំហ៊ានដំបូងកម្ពុជា អង្គការហេបភីច័ន្ទតារា អង្គការភាពញញឹមនៃកុមារក្នុងខេត្តបាត់ដំបង ខេត្តសៀមរាប និងរាជធានីភ្នំពេញ។

២៣៩. កុមាររងគ្រោះចំនួន៨៨នាក់ (ស្រី៦៣) និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៨៧នាក់ (ស្រី៦៣) ទទួលបានការប្រឹក្សាយោបល់ផ្លូវច្បាប់ និងបានចូលរួមផ្តល់សក្ខីកម្មក្នុងនីតិវិធីនគរបាលយុត្តិធម៌ និងនៅក្នុងដំណាក់កាលតុលាការដល់ក្រុមគោលដៅក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពង់ស្ពឺ ខេត្តក្រចេះ ខេត្តកណ្តាល និងបន្ទាយមានជ័យ។ ក្នុងចំណោមកុមារចំនួន៨៨នាក់ មានកុមាររងគ្រោះចំនួន២៣នាក់ (ស្រី១៦) និងដើមបណ្តឹងរដ្ឋប្បវេណីទទួលបានការប្រឹក្សាយោបល់ផ្លូវច្បាប់ និងមានមេធាវីដើម្បីចូលរួមផ្តល់សក្ខីកម្មនៅដំណាក់កាលសវនាការដែលមានជនល្មើសសរុបចំនួន១៧នាក់ ត្រូវបានតុលាការសម្រេចសេចក្តី។

២៤០. អង្គការសកម្មភាពដើម្បីកុមារ (APLE) បានសម្របសម្រួលកុមាររងគ្រោះចំនួន៥នាក់ (ស្រី៥នាក់) បានចូលរួម និងផ្តល់មតិយោបល់ក្នុងកិច្ចពិភាក្សាជាក្រុមលើប្រធានបទកិច្ចការពារកុមារក្នុងគ្រួសារ និងប្រធានបទកិច្ចការពារកុមារក្នុងសហគមន៍ក្នុងសិក្ខាសាលាពិគ្រោះយោបល់ជាមួយកុមារ និងយុវជន ស្តីពីការរៀបចំផែនការជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ នាពីថ្ងៃទី២០ និង២១ ខែកញ្ញា ឆ្នាំ២០២៤ ប្រព្រឹត្តទៅនៅខេត្តសៀមរាបដែលរៀបចំ ដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

២៤១. អង្គការសកម្មភាពដើម្បីកុមារ (APLE) បានសម្របសម្រួលកុមាររងគ្រោះចំនួន៤នាក់ (ស្រី៣នាក់ និង LGBTQ+ ១នាក់) ចូលរួមក្នុងការផ្តល់ធាតុចូលលើប្រធានបទជាក់លាក់មួយចំនួន៖ ការទទួលបានយុត្តិធម៌ ដំណើរការក្នុងយុត្តិធម៌ និងដំណោះស្រាយប្រកបដោយប្រសិទ្ធភាពក្នុងការពិគ្រោះយោបល់សម្រាប់គម្រោង "ការពង្រឹងសិទ្ធិទទួលបានយុត្តិធម៌ និងដំណោះស្រាយសម្រាប់កុមារនៅកម្ពុជា(GC27)" នៅការិយាល័យរបស់អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា (CRC Cambodia) រាជធានីភ្នំពេញ។ កិច្ចប្រជុំពិគ្រោះយោបល់នេះត្រូវបានសម្របសម្រួលដោយអង្គការដែនដីមនុស្សហូឡង់ (Terre des Hommes Netherlands) និងអង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា (CRC Cambodia)។

២៤២. អង្គការសកម្មភាពដើម្បីកុមារ (APLE) បានសម្របសម្រួលកុមាររងគ្រោះចំនួន៤នាក់ (ស្រី២ និងLGBTQ+ ២នាក់) ចូលរួមផ្តល់បទសម្ភាសន៍ស្តីពីកលល្បិចលួងលោមតាមអនឡាញ និងផលប៉ះពាល់ នៃការរំលោភបំពានផ្លូវភេទតាមអនឡាញ ព្រមទាំងវិធីសាស្ត្រគាំទ្រដល់កុមាររងគ្រោះនៃករណីកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ តាមរយៈការផលិតជាឯកសារខ្លីដើម្បីលើកកម្ពស់ការយល់ដឹងអំពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ដោយអង្គការ UNICEF ប្រចាំកម្ពុជា។

២៤៣. អង្គការសកម្មភាពដើម្បីកុមារ (APLE) បានសម្របសម្រួលកុមាររងគ្រោះចំនួន២នាក់ (ស្រី២នាក់) និងគ្រួសារ២នាក់ (ស្រី១នាក់) បានចូលរួមផ្តល់ធាតុចូលក្នុងការស្រាវជ្រាវលើ "តួនាទីរបស់ឪពុកម្តាយ និងអ្នកមើលថែក្នុងការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា" ដែលបានរៀបចំឡើងដោយអង្គការដែនដីមនុស្សហូឡង់។

២៤៤. អង្គការសកម្មភាពដើម្បីកុមារ (APLE) បានបង្កើតជំនួយការឌីជីថល "ពិសី Chatbot" និងរចនាឡើងដោយផ្អែកលើការពិគ្រោះយោបល់ជាមួយកុមារ យុវជនវ័យក្មេង ឪពុកម្តាយ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលបម្រើការងារក្នុងវិស័យកិច្ចការពារកុមារ ដើម្បីបង្កលក្ខណៈងាយស្រួលសម្រាប់ពួកគេ និងសាធារណៈជនទូទៅអាចរាយការណ៍រាល់ករណីសង្ស័យ នៃការកេងប្រវ័ញ្ចផ្លូវភេទ ការស្វែងរកជំនួយគាំទ្រសម្រាប់ជនរងគ្រោះ និងស្វែងយល់បន្ថែមពីគន្លឹះសុវត្ថិភាពតាមប្រព័ន្ធអនឡាញ និងបង្ហាញមតិយោបល់ និងក្តីកង្វល់តាមប្រព័ន្ធអនឡាញជាដើម។ តាមរយៈជំនួយការឌីជីថល "ពិសី Chatbot" មានអ្នកចូលប្រើប្រាស់ចំនួន ៤ ៧៣២នាក់ ក្នុងនោះមាន ៤៣% អ្នកប្រើប្រាស់ជាកុមារ ២៦%ជាយុវជនវ័យក្មេងមានអាយុចន្លោះពី១៨ទៅ២៥ឆ្នាំ និង១៩%នៃអ្នកប្រើប្រាស់មានអាយុលើសពី២៥ឆ្នាំ ហើយមាន ១២%មិនចង់បង្ហាញពីអាយុរបស់ពួកគេ។

### ង. អង្គការសេរីភាពកម្ពុជាអូស្ត្រាលី (AusCam Freedom Project)

២៤៥. អង្គការ AusCam Freedom Project មានគោលបំណងទប់ស្កាត់ និងការពារកុមារី និងយុវតីពីអំពើជួញដូរ និងការកេងប្រវ័ញ្ច។ តាមរយៈការពិនិត្យឡើងវិញលើផែនការយុទ្ធសាស្ត្រកម្មវិធី ពួកយើងបានអនុវត្តគម្រោងដែលរួមបញ្ចូលគ្នានូវគំរូនៃការអនុវត្តបែបទប់ស្កាត់ និងឆ្លើយតប ដើម្បីបង្កើតនូវការទប់ទល់ដ៏យូរអង្វែងជាមួយអំពើជួញដូរមនុស្សនៅក្នុងរាជធានីភ្នំពេញ។ កម្មវិធីរបស់យើងផ្តល់ឱ្យយុវតីដែលកំពុងត្រូវបានជួញដូរ (ឬត្រូវបានជួញដូរជាថ្មី) នូវឱកាសកសាងភាពជាអ្នកដឹកនាំការបណ្តុះបណ្តាលការណែនាំការគាំទ្រផ្នែកអប់រំ។

២៤៦. អង្គការ AusCam Freedom Project បានធ្វើការគាំទ្រដល់កុមារីសរុបចំនួន ៣ ៧៣៦នាក់ ទទួលបានផលនៅក្នុងកម្មវិធីយុវតីនៃសង្ឃឹមរបស់ពួកយើងដោយក្នុងនោះ៖ កុមារី ឬយុវតីងាយរងគ្រោះចំនួន ១៣៣នាក់ ទទួលជំនួយអាហារូបករណ៍ពីអង្គការលើសកម្មភាពពាក់ព័ន្ធវិស័យអប់រំ។ កុមារី ឬយុវតី ៣ ៥៥១នាក់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលបំនិនជីវិតផ្សេងៗ។ កុមារី ឬយុវតីងាយរងគ្រោះ និងរងគ្រោះ ៥២នាក់ ទទួលបានតែសេវាកិច្ចគាំពារ។

### ច. អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ (VCAO)

២៤៧. អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ (VCAO) គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនរកប្រាក់កម្រៃត្រូវបានបង្កើតឡើងនៅ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ១៩៩៤ ដោយក្រុមកុមារកំព្រាក្រោយរបបខ្មែរក្រហមមួយក្រុមដែលមានកង្វល់ទៅដល់ស្ថានភាពកុមារដែលងាយរងគ្រោះ នៅក្នុងប្រទេសកម្ពុជា។ ដោយរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ កុមារទាំងនេះងាយ នឹងធ្លាក់ខ្លួនជារងគ្រោះ នៃអំពើរជួញដូរមនុស្ស ឧស្សាហកម្មផ្លូវភេទ អ្នកបម្រើតាមផ្ទះ ឬក៏ទទួលរងនូវការរំលោភបំពានផ្សេងៗនៅក្នុងផ្ទះផ្ទាល់។ អង្គការវីស៊ីអេអូ កំពុងធ្វើការនៅក្នុង៥ខេត្ត ដើម្បីផ្តល់ឲ្យកុមារទាំងនេះ និងក្រុមគ្រួសាររបស់ពួកគេនូវមូលដ្ឋានអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងមណ្ឌលសំចតបណ្តោះអាសន្ន ដើម្បីជួយដល់ពួកគេឲ្យក្លាយ ទៅជាពលរដ្ឋដ៏សកម្មនិងទទួលខុស ត្រូវ។

២៤៨. អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ(VCAO) បានអនុវត្តគម្រោងមួយដែលមានឈ្មោះថា "បញ្ចប់ការដាក់ទណ្ឌកម្មកុមារ និងលើកកម្ពស់ការចិញ្ចឹមបីបាច់កូនបែបវិជ្ជមាននៅប្រទេសកម្ពុជា-EVAC" នៅតាមសហគមន៍ និងសាលាគោលដៅដែលស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង។ ដោយបានការគាំទ្រគម្រោងថវិកាពីម្ចាស់ជំនួយ Terre des Hommes Deutschland E.V. និង BMZ ។ គម្រោងនេះ មានគោលបំណងបង្កើនការយល់ដឹងក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ ដូចជានាយកសាលា គ្រូបង្រៀន សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅតាមសហគមន៍ អំពីផលប៉ះពាល់នៃអំពើហិង្សាលើកុមារ ការបំពានគ្រឿងញៀន សិទ្ធិកុមារ និងវិធីសាស្ត្រទំនាក់ទំនងដោយអហិង្សាជាមួយគ្នាទៅវិញទៅមក។ គម្រោងនេះផ្តោតទៅលើកុមារចំនួន និងយុវជនចំនួន ៦ ៧៥០នាក់ នៅក្នុង ៦០ភូមិ ៦ឃុំ ២ស្រុក នៅក្នុងខេត្តកំពង់ឆ្នាំង ដែលនឹងរួមចំណែកដល់វិធានការពារកុមារឲ្យកាន់តែរឹងមាំនៅក្នុងតំបន់ ជាពិសេសនៅក្នុងគ្រួសារក្រីក្រ តាមរយៈលើកកម្ពស់ជីវភាពគ្រួសារ។

### ឆ. អង្គការមូលនិធិហាការអន្តរជាតិ (Hagar International Foundation)

២៤៩. នៅឆ្នាំ២០២៤ អង្គការមូលនិធិហាការអន្តរជាតិ (Hagar International Foundation) បានជួយជនរងគ្រោះដែលជាអតិថិជនសរុបទាំងថ្មី និងចាស់បន្តរពីឆ្នាំមុនចំនួន ៣៥៩នាក់។ ៨០% នៃអតិថិជនដែលទទួលសេវាពីអង្គការមូលនិធិហាការអន្តរជាតិ មានភាពល្អប្រសើរចំពោះភាពធន់ និងភាពស៊ាំនឹងការប៉ះទង្គិចផ្លូវចិត្ត។

បានបណ្ដុះបណ្ដាលដល់អាជ្ញាធរសហគមន៍ និងមន្ត្រីរាជការចំនួន ២ ៣៤២នាក់ ក្នុងការការពារការជួញដូរមនុស្ស និងការការពារគ្រួសារឱ្យមានសុវត្ថិភាព។ អង្គការក៏បានអប់រំ និងផ្តល់ចំណេះដឹងស្តីពីសញ្ញាណនៃការកេងប្រវ័ញ្ច និងការគេចចេញពីការជួញដូរមនុស្ស ទៅដល់កុមារ និងមនុស្សពេញវ័យដែលមានហានិភ័យចំនួន ១៧ ៧៦៩នាក់។ បានបង្កើតក្រុមដឹកនាំអតិថិជនចំនួន ២ ដើម្បីធ្វើការតស៊ូមតិថ្នាក់ជាតិ។

២៥០. តាមដាន និងប្រឹក្សាយោបល់ជាមួយអតិថិជនសរុបចំនួន ៧៣៨នាក់ នូវការប្រឹក្សាយោបល់ដោយជួបផ្ទាល់ និងតាមទូរស័ព្ទ។ អតិថិជនចំនួន ១០៩នាក់ បានទទួលការងារ និងចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន។ អតិថិជនចំនួន ១០៤ទទួលបានជំនួយផ្នែកច្បាប់។ អតិថិជនចំនួន ១៥៣ ត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដោយសុវត្ថិភាព។ អតិថិជនចំនួន ១៥១ ត្រូវបានបិទករណី។

## ជ. អង្គការសម្ព័ន្ធចាប់ដៃ

២៥១. អង្គការសម្ព័ន្ធចាប់ដៃបាននឹងកំពុងតែអនុវត្តសកម្មភាពជាមួយសម្ព័ន្ធមិត្តដែលជាសមាជិកចំនួនជាង៥០ អង្គការស្ថាប័នមិនមែនរដ្ឋាភិបាលផ្សេងទៀតរបស់ខ្លួន ដែលមានទស្សនៈវិស័យ និងបេសកម្មប្រហាក់ប្រហែលគ្នា ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពាននានា ដែលជាពិសេសតែងតែកើតមានឡើងចំពោះកុមារនឹងស្ត្រី ដើម្បីគាំទ្រទៅដល់ជនរងគ្រោះ ងាយរងគ្រោះ នឹងក្រុមសហគមន៏ដែលងាយរងគ្រោះនៅកម្រិតទូទាំងប្រទេស ដើម្បីបំពេញបន្ថែម និងជំរុញទៅដល់យន្តការនានាដែលមានស្រាប់ ក្នុងការធានាថាកុមារ ស្ត្រី និងក្រុមដែលងាយរងគ្រោះដ៏ទៃទៀតទទួលបាននូវការគាំទ្រទាន់ពេលនិងសមស្របទៅតាមតម្រូវការជាក់ស្តែង។

២៥២. ចាប់តាំងពីឆ្នាំ២០២៣ សម្ព័ន្ធចាប់ដៃយបានជួយដោយផ្ទាល់ដល់ជនរងគ្រោះដែលជាកុមារចំនួន១៦៤ នាក់ (កុមារី ១៦៣ នាក់) ដែលជាជនរងគ្រោះដោយការជួញដូរ ពលកម្មដោយបង្ខំ ការកេងប្រវ័ញ្ចផ្លូវភេទតាមអ៊ីនធឺណិត ការរៀបការក្នុងវ័យកុមារនិងមិនស្របតាមឆន្ទៈ អំពើហិង្សាក្នុងគ្រួសារ និងករណីមិនយកចិត្តទុកដាក់លើកុមារ។ ក្នុងនោះដែរសមាជិកអង្គការសង្គមស៊ីវិលទាំង ៥៤ អង្គការ ដែលជាសមាជិករបស់អង្គការសម្ព័ន្ធចាប់ដៃក៏បានផ្តល់សេវាបន្ថែមទៅដល់ក្រុមកុមារគោលដៅរបស់ខ្លួននៅទូទាំងប្រទេស ដែលត្រូវបានចាត់ទុកថាជាក្រុមកុមារដែលងាយរងគ្រោះនោះចំនួនសរុប ៦៧ ៨២២នាក់ ក្នុងនោះកុមារីចំនួន ៣៦ ៤៦៥នាក់ ដើម្បីបង្ករលក្ខណៈសមស្របណាមួយក្នុងការការពារពួកគេអោយរួចផុតពីទម្រង់នៃការរំលោភបំពាននានា។

២៥៣. ឆ្នាំ២០២៤ អង្គការសម្ព័ន្ធចាប់ដៃនិងសមាជិករបស់ខ្លួន បានចូលរួមចំណែកយ៉ាងសកម្មក្នុងដំណើរការអភិវឌ្ឍន៍គោលនយោបាយជាតិ ដោយធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នរដ្ឋាភិបាលសំខាន់ៗដូចជាគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ) និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ ចំណុចសំខាន់ដែលជាផ្នែកចូលរួមក្នុងការកសាងគោលនយោបាយះ ផែនការសកម្មភាពជាតិស្តីពីការប្រឆាំងការជួញដូរមនុស្ស (២០២៤-២០២៨) ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ (២០២៥-២០៣០) និងចូលរួមក្នុងការតាមដាននិងត្រួតពិនិត្យតាមរយៈការផ្សារភ្ជាប់គោលនយោបាយ និងការអនុវត្ត អង្គការសម្ព័ន្ធចាប់ដៃនិងសមាជិករបស់ខ្លួន បន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំទិដ្ឋភាពការពារកុមារនៅកម្ពុជា និងកិច្ចការពារកុមារជាប្រព័ន្ធដោយផ្អែកលើសហគមន៍ជាមូលដ្ឋាន ដើម្បីពិនិត្យមើលនូវរាល់សកម្មភាពនៃការទទួលខុសត្រូវក្នុងការផ្តល់សិទ្ធិ និងការការពារកុមាររបស់អ្នកពាក់ព័ន្ធ។

២៥៤. គម្រោងគ្រប់គ្រងករណី បានផ្តល់សេវាក្នុងការទទួលការហៅទូរស័ព្ទផ្ទាល់ពីជនរងគ្រោះទាក់ទងនឹងករណីផ្សេងៗ ដូចជាករណីជួញដូរមនុស្ស ជួញដូរផ្លូវភេទ និងរំលោភសេពសន្ថវៈ ហើយបន្ទាប់មកកំណត់អត្តសញ្ញាណជនរងគ្រោះ។ គម្រោងក៏មានសកម្មភាពជួយដល់ជនរងគ្រោះទាំងក្នុង និងក្រៅប្រទេសផងដែរ ដោយការធ្វើការទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធដូចជា ស្ថានទូត និងអគ្គកុងស៊ុលកម្ពុជានៅបរទេស ដើម្បីជួយដល់ជនរងគ្រោះ និងឧបត្ថម្ភក្នុងការធ្វើមាតុភូមិនិវត្តន៍។ ជាមួយគ្នានេះដែរ គម្រោងមានផ្តល់សេវាប្រឹក្សាយោបល់ដល់ជនរងគ្រោះបន្ទាប់ពីកំណត់អត្តសញ្ញាណរួច។ សម្រាប់គម្រោងផ្ទាល់របស់អង្គការសម្ព័ន្ធចាប់ដៃបានផ្តល់សេវាដល់កុមារចំនួន១៦៤នាក់ កុមារី១៦៣នាក់ (ករណីរំលោភ១៣២ ករណីជួញដូរ ៣២)។

២៥៥. អង្គការសម្ព័ន្ធចាប់ដៃបានការផ្តល់ជូននៅជំនួយផ្សេងៗ ដូចជា៖ ការប្រឹក្សាផ្នែកច្បាប់ដល់ជនរងគ្រោះ និងក្រុមគ្រួសារ ការផ្តល់ថវិកាថ្លៃធ្វើដំណើរ ថ្លៃអាហារ និងការស្នាក់នៅ ការផ្តល់ជាមេធាវីដើម្បីរកយុត្តិធម៌ ក្នុងនោះបានផ្តល់ជំនួយសម្ភារជាតម្រូវការមូលដ្ឋានដល់កុមាររងគ្រោះបានចំនួន២១ នាក់ បានផ្តល់ជំនួយគាំទ្របន្ទាន់(Urgent support)ដល់កុមាររងគ្រោះបានចំនួន៦នាក់ បានផ្តល់ជំនួយសម្រាប់បង្កើតមុខរបរខ្នាតតូចដល់កុមាររងគ្រោះ និងគ្រួសារបានចំនួន៤នាក់។ ទន្ទឹមនឹងនេះដែរក្រុមការងារគម្រោងថែទាំអតិថិជនក្នុងសហគមន៍បានចុះតាមដាន ពីដំណើរការនៃការចិញ្ចឹមសត្វរបស់ជនរួចពីរងគ្រោះដោយអំពើរំលោភបំពានផ្លូវភេទ ។ តាមរយៈការតាមដាននេះឃើញថាការចិញ្ចឹមសត្វរបស់គាត់នៅមានវឌ្ឍនភាពល្អប្រសើរ លើសពីនេះទៀតគម្រោង ក៏បានពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋានក្នុងការជួយរកជម្រកសមរម្យជូនដល់ កុមាររងគ្រោះ និងគ្រួសារផងដែរ។

២៥៦. អង្គការសម្ព័ន្ធចាប់ដៃបានដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លើយតបកិច្ចការពារកុមារឆ្លងព្រំដែន ជាពិសេសចំពោះកុមាររងគ្រោះដោយការជួញដូរ និងការកេងប្រវ័ញ្ចពាក់ព័ន្ធនឹងធាតុផ្សំឆ្លងដែន។ ចន្លោះឆ្នាំ ២០២៣ និង ២០២៤ អង្គការសម្ព័ន្ធចាប់ដៃ បានគាំទ្រដោយផ្ទាល់នូវករណីឆ្លងព្រំដែនចំនួន ២៤ ក្នុងចំណោមករណីកុមារសរុបចំនួន ១៦៤នាក់ ដែលបានគាំទ្រ។ ករណីទាំងនេះពាក់ព័ន្ធនឹងការជួញដូរ ពលកម្មដោយបង្ខំ ការកេងប្រវ័ញ្ចផ្លូវភេទតាមអ៊ីនធឺណិត និងទម្រង់នៃការរំលោភបំពានផ្សេងទៀតដែលទាមទារការឆ្លើយតបដោយមានការសម្របសម្រួលជាមួយអាជ្ញាធរ និងដៃគូ CSO ឆ្លងព្រំដែន។ តាមរយៈគំរូដែលមានមូលដ្ឋានលើសម្ព័ន្ធភាព និងបណ្តាញដែលអាចជឿទុកចិត្តបាន អង្គការសម្ព័ន្ធចាប់ដៃ បានរក្សាកិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់ជាមួយ៖

- អង្គការសង្គមស៊ីវិលជាដៃគូនៅក្នុងប្រទេសគោលដៅ (ដូចជាម៉ាឡេស៊ី ថៃ និងវៀតណាម)
- ទីភ្នាក់ងាររដ្ឋាភិបាល និងស្ថានទូត និង
- យន្តការថ្នាក់តំបន់ និងប្រព័ន្ធបញ្ជូនបន្ត ក្រោមក្របខណ្ឌអាស៊ាន។

ភាពជាដៃគូទាំងនេះបានសម្របសម្រួល៖

- ការធ្វើមាតុភូមិនិវត្តន៍ដោយសុវត្ថិភាព និងការធ្វើសមាហរណកម្មកុមារឡើងវិញ។
- ការតាមដានផ្នែកច្បាប់ និងការចែករំលែកភស្តុតាងនៅទូទាំងដែនសមត្ថកិច្ច,
- ការគ្រប់គ្រងករណីរួម និងការថែទាំដែលផ្តោតលើកុមាររងគ្រោះ និង ពង្រឹងការការពារ និងការយល់ដឹងក្នុងចំណោមសហគមន៍ជនចំណាកស្រុក និងព្រំដែន។

២៥៧. ការងារនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់អង្គការសម្ព័ន្ធចាប់ដៃ និងសមាជិក ក្នុងការធានាថាគ្មានកុមារណាម្នាក់ធ្លាក់ចូលស្នាមប្រេះដោយសារព្រំដែននៃយុត្តាធិការ និងការលើកកម្ពស់យុត្តិធម៌ និងការការពារដោយមិនគិតពីភូមិសាស្ត្រ។ គំរូនៃកិច្ចសហប្រតិបត្តិការឆ្លងព្រំដែនរបស់យើងគឺទាំងការអនុវត្ត និងផ្អែកលើសិទ្ធិជាមូលដ្ឋាន ដោយធានាបាននូវការអនុលោមពេញលេញជាមួយអនុសញ្ញាស្តីពីសិទ្ធិកុមារ និងការពង្រឹងកាតព្វកិច្ចរបស់កម្ពុជាក្រោមក្របខណ្ឌតំបន់ និងអន្តរជាតិ។

**ឈ. អង្គការសង្គ្រោះកុមារ** (Save the Children)

២៥៨. អង្គការសង្គ្រោះកុមារ បាននិងកំពុងអនុវត្តគម្រោង ដូចជា៖ គម្រោងពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិលដើម្បីសិទ្ធិកុមារ (SIDA CSO STRENGTHENING PROJECT) ក្រោមជំនួយថវិកាពីប្រទេសស៊ុយអែត (SIDA) តាមរយៈអង្គការ Save the Children បានផ្តល់ជំនួយថវិកា និងបច្ចេកទេសដល់អង្គការដៃគូក្នុងស្រុកចំនួន៧ ដើម្បីពង្រឹងសមត្ថភាព ក្នុងការឆ្លើយតប និងដោះស្រាយបញ្ហាកុមារនៅក្នុងប្រទេសកម្ពុជា។

២៥៩. បានគាំទ្រ CCYMCR ក្នុងការអនុវត្តយុទ្ធនាការដឹកនាំដោយក្លឹបកុមារប្រាំបីក្នុងរាជធានី ខេត្ត ៥៖ សៀមរាប កណ្តាល ព្រះវិហារ ភ្នំពេញ និងកោះកុង។ យុទ្ធនាការទាំងនេះបានលើកឡើងពីបញ្ហាសំខាន់ៗ ដូចជា ការការពារបរិស្ថាន ការប្រែប្រួលអាកាសធាតុ សុវត្ថិភាពលើអ៊ីនធឺណិត អាពាហ៍ពិពាហ៍នៅវ័យក្មេង និងអំពើហិង្សាលើភេទ។ យុទ្ធនាការទាំងនេះបានបញ្ជ្រាបទៅកាន់អ្នកចូលរួម លទ្ធផលសំខាន់ៗ រួមមាន ការគ្រប់គ្រងសំរាមប្រសើរឡើង ការយល់ដឹងកាន់តែច្បាស់អំពីការបំពានលើអ៊ីនធឺណិត និងហានិភ័យនៃអាពាហ៍ពិពាហ៍នៅវ័យក្មេង ការគាំទ្រលើការអប់រំកាន់តែរឹងមាំ ការរៀបចំយុទ្ធនាការ១៦ថ្ងៃ ប្រឆាំងអំពើហិង្សាលើភេទដោយជោគជ័យ។

២៦០. បានគាំទ្រ CCYMCR ក្នុងការបណ្តុះបណ្តាលដល់អង្គការដៃគូអំពីសិទ្ធិកុមារ និងដំណើរការពិគ្រោះយោបល់កុមារអំពីស្ថានភាពសិទ្ធិកុមារតាមបែបចូលរួម។ បានរៀបចំសិក្ខាសាលាមួយជាមួយអ្នកចូលរួមជាកុមារ យុវជន អាជ្ញាធរមូលដ្ឋាន និងដៃគូសង្គមស៊ីវិល ដើម្បីពិនិត្យលើសេចក្តីព្រាងរបាយការណ៍ អំពីស្ថានភាពសិទ្ធិកុមារ។ កុមារបានកែសម្រួលរបាយការណ៍ ខណៈដែលអាជ្ញាធរមូលដ្ឋានបានពិនិត្យ និងទទួលស្គាល់ចំពោះបញ្ហា ដែលបានកំណត់ជាអាទិភាព។ សិក្ខាសាលានេះបានបម្រើជាវេទិកាសំខាន់មួយដើម្បីចែករំលែកលទ្ធផល អំពីស្ថានភាពសិទ្ធិកុមារ, ពិភាក្សាលើសំណូមពររបស់កុមារ និងការរៀបចំផែនការឆ្លើយតបតាមសំណើរបស់កុមារ នៅទាំងកម្រិត ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ លើសពីនេះ សិក្ខាសាលានេះក៏បានផ្តល់ព័ត៌មានអំពីការអនុវត្តសិទ្ធិកុមារ នៅកម្ពុជាដែលបានបង្ហាញដោយក្រសួងសំខាន់ៗផងដែរ។

២៦១. អង្គការ CRC-Cambodia និង CCYMCR ដែលបានទទួលការគាំទ្រពីអង្គការ Save the Children បានសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងក្រសួងសំខាន់ៗ ដើម្បីរំលឹកខួបលើកទី ៧៥ នៃទិវាកុមារអន្តរជាតិ និងខួបលើកទី ២៣ នៃទិវាពិភពលោកប្រឆាំងពលកម្មកុមារ នៅកោះពេជ្រ។ ព្រឹត្តិការណ៍នេះមានអ្នកចូលរួមចំនួន ៣ ៣២០នាក់ រួមមានកុមារ មន្ត្រីរាជរដ្ឋាភិបាល តំណាងសង្គមស៊ីវិល និងដៃគូអន្តរជាតិ។ នេះជាឱកាសដ៏សំខាន់ក្នុងការអប់អរ និងបង្កើនការយល់ដឹងអំពីសិទ្ធិកុមារនៅកម្ពុជា។

២៦២. បានគាំទ្រ CRC-Cambodia សហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដើម្បីរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីតាមដានវឌ្ឍនភាពនៃសេចក្តីអង្កេតចុងក្រោយស្តីពីសិទ្ធិកុមារ (COBs) របស់អង្គការ

សហប្រជាជាតិ។ សិក្ខាសាលានេះ បានបង្ហាញកិច្ចសហការល្អរវាងភាគីសំខាន់ៗ ដូចជា ក្រសួង អង្គការសង្គមស៊ីវិល និងបណ្ដាញកុមារ និងយុវជន ដើម្បីជំរុញការអនុវត្ត និងតាមដានCOBs។ អ្នកចូលរួមបានឃើញការកើនឡើងនៃការយល់ដឹងអំពី COBs និងផែនការអន្តរក្រសួងជាក់ស្តែង និងថវិកាស្ថាប័នពាក់ព័ន្ធ ដែលបង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងធានាលើការការពារសិទ្ធិរបស់កុមារ។

២៦៣. CRC-Cambodia សហការជាមួយ Live & Learn Cambodia ដែលបានទទួលការគាំទ្រពី Save the Children បានរួមចំណែក ក្នុងការបកប្រែ យោបល់ទូទៅលេខ ២៦ ស្តីពី សិទ្ធិរបស់កុមារ និងបរិស្ថាន ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការប្រែប្រួលអាកាសធាតុ (General Comment 26) បែបកុមារមាត្រី ដែលអាចយល់បានសម្រាប់កុមារ ទៅជាភាសាខ្មែរ។ ក្នុងដំណើរការបកប្រែនេះ កុមារ និងយុវជន ត្រូវបានអញ្ជើញអោយចូលរួម ដើម្បីធានាថា ឯកសារអាចទទួលបាននូវភាពងាយយល់។

២៦៤. បានគាំទ្រអង្គការ CDPO រៀបចំសិក្ខាសាលាបណ្តុះបណ្តាលអំពី បរិយាបន្នពិការភាព និងការប្រែប្រួលអាកាសធាតុ។ ការបណ្តុះបណ្តាលនេះមានគោលបំណង ពង្រឹងចំណេះដឹងអំពី បរិយាប័ន្នពិការភាព និងការប្រែប្រួលអាកាសធាតុ ដល់អង្គការដៃគូរដែលនៅក្នុងគម្រោង ពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិលដើម្បីសិទ្ធិកុមារ ដើម្បីធានាទៅក្នុងការអនុវត្តគម្រោង និងការអនុវត្ត នៅក្នុងស្ថាប័នប្រកបដោយបរិយាបន្ន និងគិតគូដល់បរិស្ថាន។ បានរៀបចំសិក្ខាសាលាសមភាពយេនឌ័រ សម្រាប់ឪពុកម្តាយនៃប្រធានក្លឹបកុមារ និងសមាជិកវេទិកាស្ត្រីមានពិការភាព ដែលមានគោលបំណង ដើម្បីបង្កើនការយល់ដឹងរបស់អ្នកចូលរួមអំពីសារៈសំខាន់នៃភាពសមភាពភេទ ដោយផ្តោតលើសិទ្ធិស្មើភាពរវាងកុមារា និងកុមារីហើយលើកទឹកចិត្តការចូលរួមក្នុងសកម្មភាពសង្គម នៅក្នុងសហគមន៍។ បានរៀបចំវេទិការថ្នាក់ស្រុក នៅក្នុងបណ្តាខេត្តប្រាំមួយ គឺបាត់ដំបង កំពង់ឆ្នាំង តាកែវ កំពង់ស្ពឺ កំពត និងមណ្ឌលគីរី។ វេទិការពាក់កណ្តាលថ្ងៃនេះ មានគោលបំណង ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ អំពីសិទ្ធិកុមារ បង្ហាញពីតួនាទីសំខាន់របស់កុមារ ទាំងអ្នកដែលមាន និងមិនមានពិការភាពក្នុងសង្គម ដើម្បីអាចពិភាក្សា និងជួបសម្ភាសន៍ដោយផ្ទាល់ជាមួយអាជ្ញាធរ ស្រុក និងឃុំទៅលើកង្វល់របស់ពួកគេ។ គាំទ្រក្លឹបកុមារចំនួន ៦ ដើម្បីរៀបចំយុទ្ធនាការ ១៨ ទាក់ទងនឹងទិវានារីអន្តរជាតិ ទិវាសិទ្ធិកុមារអន្តរជាតិ និងយុទ្ធនាការសម្អាតបរិស្ថាន។ អាជ្ញាធរ មាតាបិតា និងសមាជិកសហគមន៍បានគាំទ្រយ៉ាងសកម្មចំពោះយុទ្ធនាការទាំងនេះ ខណៈពេលដែលក្លឹបកុមារក៏បានក្លាយជាក្រុមដែលមានសកម្មភាពរស់រវើក និងមានទំនួលខុសត្រូវខ្ពស់ក្នុង ការរៀបចំសកម្មភាពសហគមន៍ផ្ទាល់ខ្លួន។

២៦៥. បានគាំទ្រអង្គការ WOMEN លើសកម្មភាពយុទ្ធនាការរបស់កុមារចំនួន ៨ ដែលអាចជួយដោះស្រាយបញ្ហាសង្គមសំខាន់ៗ ដូចជា ភេទ ទំនោរភេទ អត្តសញ្ញាណផ្លូវភេទ ការបង្ហាញអត្តសញ្ញាណផ្លូវភេទ និងលក្ខណៈផ្លូវភេទ (SOGIESC) អនាម័យបរិស្ថាន និងសិទ្ធិរបស់កុមារ។

២៦៦. គម្រោងថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង (FCF) គិតចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៤ បានរៀបចំ សកម្មភាពមួយចំនួន ដូចខាងក្រោម៖

| **សកម្មភាពកំឡុងពេលរាយការណ៍ ខែមករាដល់ធ្នូ ឆ្នាំ២០២៤** | **គោលដៅគម្រោង** | **សូចនាករ** |
|---|---|---|
| ១២ | ៤២ | # ចំនួនកុមារសមាហរណកម្មជាមួយគ្រួសារ |

| | | |
|---|---|---|
| ៣២ | ៥០ | # ចំនួនកុមារទុកដាក់ក្នុងការថែទាំដោយសាច់ញាតិ |
| ១៩ | ៤៣ | # ចំនួនកុមារទុកដាក់ក្នុងការថែទាំដោយឪពុកម្តាយធម៌ |
| ១ ០២០ | ២ ៨០០ | # ចំនួយករណីដាក់ចូលក្នុងប្រព័ន្ធ OSCaR ដោយអង្គការដៃគូ |
| ២ ០០៧ | ២ ៨៣២ | # នៃចំនួនអ្នកប្រើប្រាស់បង់ថ្លៃសេវាប្រព័ន្ធ OSCaR |
| ៥៦ | ៨៣ | # នៃទស្សនកិច្ចទៅកាន់កុមារបានសមាហរណកម្មទៅកាន់ការថែទាំជំនួស |
| ១៣០ | ១៥៥ | # ការប្រជុំក្រុមអ្នកចាកចេញពីការថែទាំ |
| ៩៩ | ៩៥ | # ចំនួនអ្នកចាកចេញពីការថែទាំចូលរួមកិច្ចប្រជុំ |
| ៥១ | ៦២ | # វគ្គបង្វឹកទៅកាន់បុគ្គលិកស្ថានិតិសម្បទាន |

២៦៧. ការពង្រឹងកម្លាំងសេវាសង្គម៖ ក្រុមការងារគម្រោង ក្រោមការដឹកនាំសម្របសម្រួលដោយក្រសួង ស.អ.យ. និងវិទ្យាស្ថានជាតិសង្គមកិច្ច បានរៀបចំវគ្គតម្រង់ទិសគ្រូបង្គោលថ្នាក់ជាតិកម្លាំងសេវាសង្គមផ្តោតលើកិច្ចការពារកុមារ។ បានគាំទ្រវិទ្យាស្ថានជាតិសង្គមកិច្ច រៀបចំប្រជុំពិគ្រោះយោបល់អំពីវគ្គបណ្តុះបណ្តាល កម្លាំងសេវាសង្គមផ្តោតលើកិច្ចការពារកុមារ។ បានចូលរួមក្នុងកិច្ចប្រជុំជាមួយក្រុមការងារបច្ចេកទេស កម្លាំងសេវាសង្គម ដើម្បីរៀបចំផែនការប្រារព្ធទិវាសង្គមពិភពលោកលើកទី១៦ ឆ្នាំ២០២៤ នៅកម្ពុជា។ ចូលរួមរៀបចំសេចក្តីព្រាងអនុក្រិត្យទិវាជាតិសង្គមកិច្ច ហើយដាក់ជូនក្រុមប្រឹក្សាអ្នកច្បាប់សម្រាប់ការផ្តល់ធាតុចូលបច្ចេកទេស។ បានរៀបចំកិច្ចប្រជុំដៃគូគម្រោងថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង លើកទី២៣ និងទី២៤។ កិច្ចប្រជុំនេះមានគោលបំណងចែករំលែកការរៀនសូត្រ ធ្វើបច្ចុប្បន្នភាពដោយផ្តោតជាសំខាន់លើវឌ្ឍនភាពគម្រោងក្នុងចំណោមអង្គការសមាជិកនៅថ្នាក់ជាតិ និងក្រោមជាតិ ដែលមានតំណាងមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធ។ បានធ្វើទស្សនៈកិច្ចសិក្សារបស់ក្រសួងស.អ.យ ទៅខេត្តសៀមរាប៖ គម្រោងថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង។ បានប្រជុំកម្រិតសហគមន៍ពីការអនុវត្ត និងទស្សនកិច្ចប្តូរបទពិសោធន៍៖ រយៈពេល ៦ ខែបន្ទាប់ពីកិច្ចប្រជុំកម្រិតសហគមន៍នៃការអនុវត្ត និងទស្សនកិច្ចប្តូរបទពិសោធន៍លើការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌។ បានចូលរួមកសាង ផែនការជាតិ ស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ ដែលដឹកនាំដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិដើម្បីកុមារកម្ពុជា។ បានបន្តចូលរួមគាំទ្រក្រសួងស.អ.យ ក្នុងការបោះពុម្ពគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារចំនួន ៣០០ ច្បាប់ដែលបានដាក់ឱ្យដំណើរការជាផ្លូវការកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤ កន្លងទៅនេះ។ ក្រុមចែករំលែកចំណេះដឹង (KSG)៖ ក្រុមចែករំលែកចំណេះដឹងបានមានកិច្ចប្រជុំនៅក្នុងខែវិច្ឆិកា ពិភាក្សាលើប្រធានបទសម្រាប់ចងក្រងឯកសារនៃការអនុវត្តល្អបំផុត និងពិនិត្យមើលសមាសធាតុ TOR សម្រាប់ការប្រឹក្សាយោបល់។ កិច្ចប្រជុំបានពឹងផ្អែកលើការចូលរួមយ៉ាងខ្លាំងក្លារបស់នាយកដៃគូ ឬអ្នកគ្រប់គ្រងកម្មវិធី។ បានគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់នាយកដ្ឋានកិច្ចការពារកុមារ នៃក្រសួង ស.អ.យ. ដើម្បីចូលរួមក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រី ស្តីពីការបញ្ចប់អំពើហិង្សាលើកុមារនៅ ប្រទេសកូឡុំប៊ី ដែលធ្វើឡើងនៅថ្ងៃទី ៧-៨ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅកូឡុំប៊ី។ បានធ្វើសិក្ខាសាលាផ្សព្វផ្សាយលើការសិក្សាស្រាវជ្រាវសំខាន់ពីររបស់គម្រោង (១).មេរៀនដែលបានទទួលបានអំពីការបង្វែរ និងការបិទមណ្ឌលថែទាំកុមារ និង (២).ស្វែងយល់ពីការអនុវត្តបច្ចុប្បន្ននៃការថែទាំដោយសាច់ញាតិ និងឪពុកម្តាយធម៌នៅកម្ពុជា។

២៦៨. គម្រោងលើកកម្ពស់កិច្ចការការពារ និងបរិយបន្ន(SOGIESC) នៅកម្ពុជា ដំណាក់កាលទី ២ ៖ បានរៀបចំវគ្គបណ្តុះបណ្តាល SOGIESC ដើម្បីការបណ្តុះបណ្តាលគ្រូបង្គោលស្តីពី SOGIESC កសាងទំនាក់ទំនងរវាង

ដៃគូ និងគាំទ្រអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការរួមបញ្ចូល SOGIESC ទៅក្នុងផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងគោលការណ៍ណែនាំរបស់ពួកគេ។ បានផលិតកម្មវិធីពិភាក្សាតាមអ៊ីនធឺណិតស្តីពី SOGIESC ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការរើសអើងរបស់ SOGIESC និងលើកទឹកចិត្តឱ្យមានការចូលរួមក្នុងការទទួលបានការគាំទ្រ និងការសម្រេចចិត្តសមស្រប។ បានប្រារព្ធពិធីប្រចាំឆ្នាំនៃទិវាអន្តរជាតិប្រឆាំងនឹងការស្រឡាញ់ភេទដូចគ្នា Transphobia និង Biphobia តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម។ បានសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសជាមួយនាយកសាលា និងគ្រូបង្រៀនដើម្បីដោះស្រាយការគំរាមកំហែង និងការរើសអើង ក្នុងគោលដៅរួមបញ្ចូលសមភាព និងការទទួលយកកុមារដែលមាន SOGIESC ចម្រុះទៅក្នុងក្រមសីលធម៌របស់សាលា និងគោលការណ៍ណែនាំពាក់ព័ន្ធ។ បានប្រារព្ធទិវាកុមារអន្តរជាតិ ទិវាអន្តរជាតិក្មេងស្រី និងទិវានារីអន្តរជាតិ។ អ្នកចូលរួមទទួលបានការយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិកុមារ និងសមភាពយេនឌ័រ រួមទាំងសិទ្ធិរបស់កុមារដែលមាន SOGIESC ចម្រុះ និងអំពើហិង្សាក្នុងគ្រួសារ។ បានសហការជាមួយ CCWC របស់ Klanghay និងថ្នាក់ដឹកនាំសាលារៀនដើម្បីធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងស្តីពី "បញ្ឈប់ការរើសអើងលើកុមារដែលមាន SOGIESC ចម្រុះ"។ សហការជាមួយ CCWC បានធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ រួមទាំងកុមារដែលមាន SOGIESC ចម្រុះ។ សកម្មភាពនេះនាំឱ្យមានទំនុកចិត្តកើនឡើងក្នុងចំណោមកុមារក្នុងការបញ្ចេញមតិនៅក្នុងសហគមន៍ និងសាលារៀនរបស់ពួកគេ។

### ញ. អង្គភាពការពារកុមារ (CPU)

២៦៩. អង្គភាពការពារកុមារ (CPU) គឺជាអង្គភាពមួយដែលមានជំនាញខ្ពស់ក្នុងការស៊ើបអង្កេត ធ្វើកោសល្យវិច្ច័យ និងបង្ក្រាបបទល្មើសពាក់ព័ន្ធកុមារ។ បច្ចុប្បន្ននេះ CPU បានសហការបំពេញការងារយ៉ាងជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ CPU បានធ្វើប្រតិបត្តិការចំនួន ៣៦៩ករណី មានការថយចុះ ៣% ធៀបនឹងឆ្នាំ២០២៣ (ចំនួន ៣៨១ករណី)។

| បទល្មើស | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ |
|---|---|---|---|
| ឃាតកម្ម | ៣០ | ២៦ | ២០ |
| ហិង្សាបង្កឱ្យបាត់បង់ជីវិត | ១ | ១ | 0 |
| ប៉ុនប៉ងសម្លាប់ | ៥ | ៦ | ៤ |
| មនុស្សឃាត | ១៣ | ២ | ១ |
| រំលោភសេពសន្ថវៈ | ២២៥ | ២០៨ | ២១០ |
| ប៉ុនប៉ងរំលោភ | ១៣ | ២២ | ១៩ |
| រំលោភបូក | ៧ | ២៤ | ១៦ |
| វាយប្រហារធ្ងន់ធ្ងរ | ១៣ | ៥ | 0 |
| រួមភេទជាមួយអនីតិជន | ៤៥ | ៤៤ | ៧៦ |
| ព័ត៌មានសង្ស័យ/ស៊ើបការ | 0 | ១ | 0 |

| | | | |
|---|---|---|---|
| ជួញដូរអនីតិជន | ០ | ០ | ០ |
| ប្រទូស្តកេរ្តិ៍ | ៨ | ១៨ | ៩ |
| កុមារបាត់ខ្លួន | ២ | ២ | ០ |
| គម្រាមសម្លាប់ | ០ | ០ | ០ |
| ចាប់ជំរិត | ១ | ០ | ០ |
| សញ្ញារកម្មលើកុមារ | ៣ | ៥ | ២ |
| រូបភាពអាសអាភាសកុមារ | ០ | ៤ | ៣ |
| នាំយកកុមារចេញដោយមិនស្របច្បាប់ | ០ | ២ | ០ |
| កុមារស្លាប់ដោយមានការសង្ស័យ | ០ | ១ | ០ |
| បោះបង់កុមារ | ០ | ០ | ៣ |
| បទល្មើសលើកុមារតាមប្រព័ន្ធអនឡាញ | ០ | ០ | ០ |
| បង្កហិង្សាដោយចេតនា | ០ | ១០ | ៦ |
| សរុប | **៣៦៦** | **៣៨១** | **៣៦៩** |

### ជ. អង្គការបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា (១២៨០)[16]

២៧០. អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា (CHC១២៨០) បានអនុវត្តគោលដៅយុទ្ធសាស្ត្រចំនួន ០៤ រួមមាន (១)ការការពារ ដែលមានកម្មវិធីដូចជា ការផ្តល់សេវាពិគ្រោះយោបល់តាមទូរស័ព្ទ ដោយឥតគិតថ្លៃ ២៤/៧ ការផ្តល់ការពិគ្រោះយោបល់ដល់គ្រួសារ សេវាសុខភាពបឋម និងមនុស្សធម៌ ការផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ការបញ្ជូនបន្តនិងតាមដាន ថ្នាលប្រព័ន្ធផ្សព្វផ្សាយសង្គម។ (២)ការបង្ការ-ទប់ស្កាត់ ដែលមានកម្មវិធីដូចជា យន្តការរាយការណ៍ និងការឆ្លើយតបបញ្ហារបស់កុមារ (CRRM) យុវជនប្រេសិតរបស់បណ្តាញទូរស័ព្ទជំនួយកុមារ កម្មវិធីស្វ័យសិក្សា Chatbot/Autobot កម្មវិធីអេបសុខភាពយុវវ័យ (Youth Health Mobile App) កម្មវិធីអេប "ធ្វើដំណើរឆ្លងដែនរបស់ខ្ញុំ" (My Journey Mobile App) កម្មវិធីអេប "សុវត្ថិភាពយើង" (Safe App) បន្ទប់សុខភាពសាលារៀន។ (៣)ការតស៊ូមតិ ដែលមានកម្មវិធីដូចជា ការទំនាក់ទំនង និងបោះពុម្ពផ្សាយ សិក្ខាសាលា/សន្និសីទអន្តរជាតិក្នុងតំបន់ និងថ្នាក់ជាតិ។ (៤)ការអភិវឌ្ឍស្ថាប័ន ដែលមានកម្មវិធីដូចជា ការគ្រប់គ្រងកម្មវិធី ការគ្រប់គ្រងហិរញ្ញវត្ថុនិងរដ្ឋបាល ការអភិវឌ្ឍធនធានមនុស្ស។

២៧១. ការការពារគោលបំណងនៃកម្មវិធីគឺ ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់ការការពារកុមារ និងយុវជនតាមរយៈរចនាសម្ព័ន្ធបណ្តាញជំនួយកុមារ ដោយសម្របសម្រួលសេវាដែលមានស្រាប់ និងការព្យាបាលផ្លូវចិត្ត-សង្គម។ ការផ្តល់សេវាពិគ្រោះយោបល់តាមទូរស័ព្ទដោយឥតគិតថ្លៃ ២៤/៧ ៖ ក្រុមអ្នកពិគ្រោះយោបល់របស់ CHC បានឆ្លើយការហៅចូលទូរស័ព្ទចំនួន ១៤ ១៤៥ដង ក្នុងនោះអតិថិជនចំនួន ២ ២៧៥នាក់ បានទទួលការពិគ្រោះយោបល់តាមទូរស័ព្ទ អតិថិជនចំនួន ៥៨ នាក់ បានរាយការណ៍អំពីបញ្ហាទាក់ទងនឹងការការពារកុមារ និងអតិថិជនចំនួន៤ ៣១០នាក់ បានទទួលសេវាកម្មអប់រំ និងព័ត៌មានផ្អែកលើបញ្ហា។ក្នុង

[16] របាយការណ៍សមិទ្ធផលការងារ ឆ្នាំ២០២៤ និងទិសដៅឆ្នាំ២០២៥ របស់អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា (CHC)

ចំណោមអតិថិជន ១៤ ១៤៥នាក់ មាន (ស្ត្រី ៤ ៤២៣នាក់, បុរស២ ២១៨នាក់, LGBTIQ ១៤៤នាក់, មិនអាចកំណត់អត្តសញ្ញាណយេនឌ័របាន ៧ ៣៦០នាក់)។ ក្នុងចំណោមអតិថិជន ១៤ ១៤៥នាក់ មាន (កុមារ ៦៨៧នាក់ យុវជន ១ ៣៥២នាក់ មនុស្សពេញវ័យ ២ ៩៩៧នាក់ មិនអាចកំណត់អាយុបាន ៩ ១០៩នាក់)។

២៧២. ផ្តល់ការពិគ្រោះយោបល់ដល់គ្រួសារ សេវាសុខភាពបឋម និងមនុស្សធម៌៖ សេវាប្រឹក្សាគ្រួសារ សេវាសុខភាពបឋម និងសេវាមនុស្សធម៌ គឺជាកម្មវិធីយុទ្ធសាស្ត្ររបស់ CHC ដែលបង្កើតឡើង ដើម្បីបំបែកវប្បធម៌នៃភាពស្ងៀមស្ងាត់ និងការបិទបាំងការរំលោភបំពាននៅក្នុងសហគមន៍ ដែលក្មេងស្រី និងក្មេងជំទង់ត្រូវបានអប់រំឱ្យនៅស្ងៀម និងរក្សាការសម្ងាត់ចំពោះអំពើហិង្សា និងការរំលោភបំពានដែលសមាជិកគ្រួសារ ឬដៃគូជិតស្និទ្ធបានប្រព្រឹត្តប្រឆាំងនឹងពួកគេ។ ជួយគាំទ្រដល់កុមារក្មេងជំទង់ ក្មេងស្រី និងស្ត្រីដែលរងផលប៉ះពាល់ដោយអំពើហិង្សា និងការរំលោភបំពាន។ CHC ផ្តល់សេវាប្រឹក្សាគ្រួសារ សេវាសុខភាពបឋម និងសេវាមនុស្សធម៌ដល់ស្ត្រី និងកុមារីចំនួន៤១នាក់ ដែលជាជនរងគ្រោះ/អ្នករួចរស់ពីការរំលោភបំពាន និងអំពើហិង្សា ដើម្បីកាត់បន្ថយបន្ទុកសេដ្ឋកិច្ចគ្រួសារ និងភាពក្រីក្រ។ ការផ្តល់សេវាពិគ្រោះយោបល់តាមគ្រួសារ រួមមានព័ត៌មានអប់រំអំពីសុខភាពផ្លូវភេទ និងសិទ្ធិបន្តពូជ ផែនការគ្រួសារ ការពន្យារកំណើត/គម្លាតពីកំណើត ភាពជាឪពុកម្តាយវិជ្ជមាន ផលវិបាកអវិជ្ជមាននៃកុមារ/ការរៀបអាពាហ៍ពិពាហ៍នៅក្មេងពេក ការមានផ្ទៃពោះក្នុងវ័យជំទង់ អំពើហិង្សា និងការរំលោភបំពាន និងរបៀបរាយការណ៍ទៅអាជ្ញាធរដែលនៅជិតបំផុត ឬទូរស័ព្ទជំនួយឥតគិតថ្លៃ 1280 សម្រាប់ជួយគាំទ្រ។ សេវាសុខភាពបឋម និងមនុស្សធម៌ រួមមានការផ្តល់អាហារូបត្ថម្ភ និងសម្ភារៈអនាម័យ ដូចជា ត្រីខកំប៉ុង វីតាមីន សាប៊ូ និងសាប៊ូកក់សក់ សម្ភារៈសង្គ្រោះបឋម អាល់កុល របាំង និងថ្នាំបញ្ចុះកម្តៅ និងជំងឺផ្តាសាយ។

២៧៣. ផ្តល់ជំនួយផ្នែកច្បាប់ ដោយឥតគិតថ្លៃ៖ ស្ត្រីនិងកុមារី ដែលជាជនរងគ្រោះនៃអំពើហិង្សា និងការរំលោភបំពានផ្លូវភេទ បន្តប្រាប់អ្នកពិគ្រោះយោបល់ជួរមុខរបស់ CHC ថា ពួកគេមិនអាចដាក់ពាក្យបណ្តឹងនៅតុលាការប្រឆាំងជនល្មើស បានទេ ដោយសារការលំបាក/បញ្ហាប្រឈមហិរញ្ញវត្ថុ។ CHC ផ្តល់កញ្ចប់ជំនួយផ្នែកច្បាប់ពេញលេញ ដែលរួមមាន តំណាងផ្លូវច្បាប់ ថ្លៃតុលាការ និងថ្លៃធ្វើដំណើរ ដើម្បីឱ្យស្ត្រី និងកុមារី អាចប្តឹងតវ៉ានៅតុលាការប្រឆាំងនឹងអ្នករំលោភបំពាន/ជនល្មើសផ្លូវភេទ និងអ្នកដែលប្រព្រឹត្តអំពើហិង្សា ហើយធានាថាស្ត្រី និងកុមារីអាចទទួលបានដំណោះស្រាយផ្លូវច្បាប់ និងការផ្សះផ្សា តាមរយៈជំនួយផ្នែកច្បាប់។ នៅឆ្នាំ ២០២៤ CHC បានបញ្ជូនអតិថិជនចំនួន ៩២ នាក់ (ស្រី ៦៨ នាក់ ប្រុស ២៤ នាក់) ទៅសេវាកម្មជំនួយផ្នែកច្បាប់។ យោងតាមមតិអ្នកផ្តល់សេវាផ្លូវច្បាប់ ករណីមួយត្រូវបានបញ្ចប់នៅក្នុងតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ១០ឆ្នាំ និងសងជំងឺចិត្ត ៥លានរៀល។ លើសពីនេះទៀតករណីពីរផ្សេងទៀតត្រូវបានដោះស្រាយតាមរយៈការសម្របសម្រួលនៅខាងក្រៅប្រព័ន្ធតុលាការ។

២៧៤. ការបញ្ជូនបន្ត និងតាមដាន៖ CHCមានគោលការណ៍ដើម្បីការពារការសម្ងាត់របស់អតិថិជន និងគោរពការសម្រេចចិត្តរបស់អតិថិជនក្នុងការបញ្ជូនបន្ត។ អតិថិជនចំនួន ១៧៩នាក់ (ស្ត្រី១២៧នាក់, បុរស៥០នាក់, អ្នកស្រឡាញ់ភេទដូចគ្នា២នាក់) ត្រូវបានបញ្ជូនបន្ត ដោយផ្អែកលើការយល់ព្រមរបស់ពួកគេសម្រាប់សេវាផ្ទាល់ និងអន្តរាគមន៍ភ្លាមៗជាមួយដៃគូអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ច។ ក្នុងចំណោមអតិថិជន ដែលបានបញ្ជូនបន្តចំនួន ១៧៩នាក់ អតិថិជន១៤នាក់ទទួលបានជំនួយសុខភាពផ្លូវកាយ, ២៣នាក់ទទួលបានសុខភាពផ្លូវចិត្តជំនួយ, ៩២នាក់ បានទទួលជំនួយផ្នែកច្បាប់, ១៣នាក់ បានទទួលជំនួយតម្រូវការមូលដ្ឋាន, ៣នាក់ បានទទួលការអប់រំសេវា, ១៤នាក់ ទទួលសេវាអន្តរាគមន៍, ៦នាក់ ទទួលជំនួយ

លើការស្វែងរកការងារ, ៣នាក់ ទទួលសេវាធ្វើចំណាកស្រុក, ១នាក់ បានទទួលសេវាស៊ើបអង្កេត, ១នាក់ ទទួលបានជម្រក និង ៩នាក់ បានទទួលសេវាកម្មផ្សេងៗ។ អតិថិជនចំនួន ១ ៩២២ នាក់ ត្រូវបានតាមដាន ដើម្បីធានាថាពួកគេមានសុវត្ថិភាព និងរស់នៅក្នុងបរិយាកាសការពារ។

២៧៥. ថ្នាលប្រព័ន្ធផ្សព្វផ្សាយសង្គម៖ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ទំព័រ Facebook របស់ Child Helpline Cambodia មាន អ្នកតាមដានចំនួន ១ ០៦៩ ១៣៣ នាក់ (ស្ត្រី៥១.៧% និងបុរស៤៨.៣%)។ ភាគច្រើន នៃអ្នកតាមដានមានអាយុចន្លោះពី១៣ ទៅ៤៤ឆ្នាំ។ នៅឆ្នាំ២០២៤ ក្រុមអ្នកពិគ្រោះយោបល់ CHC បានផ្តល់ សេវាប្រឹក្សាតាមអនឡាញដល់យុវជនចំនួន ៣៤៤នាក់ និងព័ត៌មានផ្អែកលើបញ្ហាដល់យុវជនចំនួន ៤ ៣១០ នាក់ តាមរយៈកម្មវិធីផ្ញើសារសន្ទនា Facebook។

២៧៦. ការបង្ការ-ទប់ស្កាត់ មានគោលបំណង ដើម្បីទប់ស្កាត់អំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច តាម រយៈ ការចូលរួមពីសហគមន៍ ភ្នាក់ងារផ្លាស់ប្តូរសង្គម និងអាជ្ញាធរមូលដ្ឋានក្នុងការបង្កើតបរិយាកាស សុវត្ថិភាព ការចូលរួម និងគាំទ្រដល់កុមារ និងយុវជន ដើម្បីឱ្យពួកគេយល់ដឹងពីសិទ្ធិ និងឈានដល់សក្តានុពលពេញ លេញ។ យន្តការរាយការណ៍ និងការឆ្លើយតបបញ្ហារបស់កុមារ (CRRM)៖ CHC បានបណ្តុះបណ្តាលមន្ត្រី រាជការនៅមូលដ្ឋានចំនួន ១៨០នាក់ (ស្រី១០៦នាក់) រួមមាន សមាជិក គ.ក.ន.ក. អភិបាលរងស្រុក មន្ត្រី មកពីមន្ទីរសង្គមកិច្ច នគរបាល មេភូមិ ប្រធានមណ្ឌលសុខភាព និងនាយកសាលា នៅខេត្តស្ទឹងត្រែង និង ខេត្តរតនគិរី ក្នុងឆ្នាំ២០២៤ ដោយផ្តោតលើយន្តការរាយការណ៍ និងការឆ្លើយតបបញ្ហារបស់កុមារ មូលដ្ឋាន គ្រឹះនៃការពិគ្រោះយោបល់ ការសង្គ្រោះផ្លូវចិត្តបឋម ការបញ្ជូនបន្ត និងការគ្រប់គ្រងករណី។

២៧៧. យុវជនប្រេសិតរបស់បណ្តាញទូរស័ព្ទជំនួយកុមារ៖ CHC បានបណ្តុះបណ្តាលយុវជនចំនួន ១៧៦នាក់ (ស្រី ១១៣នាក់) ទៅលើមូលដ្ឋានគ្រឹះនៃការពិគ្រោះយោបល់ ការអប់រំផ្លូវភេទទូលំទូលាយ (CSE) សុខភាពផ្លូវ ភេទ ការបន្តពូជ (SRH) និងជំនាញសម្របសម្រួលក្នុងការបញ្ជូនបន្ត នៅខេត្តកំពង់ចាម ត្បូងឃ្មុំ មណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ។ ក្រុមយុវជនដែលចូលរួមបានបង្ហាញពីការប្តេជ្ញា ចិត្ត និងការចូលរួមយ៉ាងសកម្មតាមរយៈការពិភាក្សា ជាក្រុម និងអនុវត្តជំនាញរបស់ពួកគេជាមួយនឹងភាព ជឿជាក់កម្រិតខ្ពស់។ ក្រុមយុវជនដែលបានទទួលការបណ្តុះបណ្តាល បានរៀនពីមូលដ្ឋានគ្រឹះនៃការ ពិគ្រោះយោបល់ ការអប់រំផ្លូវភេទ (CSE) សុខភាពផ្លូវភេទទូលំទូលាយ ការបន្តពូជ (SRH) និងដំណើរការ បន្ទប់សុខភាពសាលារៀន ការបញ្ជូនទៅកាន់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក។

២៧៨. ស្វ័យសិក្សា Chatbot/Autobot៖ នៅខែមិថុនា ឆ្នាំ២០២២ CHC ដោយមានជំនួយផ្នែកហិរញ្ញវត្ថុពីភ្លែនអន្តរ ជាតិ បានរៀបចំបណ្តាញទំនាក់ទំនងសង្គម (Social Media)។ សៀវភៅណែនាំការស្វ័យសិក្សាប្រព័ន្ធ chatbot ដែលលក្ខណៈមេត្រីសម្រាប់កុមារ អំពីសិទ្ធិកុមារ បច្ចេកទេសស្វ័យការពារ ការរំលោភបំពាន និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ សមភាពយេនឌ័រ អំពើហិង្សាលើកុមារ និងសិទ្ធិផ្លូវភេទ និង សុខភាពបន្តពូជ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ មានអ្នកប្រើប្រាស់៩២៧នាក់ (កុមារី ២០៤នាក់, ស្ត្រី ១០៤នាក់ អាយុចន្លោះ ១៨ឆ្នាំ ដល់ ២៤ឆ្នាំ, កុមារា ៤១០នាក់, បុរស ១៩៨នាក់ អាយុចន្លោះ ១៨ឆ្នាំ ដល់ ២៤ឆ្នាំ និងអត្តសញ្ញាណយេនឌ័រផ្សេងៗទៀតចំនួន ១១នាក់) បានចូលប្រើថ្នាលសន្ទនា Chatbot សម្រាប់ ស្វ័យសិក្សា ដែលក្នុងនោះ រួមមាន មេរៀនទី១ "តម្លៃ និងសិទ្ធិ" មេរៀនទី២ "ចំណេះដឹងរបស់ខ្ញុំ និងសុវត្ថិ ភាពរបស់ខ្ញុំ" មេរៀនទី៣ "ខ្ញុំឆ្លាតក្នុងការប្រើប្រាស់វេទិកាអនឡាញ" មេរៀនទី៤ "ខ្ញុំមានសក្តានុពលសម្រាប់

ការផ្លាស់ប្តូរជាវិជ្ជមាន" មេរៀនទី៥ "គ្មាននរណាម្នាក់អាចប្រព្រឹត្តអំពើហិង្សា និងការកេងប្រវ័ញ្ចលើខ្ញុំបានទេ" និងមេរៀនទី៦ "ខ្ញុំត្រៀមខ្លួនជាស្រេចដើម្បី ក្លាយជាមនុស្សពេញវ័យ"។ Chatbot សម្រាប់ស្វ័យសិក្សាអាចចូលមើលបាននៅទីនេះ https://web.facebook.com/chc1280chatbot ។

២៧៩. កម្មវិធីអេបសុខភាពយុវវ័យ (Youth Health Mobile App)៖ "សុខភាពយុវជន" គឺជាកម្មវិធីទូរស័ព្ទដែលងាយស្រួលសម្រាប់យុវវ័យដោយឥតគិតថ្លៃ ជាភាសាខ្មែរ ដែលផ្តល់ឱ្យកុមារ វ័យជំទង់ និងយុវជនកម្ពុជានូវព័ត៌មាន និងសេវាកម្មសំខាន់ៗ ដែលអាចទុកចិត្តបាន និងជាក់ស្តែងលើព័ត៌មាន និងសេវាសុខភាពបន្តពូជផ្លូវភេទ (SRHR) ការអប់រំផ្លូវភេទទូលំទូលាយ (CSE) យេនឌ័រ និងសុខភាពផ្លូវចិត្ត និងជំនួយផ្លូវចិត្ត (MHPSS) និងវីដេអូកម្សាន្តអប់រំ។ សុខភាពយុវជនត្រូវបានបង្កើតឡើងដើម្បីឱ្យកុមារ ក្មេងជំទង់ និងយុវជនអាចធ្វើការជ្រើសរើសបានកាន់តែប្រសើរ និងអនុវត្តសិទ្ធិរបស់ពួកគេ។ វាក៏មានតំណភ្ជាប់ទៅកាន់គ្លីនិក ឬអ្នកផ្តល់សេវា និងបណ្តាញជំនួយឥតគិតថ្លៃដោយផ្ទាល់ពីកម្មវិធីទូរស័ព្ទ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ កុមារជំទង់ និងយុវជនចំនួន ៣១២ ០០០ នាក់បានចូលប្រើប្រាស់កម្មវិធីសុខភាពយុវជន ដែលក្នុងនោះមានអ្នកប្រើប្រាស់សកម្មចំនួន ១០០ ០០០ នាក់ ។ Youth Health Mobile App អាចទាញយកបាននៅទីនេះ https://bit.ly/ 3Ek744T (Android) or https://apple.co/3Cagf6G (iOS)។

២៨០. កម្មវិធីអេប "ធ្វើដំណើរឆ្លងដែនរបស់ខ្ញុំ" (My Journey Mobile App) កម្មវិធីអេប "ធ្វើដំណើរឆ្លងដែនរបស់ខ្ញុំ" ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់សិទ្ធិអំណាច ដល់ស្ត្រីចំណាកស្រុកឱ្យទទួលបានព័ត៌មាន ដែលអាចឱ្យពួកគេជ្រើសរើសដោយខ្លួនឯងសម្រាប់ការធ្វើការងារចំណាកស្រុក។ កម្មវិធីអេប "ធ្វើដំណើរឆ្លងដែនរបស់ខ្ញុំ" មានផ្នែកសំខាន់ៗចំនួន៤ រួមមាន៖ ការធ្វើដំណើររបស់អ្នក សុវត្ថិភាពរបស់អ្នក ការស្វែងរកជំនួយ និងរឿងរ៉ាវរបស់អ្នក ដែលផ្តល់ព័ត៌ មានសំខាន់ៗសម្រាប់អ្នកប្រើប្រាស់ និងស្ត្រីចំណាកស្រុក។ ផ្នែកនីមួយៗមានអនុផ្នែក ដែលមានសារ និងព័ត៌មានជាក់លាក់សម្រាប់ពលករ ចំណាកស្រុកជាស្ត្រី និងសមាជិកគ្រួសាររបស់ពួកគេ ដើម្បីពិចារណា នៅពេលដែលពួកគេចង់ធ្វើចំណាកស្រុក។ មុខងារកម្មវិធី ក៏អនុញ្ញាតឱ្យអ្នកប្រើប្រាស់ចូលប្រើព័ត៌មានសំខាន់ៗទាក់ទងនឹងសុខភាពបន្តពូជ ការធ្វើផែនការគ្រួសារ ស្វ័យភាពលើរាងកាយរបស់ស្ត្រី តាមរយៈតំណភ្ជាប់។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ មានការទាញយកច្រើនជាង ៤ ០៧០។ កម្មវិធីអេប"ធ្វើដំណើរឆ្លងដែនរបស់ខ្ញុំ" អាចទាញយកបាននៅទីនេះ៖ http://bit.ly/myjourney mobileapp។

២៨១. កម្មវិធីអេប "សុវត្ថិភាពយើង" (Safe App)៖ កម្មវិធីអេប "សុវត្ថិភាពយើង" ត្រូវបានផ្តួចផ្តើមដោយក្រសួងកិច្ចការនារី ដែលផ្តល់មូលនិធិដោយ UNFPA និងអនុវត្តដោយ CHC ។ កម្មវិធីអេបសុវត្ថិភាពយើង គឺជាឌីជីថលវេទិកាដែលគាំទ្រ និងការពារជនរងគ្រោះពី អំពើហិង្សាផ្អែកលើយេនឌ័រ។ មុខងារនៅក្នុង កម្មវិធីសុវត្ថិភាពយើង រួមមាន ជំនួយបន្ទាន់ ការយល់ដឹងអំពីអំពើហិង្សាផ្អែកលើយេនឌ័រ អន្តរាគមន៍ ជំនួយផ្នែកច្បាប់ សេវាគាំទ្រ គន្លឹះសម្រាប់ការថែទាំខ្លួនឯង និងទំនាក់ទំនង ផែនទី និងតំណភ្ជាប់ទៅកាន់សេវាកម្ម។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៤ កម្មវិធីអេបសុវត្ថិភាពយើង មានអ្នកប្រើប្រាស់ច្រើនជាង ៦ ៦៨៣ នាក់ រួមទាំងស្ត្រីដែលធ្វើការក្នុងឧស្សាហកម្មកាត់ដេរ និងនិស្សិតដែលកំពុងធ្វើការ និងរស់នៅក្នុងរាជធានីភ្នំពេញ។ កម្មវិធីអេប "សុវត្ថិភាពយើង" ត្រូវបានផ្តួចផ្តើមដោយក្រសួងកិច្ចការនារី។ គាំទ្រដោយមូលនិធិ Wesley តាមរយៈ UNFPA ក្នុងការសហការជាមួយបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា។

២៨២. បន្ទប់សុខភាពសាលារៀន៖ បន្ទប់សុខភាពសាលាគឺជាយន្តការមួយដែលបានផ្តួចផ្តើម និងបើកដំណើរការដោយក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ឧបត្ថម្ភដោយ UNFPA តាមរយៈការងារនៅក្នុងភាពជាដៃគូក្នុងប្រទេសកម្ពុជា ដែលមានគោលបំណងផ្តល់លទ្ធភាពទទួលបានបញ្ហាសុខភាពនៅក្នុងសាលារៀន និងលើកកម្ពស់សមភាពយេនឌ័រ។ បន្ទប់សុខភាពសាលារៀនត្រូវបានដំណើរការនៅក្នុងសាលាគោលដៅចំនួន ៨ ក្នុងខេត្តចំនួន ៨ ក្នុងប្រទេសកម្ពុជា។ ឧបករណ៍បណ្តុះបណ្តាលបន្ទប់សុខភាពសាលា និងនីតិវិធីត្រូវបានបង្កើតឡើង ដើម្បីណែនាំដល់គណៈកម្មការបន្ទប់សុខភាពសាលា និងក្រុមមិត្តអប់រំមិត្ត។ ក្រុមមិត្តអប់រំមិត្តចំនួន ១៨៩ នាក់ (ស្រី ១១៨ នាក់) នៃបន្ទប់សុខភាពសាលាទទួលបានចំណេះដឹង និងជំនាញលើសុខភាពផ្លូវភេទ ការបន្តពូជ ការអប់រំផ្លូវភេទទូលំទូលាយ ជំនួយសង្គ្រោះបឋម មូលដ្ឋានគ្រឹះនៃការពិគ្រោះយោបល់ និងការសម្របសម្រួលដល់មិត្តភក្តិផ្សេងទៀតប្រហែល ១៧០ ០០០នាក់ ដែលជាសិស្ស និងយុវជនសហគមន៍នៅដាច់ស្រយាលពីសហគមន៍។ នៅឆ្នាំ ២០២៤ សិស្សចំនួន ៤១៤នាក់ (ស្រី ៣៣២នាក់) ទទួលបានសេវាពិគ្រោះទាក់ទងនឹងសុខភាព។ សិស្សចំនួន ១២៤នាក់ (ស្រី ៩០នាក់) បានចូលប្រើសេវាពិគ្រោះទូទៅ សិស្ស ៣៨៨នាក់ (ស្រី ៦០នាក់) បានទទួលសេវាសង្គ្រោះបឋម ហើយសិស្សចំនួន ៤៥នាក់ (ស្រី ៤៣នាក់) ត្រូវបានបញ្ជូនទៅមណ្ឌលសុខភាព។

២៨៣. ការតស៊ូមតិមានគោលបំណង ដើម្បីបញ្ចុះបញ្ចូល/តស៊ូមតិដោយផ្ទាល់ និងតាមរយៈសម្ព័ន្ធជាប្រព័ន្ធសម្រាប់កែទម្រង់គោលនយោបាយ និងបទបញ្ញត្តិ ដែលលើកកម្ពស់ប្រព័ន្ធការយល់ដឹង និងពង្រឹងការពារកុមារ ក្នុងការលើកកម្ពស់សិទ្ធិរបស់កុមារ យុវជន និងក្រុមគ្រួសាររបស់ពួកគេ។ ការទំនាក់ទំនង និងបោះពុម្ពផ្សាយ៖ ទំនាក់ទំនង និងយុទ្ធនាការសាធារណៈរបស់ទំព័រហ្វេសប៊ុក Child helpline Cambodia (CHC) មានអ្នកតាមដានជាង ១ ០៦៩ ១៣៣ នាក់ (ស្ត្រី៥១.៧% និង បុរស ៤៨,៣%) ដែលមានអាយុចន្លោះពី១៣ ទៅ៤៤ឆ្នាំ។ សិក្ខាសាលា/សន្និសីទអន្តរជាតិ ក្នុងតំបន់ និងថ្នាក់ជាតិ៖ នៅខែវិច្ឆិកា ឆ្នាំ ២០២៤ នាយកប្រតិបត្តិរបស់អង្គការបណ្តាញទូរស័ព្ទជំនួយកុមារត្រូវបានអញ្ជើញជាវាគ្មិនដ៏សំខាន់ម្នាក់នៅក្នុងកិច្ចសន្ទនាអភិវឌ្ឍន៍មេគង្គ ២.០។ នាយកប្រតិបត្តិអង្គការបណ្តាញទូរស័ព្ទជំនួយកុមារបានថ្លែងសុន្ទរកថា ផ្តោតជាសំខាន់លើ "Organized Crime ៖ ការយល់ដឹងអំពីសំណួរទាក់ទងនឹងយេនឌ័រ ការរើសអើង និងការរួមបញ្ចូលសង្គម"។ នៅក្នុងខែធ្នូ ឆ្នាំ២០២៤ នាយកប្រតិបត្តិរបស់អង្គការបណ្តាញទូរស័ព្ទជំនួយកុមារបានចូលរួមទិវាជនចំណាកស្រុកអន្តរជាតិជាមួយ IOM ។ ប្រធានបទជាសកលនៅឆ្នាំ២០២៤គឺ "រឿងរាល់ជំហាន" ។ ដើម្បីទាក់ទាញការយកចិត្តទុកដាក់ចំពោះសារៈសំខាន់ នៃការជួយជនចំណាកស្រុកក្នុងគ្រប់ដំណាក់កាលរបស់ពួកគេ វដ្តនៃការធ្វើចំណាកស្រុក។ នាយកប្រតិបត្តិរបស់បណ្តាញទូរស័ព្ទជំនួយកុមារ បានលើកឡើងពីកង្វល់ជុំវិញបណ្តាញរត់ពន្ធមនុស្សព្រំដែនកម្ពុជាជាមួយប្រទេសថៃ និងបានពិភាក្សាអំពីលទ្ធភាពណាមួយសម្រាប់កិច្ចខិតខំប្រឹងប្រែងតស៊ូមតិរួមគ្នាក្នុងចំណោមអង្គការសង្គមស៊ីវិល ដើម្បីបញ្ចុះបញ្ចូលរដ្ឋាភិបាលឲ្យបញ្ចុះតម្លៃលិខិតឆ្លងដែនដល់ពលករចំណាកស្រុក ដែលធ្វើការចំណាកស្រុកទៀងទាត់ និងមិនទៀងទាត់ដែលមានអត្តសញ្ញាណប័ណ្ណក្រីក្រ។

២៨៤. ការអភិវឌ្ឍអង្គការ៖ ការគ្រប់គ្រងកម្មវិធី ដើម្បីធានាបាននូវការអនុវត្តកម្មវិធី និងប្រតិបត្តិការសេវាកម្មប្រកបដោយប្រសិទ្ធភាព តាមរយៈចក្ខុវិស័យ ការធ្វើផែនការ ការរៃអង្គាសប្រាក់ ការត្រួតពិនិត្យ និងការវាយតម្លៃ។ ក្រុមការងារគ្រប់គ្រង រួមមាន នាយកប្រតិបត្តិ អ្នកគ្រប់គ្រងកម្មវិធី អ្នកសម្របសម្រួលគម្រោង អ្នកគ្រប់គ្រងប្រឹក្សា មន្ត្រីគម្រោង ហិរញ្ញវត្ថុ និងមន្ត្រីរដ្ឋបាល។ នាយកប្រតិបត្តិ មានតួនាទីយ៉ាងសំខាន់ក្នុងការសម្រប

សម្រួលគម្រោងទាំងអស់ និងធានាថា CHC ប្រកាន់ខ្ជាប់នូវស្តង់ដារខ្ពស់បំផុតនៃតម្លាភាព គណនេយ្យភាព និងសេវាកម្មប្រកបដោយគុណភាពដល់កុមារ យុវជន ស្ត្រី និងគ្រួសាររបស់ពួកគេ។ ការគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាល បង្កើត និងអនុវត្តគោលនយោបាយដែលធានាតម្លាភាព និងគណនេយ្យភាពក្នុងការប្រើប្រាស់មូលនិធិរបស់ CHC។ ការងារនេះមានសារៈសំខាន់ក្នុងការរក្សាការជឿទុកចិត្តក្នុងចំណោមគណៈគ្រប់គ្រង បុគ្គលិកគម្រោង និងម្ចាស់ជំនួយ។ ដើម្បីធានាបាននូវការសម្របសម្រួល និងដំណើរការដោយរលូននៃសកម្មភាពប្រចាំថ្ងៃរបស់អង្គការ ការគាំទ្រផ្នែកដឹកជញ្ជូន និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អង្គការ។ ការអភិវឌ្ឍធនធានមនុស្ស បុគ្គលិក CHC បានចូលរួមក្នុងសិក្ខាសាលាពង្រឹងសមត្ថភាពដោយផ្អែកលើតម្រូវការរបស់ពួកគេ។ នៅឆ្នាំ ២០២៤ ប្រធានផ្នែកពិគ្រោះយោបល់ អ្នកសម្របសម្រួលគម្រោង និងក្រុមអ្នកពិគ្រោះយោបល់ជួរមុខ បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការសរសេររឿងចំណាប់អារម្មណ៍របស់មនុស្ស ការសរសេររបាយការណ៍ ការប្រមូលទិន្នន័យ និងកម្មវិធីអេបសុវត្ថិភាពយើង។ សិក្ខាសាលានេះត្រូវបានគាំទ្រដោយ UNFPA កម្ពុជា។

### ៩. អង្គការសម្ព័ន្ធដើម្បីសិទ្ធិកុមារកម្ពុជា - ស.ស.ក. (CRC Cambodia)

២៨៥. នៅក្នុងឆ្នាំ២០២៤ នេះ ស.ស.ក. និងបណ្តាញ ដែលដឹកនាំដោយកុមារ និងយុវជន (CAN, CCYMCR, AYRG) បានសម្រេចនូវសមិទ្ធផលជាច្រើនទៅតាមគោលដៅយុទ្ធសាស្ត្ររបស់ស្ថាប័នរួមមាន៖

២៨៦. ចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤ អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា សហការជាមួយក្រសួងកិច្ចការនារី បានគាំទ្រដោយជោគជ័យនូវយុទ្ធនាការ ១៦ថ្ងៃ ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី និងកុមារី ដោយបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការប្រឆាំងនឹងអំពើហិង្សាលើយេនឌ័រ និងការជំរុញសមភាពយេនឌ័រនៅកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងរួមគ្នានេះ ជាកញ្ចប់ជំនួយដ៏ទូលំទូលាយមួយត្រូវបានផ្តល់ជូន រួមទាំងសម្ភារៈអប់រំ យុទ្ធនាការយល់ដឹង និងវគ្គពង្រឹងសមត្ថភាពសម្រាប់អ្នកពាក់ព័ន្ធសំខាន់ៗ។

២៨៧. អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា បានសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររៀបចំវេទិកាការជួបគ្នារវាងកុមារ និងយុវជន និងអ្នកបង្កើតគោលនយោបាយ ដែលមានអ្នកចូលរួមចំនួន ១៧៩នាក់ (ស្រី ៨៨នាក់) រួមទាំងកុមារ និងយុវជនចំនួន ១៥៦នាក់ តំណាង ៥នាក់ មកពីក្រសួងសំខាន់ៗដូចជា MoSVY, MoEYS, MoI, MPTC និង MoH រួមជាមួយនឹងអង្គការសមាជិកមកពី ១៨ CSOs ដែលជាសមាជិករបស់ CRC-Cambodia ដើម្បីធ្វើកិច្ចសន្ទនា។

២៨៨. អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា បានសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងក្រសួងសំខាន់ៗផ្សេងទៀត ដើម្បីប្រារព្ធខួបលើកទី៧៥ នៃទិវាកុមារអន្តរជាតិ និងខួបលើកទី២៣ នៃទិវាពិភពលោកប្រឆាំងពលកម្មកុមារនៅកោះពេជ្រ។ ព្រឹត្តិការណ៍នេះគឺជាការប្រមូលផ្តុំដ៏សំខាន់មួយដែលមានអ្នកចូលរួមចំនួន ៣ ៣២០នាក់ រួមទាំងកុមារជាច្រើននាក់ មន្ត្រីរដ្ឋាភិបាល តំណាងសង្គមស៊ីវិល និងដៃគូអន្តរជាតិ។ អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា បានគាំទ្រកុមារ និងយុវជនចំនួន ២៧០នាក់ (ស្រី ១៤៨នាក់) ដើម្បីចូលរួម និងការបោះពុម្ពអាវយឺតចំនួន២៥០ សម្រាប់ពិធីដ៏សំខាន់នេះ។ ក្នុងឱកាសប្រារព្ធពិធីនេះ តំណាងពីររូបមកពីបណ្តាញដឹកនាំកុមារ និងយុវជន ក៏បានបង្ហាញសេចក្តីថ្លែងការណ៍រួមក្នុងនាមមិត្តភ័ក្តិរបស់ពួកគេ ដែលពួកគេបានលើកឡើងអំពីការអភិវឌ្ឍន៍នៃការអនុវត្តសិទ្ធិកុមារនៅកម្ពុជា។

២៨៩. រាជរដ្ឋាភិបាលកម្ពុជាបានធ្វើឱ្យមានការវិវឌ្ឍន៍ផ្នែកច្បាប់ប្រឆាំងនឹងការរំលោភបំពានលើកុមារ ការជួញដូរ ការកេងប្រវ័ញ្ច និងការមិនអើពើ។ ដើម្បីដោះស្រាយអំពើហិង្សាលើកុមារជាបន្តបន្ទាប់ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានដឹកនាំរៀបចំផែនការជាតិ NVAC ឆ្នាំ២០២៥-២០៣០។ អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា ដែលជាផ្នែកមួយនៃក្រុមការងារបច្ចេកទេសអន្តរក្រសួង និងជាមួយមូលនិធិ SIDA បានគាំទ្រកុមារ និងយុវជនចំនួន១៤នាក់ មកពីខេត្តនានា ដើម្បីចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅថ្ងៃទី២០-២១ ខែកញ្ញា ឆ្នាំ ២០២៤ នៅខេត្តសៀមរាប។

២៩០. បន្ទាប់ពីកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិជាមួយកុមារ និងយុវជន អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា បានសម្របសម្រួលកុមារ និងយុវជនចំនួន ៩នាក់ មកពី CYLNs ដើម្បីចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការបញ្ចប់អំពើហិង្សាលើកុមារ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤។ ពួកគេបានពិនិត្យ និងផ្តល់ធាតុចូលសម្រាប់សេចក្តីព្រាងសេចក្តីថ្លែងការណ៍នៃការប្តេជ្ញាចិត្តសម្រាប់សន្និសីទថ្នាក់រដ្ឋមន្ត្រីសកលលើកទីមួយស្តីពី EVAC នៅទីក្រុង Bogota ប្រទេសកូឡុំប៊ី។ តំណាងកុមារ ២នាក់ (ស្រី១នាក់) បានបង្ហាញសេចក្តីថ្លែងការណ៍រួមជាមួយនឹងសំណើចំនួន ១៣ ពីការពិគ្រោះយោបល់ថ្នាក់ជាតិ។ ដំណើរការនេះ ធានាថាសំឡេងរបស់កុមារត្រូវបានរួមបញ្ចូលនៅក្នុងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការបញ្ចប់អំពើហិង្សាលើកុមារ។

២៩០. នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា បានរៀបចំសិក្ខាសាលាមួយដែលផ្តោតលើការបង្កើតសេចក្តីថ្លែងការណ៍រួម ដើម្បីជំរុញការអនុវត្តសិទ្ធិកុមារ ស្របតាមអនុសាសន៍របស់ UNCRC, UPR និង យោបល់ទូទៅលេខ២៦ (GC26)។ សិក្ខាសាលានេះមានអ្នកចូលរួមចំនួន ២០នាក់ (ស្រី ៩នាក់) មកពី ១៨ អង្គការសង្គមស៊ីវិល (CSOs)។

២៩១. កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានសហការជាមួយអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការធ្វើបច្ចុប្បន្នភាពលើការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានអ្នកចូលរួមចំនួន ៧១នាក់ (ស្រី១៩នាក់) ជាសមាជិក សមាជិកា ក.ជ.ក. មន្ត្រីបច្ចេកទេសនៃក្រសួងស្ថាប័នពាក់ព័ន្ធ តំណាងកុមារ និងយុវជន។ កិច្ចប្រជុំនះបានទទួលការគាំទ្រពីអង្គការដៃគូអភិវឌ្ឍន៍ ERIKS និងអង្គការសង្គ្រោះកុមារ តាមរយៈអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា។

២៩២. កុមារ និងយុវជនចំនួន ១៦នាក់ (ស្រី ១២នាក់) បានចូលរួមវេទិកាអាកាសធាតុ ដែលដឹកនាំដោយ LLC និងគាំទ្រការសម្របសម្រួលកុមារ និងយុវជនដោយអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា នៅខេត្តសៀមរាប និងបាត់ដំបង។ វេទិកាអាកាសធាតុរបស់យុវជន គឺជាវេទិកាមួយដែលបង្កើតឡើងដើម្បីផ្តល់សិទ្ធិអំណាចដល់យុវជនឱ្យក្លាយជាអ្នកចូលរួមយ៉ាងសកម្មក្នុងការដោះស្រាយបញ្ហាបន្ទាន់ នៃការប្រែប្រួលអាកាសធាតុ។ វេទិកានេះនឹងផ្តល់កន្លែងសម្រាប់យុវជនដើម្បីចែករំលែកទស្សនៈ គំនិត និងដំណោះស្រាយរបស់ពួកគេ និងដើម្បីសហការជាមួយភាគីពាក់ព័ន្ធ អ្នកជំនាញ និងមិត្តភ័ក្តិ ដើម្បីជំរុញសកម្មភាពប្រកបដោយអត្ថន័យ។

២៩៣. ដើម្បីលើកកម្ពស់ការចូលរួមរបស់កុមារី និងយុវតី ជាពិសេសក្នុងតួនាទីជាអ្នកដឹកនាំ អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា បានចូលរួមយ៉ាងសកម្ម និងផ្តល់សិទ្ធិអំណាចដល់ក្មេងស្រីដែលមានសក្តានុពលចំនួន ១៥ នាក់ ដែលមានអាយុពី ១២-១៧ ឆ្នាំ មកពីទីតាំងផ្សេងៗគ្នា រួមមានខេត្តពោធិសាត់ បាត់ដំបង កំពង់ឆ្នាំង កោះកុង កំពង់ស្ពឺ កំពត រតនគិរី និងរាជធានីភ្នំពេញ។ ក្មេងស្រីទាំងនេះបានដឹកនាំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការអប់រំរបស់កុមារី និងការប្រែប្រួលអាកាសធាតុ។ ការចូលរួមយ៉ាងសកម្មរបស់ពួកគេក្នុងដំណើរការសិក្ខាសាលានេះ បាលរៀបចំរបាយការណ៍មួយ ដែលត្រូវបានបញ្ចប់ និងដាក់ជូននាក់ពាក់ព័ន្ធ នៅចុងខែកុម្ភៈ ឆ្នាំ២០២៤។ គំនិតផ្តួចផ្តើមនេះបង្ហាញពីការប្តេជ្ញាចិត្តរបស់គម្រោងក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំ និងជំនាញតស៊ូមតិក្នុងចំណោមស្ត្រីវ័យក្មេង។

២៩៤. ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបានធ្វើឱ្យប្រសើរឡើងយ៉ាងខ្លាំង នូវសមត្ថភាពរបស់អង្គការសង្គមស៊ីវិលចំនួន២៤ ក្នុងការយល់ដឹង និងអនុវត្តការវិនិយោគសាធារណៈលើកុមារ (PIiC) ដោយបង្កើនជំនាញរបស់ពួកគេពី ៦៣% ទៅ ៨៩% ដែលជាការកែលម្អគួរឱ្យកត់សម្គាល់រហូតដល់ ២៦% ។ ការយល់ដឹងទាំងនេះបានធ្វើឱ្យអ្នកចូលរួមអាចអនុវត្តគម្រោងរបស់ពួកគេ ឱ្យកាន់តែមានប្រសិទ្ធភាពជាមួយនឹងផែនការរបស់រដ្ឋាភិបាល ការតស៊ូមតិសម្រាប់តម្រូវការសហគមន៍ក្នុងការបែងចែកថវិកា និងបង្កើតយុទ្ធសាស្ត្រដ៏ទូលំទូលាយដើម្បីចែករំលែកព័ត៌មាន PIiC និង CiP ជាមួយអ្នកទទួលផលគោលដៅរបស់ពួកគេ។

២៩៥. សមាជិកអង្គការក្រៅរដ្ឋាភិបាលចំនួន ៤០នាក់ (ស្រី ១២នាក់) បានបង្កើនការយល់ដឹងរបស់ពួកគេអំពីការត្រួតពិនិត្យសិទ្ធិកុមារ ដោយផ្តោតលើ UNCRC និង UPR ក្នុងអំឡុងពេលកិច្ចប្រជុំសមាជិកភាពប្រចាំឆ្នាំ។ កិច្ចប្រជុំនេះបានលើកកម្ពស់ការផ្លាស់ប្តូរការអនុវត្តប្រកបដោយជោគជ័យ និងកំណត់បញ្ហាប្រឈមក្នុងការអនុវត្ត UNCRC ដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គការក្រៅរដ្ឋាភិបាល និងរដ្ឋាភិបាល។

២៩៦. កិច្ចសហការរបស់អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា និងគណៈកម្មាធិការសហប្រតិបត្តិការសម្រាប់កម្ពុជា (CCC) ក្នុងការផ្តល់ការបណ្តុះបណ្តាលស្តីពីលំហាពលរដ្ឋសម្រាប់សិទ្ធិកុមារ អង្គការសង្គមស៊ីវិលក្នុងការបង្កើនលទ្ធភាពទទួលបានការធ្វើសេចក្តីសម្រេចចិត្ត។ តាមរយៈការបណ្តុះបណ្តាលនេះ សមាជិកអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣ មកពី អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជាបានបង្កើនការយល់ដឹងរបស់ពួកគេយ៉ាងស៊ីជម្រៅអំពីបញ្ហាដែលពាក់ព័ន្ធ និងការអនុវតត្តប្រកបដោយប្រសិទ្ធភាពនូវភាពស្មុគស្មាញនៃការតស៊ូមតិ និងការចូលរួមជាមួយអ្នកពាក់ព័ន្ធ។ ការរៀបចំផែនការយុទ្ធសាស្ត្រ និងកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់សិក្ខាសាលាបានបង្កើតនូវវេទិកាសម្រាប់អ្នកតស៊ូមតិវ័យក្មេងដើម្បីបញ្ចេញទស្សនៈរបស់ពួកគេដោយការចូលរួមប្រកបដោយអត្ថន័យកាន់តែច្រើនជាមួយអ្នកបង្កើតគោលនយោបាយ។ តាមរយៈការកសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលក្នុងការតស៊ូមតិដើម្បីសិទ្ធិកុមារ វគ្គបណ្តុះបណ្តាលក៏បានជំរុញឱ្យមានវិធីសាស្ត្រក្នុងការជះឥទ្ធិពលលើគោលនយោបាយ និងការអនុវត្តនៅថ្នាក់ជាតិ។

### ៦. អង្គការម្លប់ឬស្សី

២៩៧. ក្នុងរយៈពេលមួយឆ្នាំកន្លងមកនេះអង្គការម្លប់ឬស្សី បានធ្វើឱ្យមានការវិវត្តន៍គួរឱ្យកត់សម្គាល់នៅក្នុងទំនាក់ទំនង និងសហការជាមួយរដ្ឋាភិបាល ការចូលរួមរបស់សហគមន៍ និងកម្មវិធីថែទាំជំនួសចំពោះកុមារ។ តាមរយៈទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ការកសាងសមត្ថភាព និងការគាំទ្រដោយផ្ទាល់យើងបានពង្រឹងប្រព័ន្ធកែលម្អការថែទាំកុមារ ដែលងាយរងគ្រោះ និងលើកកម្ពស់ការថែទាំតាមគ្រួសារដើម្បី ទប់ស្កាត់ ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។ ដើម្បីបង្ហាញការងាររបស់យើងឲ្យបានច្បាស់ខណៈពេលដែលមានបញ្ហាប្រឈម យើងចាប់យកភាពប្រទាក់ក្រឡា ជាវិធីសាស្ត្ររួម ចំពោះការការពារកុមារក្នុងការថែទាំជំនួស យើងបានចាត់ថ្នាក់ភាពជាដៃគូរបស់យើងជា ៣ក្រុមៈ អ្នកមានសិទ្ធិទទួលកាតព្វកិច្ចស្របច្បាប់ អ្នកទទួលកាតព្វកិច្ចសីលធម៌ និងអ្នកម្ចាស់សិទ្ធិជាអ្នកទទួលផល ។ របាយការណ៍នេះនឹងផ្តោតលើប្រភេទទាំងនេះ ដោយសង្កត់ធ្ងន់ទាំងលទ្ធផល និងសមិទ្ធផល។

២៩៨. ការចូលរួមក្នុងគោលនយោបាយ និងបទប្បញ្ញត្តិ (ថ្នាក់ជាតិ) អង្គការម្លប់ឬស្សីបានចូលរួមជាមួយក្រុមបច្ចេកទេសថ្នាក់ជាតិនៅក្រសួងសង្គមកិច្ច ដោយបានចូលរួមបង្កើត ផែនការជាតិលើកទី២ (២០២៥-២០៣០) ស្តីពីការការពារកុមារ និងការឆ្លើយតបចំពោះអំពើហឹង្សាលើកុមារ។ ផែនការនេះនឹងធានាថាក្រុមពាក់ព័ន្ធសម្របសម្រួលវិធានការការពារកុមារ ឲ្យបានសមស្រប និងទាន់ពេលវេលា ដើម្បីអនុវត្តសិទ្ធិមូលដ្ឋានរបស់កុមារ។ លើសពីនេះ ទិវាសិទ្ធិកុមារ នឹងចងក្រងប្រតិបត្តិការណ៍ជាប្រចាំ នៅថ្ងៃទី១ ខែមិថុនា ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសិទ្ធិកុមារ។

២៩៩. គាំទ្រការអនុវត្តគោលនយោបាយ និងបទប្បញ្ញត្តិសម្រាប់ មណ្ឌលថែទាំជំនួសជាដៃគូ កិច្ចចូលរួមរបស់ភាគីពាក់ព័ន្ធត្រូវបានអនុវត្ត ដើម្បីឲ្យមណ្ឌលថែទាំ អាចឆ្លើយតបតាមស្តង់ដានៃការថែទាំកុមារ។ លើកកម្ពស់គុណភាពសេវាកម្មថែទាំកុមារ។ គ្រប់គ្រងករណីទាំងអស់ប្រកបដោយវិជ្ជាជីវៈ។ បង្កើតនីតិវិធីស្តង់ដាសម្រាប់ការធ្វើសមាហរណកម្មកុមារ និងផែនការសមាហរណកម្មសម្រាប់គ្រួសារ។ បង្កើតក្រុមការងារបច្ចេកទេសកម្រិតខេត្ត ដើម្បីគ្រប់គ្រងការបិទមណ្ឌលថែទាំ និងការបំប្លែងពីការថែទាំក្នុងមណ្ឌលទៅជាការថែទាំក្នុងសហគមន៍។ អនុវត្តនីតិវិធីស្តង់ដាសម្រាប់ការធ្វើសមាហរណកម្ម និងបិទមណ្ឌល ដើម្បីធានាសុវត្ថិភាព និងសិទ្ធិរបស់កុមារ។

៣០០. ការចូលរួមក្នុងការរៀបចំកិច្ចអន្តរាគមន៍ការការពារកុមារ (OVC Service Intervention)។ ចូលរួមក្នុងសន្និសិទករណី ដើម្បីអន្តរាគមន៍លើបញ្ហាកុមារ (ការរំលោភបំពាន អ្នកជួញដូរកុមារ ជំងឺជាសាធារណៈ និងបញ្ហាសុខភាព)។ ផ្តល់សេវាកម្មសំខាន់ៗដល់កុមារ និងគ្រួសារ (បញ្ហារចនាសម្ពន្ធ គ្រឿងសម្ភារៈសិក្សា សុវត្ថិភាព អាហារ និងលំនៅឋាន)។ ពង្រឹងសិទ្ធិកុមារ ដោយផ្តល់ឯកសារពាក់ព័ន្ធ (វិញ្ញាបនប័ត្រចំណាកស្រុក សៀវភៅគ្រួសារ និងការគាំទ្រផ្លូវច្បាប់)។ អនុវត្តការការពារកុមារដោយផ្អែកលើអនុសញ្ញាសិទ្ធិកុមារ (CRC) ក្រមរដ្ឋប្បវេណីជាតិស្តីពីការការពារកុមារ និងការណែនាំរបស់ក្រសួងសង្គមកិច្ច និងក្រសួងមហាផ្ទៃ។ គាំទ្រការធ្វើសមាហរណកម្ម (Reintegration Service)។ រៀបចំផែនការសមាហរណកម្មកុមារ។ សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការស្វែងរកគ្រួសារ និងវាយតម្លៃលទ្ធភាពសមាហរណកម្ម។ រៀបចំកិច្ចប្រជុំករណី ដើម្បីធានាការដាក់កុមារទៅក្នុងគ្រួសារ។ អភិវឌ្ឍសេវាសង្គមក្នុងសហគមន៍ ដើម្បីបំពេញតម្រូវការរបស់កុមារ។

## ឈ. សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ (ច.ក.យ.ក.ស.ក./CCYMCR)

៣០១. ច.ក.យ.ក.ស.ក. ជាសមាគមមួយមិនមែនរដ្ឋាភិបាល អព្យាក្រឹត និងមិនស្វែងរកប្រាក់កម្រៃជាឯកជន ប្រតិបត្តិការការងារមានលក្ខណៈជាបណ្តាញ ដែលមានសមាជិកជាបណ្តាញ ក្រុម ឬ ក្លឹបដែលដឹកនាំដោយកុមារ និងយុវជន ឯករាជ្យ មិនលំអៀង មិនបម្រើឲ្យនិន្នាការនយោបាយ ឬ សាសនាណាមួយឡើយ ដើម្បីបម្រើផលប្រយោជន៍របស់កុមារដោយគ្មានការរើសអើង។ ច.ក.យ.ក.ស.ក ត្រូវបានបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០០២ ដោយក្រុមកុមារ និងយុវជន និងបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩។ ច.ក.យ.ក.ស.ក មានទស្សនៈវិស័យចង់ឃើញ កុមារគ្រប់រូបនៅកម្ពុជាទទួលបានសិទ្ធិពេញលេញ ដូចដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងក្លាយជាពលរដ្ឋល្អ។ តាមរយៈគម្រោងពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិលដើម្បីសិទ្ធិកុមារ SIDA CSOs Strengthening Project 2022-2025 និងគម្រោងលើកកម្ពស់បរិយាប័ន្នកិច្ចការពារកុមារ រួមទាំងកុមារដែលមាននិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ នៅកម្ពុជាដំណាក់កាលទី២SOGIESC PROJECT 2023-2025 ។ ក្រោមការគាំទ្រពីអង្គការសង្គ្រោះកុមារ (Save The Children) ក្នុងឆ្នាំ២០២៤ ច.ក.យ.ក.ស.ក បានសម្រេចនូវសកម្មភាពជាច្រើនដើម្បីបម្រើឧត្តមប្រយោជន៍របស់កុមារនៅកម្ពុជា។

៣០២. បានរៀបចំនូវវគ្គបណ្តុះបណ្តាលស្តីពីការវិភាគស្ថានភាពសិទ្ធិកុមាររួមបញ្ចូលកុមារដែលមានSOGIE។ ដើម្បីលើកកម្ពស់ការចូលរួមរបស់កុមារក្នុងការធ្វើសេចក្តីសម្រេចចិត្ត បានការផ្តល់ការគាំទ្រថវិកាដល់ឃុំចំនួន៩ មានដូចជា ឃុំស្អក ឃុំក្លាំងហាយ ឃុំស្លា ឃុំព្រៃករកា ឃុំឈានមុខ ឃុំត្រាំសសរ ឃុំបឹងខ្នា ឃុំអ្នកលឿង ឃុំកន្ទួត លើដំណើរការ កិច្ចប្រជុំប្រចាំខែគណកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ (គ.ក.ន.ក)។ បានរៀបចំសិក្ខាសាលាស្តីពីការចូលរួមរបស់កុមារក្នុងដំណើរការកសាងផែនការវិនិយោគឃុំ/សង្កាត់។ បានរៀបចំសិក្ខាសាលាស្តីពីការពិគ្រោះយោបល់កុមារអំពីស្ថានភាពសិទ្ធិកុមារតាមបែបចូលរួមដល់អង្គការដៃគូ។ បានសហការជាមួយក្រសួង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រៀបចំនិងដឹកនាំចូលរួមកម្មវិធីវេទិការកុមារនិងអ្នកធ្វើគោលនយោបាយ ដើម្បីអោយអ្នកពាក់ព័ន្ធធ្វើការឆ្លើយតបទៅនិងសិទ្ធិមូលដ្ឋានទាំង៤របស់កុមារ។ បានរៀបចំសិក្ខាសាលា ស្តីពីការគៀងគរធនធាន។ បានមានកិច្ចសហការជាមួយក្រសួងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ចូលរួមរៀបចំទិវាកុមារអន្តជាតិ នៅសាលមហោស្រពកោះពេជ្រ។ រៀបចំកិច្ចសិក្ខាសាលាពិគ្រោះយោបល់កុមារ ស្តីពីការព្រាងរបាយការណ៍ស្ថានភាពសិទ្ធិកុមារ និងពិគ្រោះយោបល់អំពីការរៀបចំផែនការយុទ្ធសាស្ត្ររបស់អង្គការសង្គ្រោះកុមារ។ រៀបចំសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ ស្តីអំពីស្ថានភាពសិទ្ធិកុមារនៅភ្នំពេញ។ បានរៀបកិច្ចប្រជុំសន្និបាតប្រចាំឆ្នាំ២០២៤ ជាមួយសមាជិកបណ្តាញ ក្រុមគោលដៅដែលបានគាំទ្រដោយ ច.ក.យ.ក.ស.ក។

៣០៣. បានគាំទ្រលើគំនិតផ្តួចផ្តើម ក្រុមដែលដឹកនាំដោយកុមារ និងយុវជនចំនួន៨ក្រុម នៅថ្នាក់ក្រោមជាតិ គឺក្លឹបកុមារឃុំ ក្លាំងហាយ ក្លឹបកុមារឃុំព្រៃករកា ក្លឹបកុមារឃុំស្អក ក្លឹបកុមារឃុំស្លា ក្លឹបកុមារឃុំលង្វែក ក្លឹបកុមាឃុំប៉ាក់ខ្លង ក្លឹបកុមារឃុំឈានមុខ ក្លឹបយុវជននៅភ្នំពេញ ដើម្បី ក្រុមរបស់ពួកគេរៀបចំធ្វើ យុទ្ធនាការ ដោយក្នុងនោះមានចំនួន១០លើកបានធ្វើយុទ្ធនាការ នៅក្នុងសហគមន៍ ក្រោមប្រធានបទ ការលុបបំបាត់ការរើសអើងទៅលើកុមារដែលមានការភេទអត្តសញ្ញាណយេនឌ័រការបង្ហាញយេនឌ័រនិងលក្ខណៈភេទចម្រុះ (SOGIESC) ការគេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ការបោះបង់ចោលការសិក្សារបស់កុមារ យុទ្ធនាការប្រារព្វទិវាបរិស្ថាន យុទ្ធនាការសម្អាតបរិស្ថាននៅក្នុងសហគមន៍។

## ៨. បញ្ហាប្រឈម

៣០៤. ក្រសួងមហាផ្ទៃ៖ នៅខ្វះមន្ត្រីមានសមត្ថភាពជំនាញ ដើម្បីអនុវត្តមុខងារតាមវិស័យដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនោះ កត្តាសត្យានុម័ត និងអត្តនោម័តបានបង្កផលប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងនោះមានដូចជា ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជា ការកើនឡើងនូវគ្រោះថ្នាក់ចរាចរណ៍ លួច ប្លន់ គ្រឿងញៀន ឧក្រិដ្ឋកម្មឆ្លងដែន បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា...។ ស្របគ្នានេះ សមត្ថភាពធនធានមនុស្ស ក្របខ័ណ្ឌកងកម្លាំងមានការថយចុះ និងមធ្យោបាយសម្ភារៈនៅមានកង្វះខាត...។

៣០៥. ក្រសួងសុខាភិបាល ទោះបីការផ្តល់សេវាសុខភាពបន្តពូជ មាតា ទារក កុមារ និងអាហារូបត្ថម្ភ ត្រូវបានកត់សម្គាល់ដោយវឌ្ឍនភាពក្តី ក៏បញ្ហាប្រឈមចម្បងមួយចំនួន នៅតែត្រូវការបន្តដោះស្រាយប្រកបដោយប្រសិទ្ធភាពនៅក្នុងឆ្នាំ២០២៥ និងឆ្នាំបន្ត ដែលក្នុងនោះរួមមាន៖ អត្រាមរណៈភាពមាតានៅមានកម្រិតខ្ពស់ (១៥៤/១០០ ០០០កំណើតរស់) ធៀបនឹងគោលដៅដែលបានកំណត់ (៧០/១០០ ០០០កំណើតរស់) នៅឆ្នាំ២០៣០។ អត្រាសម្រាលដោយបុគ្គលិកសុខាភិបាលនៅមានកម្រិតទាប។ ការពិនិត្យស្រាវជ្រាវមរណភាពមាតា និងទារកជុំវិញកំណើតនៅមានកម្រិត។ មូលហេតុ ដែលបណ្តាលឱ្យមាតាស្លាប់ ៥៩% បណ្តាលមកពីការធ្លាក់ឈាមក្រោយសម្រាល។ បញ្ហានេះ ពាក់ព័ន្ធទៅនឹងគុណភាពនៃការសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបកើត និងគុណភាព នៃពិនិត្យរកបញ្ហាប្រឈមនៅពេលមានផ្ទៃពោះ និងពេលសម្រាលនៅមានកម្រិត។

៣០៦. អត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅមានកម្រិតខ្ពស់ ៨,១៨% នៅឆ្នាំ២០២៣ ទាបជាងគោលដៅលុបបំបាត់នៅឆ្នាំ២០២៥ ឱ្យនៅតិចជាង ៥%។ ករណីឆ្លងថ្មីនៃមេរោគស្វាយពីកំណើតមានការកើនឡើង (១០៥ ក្នុង ១០០ ០០០កំណើតទារកកើតរស់) ធៀបនឹងគោលដៅលុបបំបាត់នៅឆ្នាំ២០២៥ ឱ្យនៅតិចជាង ៥០ ក្នុង១០០ ០០០ កំណើតរស់។ អត្រាក្មេងស្គមស្គាំងមិនមានការប្រែប្រួលគឺនៅត្រឹម ១០% តាំងពីឆ្នាំ២០១៤ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា។ ការពិនិត្យសុខភាព កុមារក្រោម៥ឆ្នាំតាមយុទ្ធសាស្ត្រសមាហរណកម្មគ្រប់គ្រងជំងឺកុមារនៅមានកម្រិត។

៣០៧. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ វិបត្តិសេដ្ឋកិច្ចសកល ជំងឺកូវីដ-១៩ និងបម្រែបម្រួលអាកាសធាតុ បានដាក់សម្ពាធលើការប្រកួតប្រជែងនាំចេញកាន់តែតានតឹង និងការឆ្លើយតបលក្ខខណ្ឌការងារកាន់តែរឹតបន្តឹងដែលតម្រូវឱ្យវិធានការទប់ស្កាត់ពលកម្មកុមារកាន់តែមានលក្ខណៈបុរេសកម្ម និងនវានុវត្តន៍ទៅលើសេវាការងាររហ័ស។ លក្ខខណ្ឌការងារ លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ មិនទាន់ត្រូវបានអនុវត្តពេញលេញ និងគ្របដណ្តប់នៅគ្រប់សកម្មភាពសេដ្ឋកិច្ច និងសហគ្រាស គ្រឹះស្ថាននៅឡើយ។ ការយល់ដឹងរបស់សាធារណជន និងការផ្លាស់ប្តូរឥរិយាបថសហគមន៍នៃការប្រើប្រាស់ពលកម្មកុមារនៅមានកម្រិត។ ការយល់ដឹងរបស់និយោជក និងកម្មករនិយោជិត អំពីសិទ្ធិ និងកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធវិស័យការងារ នៅមានកម្រិតជាពិសេសការប្រើប្រាស់កម្មករនិយោជិតវ័យក្មេង។

៣០៨. ការអនុវត្តកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមានភាពបត់បែន និងគ្របដណ្តប់គ្រប់ទិដ្ឋភាព និងធានាភាពធន់នៃកម្លាំងពលកម្មនៅមិនទាន់ឆ្លើយតបបានល្អនៅក្នុងបដិវត្តន៍ឧស្សាហកម្ម៤.០ សេដ្ឋកិច្ច និង

សង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង ខណៈចំនួនសិក្ខាកាម សិស្ស និស្សិតដែលទទួលបានការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈនៅមានចំនួនតិចនៅឡើយ។

៣០៩. ក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញថា អត្រាបោះបង់ការសិក្សានៅថ្នាក់ទី៦ មាន ១០.៥% ខ្ពស់ជាងបណ្តាកម្រិតថ្នាក់ផ្សេងៗទៀត បណ្តាលមកពីមូលហេតុមួយចំនួនដូចជា មិនមានមូលដ្ឋានគ្រឹះរឹងមាំមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យា សម្រាប់បន្តការសិក្សានៅកម្រិតមធ្យមសិក្សា ទីលំនៅឆ្ងាយពីគ្រឹះស្ថានមធ្យមសិក្សា បរិយាកាសនិងលក្ខខណ្ឌសិក្សានៅមធ្យមសិក្សាខុសពីកម្រិតបឋមសិក្សា (កាលរៀននៅបឋមសិក្សាទោះបីជាមិនចេះក៏អាចបន្តរៀនជាមួយគ្រូ និងមិត្តភក្តិដែលធ្លាប់ស្គាល់គ្នា ប៉ុន្តែនៅពេលដែលត្រូវឡើងទៅរៀននៅមធ្យមសិក្សា គ្រូបង្រៀនក៏ថ្មី មិត្តរួមថ្នាក់ក៏ថ្មី អាចនឹងជះឥទ្ធិពលដល់ការសម្រេចចិត្តរៀនបន្ត) សិស្សខ្លះលើសអាយុ រួមផ្សំជាមួយកត្តាសេដ្ឋកិច្ចគ្រួសារ និងឱកាសការងារ ជាកត្តាជំរុញឱ្យពួកគាត់បោះបង់ការសិក្សា។

៣១០. អនុវិស័យការអប់រំកុមារតូច៖ ការអនុវត្តអភិបាលកិច្ចសាលាមត្តេយ្យសិក្សានៅមិនទាន់បានពេញលេញ។ ការពង្រីកសេវាអប់រំកុមារតូចនៅមិនទាន់ឆ្លើយតបនឹងតម្រូវការ។ ការអនុវត្តលិខិតបទដ្ឋានគតិយុត្តគាំទ្រការគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅមិនទាន់ឆ្លើយតបបានពេញលេញ។ ពុំទាន់មានលិខិតបទដ្ឋានគតិយុត្តគាំទ្រការបង្កើតទារកដ្ឋាន និងការអភិវឌ្ឍកុមារតូច ១០០០ ថ្ងៃដំបូង។ សមត្ថភាពបុគ្គលិកអប់រំផ្នែកអប់រំកុមារតូចនៅមិនទាន់ឆ្លើយតបតាមក្របខ័ណ្ឌគុណវុឌ្ឍ។ ខ្វះគ្រូបង្រៀនមត្តេយ្យសិក្សានៅតាមសាលាមត្តេយ្យសិក្សា និងមត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា។

៣១១. អនុវិស័យការអប់រំបឋមសិក្សា៖ ខ្វះគ្រូបង្រៀនដែលមានគុណវុឌ្ឍ គណៈគ្រប់គ្រងសាលារៀនភាគច្រើន មិនបានទទួលការបណ្តុះបណ្តាលសមត្ថភាព ស្តីពីការដឹកនាំគ្រប់គ្រងសាលារៀន និងមិនមានការចុះកិច្ចព្រមព្រៀងលទ្ធផល។ ការអនុវត្តកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង ព្រមទាំងកម្មវិធីប្រឹក្សាគរុកោសល្យទើបបានប្រមាណ ៥០ភាគរយ នៃកម្រិតថ្នាក់ទី១ ទី២ និងទី៣ ទូទាំងប្រទេស។ខ្វះអគារសិក្សា ខ្វះហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យការបង្រៀននិងរៀន បណ្ណាល័យ បន្ទប់កុំព្យូទ័រ និងការអប់រំ ឌីជីថល។ ផ្ទះបាយសាលារៀន និងកន្លែងសិស្សហូបអាហារ មិនទាន់ស្របតាមស្តង់ដា និងឆ្លើយតបទៅនឹងតម្រូវការសិស្សក្រោមកម្មវិធីផ្តល់អាហារតាមសាលារៀន។

៣១២. អនុវិស័យការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស៖ ការអនុវត្តការបង្រៀននិងរៀនពេញមួយថ្ងៃមិនទាន់បានពេញលេញ។ ខ្វះគ្រូបង្រៀនតាមនិយាមឯកទេសមុខវិជ្ជា។ ខ្វះហេដ្ឋារចនាសម្ព័ន្ធសម្រាប់បម្រើឱ្យការងារបង្រៀន និងរៀន។ ខ្វះធនធានសម្រាប់អនុវត្តប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា។ ការផ្សព្វផ្សាយឯកសារគំរូលំនាំបង្រៀន ការអនុវត្តកម្មវិធីសិក្សាថ្មី វិធីសាស្ត្របង្រៀន និងការកសាងសម្ភារៈឧបទេសនៅមិនទាន់បានទូលំទូលាយ។ គ្រឹះស្ថានសិក្សាអប់រំបច្ចេកទេសមួយចំនួនមិនអាចអនុវត្តកម្មវិធីសិក្សាឱ្យបានពេញលេញ។ គ្រូបង្រៀនបច្ចេកទេសមួយចំនួន មិនមានសមត្ថភាពប្រើប្រាស់សម្ភារបរិក្ខារគាំទ្រការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

៣១៣. អនុវិស័យការអភិវឌ្ឍយុវជន៖ កម្មវិធីយុវជននៅមិនទាន់ឆ្លើយតបនឹងតម្រូវការរបស់យុវជននៅតាមរាជធានីខេត្ត។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ សម្ភាររូបវន្ត ការផ្តល់សេវាកម្ម និងការអនុវត្តកម្មវិធីយុវជននៅ

តាម។ មជ្ឈមណ្ឌលយុវជនមិនទាន់ឆ្លើយតបទៅនឹងការបណ្តុះបំណិនសតវត្សរ៍ទី២១។ ធនធានមនុស្ស ដែលមានវិជ្ជាជីវៈការអភិវឌ្ឍយុវជន នៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការកម្មវិធីយុវជន។

៣១៤. ក្រសួងអភិវឌ្ឍន៍ជនបទ៖ ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ អត្រានៃគ្រួសារជនបទ ទទួលបានសេវាទឹកស្អាត និងអនាម័យដែលគ្រប់គ្រងដោយសុវត្ថិភាព (Safely Managed) នៅមានកម្រិត។ អត្រាគ្របដណ្តប់សេវាទឹកស្អាត និងអនាម័យជនបទ នៅតំបន់ដាច់ស្រយ៉ាល និងតំបន់ដែលមានបរិស្ថាន ប្រឈមនៅមានកម្រិត។ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ បានប៉ះពាល់ដល់ហេដ្ឋា រចនាសម្ព័ន្ធ ទឹកស្អាត និងអនាម័យជនបទ។ វិសមភាពនៃការទទួលបានសេវាទឹកស្អាត និងអនាម័យជនបទ។

៣១៥. ធនធានសម្រាប់គាំទ្រសកម្មភាពផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទមិនទាន់ឆ្លើយ ទៅនឹង តម្រូវការជាក់ស្តែង។ កិច្ចសហការរបស់អង្គការ និងដៃគូអភិវឌ្ឍន៍លើការងារផ្គត់ផ្គង់ទឹកជនបទនៅមានកម្រិត។ ការចាត់អាទិភាពការងារផ្គត់ផ្គង់ទឹក និងអនាម័យរបស់រដ្ឋបាលឃុំ-សង្កាត់ នៅមានកម្រិត។ សម្ភារៈផ្សព្វ ផ្សាយលើកកម្ពស់អនាម័យ និងទឹកស្អាតមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។ ការផ្សព្វផ្សាយអំពី ការផឹកទឹកសុវត្ថិភាព និងអនាម័យល្អសម្រាប់តំបន់ដាច់ស្រយាល និងតំបន់ បរិស្ថានប្រឈមនៅមិនទាន់ បានទូលំទូលាយនៅឡើយ។

៣១៦. ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុច ប្រឈមមួយចំនួនដូចជា៖ ការទាមទារយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបាន ជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់នាំឱ្យធកល្វែង។ ត្រូវការពិភាក្សា បន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរង គ្រោះ ជនសង្ស័យថារងគ្រោះ... ដែលធ្វើឱ្យការបូកសរុប ទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា។ ជនល្មើសមានកលល្បិចជ្រៀតចូលមកធ្វើសកម្មភាពខុសច្បាប់ និងអូសទាញមនុស្សឱ្យរងគ្រោះ ជាបន្តបន្ទាប់។ ខ្វះវិធីសាស្ត្រ និងសង្គតិភាពនៃសារអប់រំ ដែលមានប្រសិទ្ធភាព និងអាចបង្ការទប់ស្កាត់បាននូវអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់រូបភាព។

៣១៧. ទោះបីជាប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនខុសច្បាប់ទទួលបានលទ្ធផលជាវិជ្ជមានក្តី តែយើង បានពិនិត្យឃើញបញ្ហាប្រឈមថ្មីមួយចំនួនដែលបានកើតឡើង ដូចជា ការប្រើប្រាស់ល្បិចកលនាំចូលនូវ សារធាតុគីមីបម្រើឱ្យវិស័យកសិកម្ម ឧស្សាហកម្ម បន្លំយកមកកែច្នៃផលិតជាសារធាតុញៀន សំយោគ ការ ផ្លាស់ប្តូរច្រក និងផ្លូវចរាចរ រួមទាំងរូបភាពនៃការនាំចូលឆ្លងកាត់ ការកែច្នៃផលិតជាដើម។ ក្តីបារម្ភ ដែលជា បញ្ហាប្រឈមរ៉ាំរ៉ៃ និងកំពុងបង្កហានិភ័យដល់សង្គមជាតិនោះគឺការប្រើប្រាស់គ្រឿងញៀននៅតាមសហគមន៍ នៅតែបន្តកើតមាននៅឡើយ និងកំពុងតែទាមទារឱ្យចាត់វិធានការជាអាទិភាព ដើម្បីដោះស្រាយប្រកប ដោយប្រសិទ្ធភាពបានទាន់ពេលវេលា។

៣១៨. ដោយពិនិត្យឃើញថា មហន្តរាយដែលបណ្តាលមកពីឧក្រិដ្ឋកម្មគ្រឿងញៀន នៅតែបន្តរីករាលដាល ទាំងនៅ ក្នុងតំបន់និងលើពិភពលោក រួមទាំងព្រះរាជាណាចក្រកម្ពុជាផងនោះ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបន្តដាក់ ចេញនូវផែនការស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១០ ឆ្នាំ២០២៥ ក្នុងគោលដៅ

ដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន នៃគ្រឿងញៀនព្រមទាំងកសាងសង្គម ដែលមានសុខុមាលភាពនិងសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងការពារកិត្តិយស ដោយបានកំណត់នូវគោលការណ៍និងវិធានការសំខាន់ៗដូចខាងក្រោម៖ កិត្យានុភាពជាតិ។

៣១៩. ការអនុវត្តច្បាប់ លិខិតបទដ្ឋាន ផែនការជាតិ យុទ្ធសាស្ត្រជាតិ អនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែម និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធស្តីពីការការពារកុមារ ការកាត់បន្ថយ និងការលុបបំបាត់ពលកម្មកុមារ កុមារប្រើប្រាស់សារធាតុញៀន អំពើជួញដូរកុមារ អំពើហិង្សា ការកេងប្រវ័ញ្ចគ្រប់រូបភាព ការសុំកូនអន្តរប្រទេស ។ល។ និងការធានាការពារកុមារឱ្យរីកលូតលាស់មានសុខុមាលភាពកុមារ មិនទាន់បានផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅឡើយ ពិសេសការអនុវត្តរាល់លិខិតបទដ្ឋានទាំងនេះនៅមានកម្រិតនៅឡើយ។

៣២០. បញ្ហាប្រឈមក្នុងវិស័យសង្គមកិច្ច៖ បញ្ហាអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារអហ្វឡាញ ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើប្រព័ន្ធអនឡាញបានចាប់ផ្តើមកើតឡើង និងរីករាលដាលយ៉ាងឆាប់រហ័ស ស្របតាមការវិវត្តនៃបច្ចេកវិទ្យាឌីជីថល ដែលទាមទារឱ្យអ្នកផ្តល់សេវាកិច្ចការពារកុមារ ត្រូវពង្រឹងសមត្ថភាពបន្ថែមទៀត ដើម្បីឱ្យស្របតាមបរិបទថ្មីនេះ។ ដំណើរការកសាងប្រព័ន្ធកិច្ចការពារ និងថែទាំកុមារមិនទាន់បានសម្រេចតាមគោលដៅទាំងស្រុងនៅឡើយទេ។ កំណែទម្រង់ច្បាប់ និងគោលនយោបាយមិនទាន់មានលក្ខណៈសុខដុមនីយកម្ម និងនៅមានភាពភ័ន្តច្រឡំនៅជុំវិញនីតិវិធី តួនាទី និងការទទួលខុសត្រូវនានា។ បន្ថែមពីនេះ យន្តការសម្របសម្រួលនៅមានភាពខ្វះចន្លោះពាក់ព័ន្ធនឹងបែងចែកមុខងារ និងការទទួលខុសត្រូវផ្នែកកិច្ចការពារកុមារ។ ការផ្ទេរមុខងារ និងថវិកាពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការនៅមានបញ្ហាប្រឈម ដែលធ្វើឱ្យការឆ្លើយតបទៅនឹងការងារកិច្ចការពារកុមារនៅមិនទាន់ល្អប្រសើរ។ មណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមិនមានលិខិតអនុញ្ញាត និងវិញ្ញាបនបត្រទទួលស្គាល់នៅមានចំនួនច្រើន។

៣២១. ភាពមិនប្រាកដប្រជានៃប្រព័ន្ធមូលដ្ឋានទិន្នន័យថ្នាក់ជាតិជាក់លាក់ ស្តីពីកុមាររងគ្រោះ និងងាយរងគ្រោះ បានបង្កឱ្យភាពរាំងស្ទះក្នុងការប្រើប្រាស់សម្រាប់ធ្វើការវិភាគ និងកំណត់អាទិភាពកិច្ចការពារកុមារ ខណៈពេលដែលប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ កំពុងស្ថិតក្នុងដំណើរការ។ ជាមួយគ្នានេះ ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងករណីតាមបច្ចេកទេស Primero នៅមិនទាន់ដំណើរការដោយរលូន ដោយសារកត្តាខ្វះធនធានមនុស្សក្នុងគ្រប់គ្រង និងការប្រើប្រាស់ចំណេះដឹងផ្នែកបច្ចេកវិទ្យា ហើយប្រព័ន្ធនេះនៅមិនទាន់បានបន្សីុគ្នាជាមួយប្រព័ន្ធផ្សេងទៀត ដូចជាប្រព័ន្ធ OSCaR ជាដើម។

៣២២. ការកំណត់គោលដៅសមាហរណកម្មប្រកបដោយមហិច្ឆិតា ប៉ុន្តែមិនទាន់សម្រេចបាននៅក្នុងរយៈពេលដំបូង ដែលមានកំណត់នៅក្នុងផែនការសកម្មភាព ដោយសារកង្វះនីតិវិធីសម្រាប់សមាហរណកម្ម និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការធ្វើសមាហរណកម្ម និងយន្តការតាមដានត្រួតពិនិត្យលើកុមារ ដែលបានសមាហរណកម្ម ជាលទ្ធផល ការអនុវត្តផែនការនេះ បានបង្ហាញនូវភាពខុសគ្នាទាក់ទងនឹងគុណភាព នៃដំណើរការសមាហរណកម្ម និងក្តីបារម្ភទាក់ទងនឹងភាពសមស្រប និងភាពគ្រប់គ្រាន់ នៃសេវាគាំទ្រដែលផ្តល់ដល់កុមារ និងគ្រួសារ។

៣២៣. ការផ្លាស់ប្តូរឥរិយាបទសាធារណជនទូទៅ ជាពិសេសឪពុកម្តាយ ដែលគិតថា ការទុកដាក់កុមារថែទាំក្នុងមណ្ឌលជាជម្រើសល្អ ដែលជាហេតុធ្វើឱ្យការជំរុញ និងលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ និងសហ

គមន៍ និងការទប់ស្កាត់ និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ នៅមានបញ្ហាប្រឈម។ ទន្ទឹមនឹងនេះ សមត្ថភាព បទពិសោធន៍ និងគុណភាពនៃការផ្តល់សេវាសង្គមនៅថ្នាក់មូលដ្ឋាន នៅតែជាឧបសគ្គចំពោះការពង្រឹងប្រព័ន្ធកិច្ចការពារ និងការថែទាំកុមារ។ ការគ្របដណ្តប់ នៃសេវាសុខុមាលភាពកុមារ និងកិច្ចគាំពារសង្គមនៅមានកម្រិត រួមជាមួយនឹងសេវារបស់អង្គការមិនមែនរដ្ឋាភិបាលមានទំហំតូចៗ និងផ្តោតលើតំបន់គោលដៅរៀងៗខ្លួន បង្កឱ្យមានការគាំទ្រ និងលទ្ធផលខុសគ្នាស្រឡះសម្រាប់កុមារ។ ហានិភ័យនេះមានលក្ខណៈគួរឱ្យកត់សម្គាល់ចំពោះកុមារមានពិការភាព កុមារមានតម្រូវការពិសេស និងកុមារមកពីសហគមន៍ដាច់ស្រយាល ដែលតម្រូវការរបស់ពួកគេមិនត្រូវបានចាត់ជាអាទិភាព និងមិនសមស្របតាមគោលការណ៍សមធម៌។

## ៩. ទិសដៅអនុវត្តបន្ត

៣២៤. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិនិងក្រោមជាតិ ដោយប្រើប្រាស់យន្តការដែលមានស្រាប់ ធ្វើការបណ្តុះបណ្តាល ផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងអំពីច្បាប់ លិខិតបទដ្ឋាន ផែនការជាតិ យុទ្ធសាស្ត្រជាតិ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធិសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ។ ជាពិសេសជំរុញការអនុវត្តសារាចរលេខ០៦សរ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ ឱ្យមានប្រសិទ្ធភាពខ្ពស់។

៣២៥. វិស័យសុខាភិបាលបានផ្តោតលើអាទិភាពជាយុទ្ធសាស្ត្រ រួមមាន៖ ការពង្រីកការគ្រប់ដណ្តប់ នៃសេវាសុខាភិបាល ការលើកកម្ពស់គុណភាពសេវាសុខាភិបាល ការពង្រីកការគ្រប់ដណ្តប់នៃប្រព័ន្ធគាំពារសុខភាពសង្គម ការពង្រឹងប្រព័ន្ធសន្តិសុខសុខភាព និងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធគ្រឹះនៃប្រព័ន្ធសុខាភិបាល ដែលគ្រប់ដណ្តប់លើ ការអភិវឌ្ឍស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ការលើកកម្ពស់ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានជាសារវន្តផ្សេងទៀត ការអភិវឌ្ឍទិន្នន័យប្រព័ន្ធសុខាភិបាល សុខាភិបាលឌីជីថល និងនវានុវត្តន៍។

៣២៦. ក្រសួងមហាផ្ទៃ៖ បន្តពង្រឹងស្ថាប័នថ្នាក់ក្រោមជាតិ ដោយគាំទ្រតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ ចូលរួមពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម។ លើកកម្ពស់ការគ្រប់គ្រងពន្ធនាគារតាមស្តង់ដារ ដែលធានាបានសន្តិសុខ សុវត្ថិភាព និងផាសុកភាព។ បន្តអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស ដោយលើកកម្ពស់ការសិក្សាស្រាវជ្រាវការងារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម និងការជំរុញនវានុវត្តន៍។ បន្តអភិវឌ្ឍការងារបច្ចេកវិទ្យាឌីជីថល និងលើកកម្ពស់ការអភិវឌ្ឍសមត្ថភាព ព្រមទាំង បញ្ជ្រាបចំណេះដឹងជំនាញឌីជីថល។ លើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ។

៣២៧. ក្រសួងអប់រំ យុវជន និងកីឡា៖ អនុវិស័យការអប់រំកុមារតូច ត្រូវការបង្កើនការជ្រើសរើសគ្រូមត្តេយ្យសិក្សានៅតាមសាលាមត្តេយ្យសិក្សាសាធារណៈ និងមត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា។ កសាងលិខិតបទដ្ឋានគតិយុត្តគាំទ្រការបង្កើតទារកដ្ឋាន និងការអភិវឌ្ឍកុមារតូច ១ ០០០ថ្ងៃដំបូង។ ជំរុញការអនុវត្តស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ។ ជំរុញការអនុវត្តកម្មវិធីសិក្សាលម្អិត និងសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សាឱ្យបានពេញលេញ។ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកម្មវិធីបណ្តុះបណ្តាលនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា។ ពង្រឹងការអនុវត្តវិធីសាស្ត្របង្រៀនថ្មី "រៀនតាមរយៈការលេង និងបរិស្ថាន"។

៣២៨. អនុវិស័យការអប់រំបឋមសិក្សា ត្រូវបង្កើនគុណវុឌ្ឍគ្រូបឋមសិក្សាតាមរយៈប្រព័ន្ធបណ្តុះបណ្តាល ១២+៤ និងបរិញ្ញាបត្រ+១។ ធ្វើការបណ្តុះបណ្តាលគ្រូបង្រៀនតាមប្រព័ន្ធនិយោជន៍។ ពង្រឹង និងពង្រីកការអនុវត្តស្តង់ដាសាលាបឋមសិក្សាគំរូ ការដឹកនាំគ្រប់គ្រងសាលារៀន និងការបណ្តុះបណ្តាលគណៈគ្រប់គ្រងសាលាស្តីពីពង្រឹងនិងពង្រីកវិសាលភាពនៃការអនុវត្តកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង គណិតវិទ្យាថ្នាក់ដំបូង កម្មវិធីប្រឹក្សាគរុកោសល្យ និងការបណ្តុះទម្លាប់ការអាន និងសរសេរភាសាខ្មែរនៅកម្រិតបឋមសិក្សា។ ដាក់ឱ្យអនុវត្តនិងអភិវឌ្ឍផ្ទាល់បឋម PLP ដើម្បីបម្រើឱ្យការបង្រៀននិងរៀន និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ ពង្រីកការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ និងកម្មវិធីអាហា

រូបករណ៍ ដើម្បីឆ្លើយតបនឹងគោលនយោបាយជាតិគាំពារសង្គម។ លើកកម្ពស់សមត្ថភាពគ្រូបង្រៀនលើវិធីសាស្ត្របង្រៀនទំនើប និងវិធីសាស្ត្របង្រៀនភាសាខ្មែរ គណិតវិទ្យា ការអប់រំស្លែម ភាសាបរទេស កុំព្យូទ័រ ថ្នាក់ទី៤ ដល់ទី៦ ដើម្បីផ្តល់ជំនាញទន់ដល់សិស្ស។ បន្តអនុវត្តផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយ ស្តីពីកិច្ចការពារកុមារនៅសាលារៀន ព្រមទាំងពង្រឹងនិងពង្រីកការអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន និងកម្មវិធីការអប់រំវិន័យបែបវិជ្ជមាន។

៣២៩. អនុវិស័យការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស តាមរយៈការលើកកម្ពស់អភិបាលកិច្ចសាលារៀនតាមរយៈការអនុវត្តស្តង់ដាសាលារៀនគំរូ។ ជំរុញការអនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃ។ ផ្តល់គ្រូបង្រៀនឱ្យបានស្របតាមនិយាមឯកទេសមុខវិជ្ជា។ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់បម្រើឱ្យការងារបង្រៀន និងរៀន។ បង្កើនការផ្សព្វផ្សាយឯកសារគំរូលំនាំបង្រៀន ការអនុវត្តកម្មវិធីសិក្សាថ្មី វិធីសាស្ត្របង្រៀន និងការកសាងសម្ភារៈឧបទេសឱ្យបានទូលំទូលាយ។ ជំរុញអនុវត្តកម្មវិធីសិក្សាឱ្យបានពេញលេញនៅតាមគ្រឹះស្ថានសិក្សាអប់រំបច្ចេកទេស។ អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនលើវិធីសាស្ត្របង្រៀនថ្មី (សាលារៀនជំនាន់ថ្មី AI)។

៣៣០. ក្រសួងអភិវឌ្ឍជនបទ៖ ការលើកកម្ពស់ការទទួលបានទឹកស្អាត និងអនាម័យបរិស្ថានជនបទ។ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតជនបទ។ ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតជនបទ។ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្តអនាម័យជនបទ។ ការលើកកម្ពស់ការរស់នៅស្អាត ការអប់រំសុខភាព និងអនាម័យជនបទ។ ការសិក្សាស្រាវជ្រាវបច្ចេកវិទ្យាទឹកស្អាត និងអនាម័យប្រកបដោយភាពធន់។ ការលើកកម្ពស់ការទទួលបានទឹកស្អាត និងអនាម័យបរិស្ថានជនបទដោយមន្ទីរជំនាញទាំង២៥។

៣៣១. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន៖ ខិតខំបញ្ចៀសឱ្យបាន មិនឱ្យប្រទេសកម្ពុជាក្លាយជាគោលដៅ នៃការប្រព្រឹត្តបទល្មើសគ្រឿងញៀន និងមិនឱ្យឥទ្ធិពលដ៏សាហាវ នៃគ្រឿងញៀនញាំញីបំផ្លិចបំផ្លាញសង្គមជាតិ ជាពិសេសការលើកកម្ពស់សមត្ថភាពក្នុងការចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីឆ្លើយតបការប្តេជ្ញាចិត្តថា កម្ពុជាគឺជាប្រទេសគ្មានគ្រឿងញៀន ដោយផ្តើមចេញពីបុគ្គលម្នាក់ទៅគ្រួសារមួយដែលស្អាតស្អំគ្មានគ្រឿងញៀន ស្របតាមទស្សនវិស័យ "ចូលរួមទាំងអស់គ្នា ដើម្បីជីវិត និងសហគមន៍គ្មានគ្រឿងញៀន"។

៣៣២. ជំរុញបន្តអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១បប ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅបង្កើននូវជំនឿទុកចិត្ត ប្រសិទ្ធភាពការងារ និងអភិបាលកិច្ចល្អក្នុងស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងក្នុងជួរកងកម្លាំងប្រដាប់អាវុធ រួមទាំងមន្ត្រីរាជការស៊ីវិល។ ជំរុញសកម្មភាពបោសសម្អាតការប្រើប្រាស់គ្រឿងញៀន និងឈានទៅលុបបំបាត់ទីផ្សារគ្រឿងញៀនក្នុងផ្ទៃប្រទេស តាមគោលការណ៍ "សម្អាតចកចេញពីផ្ទៃបឹង និងរក្សាផ្ទៃបឹងឱ្យថ្លាជាប្រចាំ" ស្របតាមទិសស្លោក "៣កុំ ១រាយការណ៍៖ កុំពាក់ព័ន្ធ កុំអន្តរាគមន៍ កុំលើកលែង និងរាយការណ៍គ្រប់បទល្មើសគ្រឿងញៀន" ព្រមទាំងបន្តជំរុញការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ឱ្យកាន់តែសកម្មផុលផុស។

៣៣៣. បន្តជំរុញការអនុវត្តទិសដៅការងារអាទិភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមមាន (១) ការងារផ្សព្វផ្សាយអប់រំ (២) ការពង្រឹងយន្តការគ្រប់គ្រងសារធាតុគីមីផ្សំ (៣) ការទប់ស្កាត់ការនាំចូលគ្រឿងញៀន (៤) ការទប់ស្កាត់ការកែច្នៃផលិតគ្រឿងញៀន និង(៥) ការលុបបំបាត់ការ

ប្រើប្រាស់ និងការជួញដូរគ្រឿងញៀន។ ពង្រឹងយន្តការឆ្លើយតបទាន់ហេតុការណ៍ ដោយលើកកម្ពស់ប្រសិទ្ធភាពកម្មវិធីទូរស័ព្ទដៃ NoDrug និង ប្រព័ន្ធទូរស័ព្ទ Hotline ដើម្បីទទួលព័ត៌មានពីប្រជាពលរដ្ឋពាក់ព័ន្ធនឹងគ្រឿងញៀន និងចាត់វិធានការដោះស្រាយ អន្តរាគមន៍ និងបង្ក្រាបឱ្យបានទាន់ពេលវេលា។

៣៣៤. លើសពីនេះទៀត ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) នឹងពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដោយជំរុញការរៀបចំបង្កើតប្រព័ន្ធទិន្នន័យ នៃការអនុវត្តសិទ្ធិកុមារ ព្រមទាំងត្រូវបំពេញតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាល ជាច្រកចេញចូលតែមួយក្នុងការពិនិត្យ និងរាយការណ៍ពាក់ព័ន្ធនឹងវិស័យការងារកុមារ។ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្ត និងដាក់បញ្ចូលអនុសាសន៍ នៃសេចក្តីសង្កេតចុងក្រោយទៅក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងស្ថាប័នសាមី។ កាត់បន្ថយ និងលុបបំបាត់អំពើជួញដូរ អំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់រូបភាពមកលើកុមារ។ បន្តពង្រឹង និងពង្រីក ក.ជ.ក. នៅគ្រប់លំដាប់ថ្នាក់ ដើម្បីជាយន្តការសម្របសម្រួលជួយដល់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្នុងការអនុវត្តភារកិច្ចលើវិស័យការងារកុមារ ឱ្យមានប្រសិទ្ធភាព។ ពង្រីកការចូលរួមរបស់កុមារតាមរយៈព្រឹត្តិការណ៍ជាតិ ក្រោមជាតិ តំបន់ និងថ្នាក់អន្តរជាតិនានា។ រាល់មតិយោបល់របស់កុមារត្រូវយកមកពិចារណា និងដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពនានាសម្រាប់ការអភិវឌ្ឍសិទ្ធិរបស់ពួកគេ។

៣៣៥. វិស័យសង្គមកិច្ច លើកកម្ពស់ការពារកុមារ ក្រសួង ស.អ.យ. បានបន្តពង្រឹងការលើកកម្ពស់សេវាកិច្ចការពារកុមារ ទាំងអហ្វឡាញ និងអនឡាញ ដោយពន្លឿនការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ ពង្រឹងសមត្ថភាព និងគុណភាពនៃការគ្រប់គ្រងមណ្ឌលថែទាំកុមារ ពង្រឹងការអនុវត្តប្រព័ន្ធទិន្នន័យអធិការកិច្ចកន្លែងថែទាំកុមារ និងប្រព័ន្ធទិន្នន័យគ្រប់គ្រងករណីកុមារ Primero លើកកម្ពស់ការថែទាំកុមារតាមគ្រួសារ និងសហគមន៍ ព្រមទាំងពង្រឹង និងពង្រីកកម្មវិធីទុកដាក់កុមារជាអចិន្ត្រៃយ៍តាមរយៈសុំកូនក្នុងប្រទេស។

៣៣៦. លើកកម្ពស់ការអប់រំ ផ្សព្វផ្សាយ និងធ្វើការជាមួយអ្នកពាក់ព័ន្ធ ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ និងការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ និងសម្របសម្រួលផ្តល់សេវាដល់កុមារតាមម្តាយក្នុងពន្ធនាគារ។ បន្តជំរុញឱ្យអង្គការដៃគូដាក់ពាក្យស្នើសុំវិញ្ញាបនបត្រទទួលស្គាល់មណ្ឌលថែទាំជំនួសចំពោះកុមារ និងពង្រឹងនិងពង្រីកកម្មវិធីបណ្តុះបណ្តាលផ្តល់ការទទួលស្គាល់គុណវុឌ្ឍិន៍ នៃអង្គការសុវត្ថិភាពកុមារ។ បន្តគាំទ្របច្ចេកទេសពាក់ព័ន្ធនឹងកិច្ចការពារកុមារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តមុខងារ និងសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីអនុវត្តនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ លើកកម្ពស់កិច្ចការគ្រួសារ និងសេវាគាំពារជនរងគ្រោះ ដោយបន្តសហការជាមួយ ក្រសួង ស្ថាប័ន អង្គការ និងសមាគមពាក់ព័ន្ធនានា ដើម្បីសម្របសម្រួល និងផ្តល់សេវាដល់មុខសញ្ញា ដែលជាជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

៣៣៧. បន្តលើកកម្ពស់សេវាស្តារនីតិសម្បទាអនីតិជន ដោយពង្រឹងការគ្រប់គ្រងមណ្ឌលយុវនីតិសម្បទា ការគ្រប់គ្រងករណីអនីតិជនក្រោយពេលធ្វើសមាហរណកម្ម និងពង្រីកកម្មវិធីបង្វែរកុមារចេញពីប្រព័ន្ធតុលាការ។ លើកកម្ពស់សេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយផ្តោតលើការលើកកម្ពស់ការគ្រប់គ្រងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ការគ្រប់គ្រងករណីអ្នកញៀនគ្រឿងញៀនក្រោយពេលធ្វើសមាហរណកម្ម និងការតាមដានគុណភាពស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

៣៣៨. លើកកម្ពស់សុខុមាលភាពជនមានពិការភាព ដោយប្រមូលផ្តុំលើការលើកកម្ពស់សិទ្ធិការងារ និងសេវាយុត្តិធម៌ជនមានពិការភាព ការគាំទ្រសកម្មភាពកីឡា សិល្បៈនិងវប្បធម៌ជនពិការ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កើតបរជូនជនពិការ ព្រមទាំងផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនមានពិការភាព ដូចជា ការផ្តល់សេវាស្តារលទ្ធ ភាពពលកម្មកាយសម្បទា និងសេវាស្តារវេជ្ជសាស្ត្រជូនជនពិការ ការផលិតឧបករណ៍សិប្បនិម្មិត រណប ដាក់ហិបសប្បុរសធម៌ ការផ្តល់របបគោលនយោបាយជួយឧបត្ថម្ភជនពិការ និងការលើកកម្ពស់ការ គ្រប់គ្រងមជ្ឈមណ្ឌលជាតិជនពិការកម្ពុជា។

៣៣៩. ជំរុញការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងគោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដែលរាជរដ្ឋាភិបាលបានប្រកាសជាផ្លូវការនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣ នឹងត្រូវចាប់ផ្តើមចាប់ពីខែមេសា ឆ្នាំ២០២៤ តទៅ។ រៀបចំកម្មវិធីស្ពានចម្លងសេវាសង្គមដល់គ្រួសារក្រីក្រ តាមរយៈការអនុវត្តកម្មវិធីស្ពានចម្លងសេវាសង្គមដល់គ្រួសារក្រីក្រ ជាពិសេសគ្រួសារដែលមានកុមារកំព្រា កុមារដែលគេបោះបង់ចោល មនុស្សវ័យចាស់គ្មានទីពឹង ជនមានពិការភាព ជនអនាថា និងអ្នកញៀនគ្រឿងញៀន។

៣៤០. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្តអនុវត្តផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៦-២០២៥) និងបូកសរុបរបាយការណ៍សម្រាប់ឆ្នាំ២០២៥ ដើម្បីកំណត់បញ្ហាប្រឈម និងទិសដៅសម្រាប់ការរៀបចំផែនការនេះរយៈពេល១០ឆ្នាំខាងមុខទៀត។ ក្រសួងនឹងបន្តលើកកម្ពស់ការកសាងសមត្ថភាពដល់មន្ត្រីអធិការកិច្ចការងារ និងអាជ្ញាធរដែនដី ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និងពង្រឹងប្រសិទ្ធភាពទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ។ ក្រសួងក៏លើកទិសដៅផងដែរ ដល់ការផ្សព្វផ្សាយទៅដល់ទីតាំងស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅតាមសហគ្រាស គ្រឹះស្ថានផលិតឥដ្ឋ ក្បឿង និងកសិ-ឧស្សាហកម្ម និងបន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស។ ក្រសួងបានដាក់ទិសដៅការងារក្នុងឆ្នាំ២០២៥ ដោយត្រៀមនឹងបង្កើតទារកដ្ឋានចំនួន៣ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ឬតំបន់ប្រមូលផ្តុំរោងចក្រ សហគ្រាស ឬសួនឧស្សាហកម្ម។

៣៤១. ក្រសួងកិច្ចការនារី បន្តបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិលើឧបករណ៍ឯកទេស (កម្រិតទី៣) ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន។ ផ្តល់កិច្ចអន្តរាគមន៍ជំនួយផ្នែកច្បាប់និងសេវាសង្គម ការសម្របសម្រួល គាំទ្រស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើរំលោភបំពានផ្លូវភេទ។ ទប់ស្កាត់អាពាហ៍ពិពាហ៍វ័យក្មេង និងការមានផ្ទៃពោះវ័យជំទង់ អំពើហិង្សាក្នុងគ្រួសារ។

៣៤២. បន្តពង្រីកកិច្ចសហការជាមួយបណ្តាប្រទេសក្នុងតំបន់ និងអន្តរជាតិ ដើម្បីពង្រីកការអនុវត្តច្បាប់អន្តរជាតិ និងកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ សហគមន៍ ប្រជាពលរដ្ឋ មាតាបិតា អាណាព្យាបាល សំដៅជំរុញលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ។

## ១០. សេចក្ដីសន្និដ្ឋាន

៣៤៣. តាមរយៈការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយកំណត់យកនូវអាទិភាពគន្លឹះចំនួន ៥ រួមមានៈ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច សំដៅការពារ ថែរក្សា និងពូនជ្រុំសមិទ្ធផលជាតិ លើកកម្ពស់កិត្យានុភាពជាតិ ជំរុញសន្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ តាមរយៈការអនុវត្តកន្លងមក បានបង្ហាញនូវវឌ្ឍនភាពគួរជាទីមោទនៈ ដែលជាការបង្ហាញនូវជំហរ និងជំហានយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំនិងអភិវឌ្ឍប្រទេសប្រកបដោយសុខដុម។

៣៤៤. ការពង្រឹងវិស័យសុខាភិបាល មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយបានអនុវត្តកម្មវិធីលើកកម្ពស់សុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ និងការកែលម្អកង្វះអាហារូបត្ថម្ភ ដែលធ្វើឱ្យអត្រាមរណភាពរបស់មាតា ទារក កុមារ មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់។ គួរកត់សម្គាល់ថា មរណភាពទារក និងកុមារអាយុក្រោម ៥ ឆ្នាំ សម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ មុនកាលកំណត់ ៨ឆ្នាំ។ អន្តរាគមន៍នៃសេវាបង្ការ និងគ្រប់គ្រងជំងឺមិនឆ្លងចម្បងៗត្រូវបានពង្រឹង និងពង្រីកការគ្របដណ្ដប់បានកាត់បន្ថយអត្រាឈឺ និងអត្រាស្លាប់បណ្ដាលមកពីជំងឺឆ្លងចម្បងៗ ដូចជាមេរោគអេដស៍/ជំងឺអេដស៍ ជំងឺគ្រុនចាញ់ គ្រុនឈាម និងជំងឺរបេងជាដើម។ រីឯគុណភាពសេវាក៏ត្រូវបានកែលម្អជាប្រចាំ តាមរយៈការវាយតម្លៃគុណភាពនៃការងារគ្រប់គ្រង និងគុណភាពនៃសេវាថែទាំ។

៣៤៥. ក្រសួងអប់រំ យុវជន និងកីឡា បានការបង្កើនការចូលរៀនប្រកបដោយសមធម៌នៅគ្រប់ភូមិសិក្សា ជាពិសេសការអប់រំកម្រិតមូលដ្ឋាន ៩ឆ្នាំ តាមរយៈការបង្កលក្ខណៈសម្បត្តិអនុគ្រោះឱ្យកូនចៅប្រជាជន ដែលជួបការលំបាកមានលទ្ធភាពចូលរៀន រៀនបន្ត។ ពង្រឹងអភិបាលកិច្ចនៅតាមគ្រឹះស្ថានសិក្សា និងការបង្កើនអាហារូបករណ៍សម្រាប់សិស្ស និងនិស្សិតមកពីគ្រួសារក្រីក្រ។ល។ គុណភាព និងភាពឆ្លើយតបរបស់សេវាអប់រំក៏ត្រូវបានពង្រឹង តាមរយៈការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន និងការលើកទឹកចិត្ត ព្រមទាំងបង្កើនស្វ័យភាព គណនេយ្យភាព និងភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសេវាអប់រំគ្រប់លំដាប់ថ្នាក់។ល។

៣៤៦. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា បន្តការយកចិត្តទុកដាក់ការពារកុមារពីការរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់រូបភាព រួមទាំងការជួញដូរកុមារ ការប្រើប្រាស់អំពើហិង្សាលើកុមារ។ កុមារគ្រប់រូបមានសិទ្ធិក្នុងការធំលូតលាស់នៅក្នុងបរិយាកាសដោយសុវត្ថិភាព និងការចិញ្ចឹមបីបាច់គ្មាន អំពើហិង្សា និងការកេងប្រវ័ញ្ច។ ដោយសារការគាំទ្រ និងការវិនិយោគមានការកើនឡើងសម្រាប់វិស័យ កិច្ចការពារកុមារ កុមារនៅកម្ពុជាទទួលបាននូវកិច្ចការពារកាន់តែប្រសើរឡើងជាងមុន តាមរយៈ ការពង្រឹងការអនុវត្តច្បាប់បទដ្ឋានគតិយុត្ត និងសេវាឆ្លើយតបសមស្រប និងទាន់ពេលវេលា។ ជាមួយគ្នា នេះដែរ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ កម្ពុជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងការបង្កើតកម្មវិធីជំនួយសង្គម យន្តការជាមូលដ្ឋានសម្រាប់កិច្ចការពារកុមារ ការធ្វើសមាហរណកម្មកុមារចេញពីមណ្ឌលថែទាំជំនួស ការប្រយុទ្ធប្រឆាំងដើម្បីបញ្ឈប់អំពើហិង្សាលើកុមារ រួមទាំងក្លាយជាប្រទេសជាសមាជិកនៃប្រទេសដៃគូដើម្បីបញ្ចប់អំពើហិង្សាលើកុមារ។

៣៤៧. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តោតការយកចិត្តទុកដាក់ ការអនុវត្តវិធានការអធិការការងារឱ្យចំគោលដៅ និងពង្រឹងយុទ្ធនាការផ្សព្វផ្សាយទៅដល់ទីតាំង តាមរយៈការកៀរគរគ្រប់ភាគីពាក់ព័ន្ធចូលរួមអនុវត្តច្បាប់ និងអនុលោមភាពច្បាប់ស្តីពីការងារ ដោយដាក់វិធានការផាកពិន័យដ៏តឹងរ៉ឹង។ ដោយទទួលបានសម្បទាជាភ្នាក់ងារនគរបាលយុត្តិធម៌ មន្រ្តីអធិការកិច្ចការងារ និងពង្រឹងដែនអនុវត្តច្បាប់កាន់តែមុតស្រួច។ វិធានការផ្សព្វផ្សាយ ការលើកកម្ពស់ការយល់ដឹង និងការអប់រំដល់សាធារណជន និយោជក កម្មករនិយោជិត និងសហគមន៍ដែលកុមាររស់នៅ គឺជាកិច្ចការអាទិភាព ដើម្បីធានាបាននូវសហគ្រាសមួយ ជាសហគមន៍សុខសាន្តមួយ ដែលគ្មានពលកម្មកុមារ។ ទន្ទឹមនឹងនេះ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់យុវជនក្រីក្រ ចំនួនប្រមាណ ១.៥លាននាក់ នៅតែអនុវត្តឱ្យស្របទៅតាមទីផ្សារការងារ និងចូលរួមចំណែកបង្កើនផលិតភាពការងារកាន់តែប្រសើរនៅគ្រប់ខ្សែច្រវាក់ផលិតកម្ម។

៣៤៨. សមិទ្ធផលទាំងនេះ គឺជាការឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតីប្រកបដោយទំនួលខុសត្រូវខ្ពស់ របស់គ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមានមនសិការមុតមាំក្នុងការពុះពារគ្រប់បញ្ហាប្រឈម ដើម្បីលើកកម្ពស់សុខុមាលភាព និងឧត្តមប្រយោជន៍របស់កុមារ តាមរយៈការពង្រឹងការអនុវត្តសិទ្ធិកុមារ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងបន្តសម្របសម្រួលក្រសួង ស្ថាប័ន ដើម្បីបង្ការ ទប់ស្កាត់ និងអន្តរាគមន៍ចំពោះអំពើហិង្សាលើកុមារ ព្រមទាំងដាក់ចេញនូវយន្តការឆ្លើយតបចាំបាច់នានា ដើម្បីសម្រេចបានតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ ២០៣០។

៣៤៩. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារសូមសម្តែងនូវអំណរគុណដល់គ្រប់ក្រសួង ស្ថាប័នជាតិ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្រ្តីរាជការ អង្គការជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍនានា ប្រជាជន សហគមន៍ ព្រះសង្ឃ គ្រូបាធ្យាយ មាតាបិតា អ្នកអាណាព្យាបាល និងកុមារខ្លួនឯងផ្ទាល់ ដែលបានចូលរួមចំណែកក្នុងការអនុវត្តសិទ្ធិកុមារនៅកម្ពុជាឲ្យមានការរីកចម្រើនស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ។

----------------------